ក្រសួងអប់រំ យុវជន និងកីឡា

# ស្តង់ដារអំណាន

*សៀវភៅណែនាំគ្រូបង្រៀនដើម្បីពង្រឹងសមត្ថភាព អំណានដល់សិស្ស*



ថ្នាក់ទី
២

ខែ កញ្ញា ឆ្នាំ ២០១៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ២៧១១ អយក.ប្រក

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ "ស្តង់ដារអំណាន" ថ្នាក់ទី២
## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
-បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
-យោងគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មសិក្សាចំណេះទូទៅ ២០០៥-២០០៩
-យោងសេចក្តីណែនាំលេខ ៣៨៤២ អយក.សណន ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០០ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
-យោងកំណត់ហេតុប្រជុំគណៈកម្មការដឹកនាំសម្របសម្រួលការអភិវឌ្ឍកម្មវិធីសាលាកុមារមេត្រីលើកទី១ នៅសាលប្រជុំ នៃក្រសួងអប់រំ យុវជន និងកីឡា ថ្ងៃទី០១ ខែកក្កដា ឆ្នាំ ២០១៤
-យោងអនុសាសន៍ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាដែលបានថ្លែងក្នុងពិធីបិទសិក្ខាសាលាពិគ្រោះយោបល់សម្រាប់សាលារៀនជំនាន់ថ្មី និងបង្ហាញបទពិសោធល្អៗក្នុងគម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជានៅខេត្តកំពង់ចាម ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤។
-តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

## សម្រេច

**ប្រការ១**-អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ "**ស្តង់ដារអំណាន**" ថ្នាក់ទី២ដែលរៀបចំដោយនាយកដ្ឋានបឋមសិក្សា ដើម្បីប្រើប្រាស់នៅតាមសាលាបឋមសិក្សា។

**ប្រការ២**-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានបឋមសិក្សា មានភារកិច្ចអនុវត្តប្រកាសនេះ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែតុលា ឆ្នាំ ២០១៤

**កន្លែងទទួល**
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
" ដើម្បីជូនជ្រាបជាព័ត៌មាន "
-ដៃគូអភិវឌ្ឍពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
-ដូចប្រការ២
-កាលប្បវត្តិ-ឯកសារនា.បស

បណ្ឌិត ហង់ ជួន ណារ៉ុន

# គណៈកម្មការគ្រប់គ្រងកម្មវិធី

ឯកឧត្តម ណាត ប៊ុនរឿន

ឯកឧត្តម សំ សិរីរតន៍

លោក ចាន់ សុភា

## គណៈកម្មការនិពន្ធ

លោកស្រី ម៉ៅ តាន់ណារី

លោក គា គឹមស្រ៊ុន

## គណៈកម្មការត្រួតពិនិត្យ

លោក ចាន់ សុភា

លោក អេង គឹមលី

លោក លាង សេងហាក់

## អ្នកជំនួយការបច្ចេកទេស

លោក Kurt Bredenberg

លោក អ៊ុល រុន

កញ្ញា សែត សុលក្ខណា

លោក ចាយ ម៉េងឃី

## គណៈកម្មការរៀបរៀង និងរចនាទំព័រ

លោក អ៊ុល រុន

កញ្ញា សែត សុលក្ខណា

# អារម្ភកថា

សៀវភៅណែនាំពង្រឹងសមត្ថភាពអំណាន "ស្តង់ដាអំណាន" នេះបង្កើតឡើងដោយក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការអប់រំពិភពលោក (WE) អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា (KAPE) និងអ្នកពាក់ព័ន្ធជាច្រើនទៀត ។ គោលបំណងចម្បងនៃសៀវភៅនេះគឺផ្តល់បំណិនសំខាន់ៗក្នុងសមត្ថភាពអំណានជាក់ស្តែងដែលសិស្សត្រូវទទួលបានក្នុងមេរៀននីមួយៗនៃសៀវភៅសិក្សាគោល ។ សៀវភៅនេះគឺជាផ្នែកមួយនៃកិច្ចខិតខំជាបន្តបន្ទាប់របស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការលើកកម្ពស់គុណភាពនៃការបង្រៀននិងកម្មវិធីសិក្សាអំណានថ្នាក់ដំបូងដែលជាបំណិនមួយជាក់លាក់សម្រាប់ឱ្យសិស្សទទួលបានជោគជ័យក្នុងការសិក្សាលើគ្រប់មុខវិជ្ជា ។

ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងដៃគូអភិវឌ្ឍនានាបានធ្វើការជាមួយគ្នាដើម្បីកំណត់រកកម្រិតស្តង់ដាអំណានគន្លឹះៗចំពោះខ្លឹមសារក្នុងមេរៀននីមួយៗនៃសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី២ ។ កម្រិតស្តង់ដាទាំងអស់ត្រូវបានបរិយាយយ៉ាងពេញលេញក្នុងសៀវភៅនេះនឹងជួយគ្រូបង្រៀនឱ្យចេះវាយតម្លៃជាដំណាក់ និងជាបន្តបន្ទាប់ដល់សិស្សក្នុងលក្ខណៈមួយដែលធានាបាននូវសុពលភាព និងភាពអាចទុកចិត្តបានកម្រិតខ្ពស់ ។ ជាងនេះទៅទៀត សៀវភៅនេះបង្ហាញសកម្មភាពគំរូជាក់ស្តែង និងល្បែងសិក្សាដែលគ្រូបង្រៀនអាចប្រើប្រាស់ អនុវត្តលើលទ្ធផលបានពីការវាយតម្លៃ ។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថា ឯកសារនេះពិតជាមានសារៈសំខាន់ក្នុងការពង្រឹងកម្មវិធីសិក្សាផ្នែកអំណាន ។ ហេតុដូចនេះ គ្រូបង្រៀនថ្នាក់ទី២ទាំងអស់គួរត្រូវពិនិត្យជាប្រចាំនូវកម្រិតស្តង់ដាក្នុងសៀវភៅនេះ ដោយធានាថា វាត្រូវបានបញ្ចូលក្នុង កិច្ចតែងការបង្រៀននិងការបង្រៀនជាក់ស្តែងដើម្បីឱ្យសិស្សសម្រេចបានលទ្ធផលអំណានប្រកបដោយគុណភាព និងប្រសិទ្ធភាព ។

**គណៈកម្មការនិពន្ធ**

# មាតិកា


**គណៈកម្មការគ្រប់គ្រងកម្មវិធី** ..............................................................................

**អារម្ភកថា** ..........................................................................................

**មាតិកា** ..............................................................................................

**របៀបប្រើប្រាស់ស្តង់ដាអំណានដើម្បីពង្រឹងសមត្ថភាពអំណានដល់សិស្ស** ......

១. សេចក្តីផ្តើម ..........................................................................i

២. ទម្រង់នៃឯកសារ..........................................................................iv

៣. បំណិនអំណាន..........................................................................viii

៤. ការឆ្លើយតបទៅនឹងតម្រូវការសិក្សារបស់សិស្សជាប្រព័ន្ធ ............................ix

៥. អន្តរាគមន៍មានប្រយោជន៍សម្រាប់ជួយសិស្សមានតម្រូវការរៀនបន្ថែម.........xii

៦. ព័ត៌មានជំនួយបន្ថែមសម្រាប់គ្រូ..........................................................xv

**ដំណាក់កាលទី ១** : មេរៀនទី ១ - ៨ រំឭកស្រៈនិស្ស័យ និងព្យញ្ជនៈ មូសិកទន្ត ត្រីសព្ទ ព្យញ្ជនៈផ្សំស្រៈ ពាក្យប្រកប និងស្រៈពេញតួ...............................1

**ដំណាក់កាលទី ២** : មេរៀនទី ៩ - ២១ រំឭកព្យញ្ជនៈជើង ........................................11

**ដំណាក់កាលទី ៣** : មេរៀនទី ២២ - ៣១ រំឭកព្យាង្គតម្រួត ..........................................18

**ដំណាក់កាលទី ៤** : មេរៀនទី ៣២ - ៤០ អំណាន និងសំណេរ ..................................24

**ដំណាក់កាលទី ៥** : មេរៀនទី ៤១ - ៥២ អំណាន និងសំណេរ ..................................43

**ដំណាក់កាលទី ៦** : មេរៀនទី ៥៤ - ៦២ អំណាន និងសំណេរ ..................................65

**ដំណាក់កាលទី ៧** : មេរៀនទី ៦៣ - ៧១ អំណាន និងសំណេរ..................................86

**ដំណាក់កាលទី ៨** : មេរៀនទី ៧២ - ៨១ អំណាន និងសំណេរ ...............................113

**ឧបសម្ព័ន្ធ ១**

បញ្ជីល្បែងសិក្សា ..........................................................................141

**ឧបសម្ព័ន្ធ ២**

កម្មវិធីសុសវែរ *អានខ្មែរ* ក្នុងបច្ចេកវិទ្យាចល័ត..............................................145

**ឧបសម្ព័ន្ធ ៣**

តារាងសង្ខេបតេស្តដំណាក់កាល និងតេស្តផ្ទាល់មាត់ប្រចាំឆមាស....................150

សេចក្តីណែនាំទូទៅសម្រាប់ការធ្វើតេស្តដំណាក់កាល និងតេស្តផ្ទាល់មាត់ប្រចាំឆមាស ........................................................................................151

តេស្តដំណាក់កាលទី ១ ........................................................................152

តេស្តដំណាក់កាលទី ២ ........................................................................158

តេស្តដំណាក់កាលទី ៣ ........................................................................161

តេស្តដំណាក់កាលទី ៤ ........................................................................164

តេស្តផ្ទាល់មាត់ប្រចាំឆមាសទី ១ ..........................................................170

តេស្តដំណាក់កាលទី ៥ ........................................................................173

តេស្តដំណាក់កាលទី ៦ ........................................................................179

តេស្តដំណាក់កាលទី ៧ ........................................................................185

តេស្តដំណាក់កាលទី ៨ ........................................................................191

តេស្តផ្ទាល់មាត់ប្រចាំឆមាសទី ២ ..........................................................197

**ឧបសម្ព័ន្ធ ៤**

បញ្ជីតាមដានសិស្សដែលមានតម្រូវការរៀនបន្ថែម.........................................201

**ឧបសម្ព័ន្ធ ៥**

បណ្ណពិន្ទុសិស្សសម្រាប់សិស្សដែលមានតម្រូវការរៀនបន្ថែម............................204

# របៀបប្រើប្រាស់ស្តង់ដារអំណាន
# ដើម្បីពង្រឹងសមត្ថភាពអំណានដល់សិស្ស

## ១. សេចក្តីផ្តើម

### ១.១ សាវតារ

ចាប់ពីឆ្នាំ២០១០ ក្រសួងអប់រំ យុវជន និងកីឡា បានចាប់ផ្តើមកែលម្អសៀវភៅភាសាខ្មែរអាន-សរសេរថ្នាក់ទី១ដល់ទី៣ ។ សៀវភៅអាន-សរសេរថ្នាក់ទី១ដែលបានអភិវឌ្ឍថ្មីត្រូវបានដាក់ឱ្យប្រើប្រាស់ជាទូទៅនៅតាមសាលាចំណេះទូទៅក្នុងឆ្នាំ២០១១ ហើយសៀវភៅអាន- សរសេរសម្រាប់ថ្នាក់ទី២និងទី៣ត្រូវដាក់ប្រើប្រាស់និងសាកល្បងក្នុងឆ្នាំ២០១២និង២០១៣ ។ សៀវភៅទាំងនេះត្រូវបានរៀបចំឡើងដោយមានការចូលរួមយ៉ាងច្រើនពីនាយកដ្ឋានពាក់ព័ន្ធផ្សេងៗនៃក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាអង្គការសង្គមស៊ីវិលដែលធ្វើការជាមួយយ៉ាងជិតស្និទ្ធ ។

មូលហេតុនៃការណែនាំអំពីសៀវភៅអាន-សរសេរថ្មីនេះគឺចង់បញ្ឈប់ក្តីកង្វល់ពីមុនអំពីការទទួលបានលទ្ធផលអំណានទាបក្នុងចំណោមសិស្សកម្ពុជាផងដែរ ។ យោងតាមការធ្វើតេស្តសាកល្បងអំពីសៀវភៅអាន-សរសេរថ្មីនេះ លទ្ធផលពិន្ទុសម្រាប់តេស្តមានការកើនឡើងគួរឱ្យកត់ សម្គាល់ ។ នេះបង្ហាញថា យុទ្ធសាស្ត្រដែលក្រសួងអប់រំ យុវជន និងកីឡាប្រើគឺមានភាពជោគជ័យ។ បន្ទាប់ពីភាពជោគជ័យនេះ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំឯកសារបន្ថែមដែលនឹងជួយគ្រូទូទាំងប្រទេសឱ្យប្រើប្រាស់សៀវភៅថ្មីនេះយ៉ាងមានប្រសិទ្ធភាពជាពិសេសក្នុងផ្នែកវាយតម្លៃសិស្ស ។

### ១.២ គោលបំណងនៃឯកសារ

ឯកសារនេះត្រូវបានអភិវឌ្ឍឡើងដោយមានកិច្ចសហការជាមួយអង្គការសង្គមស៊ីវិលដើម្បីបន្តជួយគាំទ្រភាពជោគជ័យនៃសៀវភៅអាន-សរសេរថ្មី ។ ចំណុចផ្តោតជាចម្បងនៃឯកសារនេះគឺដើម្បីផ្តល់ឱ្យគ្រូនូវឯកសារច្បាស់លាស់អំពីសមត្ថភាពជាក់លាក់ក្នុងការអាន និងសរសេរដែលសិស្សត្រូវទទួលបានពីមេរៀននីមួយៗក្នុងសៀវភៅសិក្សាគោលនេះ ។ សមត្ថភាពទាំងនោះត្រូវបានប្រមូលផ្តុំសម្រាប់មេរៀនណាមួយពីអ្វីដែលហៅថា "កម្រិតស្តង់ដា"។ ការដែលមានកម្រិតស្តង់ដាទាំងនេះនឹងជួយឱ្យគ្រូកាន់តែមានភាពប្រសើរឡើងក្នុងការរៀបចំការវាយតម្លៃសិស្សតូចៗដែលទើបចាប់ផ្តើមរៀនអាន និងសរសេរនៅថ្នាក់ដំបូង ហើយនេះជាការវាយតម្លៃមួយដ៏មានសារៈសំខាន់ដែលត្រូវបានធ្វើឡើងជាបណ្តើរៗនៅរាល់ពេលបញ្ចប់ដំណាក់កាលនីមួយៗ ។

## ១.៣ ហេតុអ្វីបានជាការវាយតម្លៃមានសារៈសំខាន់?

ជារឿយៗ គ្រូវាយតម្លៃសិស្សរបស់ពួកគេដោយពុំយល់ថាហេតុអ្វីបានជាពួកគេវាយតម្លៃសិស្ស ឬក៏អ្វីដែលត្រូវធ្វើជាមួយព័ត៌មាននៃការវាយតម្លៃទាំងនោះបន្ទាប់ពីពួកគេបានទទួល ។ ជាធម្មតាគ្រូគ្រាន់តែកត់ត្រាពិន្ទុវាយតម្លៃទុកក្នុងសៀវភៅពិន្ទុរបស់ពួកគេ រួចហើយបន្តទៅមេរៀនបន្ទាប់ ទោះបីជាសិស្សយល់ ឬយល់មិនទាន់ច្បាស់មេរៀនមុនក៏ដោយ ។ គ្រូជាច្រើនមិនដែលប្រើព័ត៌មានដើម្បីរំឭកផ្នែកដែលសិស្សមិនយល់ឬដើម្បីកំណត់សិស្សនីមួយៗដែលកំពុងព្យាយាមដើម្បីឱ្យដល់កម្រិតស្តង់ដារជាក់លាក់ណាមួយទេ ។

សៀវភៅនេះនឹងជួយគ្រូឱ្យចាកឆ្ងាយពីការប្រើប្រាស់រង្វាយតម្លៃដើម្បីតែកត់ត្រាទុកក្នុងសៀវភៅពិន្ទុរបស់ពួកគេ ។ នេះមិនមែនមានន័យថារង្វាយតម្លៃបែបនោះមិនមានសារៈសំខាន់នោះទេ ពោលគឺវាមានសារៈសំខាន់ ប៉ុន្តែមិនទាន់គ្រប់គ្រាន់ក្នុងការនិយាយថាយើងវាយតម្លៃសិស្សបានយ៉ាងល្អនោះទេ ។ ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថា ឯកសារនេះនឹងជួយគ្រូបង្រៀនឱ្យបំពេញភារកិច្ចដូចជាគ្រូពេទ្យ ។ ពោលគឺការធ្វើរង្វាយតម្លៃក្នុងគោលបំណងកំណត់រកអ្វីដែលសិស្សមិនយល់ និងធ្វើសកម្មភាពដើម្បីដោះស្រាយបញ្ហា ដូចគ្នានឹងគ្រូពេទ្យចេញវេជ្ជបញ្ជាដើម្បីព្យាបាលជំងឺ ។

ការវាយតម្លៃសិស្សបានល្អប្រសើរនឹងជួយគ្រូឱ្យចេះកំណត់សិស្សជួបការលំបាកពិសេសក្នុងការអាន ។ នៅពេលពួកគេមានព័ត៌មានទាំងនេះពួកគេអាចអភិវឌ្ឍ ឬកំណត់បាននូវសម្ភារៈជំនួយការរៀន និងបង្រៀនជាក់លាក់ដែលនឹងជួយ ដោះស្រាយភាពខ្វះខាតនេះ ព្រោះឯកសារ ស្តង់ដាអំណានដែលមានកម្រិតស្តង់ដារត្រូវបានរៀបចំឡើងជាដំណាក់កាលខ្លីៗ (ពីដំណាក់កាលទី១ ដល់ទី៨) ដែលគ្រូអាចដឹងបានយ៉ាងរហ័សថាតើសិស្សណាដែលមានការលំបាក និងផ្នែកណាខ្លះដែលលំបាកជាជាងការរង់ចាំរហូតដល់ចប់ឆមាសដែលវាមានភាពយឺតយ៉ាវរួចទៅហើយក្នុងការធ្វើសកម្មភាពបំប៉នបន្ថែម ។ ដូច្នេះកម្រិតស្តង់ដាដែលរៀបរាប់ក្នុងឯកសារនេះគឺមានបំណងជួយគ្រូឱ្យធ្វើការវាយតម្លៃ និងផ្តល់ព័ត៌មានត្រឡប់កាន់តែ

*ក្រសួងសង្ឃឹមថា ឯកសារនេះនឹងជួយគ្រូបង្រៀនឱ្យបំពេញភារកិច្ចដូចជាគ្រូពេទ្យ ពោលគឺការធ្វើរង្វាយតម្លៃក្នុងគោលបំណងកំណត់រកអ្វីដែលសិស្សមិនយល់ និងធ្វើសកម្មភាពដើម្បីដោះស្រាយបញ្ហា ដូចគ្នានឹងគ្រូពេទ្យចេញវេជ្ជបញ្ជាដើម្បីព្យាបាលជំងឺ។*

ប្រសើរអំពីរបៀបដោះស្រាយបញ្ហាសិក្សាបានទាន់ពេលវេលា ។

### ១.៤ គោលបំណង និងវត្ថុបំណង

*គោលបំណងសំខាន់បំផុតនៃឯកសារនេះគឺផ្ដល់កម្រិតស្តង់ដាសិក្សាជាក់លាក់ដែលនឹងជួយសម្រួលកិច្ចខំប្រឹងប្រែងរបស់គ្រូក្នុងការចង្អុលបង្ហាញផ្នែកនៃការសិក្សាដែលសិស្សម្នាក់ ឬច្រើននាក់មិនយល់ និងធ្វើសកម្មភាពបំប៉ន ។*

គោលបំណងសំខាន់បំផុតនៃឯកសារនេះគឺផ្ដល់នូវកម្រិតស្តង់ដាសិក្សាជាក់លាក់ដែលនឹងជួយសម្រួលកិច្ចខំប្រឹងប្រែងរបស់គ្រូក្នុងការចង្អុលបង្ហាញផ្នែកនៃការសិក្សាដែលសិស្សម្នាក់ ឬច្រើននាក់មិនយល់និងធ្វើសកម្មភាពបំប៉នបន្ថែមទៅតាមនោះ ។

**វត្ថុបំណងជាក់លាក់** ក្នុងឯកសារនេះរួមមានដូចខាងក្រោម ៖

**ប្រអប់ទី១ : ប្រធានបទតាមដំណាក់កាល**

1. រំឭកស្រៈនិស្ស័យ ព្យញ្ជនៈ ព្យញ្ជនៈ ផ្សំស្រៈ ពាក្យប្រកប និង ស្រៈពេញតួ
2. រំឭកព្យញ្ជនៈផ្ញើជើង
3. រំឭកព្យាង្គតម្រួត
4. អំណាននិង សំណេរ
5. អំណាននិង សំណេរ
6. អំណាននិង សំណេរ
7. អំណាន និង សំណេរ
8. អំណាន និង សំណេរ

- ជួយគ្រូឱ្យយល់បានកាន់តែប្រសើរអំពី**សមត្ថភាពជាក់លាក់**ដែលសិស្សត្រូវទទួលបានដើម្បីឱ្យការអានមានភាពជោគជ័យ ។
- ជួយគ្រូឱ្យយល់បានកាន់តែប្រសើរអំពី **បំណិនអំណានគន្លឹះទាំង៥** (ការស្គាល់តួអក្សរ ការញែកសូរ ការចេះអានស្ទាត់ ការចេះវាក្យសព្ទ និងការអានដើម្បីយល់) និងបំណិនសំណេរ ( សរសេរតាមអាន សរសេរអក្សរផ្ចង់ តែងសេចក្ដី) ដែលសិស្សត្រូវទទួលបានតាមរយៈការហ្វឹកហាត់អាននិងសរសេរ សូរ ស្រៈ ព្យញ្ជនៈ ពាក្យ ឃ្លា ល្បះ ។ល។ បានជោគជ័យ។
- រៀបចំ**ខ្លឹមសារ**ក្នុងសៀវភៅអាន-សរសេរថ្មីនេះតាមរបៀបសមហេតុផលនិងច្បាស់លាស់ ។
- ផ្ដល់នូវ**ឧបករណ៍វាយតម្លៃ**ជាក់លាក់ដែលធ្វើឱ្យគ្រូអាចធ្វើការវាយតម្លៃជាញឹកញាប់ ។ ដូច្នេះគ្រូអាចកំណត់បទពិសោធចំពោះសិស្សជួបការលំបាកក្នុងការរៀនអាននិងសរសេរ ។
- ផ្ដល់សេចក្ដីណែនាំស្របតាម **សម្ភារៈជំនួយការសិក្សា និងល្បែងសិក្សា**ដែល

នឹងជួយសិស្សដែលមានភាពលំបាកឱ្យទទួលបានសមត្ថភាពក្នុងការអានជាក់លាក់យ៉ាងឆាប់រហ័ស ។



## ២. ទម្រង់នៃឯកសារ

### ២.១ តើអ្វីជាដំណាក់កាល?

កម្រិតស្តង់ដានៃការសិក្សាក្នុងសៀវភៅនេះត្រូវបានរៀបចំឡើងជា "ដំណាក់កាល" ។ ការរៀបចំឯកសារតាមដំណាក់កាលនេះគឺផ្អែកតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្របនឹងចំនួនម៉ោងសម្រាប់បង្រៀនតាមមេរៀននីមួយៗក្នុងសប្តាហ៍ដែលបានផ្តល់ ។ ក្នុងន័យនេះ សិស្សត្រូវរៀន១៣ម៉ោង(១)ក្នុងមួយសប្តាហ៍ ។

តាមសេចក្តីណែនាំអំពីចំនួនសប្តាហ៍ដែលត្រូវចំណាយសម្រាប់មេរៀនជាក់លាក់ណាមួយនៃខ្លឹមសារសៀវភៅសិក្សាក្រុមការងារ ក៏បានបង្កើតដំណាក់កាលដែលមាន៨ប្រធានបទយ៉ាងច្បាស់លាស់ផ្អែកលើសៀវភៅអាន-សរសេរ ថ្នាក់ទី២ ។ ប្រធានបទទាំងនោះត្រូវបានសង្ខេបនៅក្នុងប្រអប់ទី១ ។

ដំណាក់កាលនីមួយៗរួមបញ្ចូលនូវព័ត៌មានខាងក្រោម ៖

- **ចំនួនមេរៀនដែលគ្របដណ្តប់ក្នុងខ្លឹមសារ**
- **ប្រធានបទ**
- **ពេលវេលាសន្មតសម្រាប់បង្រៀនខ្លឹមសារក្នុងអំឡុងពេលកាលវិភាគប្រចាំឆ្នាំ**
- **ចំនួនម៉ោងនិងសប្តាហ៍ដែលគ្រូគួរចំណាយចំពោះប្រធានបទ**

ឧទាហរណ៍នៃទំព័រណែនាំអំពីដំណាក់កាលគឺបង្ហាញក្នុង**រូបភាពទី១** ។

ជាការពិតណាស់គ្រូត្រូវចំណាយពេលបន្ថែមចំពោះដំណាក់កាលជាក់លាក់ណាមួយ ប្រសិនបើឧបករណ៍វាយតម្លៃតាមកម្រិតស្តង់ដាបង្ហាញថាចំនួនសិស្សភាគ

***រូបភាព ១ : គំរូទំព័រណែនាំអំពីដំណាក់កាល***


ដំណាក់កាលទី ១ ៖ មេរៀនទី ១-៨
(ទំព័រទី១ ដល់ ៨)
១.រំឭកស្រៈនិស្ស័យ និងព្យញ្ជនៈ
២.រំឭកព្យញ្ជនៈផ្សំស្រៈ
៣.រំឭកព្យញ្ជនៈប្រើមូសិកទន្ត និងត្រីសព្ទ
៤.រំឭកពាក្យប្រកប
៥.រំឭកស្រៈពេញតួ
សប្តាហ៍ទី២ នៃ តុលា ដល់សប្តាហ៍ទី៣ នៃ តុលា
(២៦ ម៉ោង / ២,០ សប្តាហ៍)

*__កំណត់សម្គាល់ :__* (១) ១ម៉ោងសិក្សាគឺស្មើនឹង៤០នាទី ។

ច្រើនមិនទាន់ទទួលបានសមត្ថភាពដែល បញ្ជាក់ក្នុងកម្រិតស្តង់ដា ។

## ២.២ សមាសភាគសំខាន់ៗនៃស្តង់ដា

ដំណាក់កាលសិក្សានីមួយៗគឺមានបញ្ចូលនូវកម្រិតស្តង់ដាសិក្សាមួយ ឬច្រើនជាងនេះ ។ កម្រិតស្តង់ដាជាក់លាក់ត្រូវបានបង្ហាញដោយសញ្ញាបួនជ្រុងបញ្ឈរពណ៌ខៀវខ្ចី និងរួមបញ្ចូលទាំងលេខ និង អក្សរ ។ លេខ បង្ហាញពីដំណាក់កាលសិក្សា (ឧទាហរណ៍ : លេខ១ បង្ហាញពីដំណាក់កាលសិក្សាទី១) ខណៈដែលអក្សរបង្ហាញពីលំដាប់របស់វានៅក្នុងដំណាក់កាល (ឧទាហរណ៍ : ក ជាកម្រិតស្តង់ដារទីមួយនៅក្នុងដំណាក់កាលទី១) ។

លេខ
១ក

សមាសភាគផ្សេងៗទៀតនៃកម្រិតស្តង់ដានីមួយៗត្រូវបានសង្ខេបក្នុង**រូបភាពទី២**នៃទំព័របន្ទាប់ ។ ធាតុសំខាន់នៃកម្រិត ស្ត ង់ដារួមមាន (១) **ឃ្លាបញ្ជាក់ពីសមត្ថភាព** (២) **មានខ្លឹមសារសង្ខេប និង** (៣) **បំណិនអំណានឬសំណេរពាក់ព័ន្ធ** ។ ទាំងនោះគឺជាអ្វីដែលគ្រូគួរប្រើដើម្បីកំណត់ពីអ្វីដែលសិស្សគួរដឹងនៅផ្នែកចុងក្រោយ នៃដំណាក់កាលនីមួយៗ ។

## ២.៣ សមាសភាគបន្ថែមនៃកម្រិតស្តង់ដា

ធាតុដទៃទៀតនៃកម្រិតស្តង់ដាគឺជាការបន្ថែមថ្មីដែលរួមមាន **សកម្មភាពគំរូ ការវាយតម្លៃ និងល្បែងសិក្សា** ។ ធាតុទាំងនេះត្រូវបានរៀបចំឡើងដើម្បីជួយគ្រូក្នុងការវាយតម្លៃថាតើសិស្សបានទទួលធាតុស្នូលនៃកម្រិតស្តង់ដា និងអភិវឌ្ឍការយល់ដឹងរបស់ពួកគេបានកម្រិតណា ។

ឧទាហរណ៍ **សកម្មភាពគំរូ** គឺមានលក្ខណៈមិនផ្លូវការដែលគ្រូគួរប្រើក្នុងអំឡុងពេលបង្រៀនជាក់ស្តែង ។ ខណៈពេលដែលសិស្សធ្វើសកម្មភាពជាបុគ្គល ឬជាក្រុមគ្រូអាចដឹងថាតើសិស្សរូបណាជួបការលំបាកក្នុងផ្នែកណា ។

**ការវាយតម្លៃ (តេស្ត)** ដែលបង្ហាញក្នុងប្រអប់ពណ៌ផ្កាឈូកសម្រាប់កម្រិតស្តង់ដានីមួយៗមានលក្ខណៈជារង្វាយតម្លៃផ្លូវការដែលអាចធ្វើមួយវគ្គម្តងៗក្នុងអំឡុងដំណាក់កាល ឬធ្វើជារួមនៅចុងបញ្ចប់នៃដំណាក់កាល ។ តេស្តអាចរកបាននៅក្នុង**ឧបសម្ព័ន្ធ ៣** នៃឯកសារនេះ ។ ផ្នែកនីមួយៗនៃតេស្តឆ្លើយតបទៅនឹងកម្រិតស្តង់ដាជាក់លាក់ ។ ឧទាហរណ៍ : ផ្នែក១ក នៃតេស្តទី១គឺសម្រាប់វាយតម្លៃកម្រិតស្តង់ដា១ក ខណៈដែលផ្នែក១ខនៃតេស្តគឺសម្រាប់ការវាយតម្លៃកម្រិតស្តង់ដា១ខ ។ ក្នុងឧបសម្ព័ន្ធនេះក៏មានផ្តល់នូវតេស្តផ្ទាល់មាត់ដើម្បីតេស្តលើសមត្ថភាពអានស្ទាត់ ។ តេស្តផ្ទាល់មាត់ត្រូវធ្វើជាមួយសិស្សម្នាក់ៗ (មួយទល់មួយ) ដូច្នេះត្រូវចំណាយពេលច្រើន ។ ដោយហេតុនេះតេស្តផ្ទាល់មាត់គួរត្រូវបានធ្វើឡើងនៅចុងបញ្ចប់នៃឆមាសនីមួយៗ ។

វាមានសារៈសំខាន់ដែលត្រូវចងចាំថា

*រូបភាពទី២ : សមាសភាគនៃស្តង់ដាអំណាន*

**១. សមត្ថភាពសិស្ស :** ផ្នែកនេះបង្ហាញអំពីសមត្ថភាពអំណានដែលសិស្សត្រូវសម្រេចឱ្យបានក្នុងពេលសិក្សាតាមដំណាក់កាលនីមួយៗ ។

**២. បំណិនអំណាន :** ផ្នែកនេះបង្ហាញអំពីបំណិនមួយក្នុងចំណោមបំណិនអំណានទាំង៥ដែលសិស្សត្រូវចេះ រួមមាន ការស្គាល់សូរ ការស្គាល់តួអក្សរ និងសូរ ការចេះវាក្យសព្ទ ការចេះអានស្ទាត់ និងការអានដើម្បីយល់ន័យ ។




**៣. ខ្លឹមសារ :** ផ្នែកនេះបង្ហាញពីខ្លឹមសារសង្ខេបដែលសិស្សត្រូវរៀនតាមដំណាក់កាលនីមួយៗ ដូចជា តួអក្សរ វណ្ណយុត្ត ។ល។

**៤. សកម្មភាពគំរូ :** ផ្នែកនេះផ្តល់នូវកិច្ចការជាក់លាក់ឆ្លើយតបទៅនឹងសមត្ថភាពសិស្ស ។ បើសិស្សបំពេញកិច្ចការមួយឬច្រើនបានជោគជ័យ នោះមានន័យថាសិស្សទទួលបាននូវសមត្ថភាព ។

**៥. ឧបករណ៍វាយតម្លៃ :** ផ្នែកនេះបង្ហាញពីឧបករណ៍តេស្តដែលមានក្នុងឧបសម្ព័ន្ធដែលគ្រូអាចប្រើប្រាស់ដើម្បីវាយតម្លៃសមត្ថភាពសិស្ស ។ ដោយផ្អែកទៅតាមបំណិនអំណានគឺមានទាំងតេស្តសំណេរ និងផ្ទាល់មាត់ ។

**៦. ល្បែងសិក្សា :** ផ្នែកនេះបង្ហាញអំពីល្បែងសិក្សាដែលគ្រូអាចប្រើប្រាស់ដើម្បីលើកកម្ពស់សមត្ថភាពសិស្ស ។

*សេចក្តីពន្យល់ : ស្តង់ដាអំណាននីមួយៗនៅក្នុងសៀវភៅនេះមានសមាសភាគសំខាន់ៗចំនួន៦ ។ សូមមើលសេចក្តីពន្យល់ក្នុងដ្យាក្រាមខាងលើដែលដកស្រង់ពីកម្រិតស្តង់ដាអំណាន លេខ១ក ទំព័រទី២ នៃឯកសារនេះ ។*

ឧបករណ៍តេស្តដែលមានផ្តល់ក្នុងឯកសារនេះ**មិនត្រូវ**ប្រើក្នុងបំណងដើម្បីបញ្ចូលពិន្ទុរបស់សិស្សទៅក្នុងសៀវភៅពិន្ទុទេ ។ តេស្តកម្រិតស្តង់ដាក្នុងសៀវភៅនេះគឺមានបំណងប្រើជា**ការវាយតម្លៃបន្តបន្ទាប់** ។ ដូច្នេះគ្រូអាចត្រឡប់ក្រោយ និងរំឭកពីកម្រិតស្តង់ដាណាមួយឬកំណត់រកសិស្សដែលជួបការលំបាកក្នុងការរៀនអាន ។ ជាថ្មីម្តងទៀត គ្រូគួរប្រើឧបករណ៍តេស្តដទៃទៀតដើម្បីធ្វើតេស្តប្រចាំខែ ឬឆមាសដែលនឹងត្រូវកត់ត្រាទុកក្នុងសៀវភៅពិន្ទុ ។

***វាមានសារៈសំខាន់ដែលត្រូវចងចាំថា ឧបករណ៍វាស់ស្ទង់ដែលមានក្នុងឯកសារនេះមិនគួរត្រូវបានប្រើក្នុងបំណងដើម្បីបញ្ចូលពិន្ទុរបស់សិស្សទៅក្នុងសៀវភៅពិន្ទុនោះទេ។***

**ល្បែងសិក្សា**ដែលបានស្នើក្នុងកម្រិតស្តង់ដារនីមួយៗគឺជាល្បែងដែលសិស្សនឹងចូលចិត្តលេង ។ ខណៈពេលដែលសិស្សលេងល្បែងទាំងនោះ ពួកគេនឹងពង្រឹងការយល់ដឹងរបស់ពួកគេអំពីកម្រិតស្តង់ដាជាក់លាក់ ។ **គ្រូអាចចាត់ឱ្យសិស្សលេងល្បែងទាំងនេះក្នុងអំឡុងពេលចេញលេងក្នុងអំឡុងពេលសិក្សាឬក្នុងបណ្ណាល័យសាលា។** ការរៀបចំកៀនសិក្សាក្នុងបន្ទប់រៀនជាវិធីមួយទៀតដែលគ្រូអាចបង្កឱ្យសិស្សបានលេងល្បែងសិក្សាទាំងនេះ ។ ល្បែងសិក្សានីមួយៗត្រូវបានសង្ខេបក្នុង**ឧបសម្ព័ន្ធ១ និង ២** នៃឯកសារនេះ ។ ល្បែងទាំងនេះក៏មានលក់ក្នុងទីផ្សារនៃប្រទេសកម្ពុជា ។ ប្រសិនបើសាលារបស់អ្នកមិនសូវមានសម្ភារៈ សូមទាក់ទងនាយកសាលារបស់អ្នក ។ ដូច្នេះសាលារបស់អ្នកអាចស្វែងរកវិធីក្នុងការទិញវា ។ អ្នកក៏អាចសាកល្បងបង្កើតសម្ភារៈទាំងនេះនិងល្បែងស្រដៀងនេះដោយប្រើសម្ភារៈក្នុងមូលដ្ឋានរបស់អ្នក ។



## ៣. អំពីបំណិនអំណាន

ដើម្បីឱ្យការប្រើប្រាស់កម្រិតស្តង់ដានៅក្នុងសៀវភៅនេះឱ្យមានប្រសិទ្ធភាព គ្រូគួរដឹងពីបំណិនអំណានគន្លឹះទាំង៥ដែលមានរៀបរាប់ក្នុងកម្រិតស្តង់ដានីមួយៗ ។ ការកត់

សម្គាល់បំណិនទាំងនោះត្រូវបានយោងតាមការស្រាវជ្រាវអន្តរជាតិដែលត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា ។ និយមន័យនៃបំណិនទាំងនោះមានដូចខាងក្រោម ៖

**(១) ការស្គាល់សូរ** គឺសំដៅការបង្រៀនដើម្បីជួយឱ្យសិស្សមានសមត្ថភាពកំណត់ ប្រើប្រាស់ និងញែកសូរក្នុងពាក្យ ។

***ឧទាហរណ៍*** *សិស្សប្រាប់សូរតួអក្សរក្នុងពាក្យ "កា" (ក និង ស្រៈ អា "ា")តាមរយៈរូបភាព ឬការស្តាប់ពីគ្រូ*

**(២) ការស្គាល់តួអក្សរ និងសូរ** គឺសំដៅដល់ការបង្រៀនដែលជួយដល់អ្នកអាន (សិស្ស) យល់ និងអនុវត្តចំណេះដឹងស្តីពីទំនាក់ទំនងរវាងតួអក្សរ និងសូរ ។

***ឧទាហរណ៍*** *សិស្សអាចប្រាប់គ្រូថារូបភាពនៃពាក្យ កា មានសូរតួអក្សរ ក ។*

**(៣) ការចេះអានស្ទាត់** គឺសំដៅការបង្រៀនដែលជួយពង្រឹងដល់សមត្ថភាពអានឮដោយមានល្បឿនច្បាស់លាស់ និងការបង្ហាញគំនិតត្រឹមត្រូវ ។

***ឧទាហរណ៍*** *សិស្សអាចអានពាក្យ ឃ្លា ឬល្បះឮខ្លាំងៗ ។*

**(៤) ការចេះវាក្យសព្ទ** គឺសំដៅការបង្រៀនដើម្បីបង្កឱ្យមានចំណេះដឹងស្តីពីពាក្យ ។ រាប់ទាំងពាក្យប្រើប្រាស់ផ្ទាល់ខ្លួន និងពាក្យសរសេរដូចជាតាមរយៈការស្គាល់ពាក្យដោយការឮ និងឃើញ មើល ឬអាន ។

***ឧទាហរណ៍*** *សិស្សអាចអានពាក្យចំណាំដែលប្រើញឹកញាប់ដែលគ្រូសរសេរលើក្តារខៀន ឬបង្ហាញលើបណ្ណពាក្យ ។*

**(៥) ការអានដើម្បីយល់ន័យ** គឺសំដៅការបង្រៀនដែលធ្វើឱ្យសិស្សមានសមត្ថភាពចូលរួម និងបញ្ចេញន័យដោយប្រើពាក្យសម្តីផ្ទាល់ខ្លួនពីអត្ថបទដែលបានអាន ។

***ឧទាហរណ៍*** *សិស្សអាចប្រាប់គ្រូអំពីអត្ថន័យនៃល្បះដោយប្រើពាក្យសម្តីផ្ទាល់ខ្លួន ។*

ស្តង់ដាអំណានថ្នាក់ទី២ក៏បានបន្ថែមបំណិនសំណេរសំខាន់ៗមួយចំនួនដូចជា : សរសេរតាមអាន សរសេរអក្សរផ្ចង់ និងតែងសេចក្តី ។

កម្រិតស្តង់ដានីមួយៗកំណត់បំណិនគន្លឹះមួយដែលគ្រូត្រូវបង្រៀនក្នុងអំឡុងដំណាក់កាល ។ គេបានយល់ថាការទទួលយករបស់សិស្សអំពីបំណិនក្នុងការអានមានដំណើរការជាដំណាក់ៗ ។ ដូច្នេះ បំណិនអំណានគន្លឹះទាំង៥ខាងលើផ្តល់នូវការណែនាំដែលមានសារប្រយោជន៍ដើម្បីកសាងវិធីសាស្ត្រនៃការទទួលយកបំណិនទាំងនោះទៅតាមដំណាក់កាលជាក់លាក់ណាមួយ ។ សកម្មភាពគំរូ និងឧបករណ៍វាយតម្លៃផ្តល់ឱ្យគ្រូនូវឧទាហរណ៍ងាយៗជាច្រើននៃ បំណិនទាំងនេះ ។ ខ្លឹមសារទាំងនេះក៏បានជួយសាងចំណេះដឹងដល់គ្រូទាំងអស់ឱ្យដឹងថាបំណិនអ្វីខ្លះដែលសិស្សត្រូវទទួលយកដើម្បីអាចរៀនបាន ។

## ៤. ការឆ្លើយតបទៅនឹងតម្រូវការសិក្សារបស់សិស្សជាប្រព័ន្ធ

នៅក្នុងឯកសារនេះ ផ្តល់នូវជំហានងាយៗចំនួន៦ដែលមានលក្ខណៈជាប្រព័ន្ធដើម្បីប្រើប្រាស់សម្រាប់កែលម្អសមត្ថភាពអានរបស់សិស្ស ។ ជំហានទាំងនេះត្រូវបានសង្ខេបតាមរយៈ**រូបភាពទី៣**ខាងក្រោម ៖

### ៤.១ បង្រៀនមេរៀនរហូតដល់ចប់ដំណាក់កាលនីមួយៗ

គ្រូបង្រៀនត្រូវបង្រៀនតាមសៀវភៅអាន-សរសេរភាសាខ្មែរថ្នាក់ទី២ របស់ក្រសួងអប់រំ យុវជន និងកីឡា ដោយប្រើប្រាស់ឃ្លាសមត្ថភាពសិស្សដែលបានណែនាំក្នុងសៀវភៅនេះជាគោល ។ ឃ្លាសមត្ថភាពសិស្សនីមួយៗគឺផ្អែកតាមសៀវភៅសិក្សាគោលថ្នាក់ទី២ និងមានបង្ហាញអំពីលេខទំព័រសម្រាប់ខ្លឹមសារទាំងនោះ ។ សូមប្រើប្រាស់សកម្មភាពគំរូ និងល្បែងសិក្សាដើម្បីជួយអ្នកក្នុងការរៀបចំកិច្ចតែងការបង្រៀនឱ្យមានប្រសិទ្ធភាពទៅតាមសៀវភៅសិក្សាភាសាខ្មែរ អាន-សរសេរថ្នាក់ទី២ ។

### ៤.២ វាយតម្លៃសិស្សដោយប្រើប្រាស់តេស្តសំណេរដែលចង្អុលបង្ហាញក្នុងស្តង់ដានីមួយៗ

នៅចុងបញ្ចប់ដំណាក់កាលនីមួយៗ សូមប្រើប្រាស់ឧបករណ៍វាយតម្លៃដែលផ្តល់ជូននៅក្នុងឧបសម្ព័ន្ធសម្រាប់ធ្វើតេស្តសិស្ស។ តេស្តទាំងនេះជាសន្លឹកអ៊ិតមាននៅតាមសាលារៀនរបស់អ្នកដែលអ្នកអាចប្រើប្រាស់បានច្រើនដង ។ សូមចងចាំនូវគំនិតសំខាន់ៗមួយចំនួននៅពេលធ្វើតេស្តសិស្ស:




*រូបភាពទី៣ : របៀបឆ្លើយតបទៅនឹងតម្រូវការរៀនរបស់សិស្សជាប្រព័ន្ធ*

- សិស្សម្នាក់ត្រូវធ្វើតេស្តជាបុគ្គល ។
- ចម្លើយរបស់តេស្តសំណេរត្រូវសរសេរដោយបិកហ្វឺតលើសន្លឹកអ៊ុត ។ ការធ្វើបែបនេះគ្រូអាចលុបចម្លើយចេញនៅពេលបញ្ចប់តេស្តសម្រាប់ប្រើប្រាស់លើកក្រោយទៀត ។
- គ្រូត្រូវកំណត់ពេលឱ្យបានសមស្របសម្រាប់ធ្វើតេស្ត ។ ជាទូទៅរយៈពេលប្រហែល៣០នាទីគឺអាចគ្រប់គ្រាន់ហើយ ។
- បន្ទាប់ពីធ្វើតេស្តចប់សិស្សត្រូវប្រគល់កិច្ចការជូនគ្រូដើម្បីកែ ។
- សិស្សទាំងអស់ត្រូវយល់ថា ការធ្វើតេស្តនេះគឺដើម្បីជួយពួកគេ ។ ដូច្នេះវាមិនមានបញ្ហាអ្វីទេនៅពេលមានចម្លើយខុសនោះ ។ **ចូរចាំថា :** តេស្តនេះគឺប្រើប្រាស់សម្រាប់ជួយសិស្ស និងមិនត្រូវកត់ទុកក្នុងបញ្ជីពិន្ទុឡើយ ។
- បន្ទាប់ពីធ្វើកិច្ចការនេះ មាតាបិតា និងសិស្សគួរលៃលកពេលឱ្យបានច្រើនដើម្បីហ្វឹកហាត់រៀនចំពោះខ្លឹមសារណាដែលមានការលំបាកជាមួយគ្នា និងនៅផ្ទះ ។

### ៤.៣ គ្រូត្រួតពិនិត្យលទ្ធផលតេស្ត និងជ្រើសរើសល្បែងសិក្សាសមស្របដើម្បីដោះស្រាយបញ្ហា

គ្រូត្រូវត្រួតពិនិត្យចម្លើយរបស់សិស្សបន្ទាប់ពីធ្វើតេស្ត ។ តេស្តក្នុងដំណាក់កាលនីមួយៗចែកចេញជាផ្នែកៗ (ឧទាហរណ៍ ១ក ១ខ ១គ ។ល។) កម្រិតពិន្ទុត្រូវបានប្រើប្រាស់ដើម្បីកំណត់ឱ្យដឹងពីភាពរីកចម្រើននៃសមត្ថភាពសិស្ស (ពោលគឺស្តង់ដា) (មើលតារាងទី១) ។ បើសិស្សទទួលបានពិន្ទុក្រោម៥០%សម្រាប់ស្តង់ដាណាមួយពួកគេត្រូវទទួលបានការពង្រឹងការយល់ដឹងបន្ថែមតាមរយៈល្បែងសិក្សា ។ សាលារៀនរបស់អ្នកអាចមានល្បែងសិក្សាទាំងនេះនៅក្នុងបណ្ណាល័យ ។ បើសិនមិនមានអ្នកអាចស្នើសុំឱ្យនាយកសាលារៀនទិញដោយប្រើថវិកាសាលារៀន ។

### ៤.៤ ជួបជាមួយគ្រូបង្វឹកអំណានដើម្បីពិភាក្សាលទ្ធផលតេស្តកម្រិតស្តង់ដា និងសកម្មភាពតាមដានផ្សេងៗ

បន្ទាប់ពីធ្វើតេស្តកម្រិតស្តង់ដា គ្រូបង្រៀនគួរជួបជាមួយគ្រូបង្វឹកអំណានប្រចាំសាលារៀនដើម្បីកំណត់រកសិស្សដែលមានតម្រូវការរៀនបន្ថែម និងផ្នែកសមត្ថភាពឬកម្រិតស្តង់ដាដែលពួកគេជួបការលំបាក ។ គ្រូត្រូវកត់ឈ្មោះសិស្សទាំងនេះនិងសកម្មភាពតាមដានជួយផ្សេងៗនៅក្នុងតារាងតាមដានសិស្ស ដែលមានក្នុង **ឧបសម្ព័ន្ធ៤** ។ សកម្មភាពតាមដានជួយមួយចំនួនមានដូចជា ៖

- **ល្បែងសិក្សាក្នុងបណ្ណាល័យ**
- **ល្បែងសិក្សាក្នុងថ្នាក់រៀន (កៀនសិក្សា)**

- ការសិក្សាតាមសុសវែរល្បែងសិក្សាចល័តក្នុងបណ្ណាល័យ
- សៀវភៅបន្ថែមក្នុងបណ្ណាល័យ
- ផ្ដល់បណ្ណពិន្ទុសិស្សទៅមាតាបិតា
- សកម្មភាពសិស្សធំជួយសិស្សតូច
- សកម្មភាពបង្រៀនពីមាតាបិតា
- ការប្រជុំគ្នារវាងគ្រូបង្វឹកអំណាន និងមាតាបិតាសិស្ស

*តារាងទី១ : កម្រិតពិន្ទុសម្រាប់វាយតម្លៃសមត្ថភាពសិស្សតាមរយៈតេស្តសំណេរ*

| មធ្យមភាគ | % ចម្លើយត្រឹមត្រូវ | និទ្ទេស |
|---|---|---|
| ៩,៥០ ដល់១០ | ៩៥%ដល់១០០% | ល្អណាស់ |
| ៨,០០ ដល់ ៩,៤៩ | ៨០% ដល់ ៩៤% | ល្អ |
| ៦,៥០ ដល់៧,៩៩ | ៦៥% ដល់ ៧៩% | បង្គួរ |
| ៥,០០ដល់ ៦,៤៩ | ៥០% ដល់ ៦៤% | មធ្យម |
| ៤,៩៩ ដល់ ០.០ | ៤៩% ដល់ ០% | ខ្សោយ |

## ៤.៥ រាយការណ៍លទ្ធផលទៅមាតាបិតាដើម្បីឱ្យពួកគាត់ជួយបង្រៀនកូន

នៅពេលបំពេញបណ្ណរបាយការណ៍ពិន្ទុសិស្សដែលមានបង្ហាញក្នុង **ឧបសម្ព័ន្ធ៥** ដើម្បីផ្ញើទៅមាតាបិតាគ្រូបង្រៀនគួរកំណត់សម្គាល់អំពីសមត្ថភាពសិស្ស ឬស្តង់ដាដែលសិស្សជួបការលំបាក (ពោលគឺសិស្សដែលមានមធ្យមភាគក្រោម៥០%) ឬក៏រួមនឹងការប្រាប់អំពីល្បែងសិក្សាដើម្បីជួយសិស្សឱ្យរីកចម្រើននៅក្នុងស្តង់ដាណា មួយ ។ គួរតែប្រាប់មាតាបិតាឱ្យពួកគាត់ខ្ចីសម្ភារៈពីបណ្ណាល័យយកទៅប្រើប្រាស់នៅផ្ទះបាន ។ សម្ភារៈទាំងនោះរួមមានល្បែងសិក្សា សៀវភៅអាន ព្រមទាំងសុសវែរល្បែងសិក្សាសម្រាប់ដាក់ក្នុងទូរសព្ទទំនើប បើសិនជាពួកគាត់មាន ។ សម្ភារៈទាំងនេះ អាចខ្ចីបានក្នុងរយៈពេលយ៉ាងយូរមួយសប្ដាហ៍ ។



## ៤.៦ រៀបចំឱ្យសិស្សហ្វឹកហាត់រហូតដល់ពេលចាប់ផ្ដើមដំណាក់កាលបន្ទាប់ទៀត

សិស្សម្នាក់ៗត្រូវហ្វឹកហាត់ឱ្យបានទៀងទាត់តាមរយៈល្បែងសិក្សាដែលបានបង្ហាញជូននៅខាងក្រោមស្តង់ដានីមួយៗ ។ ឧបករណ៍សិក្សាទាំងនេះ ភាគច្រើនជាល្បែងសិក្សាសម្រាប់ពង្រឹងបំណិនអំណានផ្សេងៗរួមមាន ការចេះអានស្ទាត់ ការអានដើម្បីយល់ ។ល។ល្បែងសិក្សាទាំងនេះនិងសម្ភារៈផ្សេងៗទៀតគួរមានជាស្រេចនៅក្នុងបណ្ណាល័យ ឬកៀនសិក្សាក្នុងថ្នាក់បើគ្រូបានរៀបចំ ។ នាយករងដែលទទួលបន្ទុកបច្ចេកទេសត្រូវតាមដានជួយបណ្ណារក្ស

ដើម្បីធានាថាសកម្មភាពទាំងអស់មានដំណើរការជាទៀងទាត់ ។ បើសិនជាសាលារៀនមានគ្រូបង្វឹកអំណានដែលជួយគ្រូបង្រៀនក្នុងការកែលម្អសមត្ថភាពអានរបស់សិស្ស គាត់គឺជាអ្នកដែលត្រូវតាមដានជួយសកម្មភាពទាំងអស់នេះឱ្យបានជាប្រចាំ ។ ក្នុងខណៈដែលសកម្មភាពពង្រឹងទាំងអស់នេះកើតឡើងនៅក្រៅម៉ោងរៀន គ្រូគួរបន្តបង្រៀនស្តង់ដា ផ្សេងៗទៀតនៅក្នុងដំណាក់កាលបន្ទាប់ ។



## ៥. អន្តរាគមន៍មានប្រយោជន៍សម្រាប់ជួយសិស្សដែលមានតម្រូវការរៀនបន្ថែម

គ្រូបង្រៀនអាចពិចារណាជ្រើសរើសអន្តរាគមន៍ខាងក្រោមនៅពេលកំណត់បានសិស្សដែលមានតម្រូវការរៀនពិសេសរួចហើយ ។ គ្រូបង្រៀនគួរធ្វើការជាមួយគ្រូបង្វឹកអំណាននៅតាមសាលារៀននីមួយៗដើម្បីសម្រេចចិត្តថាតើគួរជ្រើសរើសសកម្មភាពចំនួនប៉ុន្មានសម្រាប់សិស្សដែលមានតម្រូវការរៀនបន្ថែម ។

### ៥.១ ល្បែងសិក្សាក្នុងបណ្ណាល័យ

កម្រិតស្តង់ដានីមួយៗក្នុងសៀវភៅ ស្តង់ដាអំណានគឺមានយោងអំពីល្បែងសិក្សាដែលមាននៅក្នុងហឹបសម្ភារៈអំណាន ដែលប្រើប្រាស់សម្រាប់ពង្រឹងកម្រិត ស្តង់ដានោះ ។ តាមរយៈការយោងល្បែងសិក្សា និងលទ្ធផលតេស្តរបស់សិស្សដែលជួបបញ្ហាក្នុងការអាន គ្រូបង្វឹកអំណាន និងគ្រូបង្រៀននឹងអាចកំណត់ថាល្បែងសិក្សាណាមួយដែលមានប្រយោជន៍បំផុតសម្រាប់បម្រើឱ្យការអានកាន់តែប្រសើរដល់សិស្ស ។ បណ្ណារក្សដែលបានចូលរួមការប្រជុំនេះជាមួយគ្រូបង្វឹកអំណាន និងគ្រូបង្រៀនក៏ត្រូវដឹងថាល្បែងសិក្សាមួយណាសម្រាប់សិស្សលេង ។ ល្បែងសិក្សាទាំងនេះគួរមានចំនួនច្រើនល្មមនៅក្នុងបណ្ណាល័យដើម្បីឱ្យសិស្សអាចលេងម្នាក់ឯងដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន ឬលេងជាក្រុម ។



### ៥.២ ល្បែងសិក្សាក្នុងថ្នាក់រៀន

គ្រូបង្រៀនគួរបង្កើតកៀនសិក្សានៅក្នុងថ្នាក់រៀនដើម្បីឱ្យសិស្សអាចលេងល្បែងសិក្សាដែលមាននៅក្នុងហឹបសម្ភារៈ

អំណាន ។ ដូចគ្នាទៅនឹងការលេងក្នុងបណ្ណាល័យគ្រូបង្រៀនគួរណែនាំសិស្សដែលជួបការលំបាកក្នុងការអានហ្វឹកហាត់លើល្បែងសិក្សាណាមួយយ៉ាងជាក់លាក់ដោយផ្អែកទៅលើកម្រិតស្តង់ដាដែលពួកគេជួបការលំបាក ។ ល្បែងទាំងនេះគួរមានជាស្រេចក្នុងកៀនសិក្សា ។ ដូច្នេះសិស្សអាចលេងបានក្នុងពេលឈប់សម្រាក ។ ជម្រើសមួយផ្សេងទៀត គ្រូអាចផ្តល់ល្បែងទាំងនេះដល់សិស្សដើម្បីលេងក្នុងខណៈដែលខ្លួនកំពុងកែតេស្ត ឬកែកិច្ចការសិស្សធ្វើនៅផ្ទះ ដូច្នេះសិស្សទទួលបានឱកាសច្រើនក្នុងការលេងល្បែងនៅសាលារៀន ។



## ៥.៣ សុសវែរល្បែងសិក្សាចល័តក្នុងបណ្ណាល័យ

បើបណ្ណាល័យមានបំពាក់នូវឧបករណ៍បច្ចេកវិទ្យាចល័ត ដូចជា ទូរសព្ទទំនើប និងថាប់ប្លែត នោះសិស្សនឹងមានឱកាសលេងល្បែងសិក្សាប្រភេទសុសវែរដែលផ្អែកតាមសៀវភៅអាន-សរសេរថ្នាក់ទី១ និងទី២ ។ សុសវែរល្បែងសិក្សាទាំងនេះមានចំនួន៣១មេរៀន ។

ជាថ្មីម្តងទៀត គ្រូបង្វឹកអំណានត្រូវពិភាក្សាជាមួយបណ្ណារក្សអំពីសិស្សដែលជួបការលំបាកក្នុងការអានលើកម្រិតស្តង់ដាណាមួយ ។ ដូច្នេះ បណ្ណារក្សត្រូវជួយសិស្សដើម្បីចូលទៅលេងសុសវែរល្បែងសិក្សាទាំងនេះផងដែរ ។



## ៥.៤ សៀវភៅបន្ថែមក្នុងបណ្ណាល័យ

វិធីបង្រៀនអំណានដែលល្អមួយក្នុងចំណោមវិធីផ្សេងៗទៀតគឺការផ្តល់ឱកាសឱ្យសិស្សហ្វឹកហាត់បំណិនអំណានរបស់ពួកគេ។ សៀវភៅដែលសិស្សអានទទួលបានភាពរីករាយគួរតែត្រៀមជាស្រេចនៅក្នុងបណ្ណាល័យដែលសិស្សអាចយកមកអានដោយសេរី ។ម្យ៉ាងទៀត គ្រូអាចរៀបចំកៀនអំណាននៅក្នុងថ្នាក់រៀនផងដែរដើម្បីឱ្យសិស្សអានយ៉ាងសប្បាយរីករាយពេលចេញលេង ។

## ៥.៥ ការផ្តល់បណ្ណពិន្ទុសិស្សទៅឱ្យមាតាបិតាដើម្បីជួយបង្រៀនកូន

តួនាទីរបស់មាតាបិតាក្នុងការជួយសិស្សរៀនអានគឺមានសារៈសំខាន់ណាស់។

មាតាបិតាអាចផ្ដល់នូវការគាំទ្របានយ៉ាងល្អ នៅពេលពួកគេយល់ដឹងអំពីផ្នែកណាមួយ ដែលត្រូវជួយកូនរបស់ពួកគេ ។ បន្ទាប់ពីធ្វើតេស្តតាមដំណាក់កាលចប់ គ្រូបង្រៀនត្រូវបំពេញ**បណ្ណពិន្ទុសិស្ស** ដើម្បីប្រាប់មាតាបិតាសិស្សអំពីផ្នែកឬសមត្ថភាពដែលសិស្សកំពុងជួបការលំបាក ។ បណ្ណពិន្ទុនេះគឺប្រើសម្រាប់តែសិស្សណាដែលទទួលបានពិន្ទុក្រោម៥០%ពីតេស្តដំណាក់កាលប៉ុណ្ណោះ ។ បណ្ណពិន្ទុសិស្សប្រាប់អំពីប្រភេទល្បែងសិក្សា និងសកម្មភាពដែលមាតាបិតាគួរលេងជាមួយកូនដើម្បីពង្រឹងសមត្ថភាពអានរបស់សិស្ស ។ មាតាបិតាអាចសុំខ្ចីល្បែងសិក្សាទាំងនេះពីបណ្ណាល័យសាលារៀន តាមរយៈការបង្ហាញបណ្ណពិន្ទុសិស្សដែលមានហត្ថលេខារបស់គ្រូបង្រៀន ។ បណ្ណពិន្ទុក៏មាននូវការស្នើឱ្យមាតាបិតាជួបជាមួយគ្រូបង្វឹកអំណាន ដើម្បីឱ្យពួកគាត់ចេះធ្វើផែនការជួយកូនរបស់ពួកគាត់កាន់តែប្រសើរឡើងនៅផ្ទះ ។

## ៥.៦ សកម្មភាពសិស្សជួយសិស្ស

ជាទូទៅសិស្សចូលចិត្តលេងជាមួយគ្នា។ ដូច្នេះសាលារៀនអាចប្រើប្រាស់ទម្លាប់ពីធម្មជាតិនៃការលេងជាមួយគ្នាដោយរៀបចំជាសកម្មភាពសិស្សជួយសិស្ស។ នៅក្នុងសកម្មភាពនេះ សិស្សធំដែលរៀនក្នុងថ្នាក់ទី ៤, ៥ និង៦ អាចចាត់ចែងពួកគេជួយបង្រៀនអំណានដល់សិស្សតូច ។ សិស្សធំអាចទទួលបានល្បែងសិក្សាពីសាលារៀនសម្រាប់លេងជាមួយសិស្សថ្នាក់ទាប ដោយផ្អែកលើអ្វីដែលសិស្សតូចនោះកំពុងជួបការលំបាក ។ គ្រូបង្វឹកអំណានត្រូវជួយក្នុងការរៀបចំសកម្មភាពទាក់ទងនឹងការបង្កើតល្បែងសិក្សា និងទីកន្លែងសម្រាប់ដំណើរការសកម្មភាព ដូចជាក្រោមដើមឈើ និងលើកៅអីក្នុងទីធ្លាសាលាជាដើម ។



## ៥.៧ ការជួយបង្រៀនពីមាតាបិតា

គ្រូបង្រៀន និងគ្រូបង្វឹកអំណានគួរលើកទឹកចិត្តមាតាបិតាសិស្សឱ្យចេះជួយកូនរបស់ពួកគេហ្វឹកហាត់រៀនអំណាននៅផ្ទះ ។ បណ្ណពិន្ទុសិស្សដែលបានរៀបរាប់ខាងដើម ជាវិធីមួយមានសារៈសំខាន់សម្រាប់អប់រំណែនាំដល់មាតាបិតា ។ ការសម្របសម្រួលមាតាបិតាឱ្យចេះបង្រៀនកូន អំពីការអានសាលារៀនគួរពិចារណាចំណុចមួយចំនួនដូចខាងក្រោម ៖

- ផ្ដល់បណ្ណពិន្ទុសិស្សទៅមាតាបិតាឱ្យបានទៀងទាត់អំពីសិស្សដែលជួបការលំបាកក្នុងការអាន ។

- អនុញ្ញាតឱ្យមាតាបិតាសុំខ្ចីល្បែងសិក្សា និងសៀវភៅអានពីបណ្ណាល័យសម្រាប់លេង និងអានជាមួយកូនរបស់ពួកគាត់ ។
- ចំពោះមាតាបិតាណាដែលមានទូរសព្ទទំនើប សូមអញ្ជើញពួកគាត់មកសាលារៀន ហើយដំឡើងសុសវែរល្បែងសិក្សាទាំងនេះទៅក្នុងទូរសព្ទរបស់ពួកគាត់ ។ ដូច្នេះសិស្សនឹងអាចលេងល្បែងទាំងនៅតាមផ្ទះផងដែរ ។
- ពន្យល់មាតាបិតាអំពីរបៀបតាមដានការសិក្សារបស់កូននៅក្នុងសុសវែរល្បែងសិក្សាដែលប្រើទូរសព្ទទំនើប ។ ការធ្វើបែបនេះនឹងជួយឱ្យមាតាបិតាដឹងអំពីផ្នែកណាមួយដែលពួកគេត្រូវជួយកូនរបស់ពួកគេ ។



## ៥.៨ ការប្រជុំគ្នារវាងគ្រូបង្វឹកអំណាននិងមាតាបិតាសិស្ស

គ្រូបង្វឹកអំណានគឺជាតួនាទីថ្មីនៅក្នុងសាលារៀនដែលជួយពង្រឹងទំនាក់ទំនងឱ្យកាន់តែប្រសើរឡើងរវាងមាតាបិតាសិស្ស និងសាលារៀន ជាពិសេសទាក់ទងនឹងការអាន ។ គ្រូបង្វឹកអំណានអាចជាមនុស្សមកពីសហគមន៍ សមាជិកក្រុមប្រឹក្សាឃុំ ឬជាគ្រូបង្រៀន ។ គ្រូបង្វឹកអំណានជួបប្រជុំជាមួយមាតាបិតាដើម្បីផ្តល់ការណែនាំអំពីរបៀបជួយកូនបណ្តុះបំណិនអំណានឱ្យមានភាពរីកចម្រើន ។ គ្រូបង្វឹកអំណានដើរតួនាទីយ៉ាងប្រសើរក្នុងការប្រាស្រ័យទាក់ទងរវាងមាតាបិតា និងគ្រូបង្រៀន និងជួយមាតាបិតាឱ្យទទួលបានសម្ភារៈពង្រឹងអំណានដែលមានក្នុងសាលរៀន ។ សម្ភារៈសិក្សាទាំងនេះរួមមានល្បែងសិក្សា សៀវភៅរឿង សៀវភៅសិក្សាគោល (បើសិនសិស្សមិនមានសៀវភៅនេះ) និងសុសវែរល្បែងសិក្សាចល័តសម្រាប់ដំឡើងក្នុងទូរសព្ទទំនើប បើសិនជាមាតាបិតាមាន ។ ការដំឡើងកម្មវិធីនេះគឺមិនគិតថ្លៃទេ ព្រមទាំងមានការពន្យល់អំពីរបៀបលេងផងដែរ ។

## ៦. ព័ត៌មានជំនួយបន្ថែមសម្រាប់គ្រូ

### ៦.១. ទីសេចក្តី (Context Clue)

អ្វីទៅជាទីសេចក្តី? ទីសេចក្តីគឺជាប្រភពព័ត៌មាននៃពាក្យក្នុងល្បះដែលស្ថិតនៅខាងមុខឬបន្ទាប់ពាក្យនោះ ដែលជួយបកស្រាយអត្ថន័យនៃពាក្យនោះ ។ ទីសេចក្តីមានច្រើនប្រភេទដូចជា៖

១. ការយល់ដឹងពីអត្ថន័យនៃពាក្យដោយប្រើប្រាស់ពាក្យ "មាន, ដូច, ដូចជា" ជាពាក្យជំនួសឱ្យពាក្យ "ឧទាហរណ៍" ។

**ឧទាហរណ៍ (១)** ខ្ញុំសម្តែងការគោរព ចំពោះ *មនុស្សចាស់* ដូចជា *ជីដូនជីតា មាតាបិតា* ។ល។

**ឧទាហរណ៍ (២)** ខ្ញុំទៅផ្សារទិញ *ម្ហូបអាហារ* មាន *ត្រី សាច់ បន្លែ និងផ្លែឈើ* ។

**២.** ការប្រើប្រាស់ពាក្យន័យដូច (វេវចនសព្ទ) ឬ ពាក្យន័យផ្ទុយ (បដិសព្ទ) នៅក្នុងល្បះដើម្បីសន្និដ្ឋានអត្ថន័យនៃពាក្យមួយផ្សេងទៀតដែលយើងមិនទាន់ដឹងអត្ថន័យរបស់វា ។

**ឧទាហរណ៍ (១)** សុខមាន *អារម្មណ៍ល្អ* ពីព្រោះគាត់ *សប្បាយចិត្ត* ។

**ឧទាហរណ៍ (២)** ខ្ញុំ *ស្រឡាញ់* មនុស្សល្អ ប៉ុន្តែខ្ញុំ *ស្អប់* មនុស្សអាក្រក់ ។

**៣.** ការប្រើប្រាស់បរិបទនៃល្បះដើម្បីបកស្រាយឬកំណត់អំពីការប្រើឬអានសទិសសព្ទ ។

**ឧទាហរណ៍** ពូសុខយក *លាមក* គោដាក់ស្រែ។

ដូចនេះបើកំណត់ការអាន

(ក) "លាមក" មានន័យថាសិស្សកំណត់ន័យរបស់ពាក្យបានត្រឹមត្រូវពីព្រោះមានពាក្យ គោ ស្រែ បញ្ជាក់ន័យ ។

(ខ) "លា-មក" មានន័យថាសិស្សកំណត់ការអានពាក្យមិនត្រឹមត្រូវ ហើយក៏ធ្វើឱ្យការកំណត់ន័យរបស់ពាក្យខាងក្រោយពាក្យ "លាមក" មិនបានត្រឹមត្រូវផងដែរ ។

## ៦.២. លំហាត់ក្លូស្ស (Cloze Exercise)

ក្លូស្ស គឺជាអត្ថបទដែលខ្លឹមសារមួយចំនួនត្រូវបានគេលុបចោលឬដកចេញដូចជា ពាក្យ ផ្នែកនៃពាក្យ ឬ តួអក្សរ ។ សិស្សត្រូវបំពេញខ្លឹមសារដែលគេលុបចោលឬដកចេញនោះដោយដកស្រង់ពីបញ្ជីពាក្យនៅលើទំព័រក្រោមអត្ថបទនោះ ឬ ពាក្យណាមួយដែលយោងទៅលើការយល់ដឹងរបស់សិស្សទាក់ទងនឹងបរិបទជាទីសេចក្តី ។ លំហាត់ក្លូស្សគឺប្រើដើម្បីជួយសិស្សក្នុងអានដោយការយល់ន័យ ហ្វឹកហាត់វាក្យសព្ទ ពង្រឹងការប្រកបពាក្យ និងរំឭកពីសូររបស់តួអក្សរ ។ លំហាត់ក្លូស្សជាលំហាត់មួយដែលមានប្រសិទ្ធភាពខ្លាំងក្នុងការបង្រៀនអំណាន ។

លំហាត់ក្លូស្សចាប់ផ្តើមដោយការជ្រើសរើសពាក្យនៅលំដាប់លេខរៀងណាមួយក៏បានចាប់ពីលំដាប់លេខរៀងទី៤ ទៅ ៨នៅក្នុងកថាខណ្ឌ ឬអត្ថបទ ។ ការជ្រើសរើសលំដាប់លេខរៀងកាន់តែតូច (លេខ៤) ធ្វើឱ្យលំហាត់ក្លូស្ស កាន់តែមានភាពលំបាក រីឯលំដាប់លេខរៀងខ្ពស់ (លេខ៨) ធ្វើឱ្យលំហាត់ក្លូស្សមានភាពងាយស្រួលជាង ។ ឧទាហរណ៍ បើគ្រូជ្រើសរើសយកពាក្យនៅលំដាប់ទី៦ (កម្រិតលំបាកមធ្យម) គ្រូត្រូវរាប់រៀងរាល់ពាក្យទី៦ក្នុងកថាខណ្ឌឬអត្ថបទ រួចលុបចោលឬដកចេញពាក្យទី៦នោះរហូតចប់កថាខណ្ឌឬអត្ថបទ ហើយគ្រូឱ្យសិស្សបំពេញចន្លោះនៃពាក្យដែលបានដកចេញទាំងនោះ។

សិស្សត្រូវបំពេញពាក្យណាមួយក៏បាន ដើម្បីជំនួសពាក្យដែលលុបចោលឬដកចេញ ដរាបណាវាត្រូវនឹងបរិបទជាទីសេចក្ដី និងមានន័យគ្រប់គ្រាន់សម្រាប់កថាខណ្ឌឬអត្ថបទនោះ ។

**ឧទាហរណ៍** ចូរសង្កេតលំហាត់ក្លូស្សខាងក្រោមដែលគេបានដកចេញនូវពាក្យមួយចំនួននៅរៀងរាល់លំដាប់ទី៦ ។

ថ្ងៃនេះជាថ្ងៃចូល...(**រៀន**)១ ដំបូង ។

ព្រឹកនេះ ម្ដាយសុភី...(**ដាស់**)២កូនពីព្រលឹម។ គាត់ប្រាប់...(**សុភី**)៣ឱ្យរៀបចំខ្លួនទៅសាលារៀន ។...(**សុភី**)៤ភ្ញាក់ ពីដំណេក រួចដើប...(**ចេញ**)៥ ពីគ្រែ ។ នាងនិយាយ :"អូ...(**ព្រឹក**)៦នេះជាថ្ងៃបវេសនកាលផង ។...(**តើ**)៧ម៉ាក់អញ្ជើញទៅជាមួយកូន...(**ដែរ**)៨ឬទេ?" ។ "ទេកូន! ឆ្នាំ...(**ហ្នឹង**)៩ កូនធំហើយ។ កូនទៅ...(**ជាមួយ**)១០ប្អូន ហើយមើលប្អូនផង...)**ណា៎!**)១១" ។ សុភីនិងប្អូនទៅងូតទឹក ...)**ហើយ**)១២ស្លៀកពាក់ រៀបចំកាតាប ទើបសំពះ...(**លា**)១៣ម្ដាយឪពុកទៅ សាលារៀន ។ ពួក...)**វា**)១៤ទៅសាលារៀនទាំងពីរនាក់ ...(**ដោយ**)១៥ទឹកមុខរីករាយ ។

១.រៀន.,សិក្សា ២.ដាស់ ៣.សុភី.,កូន ៤.សុភី,កូន ៥.ចេញ.,ចាកចេញ ៦.ថ្ងៃ.,ព្រឹក ៧.តើ ៨.ដែរ ៩.នេះ.,ហ្នឹង ១០.ជាមួយ., ១១. ណា៎,ដែរ ១២. រួចហើយ.,បន្ទាប់មក ១៣.លា.,ប្រាប់ ១៤.គេ.,វា ១៥.ដោយ, មាន

## ៦.៣ យុទ្ធវិធីបុរេអំណាន (មុនអំណាន)

យុទ្ធវិធីបុរេអំណាន ឬការបង្រៀនមុនអំណានជាវិធីមួយដែលផ្ដល់នូវមូលដ្ឋានគ្រឹះដល់សិស្សក្នុងការយល់ដឹង និងទទួលបាននូវភាពរីករាយចំពោះអត្ថបទដែលពួកគេបម្រុងនឹងអាន ។ ខាងក្រោមនេះគឺជាការបកស្រាយសង្ខេបអំពីយុទ្ធវិធីបុរេអំណានមួយចំនួនដែលជួយលើកកម្ពស់ការយល់ដឹងឱ្យប្រសើរឡើងក្នុងអំឡុងពេលអាន៖

- **ការលើកទឹកចិត្ត:** បង្កការចូលរួម និងទាញការចាប់អារម្មណ៍សិស្សដើម្បីឱ្យពួកគេមានទឹកចិត្តចង់អានអត្ថបទ ។ **ឧទាហរណ៍** គ្រូបង្ហាញឧទាហរណ៍ជាក់ស្ដែង ឬរូបភាពដែលទាក់ទងអត្ថបទរឿងមុនពេលចាប់ផ្ដើមការអាន ។
- **ការផ្សារភ្ជាប់ទៅនឹងចំណេះដឹងមានស្រាប់:** ជំរុញទឹកចិត្តសិស្សឱ្យបង្ហាញនូវចំណេះដឹងមានស្រាប់របស់ពួកគេដែលពាក់ព័ន្ធនឹងប្រធានបទអំណាន និងធ្វើការផ្សារភ្ជាប់គ្នាដើម្បីឱ្យពួកគេមានគោលដៅសម្រាប់ការអាន ។ **ឧទាហរណ៍** គ្រូសួរសិស្សថាតើពួកគេបានដឹងអ្វីខ្លះរួចហើយអំពីប្រធានបទអំណាន បទពិសោធស្រដៀងគ្នា ។ល។
- **ការមើលអត្ថបទអំណានត្រួសៗជាមុន:** មើលអត្ថបទត្រួសៗមុននឹងអានដើម្បីយល់ដឹងអំពី មាតិកា ប្រភេទអត្ថបទ

(ពាក្យរាយ ពាក្យកាព្យ...) និង ចំណងជើង ប្លង់អត្ថបទអំណាន ។ល។ ឧទាហរណ៍ គ្រូឱ្យសិស្សមើលប្រភេទអត្ថបទ រួចផ្សារភ្ជាប់ទៅនឹងអត្ថបទដែលមានប្រភេទស្រដៀងគ្នាដែលពួកគេធ្លាប់បានដឹង ឬអាន ដោយសួរថាតើពួកគេបានដឹងអ្វីខ្លះអំពីប្រភេទអត្ថបទ។

- **បរិបទ:** បង្ហាញនូវប្រធានបទឬផ្ទៃរឿងថ្មីដែលទាក់ទងនឹងអត្ថបទអំណានដែលសិស្សបម្រុងនឹងអានដើម្បីឱ្យសិស្សយល់ដឹងកាន់តែទូលំទូលាយអំពីអត្ថបទ ។ **ឧទាហរណ៍** បើសិនជាអត្ថបទអំណានពាក់ព័ន្ធនឹងតំបន់ភូមិសាស្ត្រដែលសិស្សអាចនឹងមិនដឹង គ្រូអាចបង្រៀនពួកគេអំពីចំណុចទាំងនោះជាមុនសិន មុននឹងអាន ។

- **ការបង្រៀនបញ្ញត្តិ និងវាក្យសព្ទជាមុន:** បង្រៀនបញ្ញត្តិឬវាក្យសព្ទថ្មីៗដែលសិស្សមិនទាន់ដឹង ឬក៏អ្វីមួយដែលសិស្សមិនអាចកាត់យល់បានពីបរិបទ និងជាចំណុចមួយដែលចាំបាច់សម្រាប់ការស្វែងយល់អត្ថបទអំណាន ។ **ឧទាហរណ៍** សម្រាប់ការបង្រៀនបញ្ញត្តិថ្មី គ្រូអាចផ្តល់ឧទារណ៍ដែលទាក់ទងនឹងនឹងបញ្ញត្តិនោះ ។ សម្រាប់ការបង្រៀនវាក្យសព្ទថ្មី គ្រូអាចបង្ហាញពាក្យថ្មីនោះ រួមជាមួយនឹងនិយមន័យដល់សិស្សទាំងអស់ ។

- **ការផ្តោតចំណាប់អារម្មណ៍សិស្ស:** ផ្តោតចំណាប់អារម្មណ៍សិស្ស និងប្រាប់ពួកគេអំពីចំណុចសំខាន់ៗដែលពួកគេត្រូវចាប់អារម្មណ៍នៅពេលអាន ។ សកម្មភាពទាំងនោះរួមមាន ការសួរសំណួរមុនអំណាន និងការទស្សន៍ទាយ ។ **ឧទាហរណ៍** គ្រូឱ្យសិស្សមើលចំណងជើង និងរូបភាពអត្ថបទអំណាន រួចសួរសិស្សថា តើអត្ថបទរឿងនេះនិយាយអំពីអ្វីបើផ្អែកលើចំណងជើង និងរូបភាព។ ម្យ៉ាងវិញទៀត គ្រូក៏អាចសង្ខេបនូវទិដ្ឋភាពរួមមួយឬពីរល្បះអំពីអត្ថបទអំណាន ហើយឱ្យសិស្សបង្កើតសំណួរបែបទស្សន៍ទាយ មុននឹងធ្វើការអានអត្ថបទ ។

## ៦.៤ ការសរសេរអក្សរផ្ចង់

ការបង្រៀនអក្សរផ្ចង់ ជាការងារសំខាន់សម្រាប់គ្រូ ក្នុងការនាំសិស្សហ្វឹកហាត់សរសេរតួអក្សរ រហូតដល់ពាក្យពេចន៍ក្នុងឃ្លា ល្បះ។ល។ បានស្អាតល្អត្រឹមត្រូវតាមទម្រង់ ទំហំ និងក្រុមអក្សរក្នុងភាសាខ្មែរ។ ដើម្បីឱ្យសិស្សសរសេរអក្សរផ្ចង់បានស្អាតល្អ គ្រូត្រូវស្គាល់ពីគំរូអក្សរផ្ចង់ទាំងអស់ដែលចែកជា ៧ក្រុម តាមទម្រង់អក្សរដែលមានលំនាំតួអក្សរស្រដៀងគ្នាថែមទៀត ទៅតាមលំដាប់ព្យញ្ជនៈ និងស្រៈពេញតួ ដូចខាងក្រោម៖

ក្រុមទី១ : រ វ អ

ក្រុមទី២ : ក ភ គ ត ឥ ឮ

ក្រុមទី៣ : ច ប ម ឫ ឬ ហ យ ឃ

ក្រុមទី៤ : ល ស ណ ឈ

ក្រុមទី៥: ង ជ ដ ផ ឋ ថ ឯ

ក្រុមទី៦: ឆ ធ ព ឰ ញ ឭ ឮ ឍ ឌ

ក្រុមទី៧: ឧ ឩ ឪ ឱ ន ទ ឡ។

តួអក្សរទាំង ៧ក្រុមខាងលើនេះ ត្រូវបែងចែកជា ៤ពួកទៀត ដែលបង្ហាញពីចំនួនល្វែង និងការកំណត់ទំហំដូចជាៈ

**ពួកទី១:** ហៅថាអក្សរ១ល្វែង មាន៣៣តួគឺ

ក ខ គ ង ច ឆ ជ ដ ឋ ឌ ត ថ ទ ធ ន ប ផ ព ភ ម អ ឥ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឪ

**ពួកទី ២:** ហៅថា អក្សរ២ល្វែង មាន១០តួគឺ

យ ញ ឈ ឃ ល ស ហ ឡ អា ឮ

**ពួកទី ៣:** ហៅថាអក្សរ៣ល្វែងមាន ២តួគឺ

ឈ និង ណ

**ពួកទី ៤:** ហៅថាអក្សរពាក់កណ្ដាលល្វែង មាន ២តួគឺ រ និង វ

ចំពោះទំហំស្រៈវិញក៏មានការកំណត់ ដែលគ្រូគួរយល់ដឹង និងបង្រៀនសិស្សឱ្យគូរទៅតាមការកំណត់ដូចខាងក្រោមដែរៈ

- ទទឹងស្រៈ "ា" ជិតស្មើទទឹងតួព្យញ្ជនៈមួយល្វែង
- ទទឹងស្រៈ "ិ ី ឹ ឺ" ជិតស្មើទទឹងតួព្យញ្ជនៈមួយល្វែង
- ទទឹងស្រៈ "ុ" យក ១ភាគ៣ នៃព្យញ្ជនៈ
- ទទឹងស្រៈ "ូ" យក ២ភាគ៣ នៃព្យញ្ជន
- ទទឹងស្រៈ "ួ" យកជិតស្មើតួព្យញ្ជនៈ។ រីឯកម្ពស់ស្រៈ "ុ ូ ួ" ក៏យកជិតស្មើពាក់កណ្ដាលនៃតួព្យញ្ជនៈ។
- ទទឹងស្រៈ "ៀ ឿ" ស្មើនឹងព្យញ្ជនៈ
- ទទឹងស្រៈ "ំ" យក១ភាគ៣នៃតួព្យញ្ជនៈដែរ។

### ១. ការបង្ហាញគំរូ

**ក. របៀបដឹកនាំ**

- ដំបូងគ្រូដឹកបន្ទាត់ផ្ដេក៨ប្រឡោះស្មើៗគ្នា ដាក់នៅលើក្ដារខៀនតាមគំរូនេះ 
  បន្ទាត់ផ្ដេកធំ១មាន ៤ ប្រឡោះតូចៗ។
- បន្ទាប់មក ត្រូវគូសរាងចតុកោណកែង២នៅដើមបន្ទាត់ ដោយចតុកោណកែង ១ មានទទឹង១ក្រឡា នឹងបន្ទាត់បញ្ឈរ ២ក្រឡា (បន្ទាត់បញ្ឈរស្មើ ២ដងនៃក្រឡាបន្ទាត់ផ្ដេក)។
- ធ្វើបែបនេះឱ្យបានចតុកោណកែង ២ ជាប់គ្នា។
- បន្ទាប់មកទៀត ដឹកបន្ទាត់តាមអង្កត់ទ្រូងចតុកោណកែងដោយចាប់ពីជ្រុងមុំខាងស្ដាំមកចំមុំជ្រុងខាងឆ្វេង ដូចគំរូនេះ  ។

- ដឹកបន្ទាត់ទ្រេតឱ្យស្របនឹងបន្ទាត់ទ្រេតទី១រហូតដល់ចុងបន្ទាត់ផ្ដេក។

ចន្លោះបន្ទាត់ទ្រេត។ ឯស្រះ ា ត្រូវសរសេរជិតប៉ុនអក្សរមួយល្វែង។




## ខ. របៀបសរសេរ

គ្រូត្រូវបែងចែកបន្ទាត់ផ្ដេក (ដែលមាន ៩បន្ទាត់តូច) ជា៣ភាគ។

- សរសេរអក្សរ រ ត្រូវកួចតួខាងក្រោមត្រឹម ១ភាគ៣ តួ ១ភាគ៣ និងសក់ ១ភាគ៣ នៃក្រឡាបន្ទាត់ផ្ដេក។ កម្ពស់អក្សរ រ ពេញ១បន្ទាត់ធំ ទទឹង ១ភាគ២ នៃចន្លោះបន្ទាត់ទ្រេត ។
- អក្សរ វ ត្រូវកួចខាងក្រោម ១ភាគ៣ ដូច រ ដែរ តួ ១ភាគ៣ និងសក់ ១ភាគ៣ រួចវាត់ទៅលើ ១ភាគ២ នៃក្រឡាបន្ទាត់ធំខាងលើ។ កម្ពស់ វ ស្មើនឹង ១ ក្រឡាបន្ទាត់កន្លះ។ ទទឹង វ ស្មើនឹង ១ភាគ២ នៃចន្លោះបន្ទាត់ទ្រេត។
- អក្សរ អ សរសេរដូច អក្សរ រ ២ដង។ ទទឹងអក្សរ អ ស្មើនឹង ២ភាគ៣ នៃ

## ២. លំណែនាំគូសបន្ទាត់

**ក.** គ្រូណែនាំសិស្សអំពីរបៀបដឹកបន្ទាត់តាមគំរូខាងលើ។ ដោយក្នុងសៀវភៅសរសេររបស់សិស្សមានក្រឡាបន្ទាត់រួចស្រេចហើយ គ្រូគ្រាន់តែណែនាំសិស្សឱ្យដឹកបន្ទាត់ទ្រេតតាមក្រឡាបន្ទាត់ក្នុងសៀវភៅសរសេររបស់សិស្ស។

**ខ.** គ្រូសរសេរគំរូនៅលើក្ដារខៀនយឺតៗតាមចលនានីមួយៗ។

- ដំបូងសរសេរអក្សរ រ វ អ កម្ពស់ពេញបន្ទាត់ (ចំនួន១បន្ទាត់)។
- បន្ទាប់មកសរសេរពាក្យ អារ កម្ពស់ពេញបន្ទាត់ (ចំនួន១បន្ទាត់)។
- ទីបញ្ចប់សរសេរពាក្យ រាវ កន្លះបន្ទាត់ (ចំនួន១បន្ទាត់)។

# ដំណាក់កាលទី ១ : មេរៀនទី ១-៨

(ទំព័រទី១ ដល់ ៨)

*១. រំឭកស្រៈនិស្ស័យ និងព្យញ្ជនៈ*

*២. រំឭកព្យញ្ជនៈផ្សំស្រៈ*

*៣. រំឭកព្យញ្ជនៈប្រើមូសិកទន្ត និងត្រីសព្ទ*

*៤. រំឭកពាក្យប្រកប*

*៥. រំឭកស្រៈពេញតួ*

*សប្ដាហ៍ទី២ ខែ តុលា ដល់សប្ដាហ៍ទី៣ ខែ តុលា*

*( ២៦ ម៉ោង / ២,០ សប្ដាហ៍)*

**លេខ ១ក**

# សិស្សអាចអានស្រៈនិស្ស័យទាំងអស់បានច្បាស់លាស់

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់តួអក្សរនិងសូរ**

**: ការចេះអានស្ទាត់**

សូមមើល មេរៀនទី ១ (ទំព័រទី ១) →

## សកម្មភាពគំរូ

- ☑ សិស្សឆ្លើយនឹងសំណួររំឭករបស់គ្រូថា :តើស្រៈនិស្ស័យមានប៉ុន្មានតួ?
- ☑ សិស្សអានស្រៈនិស្ស័យម្តងម្នាក់ៗតាម របៈការបង្ហាញបណ្ណស្រៈរបស់គ្រូពីដើមដល់ចប់ (ឧទាហរណ៍ : ា ... ោះ ) ។
- ☑ សិស្សអានស្រៈនិស្ស័យតាមលំដាប់ និងបញ្ច្រាស (ឧទាហរណ៍ : ា.....ោះ, ោះ......ា) ។
- ☑ សិស្សអានស្រៈនិស្ស័យដែលគ្រូរៀបចម្រុះ (មិនតាមលំដាប់) ( ឧទាហរណ៍ : ឹ ា ុ ឿ ...ោ ) ។
- ☑ សិស្សរៀបបណ្ណស្រៈនិស្ស័យតាមលំដាប់និងអានឡើងវិញឱ្យបានត្រឹមត្រូវ ។ ( ឧទាហរណ៍ : ា ...ោះ )

## ខ្លឹមសារ

- ស្រៈនិស្ស័យទាំង២៣

តួ : ា ិ ី ឹ ឺ ុ ូ ួ

ើ ឿ ៀ េ ែ ៃ ោ

ៅ ុំ ំ ាំ ះ ុះ



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ១ក



លេខ ១



លេខ ២



**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ** → លេខ ១២ មេរៀនទី១

លេខ ១ខ

# សិស្សអាចអានព្យញ្ជនៈនិងជើងព្យញ្ជនៈទាំងអស់បានច្បាស់លាស់

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់តួអក្សរនិងសូរ**

**: ការចេះអានស្ទាត់**

សូមមើល មេរៀនទី ១ (ទំព័រទី ១ )

## សកម្មភាពគំរូ

- ☑ សិស្សរៀបរាប់ព្យញ្ជនៈទាំង៣៣តួឡើងវិញ ។
- ☑ សិស្សអានព្យញ្ជនៈទាំង៣៣តួម្ដងម្នាក់ៗពីដើមដល់ចប់តាមរយៈការបង្ហាញរបស់គ្រូ(ក...អ)។
- ☑ សិស្សអានព្យញ្ជនៈទាំងអស់តាមលំដាប់និងបញ្ច្រាស ។ (ឧ. ក...អ និង អ...ក)
- ☑ សិស្សអានព្យញ្ជនៈចម្រុះ(មិនតាមលំដាប់) តាមការកំណត់របស់គ្រូ ។ (ឧ. គ  ក អ ជ ... ធ)
- ☑ សិស្សរៀបបណ្ណព្យញ្ជនៈតាមលំដាប់ និងអានឡើងវិញឱ្យបានត្រឹមត្រូវ ។ (ឧ. ក... អ )
- ☑ សិស្សពិនិត្យមើលជើងព្យញ្ជនៈទាំងអស់ដែលគ្រូសរសេរ ឬបិទលើក្ដារខៀន ហើយឡើងមកចង្អុលនិងថាតាមគ្រូម្ដងមួយៗរហូតដល់ចប់ ។
- ☑ សិស្សអានជើងព្យញ្ជនៈទាំងអស់តាមលំដាប់និងមិនតាមលំដាប់ឡើងវិញបានត្រឹមត្រូវគ្រប់គ្នា ។
- ☑ សិស្សផ្គូផ្គងបណ្ណជើងព្យញ្ជនៈទៅនឹងបណ្ណតួព្យញ្ជនៈបានត្រឹមត្រូវ និងអានឡើងវិញតាមរយៈការកំណត់របស់គ្រូ ។

| | | | |
|---|---|---|---|
| ◌្ខ | ង | ◌្គ | ឈ |
| ◌្ង | ខ | ◌្ឈ | ឆ |
| ◌្ថ | ថ | ◌្ឆ | គ |

## ខ្លឹមសារ

- ♦ **ព្យញ្ជនៈទាំង៣៣តួនិងជើងមាន ៖**

ក្ក ខ្ខ គ្គ ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ ត្ត ថ្ថ ទ្ទ ធ្ធ ន្ន ប្ប ផ្ផ ព្ព ភ្ភ ម្ម យ្យ រ្រ ល្ល វ្វ ស្ស ហ្ហ ឡ អ្អ ។



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ១ខ

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**




លេខ ៣



លេខ ៤



លេខ ១២ មេរៀនទី២ និងទី១០

លេខ ១គ

# សិស្សអាចអានការផ្សំស្រៈព្យញ្ជនៈនិងស្រៈដើម្បីអានពាក្យនិងល្បះបានត្រឹមត្រូវ ( ព្យញ្ជនៈពួកអ )

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់តួអក្សរនិងសូរ**

**: ការចេះវាក្យសព្ទ និង ការចេះអានស្ទាត់**

សូមមើល មេរៀនទី ២ ( ទំព័រទី ២ ) →

## សកម្មភាពគំរូ

- ☑ សិស្សរៀបរាប់ព្យញ្ជនៈពួក **អ** ទាំងអស់ឡើងវិញតាមរយៈការពន្យល់របស់គ្រូ ។
- ☑ សិស្សរៀបពាក្យដោយប្រើបណ្ណអក្សរចល័តតាមការពន្យល់របស់គ្រូ រួចអានឱ្យបានត្រឹមត្រូវ (កោះ...អុំ និង កក្ករ...អាហារ) ។
- ☑ សិស្សអានល្បះតាមការកំណត់របស់គ្រូ ។ ( -កុំធីចំណីឆៅ។ -បងចំណានខំដេរខោ។ -ចៃអាំសរសើរបុប្ផាថា ចេះចៃដំណាំ។)
- ☑ សិស្សរៀបល្បះដោយប្រើបណ្ណពាក្យតាមការកំណត់របស់គ្រូហើយអានបានត្រឹមត្រូវ ។
- ☑ សិស្សបង្កើតល្បះដោយប្រើបណ្ណពាក្យតាមគំនិតផ្ទាល់ខ្លួនហើយអានបានត្រឹមត្រូវ ។

## ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ


លេខ ៥


លេខ ៦


លេខ ៨


លេខ ១០


លេខ ១១



លេខ ១២ មេរៀនទី៣

## ខ្លឹមសារ

- ស្រៈនិស្ស័យទាំង២៣ តួ : ◌ា ◌ិ ◌ី ◌ី ◌ឹ ◌ឺ ◌ុ ◌ូ ◌ួ ◌ើ ◌ឿ ◌ៀ ◌េ ◌ែ ◌ៃ ◌ោ ◌ៅ ◌ុំ ◌ំ ◌ាំ ◌ុះ ◌េះ ◌ោ ះ ។
- ព្យញ្ជនៈពួក**អ**ទាំង១៥ តួ : **ក ខ ច ឆ ដ ឋ ណ ត ថ ប ផ ស ហ ឡ អ**
- ពាក្យនិងល្បះក្នុងមេរៀនទី២ :
  - កោះ ............... អុំ
  - កក្ករ ............អាហារ
  - កុំធីចំណីឆៅ ។
  - បងចំណានខំដេរខោ។
  - ចៃអាំសរសើរបុប្ផាថា ចេះចៃដំណាំ ។



## ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ១គ

លេខ ១ឃ

# សិស្សអាចអានការផ្សំស្រៈព្យញ្ជនៈ និងស្រៈដើម្បីអានពាក្យនិងល្បះបានត្រឹមត្រូវ (ព្យញ្ជនៈពួកអ៊)

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់តួអក្សរនិងស្នូរ**

**: ការចេះវាក្យសព្ទ និង ការចេះអានស្ទាត់**

សូមមើល មេរៀនទី ៣ (ទំព័រទី ៣ ) →

## សកម្មភាពគំរូ

- ☑ សិស្សរៀបរាប់ព្យញ្ជនៈពួក **អ៊** ទាំងអស់ឡើងវិញតាមការឆ្លើយសំណួររបស់គ្រូថា តើព្យញ្ជនៈពួកអ៊មានអ្វីខ្លះ ?
- ☑ សិស្សរៀបពាក្យដោយប្រើបណ្ណអក្សរចល័តតាមការពន្យល់របស់គ្រូ រួចអានឮបានត្រឹមត្រូវ ។ ( គោ.........វះ និង គគីរ.......  ទីលំនៅ ) ។
- ☑ សិស្សអានល្បះតាមការកំណត់របស់គ្រូ។(-គោញីតាឃុំឈើ។ -ពូទីចុះពីលើនាវា។ -សេះថៅងីជាសះដំបៅងា។ -តាឌីដើរសំដៅសាលាឃុំគគីរ។ )
- ☑ សិស្សរៀបល្បះដោយប្រើបណ្ណពាក្យតាមការកំណត់របស់គ្រូ ហើយអានបានត្រឹមត្រូវ ។
- ☑ សិស្សបង្កើតល្បះដោយបណ្ណពាក្យតាមគំនិតផ្ទាល់ខ្លួនហើយអានបានត្រឹមត្រូវ។

## ខ្លឹមសារ

- ស្រៈនិស្ស័យទាំង២៣តួ :
  ◌ា ◌ិ ◌ី ◌ឹ ◌ឺ ◌ុ ◌ូ ◌ួ ◌ើ
  ◌ឿ ◌ៀ ◌េ ◌ែ ◌ៃ ◌ោ ◌ៅ
  ◌ុំ ◌ំ ◌ាំ ◌ុះ ◌េះ ◌ោះ ។
- ព្យញ្ជនៈពួកអ៊ទាំង១៨តួ :
  **គ ឃ ង ជ ឈ ញ ឌ ឍ ទ**
  **ធ ន ព ភ ម យ រ ល វ**

-គោ.................វះ

-គគីរ...............ទីលំនៅ

-គោញីតាឃុំឈើ ។

-ពូទីចុះពីលើនាវា ។

-សេះថៅងីជាសះដំបៅងា ។

-តាឌីដើរសំដៅសាលាឃុំគគីរ ។

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



លេខ ៥



លេខ ៦



លេខ ៨



លេខ ១០



លេខ ១១



លេខ ១២: មេរៀនទី៤



## ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ១ឃ

# លេខ ១ង

# សិស្សអាចអានពាក្យ ឃ្លា ល្បះខ្លី ដែលប្រើ មូសិកទន្ត ( ៉ ) និងត្រីសព្ទ ( ៊ )

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់តួអក្សរនិងសូរ**

**: ការចេះវាក្យសព្ទ និង ការអានដើម្បីយល់ន័យ**

សូមមើល មេរៀនទី ៤-៥ (ទំព័រទី ៤-៥) ⟶

## សកម្មភាពគំរូ

☑ សិស្សឆ្លើយយល់អំពីន័យរបស់ ឃ្លាល្បះខ្លីៗ ដែលបានប្រើមូសិកទន្ត និងត្រីសព្ទ ។

☑ សិស្សរៀបបណ្ដុំពាក្យដែលមានប្រើ មូសិកទន្ត និងត្រីសព្ទទៅតាមការកំណត់របស់គ្រូ ហើយអានបានត្រឹមត្រូវ។

☑ សិស្សរៀបល្បះដែលប្រើមូសិកទន្តនិង ត្រីសព្ទទៅជាល្បះ ហើយអានបានត្រឹមត្រូវ ។

**ឧទាហរណ៍ :**

- ចាប៉ី តាម៉ី លីៗ ➜ តាម៉ីលីចាប៉ី ។
- បូណា ពុំរ៉ៃ ឈីៗ ➜ បូណាឈីពុំរ៉ៃៗ

-តៅហ៊ូ អាវ៉ា ញុំៗ ➜ អាវ៉ាញុំតៅហ៊ូ ។

-ជ័រកៅស៊ូ អ៊ំៗ មមាញឹកចៀរ ។

➜ អ៊ំៗមមាញឹកចៀរជ័រកៅស៊ូ ។

☑ សិស្សកំណត់ន័យរបស់ពាក្យតាមរយៈការប្រើទីសេចក្ដី

**ឧទាហរណ៍ :** អាវ៉ាញុំតៅហ៊ូៗ គេអាចដឹងថា "**តៅហ៊ូ**" ជាឈ្មោះម្ហូបដោយសារពាក្យនេះប្រើជាមួយពាក្យ "**ញុំ**" ។

## ខ្លឹមសារ

- ពាក្យនិងល្បះទាំងអស់ដែលប្រើមូសិកទន្ត ៉ និងត្រីសព្ទ ៊ ជាមួយព្យញ្ជនៈ **ង ញ ប ម យ រ វ និង ប ស ហ អ (ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉ និង ប៊ ស៊ ហ៊ អ៊)**
- មេរៀនទី៤ (ទំព័រទី៤)
  - ង៉ា .................. វ៉ែន
  - អាយ៉ៃ .............វ៉ែនតា
  - តាម៉ីលីចាប៉ី ។
  - បូណាឈីពុំរ៉ៃ ។
  - ពូម៉ៅ ពូកែញ៉េះញ៉ោះ។
- មេរៀនទី៥ (ទំព័រទី៥)



## ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ១ង

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ** ➜



លេខ ៧



លេខ ៨



លេខ ១១



លេខ ១២ មេរៀនទី៥,ទី៦

លេខ ១៤

# សិស្សអាចប្រកប ព្យញ្ជនៈ និងព្យញ្ជនៈ ព្យញ្ជនៈ ស្រៈ និង ព្យញ្ជនៈប្រកបខាងចុងមានៈ ក ខ គ ឃ ច ជ ត ថ ទ ព ប ស និង ន ណ ង ញ ម យ ល វ ដែល ប្រើវណ្ណយុត្ត ( ៉ ៊ ់ )

**បំណិនអំណានពាក់ព័ន្ធ :** ការស្គាល់តួអក្សរនិងសូរ

: ការចេះវាក្យសព្ទ និង ការអានដើម្បីយល់ន័យ

សូមមើល មេរៀនទី ៦-៧ (ទំព័រទី ៦-៧ )

## ខ្លឹមសារ

| | |
|---|---|
| ♦ ពាក្យទាំងអស់ក្នុងមេរៀនទី៦-៧ ដែលមានប្រើ ។<br>♦ ព្យញ្ជនៈនិងព្យញ្ជនៈ<br>♦ ព្យញ្ជនៈ ស្រៈ និងព្យញ្ជនៈ និង ព្យញ្ជនៈប្រកបខាងចុងមានៈ ក ខ គ ឃ ច ជ ត ថ ទ ព ប ស ន ណ ង ញ ម យ ល វ | ♦ រួមទាំងប្រើវណ្ណយុត្ត ( ៉ ៊ ់ ) មេរៀនទី៦៖<br>-កាច់...លើស<br>-អំណាច... សុភាព<br>មេរៀនទី៧ :<br>-បាន... កែវ<br>-រលួយ.... ផាងដូង |

## សកម្មភាពគំរូ

☑ សិស្សបង្កើតពាក្យជាព្យញ្ជនៈប្រកបខាងចុងជាមួយស្រៈនិស្ស័យ ដែលគ្មានបន្តក់និងមានបន្តក់ទៅតាម ការកំណត់របស់គ្រូដោយប្រើបណ្ណអក្សរចល័ត ។

☑ សិស្សកំណត់ការប្រកបពាក្យដែលជាព្យញ្ជនៈប្រកបខាងចុងជាមួយស្រៈនិស្ស័យដែលគ្មានបន្តក់និងមានបន្តក់បានត្រឹមត្រូវតាមរយៈការនិយាយ ឬការប្រើប្រាស់រូបភាពដែលគ្រូបាននិយាយនិងផ្ដល់ឱ្យ ។

**ឧទាហរណ៍ :**



= ងដូ | ដង្ង | ដូង



= ម៉ាវសារ | សារម៉ាវ | សាវម៉ារ

បន្តទៅទំព័របន្ទាប់

លេខ ១៥

**បន្ត...**

## សកម្មភាពគំរូ

☑ សិស្សអាចរៀបបណ្ណអក្សរដើម្បីបង្ហាញពាក្យដែលជាព្យញ្ជនៈប្រកបខាងចុងជាមួយស្រៈនិស្ស័យដែលគ្មានបន្តក់ និងមានបន្តក់តាមរយៈសកម្មភាពឬកាយវិការបង្ហាញរបស់គ្រូ ។
ឧទាហរណ៍: គ្រូបង្ហាញសកម្មភាពឬកាយវិការ "**ជូតតុ**" ឱ្យសិស្សមើលរួចឱ្យសិស្សរៀប បណ្ណអក្សរជាពាក្យ "**ជូតតុ**" ។

☑ សិស្សអាចប្រកបពាក្យដោយផ្ទាល់មាត់នៅពេលគ្រូអានឬថាពាក្យទាំងនោះជាព្យញ្ជនៈប្រកបខាងចុងគ្មានបន្តក់ និងមានបន្តក់ ។
ឧទាហរណ៍: គ្រូថាពាក្យ "**កាច់**" រួចឱ្យសិស្សប្រកបដោយឆ្លើយសំណួរ តើពាក្យ"**កាច់**" មានអក្សរអ្វីខ្លះ? សិស្សឆ្លើយ ផ្ទាល់មាត់: **ក** ា និង**ច** **កាច** បន្តក់មួយ **កាច់** ឯពាក្យដទៃទៀតគ្រូធ្វើតាមលំនាំដូចនេះដែរ ។

☑ សិស្សអាចបំពេញព្យញ្ជនៈក្នុងតារាងដើម្បីបង្កើតបានជាពាក្យមានន័យត្រឹមត្រូវ (២) ។

| | | | |
|---|---|---|---|
| | រឹ | | ក |
| | វ | ក | |
| ង | | ម៉ា | ត់ |
| ទឹ | ក | | វ |

→

| | | | |
|---|---|---|---|
| សា | រឹ | ង | ក |
| ក | វ | ក | ប |
| ង់ | ក | ម៉ា | ត់ |
| ទឹ | ក | រា | វ |

**ចម្លើយ**
-សារម៉ាវ
-ទឹកកក
-ទឹករាវ
-រឹង កង់ បត់

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**







លេខ ៣ លេខ ៨ លេខ ១០ លេខ ១២ មេរៀនទី៧,ទី៨

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ១៥

***កំណត់សម្គាល់ :*** (២)*សកម្មភាពគំរូមួយនេះគ្រូអាចឱ្យសិស្សអនុវត្តនៅលើ ក្តារខៀនក្នុងសៀវភៅសរសេររបស់សិស្សក្នុងថ្នាក់ឬនៅផ្ទះ ។*

លេខ ១៨

# សិស្សអាចអានស្រៈពេញតួ និងពាក្យទាំងអស់

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់តួអក្សរនិងសូរ**
**: ការចេះវាក្យសព្ទ**
**: ការអានដើម្បីយល់ន័យ**

សូមមើល មេរៀនទី ៨ (ទំព័រទី ៨ ) ⟶

## សកម្មភាពគំរូ

- ☑ សិស្សអានស្រៈពេញតួទាំងអស់តាមលំដាប់លំដោយបានត្រឹមត្រូវ ។ (អ ... ឪ)
- ☑ សិស្សអានស្រៈពេញតួទាំងអស់មិនតាមលំដាប់លំដោយ (អានឆ្លាស់ចុះឡើង)តាមការកំណត់របស់គ្រូ ។
- ☑ សិស្សអានពាក្យចំណាំដែលប្រើញឹកញាប់មានស្រៈពេញតួនៅក្នុងបណ្ណពាក្យដែលគ្រូបង្ហាញ ។
- ☑ សិស្សផ្គូផ្គងពាក្យចំណាំដែលប្រើញឹកញាប់មានស្រៈពេញតួជាមួយបណ្ណរូបភាពតាមការកំណត់របស់គ្រូ ។
- ☑ សិស្សជ្រើសរើសរូបភាពមួយចំនួនហើយផ្គូផ្គងទៅនឹងពាក្យចំណាំមានស្រៈពេញតួដែលប្រើញឹកញាប់ ។
- ☑ សិស្សឆ្លើយទៅនឹងសំណួរអំពីន័យរបស់ឃ្លាល្បះមានស្រៈពេញតួដែលបានអាន ។
- ☑ សិស្សរៀបពាក្យក្នុង ឃ្លា ល្បះមានស្រៈពេញតួ ឡើងវិញបានត្រឹមត្រូវ ។
  ឧទាហរណ៍ : ឰឱម|ក្រឪឈូក|នៅឯបឹង|ដក
  ☛ ឰឱមដកក្រឪឈូកនៅឯបឹង ។
- ☑ សិស្សប្រើពាក្យផ្ទាល់ខ្លួនដើម្បីពន្យល់ន័យរបស់ ឃ្លា ឬល្បះខ្លីមានស្រៈពេញតួ ។

## ខ្លឹមសារ

- ស្រៈពេញតួទាំង១៥តួ និងពាក្យទាំងអស់ដែលបង្កើតចេញពីស្រៈពេញតួក្នុងមេរៀនទី៨ ៖
  - អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ ។
  - អគារ អាហារ ឥសី ឧកញ៉ា ឳទឹន ឫក្ស ឱសថ ឰដ៏



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ១៨

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ** →



លេខ ៨



លេខ ៩



លេខ ១១



លេខ ១២ មេរៀនទី៩




**ដំណាក់កាលទី ១ ត្រូវបានបញ្ចប់ហើយ!**

សូមធ្វើតេស្តសិស្សដោយប្រើ

តេស្តដំណាក់កាលទី ១

នៃឧបសម្ព័ន្ធ ៣ នៅក្នុងសៀវភៅនេះ

ទំព័រទី ១៥២

# ដំណាក់កាលទី ២ : មេរៀនទី ៩ - ២១

(ទំព័រទី ៩ ដល់២១ )

*វំពុកព្យញ្ជនៈផ្ញើជើង*

*សប្តាហ៍ទី ៤ ខែ តុលា  ដល់ សប្តាហ៍ទី ២ ខែវិច្ឆិកា*

*( ៣៩ ម៉ោង / ៣,០ សប្តាហ៍)*

## លេខ ២ក សិស្សអាចប្រាប់សូរព្យញ្ជនៈផ្ញើជើង និងអាចអានព្យាង្គព្យញ្ជនៈផ្ញើជើងផ្សំនឹងស្រៈ

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់តួអក្សរនិងសូរ**

សូមមើល មេរៀនទី៩ - ២១ (ទំព័រទី៩ - ២១) →

### ខ្លឹមសារ

- សូមស្រង់ព្យាង្គព្យញ្ជនៈផ្ញើជើងក្នុងមេរៀនទី៩-២១ និងរំឭកព្យាង្គព្យញ្ជនៈផ្ញើជើងក្នុងសៀវភៅអាន-សរសេរភាសាខ្មែរថ្នាក់ទី២ទំព័រទី៩-២១ ។

### សកម្មភាពគំរូ

- ☑ សិស្សរៀបព្យញ្ជនៈ និងបណ្ណជើងព្យញ្ជនៈ ទៅតាមសូរដែលគ្រូអាន ។
- ☑ សិស្សរៀបព្យញ្ជនៈ បណ្ណជើងព្យញ្ជនៈ និងបណ្ណស្រៈទៅតាមព្យាង្គដែលគ្រូអាន ។
- ☑ សិស្សចង្អុលព្យញ្ជនៈផ្ញើជើងតាមគ្រូអាននៅលើក្តារខៀន ។
  ឧទាហរណ៍ : ខ្ល ឆ្ក ត្ន ថ្ក ផ្ត...
- ☑ សិស្សចង្អុលព្យាង្គ (មានព្យញ្ជនៈ ជើងព្យញ្ជនៈ និងស្រៈ) តាមគ្រូអាននៅលើក្តារ ខៀន ។
  ឧទាហរណ៍ : ខ្លា ឆ្កិ ត្នី ថ្កី ផ្តី...។ ពេលគ្រូថា "ខ្លា" សិស្សចង្អុលលើក្តារខៀនត្រង់ "ខ្លា"

### ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ២ក

### ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



លេខ ១០



លេខ ១២ មេរៀនទី១១, ១២, ១៣, ១៤, ១៥, ១៦, ១៧, ១៨, ១៩, ២០, ២១, ២២, ២៣, ២៤, ២៥, ២៦, ២៧, ២៨, និង ២៩

**លេខ ២ខ**

# សិស្សអាចអានព្យញ្ជនៈផ្ញើជើងផ្សំនឹងស្រៈនិស្ស័យ ព្រមទាំងពាក្យដែលមាន ឬគ្មានព្យញ្ជនៈប្រកបខាងចុង

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់តួអក្សរនិងសូរ**

**: ការចេះវាក្យសព្ទ**

សូមមើល មេរៀនទី៩ - ២១ (ទំព័រទី៩ -២១) ⟶

## សកម្មភាពគំរូ

☑ សិស្សរៀបបណ្ណអក្សរចល័ត (ព្យញ្ជនៈ ជើងព្យញ្ជនៈ និងស្រៈ) ទៅជាពាក្យតាមរូបភាពដែល គ្រូកំណត់ ។

ឧទាហរណ៍ :  ខ+ ្ទ + ឹ+ ម = ខ្ទឹម

☑ សិស្សផ្គូផ្គងបណ្ណពាក្យ ផ្ញើជើងទៅនឹងបណ្ណរូបភាព ។ ឧទាហរណ៍ :

| |
|---|
| ម្នាស់ |
| ថ្កូវ |
| ម្ទេស |



☑ សិស្សបំពេញជើងព្យញ្ជនៈក្នុងពាក្យផ្ញើជើងមួយព្យាង្គ ពីរព្យាង្គ បានត្រឹមត្រូវ ។ ឧទាហរណ៍ :

មាស់ ⟶ ម្នាស់

ត្នញតែរ ⟶ ត្នួញត្អែរ

សាត់សៀម ⟶ ស្វាត់ស្វៀម

☑ សិស្សចង្អុលពាក្យផ្ញើជើងក្នុងមេរៀនសៀវភៅសិស្ស តាមការអានរបស់គ្រូ ។

☑ សិស្សរៀបព្យញ្ជនៈ ជើងព្យញ្ជនៈ និងស្រៈនិស្ស័យដែលមិនត្រូវតាមលំដាប់ទៅជាពាក្យត្រឹមត្រូវវិញ ។

| | | |
|---|---|---|
| ង ្ក េក | ⟶ | ក្មេង |
| ា ខ ្ល | ⟶ | ខ្លា |
| ប់ ស្ង ង ស្វែ | ⟶ | ស្ងប់ស្ងែង |
| ាំ ផ្ក ផ្ក ែ | ⟶ | ផ្អែផ្កាំ |

## ខ្លឹមសារ

◆ សូមស្រង់ពាក្យពីមេរៀនទី៩-២១និងរំឭកពាក្យផ្ញើជើងក្នុងសៀវភៅអាន-សរសេរ ភាសាខ្មែរ



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ២ខ



លេខ ៨



លេខ ១០



លេខ ១២ : មេរៀនទី១១,១២, ១៣,១៤,១៥,១៦,១៧,១៨,១៩ ,២០,២១,២២,២៣,២៤,២៥,២៦,២៧,២៨ និង២៩

↑

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**

**លេខ ២គ**

# សិស្សអាចអាន ឃ្លា ល្បះខ្លីដែលកើតចេញពីព្យញ្ជនៈផ្ញើជើង ផ្សំនឹងស្រៈ និងព្យញ្ជនៈប្រកបបានស្ទាត់

**បំណិនអំណានពាក់ព័ន្ធ : ការចេះអានស្ទាត់**

សូមមើល មេរៀនទី៩ - ២១ (ទំព័រទី ៩- ២១) →

## ខ្លឹមសារ

- សូមស្រង់ឃ្លា ល្បះទាំងអស់ក្នុងមេរៀនទី៩-២១នៃសៀវភៅអាន-សរសេរភាសាខ្មែរថ្នាក់ទី២ ដែលមានព្យញ្ជនៈផ្ញើជើងផ្សំនឹងស្រៈ និងព្យញ្ជនៈប្រកប ។

## សកម្មភាពគំរូ

☑ សិស្សអានឮ ឃ្លា ល្បះខ្លីៗមួយចំនួនក្នុងសៀវភៅសិស្សដែលមានប្រើព្យញ្ជនៈផ្ញើជើងផ្សំនឹងស្រៈ និង ព្យញ្ជនៈប្រកបបានស្ទាត់ ។

☑ សិស្សអានឮឃ្លាមួយចំនួនមានពាក្យដែលប្រើព្យញ្ជនៈផ្ញើជើង ស្រៈនិងព្យញ្ជនៈប្រកប តាមពេលកំណត់របស់គ្រូ ។



## ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ២គ

## ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



លេខ ១០



លេខ ១១




លេខ ១២: មេរៀនទី១១, ១២, ១៣, ១៤, ១៥, ១៦, ១៧, ១៨, ១៩, ២០, ២១, ២២, ២៣, ២៤, ២៥, ២៦, ២៧, ២៨, និង ២៩

លេខ ២យ

# សិស្សអាចអានយល់ ឃ្លា ល្បះខ្លីៗ ដែលប្រើពាក្យកើតចេញពី ព្យញ្ជនៈផ្ញើជើង ផ្សំនឹងស្រៈនិស្ស័យ មាន ឬគ្មានព្យញ្ជនៈប្រកបខាងចុង

## បំណិនអំណានពាក់ព័ន្ធ : ការអានដើម្បីយល់ន័យ

សូមមើល មេរៀនទី៩- ២១ (ទំព័រទី៩- ២១)

### ខ្លឹមសារ

- សូមស្រង់ ឃ្លា ល្បះខ្លីៗពីមេរៀនទី៩-២១ ដែលមានពាក្យផ្ញើជើងក្នុងសៀវភៅអាន-សរសេរ ភាសាខ្មែរថ្នាក់ទី២ទំព័រទី ៩-២១

### សកម្មភាពគំរូ

☑ សិស្សរៀបបណ្តាពាក្យទៅជា ឃ្លា ល្បះ ពេញលេញតាមការកំណត់របស់គ្រូ ហើយអានបានត្រឹមត្រូវ។

ឧទាហរណ៍ : ក

| | | | | | | |
|---|---|---|---|---|---|---|
| ក្បែរ | ចាក់ | ក្មេង | លោត | ត្នោត។ | ត្លុក | ដើម |

→ ក្មេងលោតចាក់ត្លុកក្បែរដើមត្នោត ។

ឧទាហរណ៍ : ខ

| | | | | | |
|---|---|---|---|---|---|
| ពីលើ | គ្រែ។ | ឆ្មា | ទៅ | តុ | លោត |

→ ឆ្មាលោតពីលើតុទៅគ្រែ ។

☑ សិស្សជ្រើសរើសពាក្យផ្ញើជើងបំពេញក្នុងល្បះ ហើយអានបានត្រឹមត្រូវ ។ ឧទាហរណ៍ : ចូរជ្រើសរើសពាក្យក្នុងប្រអប់មកបំពេញក្នុងល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| | | | | | | | |
|---|---|---|---|---|---|---|---|
| ខ្លា | ព្រឹក | ធ្យូង | ម្ហូប | ផ្កា | ម្ទេស | ស្ពាន | ម្ជូរ |

ក.មីងខុមស្ល..................ត្រីស្លឹកអំពិល ។

ខ.អំបិល.......................នេះហឹរណាស់ ។

គ.................រីកស្គុះស្គាយក្នុងសួនពេល................។

បន្តទៅទំព័របន្ទាប់ →

លេខ ២ឃ

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សអាចឆ្លើយសំណួរ អំពីន័យរបស់ឃ្លានិងល្បះដែលមានពាក្យជាព្យញ្ជនៈផ្ញើជើងបានត្រឹមត្រូវ ។

ឧទាហរណ៍ :

-ឆ្មាលោតពីតុទៅលើគ្រែ ។ តើឆ្មាកំពុងធ្វើអ្វី?

-ក្មេងៗលោតចាក់ត្លុកក្បែរដើមត្នោត។ តើក្មេងៗកំពុងធ្វើអ្វី?

-តើល្បះខាងលើនេះពាក្យណាខ្លះជាពាក្យដែលមានព្យញ្ជនៈផ្ញើជើង?

### ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



លេខ ៨



លេខ ១០



លេខ ១១



លេខ ១២: មេរៀនទី១១,១២,១៣, ១៤,១៥,១៦,១, ១៨,១៩,២០,២១,២២, ២៣,២៤, ២៥,២៦,២៧,២៨ និង២៩

### ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ២ឃ




**ដំណាក់កាលទី ២ ត្រូវបានបញ្ចប់ហើយ!**

សូមធ្វើតេស្តសិស្សដោយប្រើ

តេស្តដំណាក់កាលទី ២

នៃឧបសម្ព័ន្ធ ៣ នៅក្នុងសៀវភៅនេះ

ទំព័រទី ១៥៨

# ដំណាក់កាលទី ៣ : មេរៀនទី ២២ - ៣១

**(ទំព័រទី ២២ ដល់៣១)**

*វិញ្ញាសាត្រៀមការប្រឡង*

*( សប្តាហ៍ទី៣ ខែ វិច្ឆិកា ដល់ សប្តាហ៍ទី១ ខែធ្នូ )*

*(៣០ ម៉ោង/ ២,៣០ សប្តាហ៍ )*

លេខ ៣ក

# សិស្សអាចបំបែកពាក្យព្យាង្គតម្រួត(ព្យញ្ជនៈព្យាង្គតម្រួតដែលមានជើងមួយ និងជើងពីរ)

ឧទាហរណ៍ :

-អង្គាម អានថា អ និង ង អង់ ជើង ្គ អា កា កា និង ម កាម = អង្គាម

-កញ្ច្រោង អានថា ក និង ញ កញ់ ជើង ្ច និង ្រ ជ្រ ជ្រ អោ ជ្រោ ជ្រោ និង ង ជ្រោង = កញ្ច្រោង

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់សូរ**

**: ការស្គាល់តួអក្សរនិងសូរ**

សូមមើល មេរៀនទី ២២ - ៣១ (ទំព័រទី ២២- ៣១) →

## ខ្លឹមសារ

- សូមស្រង់ពាក្យព្យាង្គតម្រួតទាំងអស់ដែលមានជើងមួយនិងជើងពីរ ក្នុងមេរៀនទី ២២-៣១

## សកម្មភាពគំរូ

☑ សិស្សកំណត់ចំនួនសូរក្នុងពាក្យដែលគ្រូបង្ហាញ ។

ឧទាហរណ៍ : តើពាក្យកញ្ច្រោងមានសូរប៉ុន្មាន ?

☑ សិស្សរៀបបណ្ណអក្សរដើម្បីបង្ហាញពាក្យព្យាង្គតម្រួតដែលកំណត់ដោយគ្រូ។

| ញ្ជ | ង | ញ្ជ | ក | ោ | ្រ | = | កញ្ច្រោង |
|---|---|---|---|---|---|---|---|

## ការវាយតម្លៃ



ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៣ក

## ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



លេខ ១០



លេខ ១១



លេខ ១២: មេរៀនទី៣០,ទី៣១

**លេខ ៣២**

# សិស្សអាចអាន ពាក្យព្យាង្គតម្រួតព្រមទាំងស្រៈ និស្ស័យនិងព្យញ្ជនៈប្រកបខាងចុងបានត្រឹមត្រូវ

**បំណិនអំណានពាក់ព័ន្ធ :** **ការស្គាល់តួអក្សរនិងសូរ**

**: ការចេះវាក្យសព្ទ**

សូមមើលមេរៀនទី២២-៣១ (ទំព័រទី២២-៣១) →

## ខ្លឹមសារ

- សូមស្រង់ពាក្យព្យាង្គតម្រួតទាំងអស់ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី២ មេរៀន ទី២២-៣១ (ទំព័រទី ២២-៣១)

## សកម្មភាពគំរូ

☑ សិស្សចង្អុលពាក្យព្យាង្គតម្រួតក្នុងសៀវភៅសិស្សទៅតាមការហៅរបស់គ្រូ ។

☑ សិស្សកំណត់ពាក្យព្យាង្គតម្រួតក្នុងតារាងត្រូវនឹងរូបភាពតាមការកំណត់របស់គ្រូបានត្រឹមត្រូវ ។ ឧទាហរណ៍



| | | |
|---|---|---|
| កង្កែប | ទន្សាយ | កញ្ជ្រោង |



| | | |
|---|---|---|
| កញ្ជ្រោង | កង្កែប | ចង្អេរ |

☑ សិស្សបំពេញជើងព្យញ្ជនៈក្នុងពាក្យព្យាង្គតម្រួត មួយព្យាង្គ ពីរព្យាង្គបានត្រឹមត្រូវ ។ ឧទាហរណ៍

កញ្ជោង → កញ្ជ្រោង

ចងេរ → ចង្អេរ

អង្កង → អង្រ្កង



## ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៣២



លេខ ១២: មេរៀនទី៣០,ទី៣១

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ** →



លេខ ៨



លេខ ១០



លេខ ១១

លេខ ៣គ

# សិស្សអាចអានស្ទាត់ឃ្លាល្បះខ្លីៗដែលមានពាក្យជាព្យាង្គតម្រួតកើតឡើងពីព្យញ្ជនៈផ្ញើជើងមួយនិងជើងពីរ

**បំណិនអំណានពាក់ព័ន្ធ : ការចេះអានស្ទាត់**

សូមមើល មេរៀនទី២២- ៣១ (ទំព័រទី ២២ - ៣១) →

## ខ្លឹមសារ

- សូមស្រង់ឃ្លា ល្បះ ព្យាង្គតម្រួតទាំងអស់ក្នុងសៀវភៅភាសាខ្មែរអាន-សរសេរថ្នាក់ទី២ មេរៀនទី២២-៣១ (ទំព័រទី ២២-៣១) ។

## សកម្មភាពគំរូ

☑ សិស្សអានស្ទាត់ ឃ្លា ល្បះខ្លីៗ ក្នុងសៀវភៅសិស្សដែលមានប្រើពាក្យព្យាង្គតម្រួតកើតឡើងពីព្យញ្ជនៈផ្ញើជើងមួយនិងជើងពីរ ។

☑ សិស្សអានដោយស្ទាត់ ឃ្លា ល្បះខ្លីៗក្នុងតារាងដែលមានប្រើពាក្យព្យាង្គតម្រួតកើតឡើងពីព្យញ្ជនៈផ្ញើជើងមួយនិងជើងពីរ តាមការកំណត់របស់គ្រូ ។

## ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៣គ

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



លេខ ១០



លេខ ១១



លេខ ១២: មេរៀនទី៣០, ទី៣១

# លេខ ៣៥ សិស្សអាចអានយល់ឃ្លាឬល្បះខ្លីៗដែលប្រើពាក្យព្យាង្គតម្រួតកើតឡើងពីព្យញ្ជនៈផ្ញើជើងមួយ និងជើងពីរ

**បំណិនអំណានពាក់ព័ន្ធ : ការអានដើម្បីយល់ន័យ**

សូមមើល មេរៀនទី២២- ៣១ (ទំព័រទី ២២ - ៣១) ⟶

## សកម្មភាពគំរូ

☑ សិស្សអាចឆ្លើយសំណួរអំពីន័យរបស់ឃ្លា ល្បះខ្លីៗដែលកើតឡើងពីព្យញ្ជនៈផ្ញើជើងមួយ និងជើងពីរ តាមការកំណត់របស់គ្រូ ។

☑ សិស្សអាចរៀបបណ្តាពាក្យ និងពាក្យព្យាង្គតម្រួតទៅជាឃ្លា ល្បះមានន័យត្រឹមត្រូវ ។

| ទន្សើម ។ | ទឹក | ផឹក | ទន្សាយ |
|---|---|---|---|

⟹ ទន្សាយផឹកទឹកសន្សើម ។

☑ សិស្សអាចប្រើពាក្យផ្ទាល់ខ្លួនដើម្បីពន្យល់ន័យនៃឃ្លាល្បះមានប្រើពាក្យព្យាង្គតម្រួតដែលកើតឡើងពីព្យញ្ជនៈផ្ញើជើងមួយនិងជើងពីរ។

## ខ្លឹមសារ

- សូមស្រង់ឃ្លា ល្បះ ទាំងអស់ដែលមាន ប្រើពាក្យព្យាង្គតម្រួតកើតពីព្យញ្ជនៈផ្ញើជើងមួយ និងជើងពីរ ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរថ្នាក់ទី២ មេរៀនទី ២២-៣១ (ទំព័រទី២២-៣១)



## ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៣៥

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ** ⟶



លេខ ១០



លេខ ១១



លេខ ១២: មេរៀនទី៣០,ទី៣១




**ដំណាក់កាលទី ៣ ត្រូវបានបញ្ចប់ហើយ!**

សូមធ្វើតេស្តសិស្សដោយប្រើ

<u>តេស្តដំណាក់កាលទី ៣</u>

នៃឧបសម្ព័ន្ធ ៣ នៅក្នុងសៀវភៅនេះ

ទំព័រទី១៦១

# **ដំណាក់កាលទី ៤ : មេរៀនទី ៣២-៤០**(៣)

**(ទំព័រទី ៣២ ដល់ ៥៧)**

-**អំណាន និងសំណេរ** : អត្ថបទ កំណាព្យ និងចម្រៀងអំពី

*១. មេរៀនទី ៣២ : បរិវេសនកាល*

*២. មេរៀនទី៣៣ : ពេលចេញលេង*

*៣. មេរៀនទី៣៤ : ឆ្មាចង់ទៅរៀន (កំណាព្យ/មេសូត្រ)*

*៤. មេរៀនទី៣៦ : សត្វក្រសារ*

*៥. មេរៀនទី៣៧ : ការខិតខំរៀនសូត្រ*

*៦. មេរៀនទី៣៩ : យើងទៅសាលារៀន (ចម្រៀង)*

*៧. មេរៀនទី ៤០ : ការធ្វេសប្រហែស*

*( សប្ដាហ៍ទី ២ ខែ ធ្នូ ដល់សប្ដាហ៍ទី ២ ខែ មករា )*

*( ៥៦ម៉ោង/ ៤,៣ សប្ដាហ៍ )*

***កំណត់សម្គាល់ :*** *(៣)ចំពោះមេរៀនទី៣៥សមត្ថភាពនិយាយមានចំនួន៦ម៉ោងសិក្សា និងមេរៀនទី៣៨ សមត្ថភាពស្ដាប់មានចំនួន៦ម៉ោងសិក្សា ។ មេរៀនទាំងនេះមិនទាក់ទងស្ដង់ដាអំណានទេគ្រូត្រូវបង្រៀនធម្មតា*

លេខ ៩ក

# សិស្សអាចអានពាក្យក្នុងមេរៀនដោយផ្សំនិងប្រកប

ឧទាហរណ៍: អញ្ជើញ អានថា អាញ់ - ជើញ

បរវេសនកាល អានថា ប៉ះ-វ៉េ-សៈ-ន៉ៈ-កាល

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់តួអក្សរនិងស្រៈ**

សូមមើល មេរៀនទី៣២- ៤០ (ទំព័រទី ៣២- ៥៧)

**ខ្លឹមសារ**

- សូមស្រង់ពាក្យក្នុងមេរៀនទី៣២-៤០ដូចខាងក្រោម ៖

**មេរៀនទី៣២** : អញ្ជើញ បរវេសនកាល

**មេរៀនទី៣៣** : សិស្សានុសិស្ស ត្រែះ បណ្ណាល័យ អន្ទាក់ អង្គុយ ប្រយោជន៍

**មេរៀនទី៣៤** : កាយា ឫកពា អៀនប្រៀន

**មេរៀនទី៣៦** : ត្រីចង្វា ត្រីក្រាញ់ ត្រីឆ្ដោ ងងឹត ទ្រនំ ក្រសារ ស្រែកឃ្លាន ព្រលប់

**មេរៀនទី៣៧** : ក្មេងខ្ចី ការងារ ដូច្នេះ ខ្ជាប់ខ្ជួន ព្យាយាម លទ្ធផល សប្បាយ មាតាបិតា អនាគត ភ្លឺស្វាង

**មេរៀនទី៣៩** : កម្សាន្ត មិត្ត យើង អារម្មណ៍ ពាក្យ បង្រៀន កន្ទើយ សាលារៀន ស្គាំ

**មេរៀនទី៤០** : ថ្ងៃ មេរៀន ប្រាប់ សៀវភៅ ឆ្វេង ស្ដាំ លូក រាវ

## សកម្មភាពគំរូ

☑ សិស្សអានពាក្យដោយការញែកព្យាង្គរបស់ពាក្យនីមួយៗហើយថាតាមបន្តគ្នាម្ដងម្នាក់ឬថាតាមជាក្រុមតូចៗរហូតដល់ចប់ពាក្យនីមួយៗតាមការពន្យល់របស់គ្រូនៅលើក្ដារខៀន ។

ឧទាហរណ៍ :គ្រូសរសេរពាក្យ **បរវេសនកាល** នៅលើក្ដារខៀនរួចនាំសិស្សអាន:

| | |
|---|---|
| -គ្រូថា | **ប៉ះ** |
| -សិស្សទី១ថា | **វ៉េ** |
| -សិស្សទី២ថា | **សៈ** |
| -សិស្សទី៣ថា | **នៈ** |
| -សិស្សទី៤ ថា | **កាល** |

បន្តទៅទំព័របន្ទាប់

## លេខ ៩ក បន្ត...

### សកម្មភាពគំរូ

☑ សិស្សអាចអានពាក្យដោយការញែកព្យាង្គរបស់ពាក្យតាមការហៅរបស់គ្រូនៅលើក្ដារខៀនរួចអានព្យាង្គទី១ក្នុងពាក្យនោះ ។ បន្ទាប់មកសិស្សម្នាក់ទៀតនៅខាងស្ដាំដៃគេអានព្យាង្គមួយទៀតបន្តធ្វើបែបនេះរហូតដល់ចប់ពាក្យនីមួយៗ ។

ឧទាហរណ៍ : សិស្សទី១អានថា ប៉ះ
សិស្សខាងស្ដាំដៃទី១ថា រ៉េ
សិស្សខាងស្ដាំដៃមួយទៀតថា សះ
... ។

☑ គ្រូនាំសិស្សលេងល្បែងទះដៃដើម្បីកំណត់ចំនួនព្យាង្គរបស់ពាក្យក្នុងការអានពាក្យពីរព្យាង្គ បីព្យាង្គ ឬច្រើនព្យាង្គដោយឱ្យសិស្សជ្រើសរើសពាក្យធ្លាប់រៀនឬចេះចាំដោយខ្លួនឯង ។

ឧទាហរណ៍ : គ្រូទះដៃតាមចំនួនព្យាង្គរបស់ពាក្យ ២ដងឬ៣ដងសិស្សត្រូវថាពាក្យនោះពីរព្យាង្គ ឬបីព្យាង្គដែរ ។

-ទះដៃពីរដង : កង្កែប កញ្ជ្រោង កញ្ច្រែង ក្រសារ ព្រលប់ ស្រែកឃ្លាន... (ពាក្យពីរព្យាង្គ)

-ទះដៃបីដង : បណ្ណាល័យ កណ្ដៀតក្អម សណ្ឋាគារ សាលារៀន លទ្ធផលអនាគត... (ពាក្យបីព្យាង្គ)

-ទះដៃបួនដង : សន្ទោសន្ទៅ បន្លែបង្ការ កណ្ដោចកណ្ដែង បញ្ឆិតបញ្ឆៀង មាតាបិតា អំពិលអំពែក សម្លោងសម្លាយ សម្លក់សម្លឹង...(ពាក្យបួនព្យាង្គ) ។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



លេខ ១០



លេខ ១១



លេខ ១៤



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៩ក

លេខ ៤ខ

# សិស្សអាចពន្យល់ពាក្យពិបាក ពាក្យន័យដូច និង ពាក្យផ្ទុយ

**បំណិនអំណានពាក់ព័ន្ធ : ការចេះវាក្យសព្ទ**

សូមមើល មេរៀនទី ៣២- ៤០ (ទំព័រទី ៣២ - ៥៧)

## ខ្លឹមសារ

- **សូមមើលនិងស្រង់** ពន្យល់ពាក្យ ពាក្យន័យដូច ពាក្យផ្ទុយក្នុងមេរៀនទី៣២-៤០ ៖

**ពន្យល់ពាក្យ**

បរវេសនកាល បណ្ណាល័យ

សិស្សានុសិស្ស ត្រែះ សិស្ស

ឫកពា កាយា ចឹក ទ្រនំ លទ្ធផល

តបស្នង អនាគត កន្តើយ កម្សាន្ត

អារម្មណ៍ ធ្វេសប្រហែស រាវ ពុម្ព

**ពាក្យន័យដូច**

ម៉ាក់ ម៉ែ ម្ដាយ មាតា ស្រស់ស្រូប

ទទួលទាន ហូប ពិសា ស៊ី ឆី ឆាន់

សោយ ទ្រនំ សម្បុក លំនៅ ផ្ទះ,

ព្យាយាម ប្រឹងប្រែង ខិតខំ អំណត់ ដើរ

យាង យាត្រា និមន្ត ធ្វើដំណើរ, ឱ្យ ជូន

ប្រគេន ថ្វាយ ប្រទាន

**ពាក្យផ្ទុយ**

រីករាយ ≠ កើតទុក្ខ

បរវេសនកាល ≠ វិស្សមកាល

ទូលាយ ≠ ចង្អៀត

សប្បាយ ≠ កើតទុក្ខ

ធំ ≠ តូច

ស្រេកឃ្លាន ≠ ឆ្អែតឆ្អន់

មិត្ត ≠ សត្រូវ

គុណ ≠ ទោស

ធូរ ≠ តឹង

ភ្លឺស្វាង ≠ ងងឹតងងល់

យូរ ≠ឆាប់

បន្តទៅទំព័របន្ទាប់

លេខ ៤ខ

**បន្ត...**

## សកម្មភាពគំរូ

☑ សិស្សគូសរង់ជុំវិញពាក្យន័យដូច និងពាក្យផ្ទុយតាមបញ្ជីពាក្យដែលគ្រូកំណត់ ។

ឧទាហរណ៍ : តារាងបញ្ជីពាក្យ

| គូសរង់ពាក្យន័យដូច | គូសរង់ពាក្យន័យដូច | គូសរង់ពាក្យផ្ទុយ |
|---|---|---|
| បន្ថែបង្ការ | កណ្ដោចកណ្ដែង | វែង |
| ឪពុក | ទីលំនៅ | តូច |
| កញ្ច្រែង | បណ្ណាល័យ | ធ្ងន់ |
| ប៉ា | អណ្ដើក | ខ្ពស់ |
| សណ្ឋាគារ | គេហដ្ឋាន | ធំ |

☑ សិស្សផ្គូផ្គងពាក្យពិបាកទៅនឹងន័យរបស់វាបានត្រឹមត្រូវតាមការកំណត់របស់គ្រូ។

ឧទាហរណ៍ : តារាងផ្គូផ្គងពាក្យពិបាកទៅនឹងន័យ

| ពាក្យពិបាក | និយមន័យ |
|---|---|
| | ទីកន្លែងដែលសត្វស្លាបតែងហើរ ។ |
| ទ្រនំ → | ទីកន្លែងដែលសត្វស្លាបតែងទំ ។ |
| | ទីកន្លែងដែលសត្វតែងរកស៊ី ។ |
| | ផលដែលមើលឃើញ ។ |
| | ផលដែលគេធ្វើ ។ |
| លទ្ធផល → | ផលដែលសម្រេចបាន ។ |
| | ពេលឥឡូវ ។ |
| អនាគត → | ពេលខាងមុខ ។ |
| | ពេលកន្លងទៅ ។ |

បន្តទៅទំព័របន្ទាប់

**លេខ ៤ខ**

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សជ្រើសរើសពាក្យដែលមានន័យដូចគ្នា នឹងពាក្យក្នុងអត្ថបទមកបំពេញបានត្រឹមត្រូវ ។

ឧទាហរណ៍ទី១ :

សុភីចង់ទៅផ្ទះ...(១) បាយ និងត្រីកន្ត្រប់អាំងជាមួយ... (២) ... (៣) យ៉ាង... (៤) ។

- ប៉ា ញ៉ាំ សប្បាយ ម៉ាក់

***ចម្លើយ*** (១).ញ៉ាំ...... (២).ប៉ា....... (៣).ម៉ាក់.......(៤).សប្បាយ.....

ឧទាហរណ៍ទី២ :

ការងារទីមួយ(១)របស់សិស្សគឺខិតខំ(២)រៀនសូត្រ ។ សិស្សត្រូវឆ្លៀតពេល(៣)ខិតខំរៀនសូត្រឱ្យបានខ្ជាប់ខ្ជួន(៤)។ ការរៀនសូត្រល្អ(៥)គឺដោយសារ(៦)ការព្យាយាម ។

-ដំបូង រកឱកាស ជាប់ជានិច្ច ពូកែ មកពី ប្រឹងប្រែង

***ចម្លើយ*** (១)ដំបូង................ (២)ប្រឹងប្រែង............. (៣)រកឱកាស.............

(៤)ជាប់ជានិច្ច........ (៥)ពូកែ...................... (៦)មកពី......................

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



លេខ ១៦



លេខ ១៣



លេខ ១៥

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៤ខ

លេខ ៩គ

# សិស្សអាចអានពាក្យក្នុងមេរៀនដោយមិនបាច់ផ្សំ និងប្រកប

**បំណិនអំណានពាក់ព័ន្ធ : ការចេះអានស្ទាត់**

សូមមើល មេរៀនទី ៣២ - ៤០ (ទំព័រទី ៣២- ៥៧)

## ខ្លឹមសារ

♦ ស្រង់ពាក្យមេរៀនទី៣២-៤០ដូចខាងក្រោម ៖

**មេរៀនទី៣២** : ព្រលឹម សាលារៀន ស្លៀកពាក់ អញ្ជើញ បរវេសនកាល ឪពុកម្ដាយ កាយា ។

**មេរៀនទី៣៣** : សិស្សានុសិស្ស ត្រៃ: បណ្ណាល័យ ទូលាយ សប្បាយ អង្គុយ ។

**មេរៀនទី៣៤** : ឫកពា កាយា ព្រលឹម អាហារ អៀនប្រៀន ស្រស់ស្រូប ស្អាត ។

**មេរៀនទី៣៦** : ត្រីចង្វា ទ្រនំ ត្រីក្រាញ់ ត្រីឆ្ដោ ស្រេកឃ្លាន ងងឹត ក្រសារ ព្រលប់ ។

**មេរៀនទី៣៧** : ក្មេង ខ្ញី ការងារ ខ្ជាប់ខ្ជួន ដូច្នេះ ព្យាយាម លទ្ធផល សប្បាយ មាតាបិតា អនាគត ភ្លឺស្វាង ។

**មេរៀនទី៣៩** : កម្សាន្ត យើង អារម្មណ៍ ពាក្យ មិត្ត បង្រៀន កន្ទើយ សាលារៀន ស្ដាំ ។

**មេរៀនទី៤០** : ថ្ងៃ មេរៀន ប្រាប់ សៀវភៅ ឆ្វេង ស្ដាំ លូក រាវ ។

## សកម្មភាពគំរូ

☑ សិស្សអានពាក្យដោយមិនបាច់ផ្សំ និងប្រកបបានយ៉ាងលឿនតាមការកំណត់របស់គ្រូ ឬតាមបញ្ជីពាក្យក្នុងលំហាត់ ។

ឧទាហរណ៍ :ព្រលឹម សាលារៀន បរវេសនកាល អញ្ជើញ ស្លៀកពាក់ ឪពុកម្ដាយ កាយា អាហារ ស្រស់ស្រូប អៀនប្រៀន ត្រីចង្វា ត្រីឆ្ដោ អារម្មណ៍ ទ្រនំ ក្រសារ ស្រេកឃ្លាន ព្រលប់... ។

បន្តទៅទំព័របន្ទាប់

## លេខ ៩គ

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សមើលបញ្ជីពាក្យដែលគ្រូសរសេរឬបិទនៅលើក្ដារខៀន ។ បន្ទាប់មកគ្រូឱ្យសិស្សពីរនាក់ព្យាយាមអានបញ្ជីពាក្យ នោះឱ្យបានលឿនបំផុតដោយមិនបាច់ផ្សំ និងប្រកបតាមដែលអាចធ្វើទៅបាន ។ សិស្សណាអានបានគ្រប់ពាក្យបានត្រឹមត្រូវ ហើយចប់មុនគេសិស្សនោះជាអ្នកឈ្នះ ។

ឧទាហរណ៍ :ព្រលឹម សាលារៀន បរទេសនកាល អញ្ជើញ ស្លៀកពាក់ ឪពុកម្ដាយ កាយា អាហារ ស្រស់ស្រូប អៀនប្រៀន ត្រីចង្វា ត្រីឆ្ពោ អារម្មណ៍ ទ្រនំ ក្រសារ ស្រែកឃ្លាន ព្រលប់... ។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



លេខ ១០



លេខ ១១



លេខ ១៤



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៩គ

លេខ ៤យ

# សិស្សអាចបកស្រាយន័យឈ្មោះនិងអត្ថបទ

## ឧទាហរណ៍ :ឆ្លើយសំណួរកំណត់អំពីមនុស្ស វត្ថុ សត្វ...

## ការបំពេញឈ្មោះ និងលំហាត់ក្លូស្ស "cloze"

**បំណិនអំណានពាក់ព័ន្ធ : ការចេះវាក្យសព្ទ**

**: ការអានដើម្បីយល់ន័យ**

សូមមើល មេរៀនទី៣២- ៤០ (ទំព័រទី៣២ - ៥៧)

**ខ្លឹមសារ**

♦ សូមដកស្រង់ឈ្មោះ វត្ថុ អត្ថបទក្នុងមេរៀនទី៣២-៤០ "បវេសនកាល ពេលចេញលេង ឆ្មាចង់ទៅរៀន សត្វក្រសារ ការខិតខំរៀនសូត្រ យើងទៅសាលារៀន ការធ្វេសប្រហែស"

**សកម្មភាពគំរូ**

☑ សិស្សឆ្លើយនឹងសំណួរក្នុងមេរៀនសៀវភៅសិស្ស ។

**មេរៀនទី៣២ :**

១. តើនៅថ្ងៃបវេសនកាលសុភីទៅសាលាជាមួយនរណា?

២. តើម្ដាយសុភីផ្ដាំឱ្យសុភីធ្វើអ្វី?

៣. មុននឹងទៅសាលារៀន តើសុភីនិងប្អូនធ្វើអ្វីខ្លះ?

**មេរៀនទី៣៣ :**

១. តើសិស្សមានទឹកមុខដូចម្ដេច នៅពេលចេញលេង?

២. តើពួកគេលេងអ្វីខ្លះ នៅពេលចេញលេង ?

៣. តើនៅក្នុងបណ្ណាល័យ សិស្សកំពុងធ្វើអ្វី ?

៤. តើសិស្សគួរលេងល្បែងដូចម្ដេច ?

**មេរៀនទី៣៤ :**

១. តើពេលព្រលឹមនរណារៀបចំខ្លួនទៅសាលារៀន?

២. តើនារីធ្វើអ្វីខ្លះ មុនទៅសាលារៀន?

៣. តើនរណាចង់ទៅរៀនជាមួយនារី ?

៤. តើឆ្មាបានទៅរៀន ជាមួយនារីដែរឬទេ? ព្រោះអ្វី ?

បន្តទៅទំព័របន្ទាប់

លេខ ៩យ

**បន្ត...**

## សកម្មភាពគំរូ

**មេរៀនទី៣៦ :**

១. តើសត្វក្រសាររង់ចាំចឹកត្រីនៅឯណា?

២. តើក្រសារឃើញត្រីអ្វី មុនដំបូងគេ?

៣. តើក្រសារឃើញត្រីអ្វីខ្លះ ហែលពីមុខវា?

៤. តើក្រសារចឹកត្រីទាំងនោះស៊ីដែរឬទេ?

**មេរៀនទី៣៧ :**

១. តើការងារទី១របស់សិស្សគឺអ្វី?

២. តើការសិក្សាបានទទួលលទ្ធផលល្អដោយសារអ្វី?

៣. ដើម្បីតបស្នងសងគុណមាតាបិតា និងគ្រូតើសិស្សត្រូវធ្វើដូចម្ដេច?

៤. តើការខិតខំរៀនសូត្រនឹងធ្វើឱ្យសិស្សមានអនាគតដូចម្ដេច?

**មេរៀនទី៣៨ :**

១. តើពួកគេនាំគ្នាទៅឯណា?

២. តើគេប្រញាប់ទៅសាលារៀនឱ្យបានមុនអ្នកណា?

៣. តើពេលចេញលេងពួកគេនាំធ្វើអ្វី?

៤. តើអ្នកចូលចិត្តរៀនផង លេងកម្សាន្តផងដែរឬទេ? ព្រោះអ្វី?

**មេរៀនទី៤០ :**

១. តើអ្នកគ្រូបង្រៀនមេរៀនអ្វី?

២. តើធីតារកសៀវភៅអ្វី?

៣. តើធីតាទុកសៀវភៅ នៅឯណា?

៤. តើប្អូនត្រូវធ្វើដូចម្ដេចដើម្បីកុំឱ្យភ្លេចសៀវភៅ?

បន្តទៅទំព័របន្ទាប់

លេខ ៤ឃ

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សធ្វើចំណាត់ថ្នាក់មនុស្ស និងវត្ថុក្នុងល្បះដែលបានអានបានត្រឹមត្រូវ ។
ឧទាហរណ៍ : មេរៀនទី៣២ទំព័រ៤០ : សុភីនិងប្អូន ទៅងូតទឹក រួចស្លៀកពាក់ រៀបចំកាតាបទើបសំពះលាឪពុកម្ដាយទៅសាលារៀន ។

**ចម្លើយ :**

| វត្ថុ | មនុស្ស |
|---|---|
| -ទឹក | -សុភី |
| -កាតាប | -ឪពុក |
| ... | -ម្ដាយ |

☑ សិស្សឆ្លើយសំណួរបន្ថែមរបស់គ្រូទាក់ទងចំណងជើងអត្ថបទ ។
ឧទាហរណ៍ : ចូរដាក់ចំណងជើងអត្ថបទខាងលើជាថ្មីមួយទៀតក្នុងមេរៀនទី ៣៦,៣៧,៣៩,៤០។

ចូរប្អូនរកឬប៉ាន់ស្មានចំណងជើងអត្ថបទថ្មីមួយទៀតឱ្យអត្ថបទខាងលើតាមគំនិតផ្ទាល់ខ្លួន ។

**ចម្លើយ :**

**មេរៀនទី៣៦ :** សត្វក្រសារ ⟶ សត្វក្រសារចង់ស៊ីត្រីធំ ឬ...
**មេរៀនទី៣៧ :** ការខិតខំរៀនសូត្រ ⟶ ការព្យាយាមរៀនសូត្រ ឬ...
**មេរៀនទី៣៩ :** យើងទៅសាលារៀន ⟶ រៀនផងលេងផង ឬ...
**មេរៀនទី៤០ :** ការធ្វេសប្រហែស ⟶ ការមិនយកចិត្តទុកដាក់ ឬ...

បន្តទៅទំព័របន្ទាប់ ⟶

លេខ ៨យ

**បន្ត...**

## សកម្មភាពគំរូ

☑ សិស្សជ្រើសរើសពាក្យក្នុងប្រអប់ដើម្បីបំពេញល្បះបានត្រឹមត្រូវមេរៀនទី៣៦-៤០

ឧទាហរណ៍ :

| ទ្រនំ | ត្រីចង្វា | ហែល | ស្រេកឃ្លាន | មាត់បឹង | តូច |
|---|---|---|---|---|---|

១. មានក្រសារមួយឈរចាំចឹកត្រីនៅ................................................។

២. ពេលនោះមាន...................................តូចមួយបានហែលពីមុខវា ។

៣. សត្វក្រសារគិតថា ត្រីចង្វានេះ..........ណាស់ស៊ីក៏មិនឆ្អែតដែរ ។

៤. ត្រីចង្វាក៏.................................................បាត់ទៅ ។

៥. ក្រសារវិលទៅរក.....................វិញ ទាំងក្តី.................។

☑ សិស្សប្រាប់ពាក្យចួនក្នុងអត្ថបទចម្រៀងបានត្រឹមត្រូវតាមការណែនាំរបស់គ្រូដោយគូសរង្វង់ជុំវិញពាក្យចួននោះក្នុងឧទាហរណ៍នៅលើក្តារខៀន។ បន្ទាប់មកសិស្សអនុវត្ត ។

ឧទាហរណ៍ : មកមិត្តយើង**អើយ** កុំនៅក**ន្តើយ**ទៅសាលា**រៀន**

ដើរអែបខាងស្តាំតាមគ្រូ**បង្រៀន** ទៅសាលារៀនឱ្យបានមុនគ្រូ ។

............................................ ........................................ ។

**ចម្លើយ :**

| | | | | |
|---|---|---|---|---|
| វគ្គទី១ | ពាក្យ **អើយ** | ចួននឹងពាក្យ | **កន្តើយ** |
| | ពាក្យ **រៀន** | ចួននឹងពាក្យ | **បង្រៀន** |
| វគ្គទី២ | ពាក្យ **លេង** | ចួននឹងពាក្យ | **ក្មេង** |
| | ពាក្យ **យូរ** | ចួននឹងពាក្យ | **ធូរ** |

បន្តទៅទំព័របន្ទាប់

លេខ
៨យ

## មន្ត...

### សកម្មភាពគំរូ

☑ សិស្សបកស្រាយន័យរបស់ពាក្យពិបាកដោយប្រើបរិបទជាទីសេចក្តីជុំវិញពាក្យពិបាកនោះ ។

ឧទាហរណ៍ : ការខិតខំរៀនសូត្រធ្វើឱ្យសិស្សមានអនាគតភ្លឺស្វាង ។ សិស្សអាចពន្យល់ន័យរបស់ពាក្យ ភ្លឺស្វាង តាមភាសាផ្ទាល់ខ្លួន ។

ន័យពាក្យ ភ្លឺស្វាងគឺ ភ្លឺថ្លា ភ្លឺច្បាស់ល្អ ភ្លឺត្រចះត្រចង់ ។

ន័យក្នុងល្បះ មានន័យថាក្នុងល្បះនេះ ឃ្លាថា" អនាគតភ្លឺស្វាង" គឺជាភាពភ្លឺច្បាស់ ភ្លឺថ្លា ភ្លឺច្បាស់ល្អ ភ្លឺត្រចះត្រចង់នៅពេលខាងមុខដែលបញ្ជាក់ន័យឱ្យឃ្លា " ការខិតខំរៀនសូត្រ" របស់សិស្ស ។

☑ សិស្សបំពេញលំហាត់ក្លូស្ស(Cloze) ដោយប្រើបរិបទជាទីសេចក្តីក្នុងអត្ថបទតាមមេរៀនកំណត់ ។

ឧទាហរណ៍ : ថ្ងៃនេះជាថ្ងៃចូល... (១)ដំបូង ។

ព្រឹកនេះ ម្តាយសុភី...(២)កូនពីព្រលឹម។ គាត់ប្រាប់...(៣)ឱ្យរៀបចំខ្លួនទៅសាលារៀន ។ .......(៤)ភ្ញាក់ពីដំណេក រួចងើប.........(៥) ពីគ្រែ ។ នាងនិយាយ : "អូ............(៦) នេះជាថ្ងៃបវេសនកាលផង ។ ...........(៧)ម៉ាក់អញ្ជើញទៅជាមួយកូន............(៨)ឬទេ?" ។ "ទេកូន! ឆ្នាំ..........(៩)កូនធំហើយ ។ កូនទៅ...........(១០)ប្អូនហើយមើលប្អូនផង............(១១) !" ។

| | | | |
|---|---|---|---|
| ១. រៀន , សិក្សា | ៤. សុភី ,កូន | ៧. តើ | ១០. ជាមួយ |
| ២. ដាស់,ដាស់ | ៥. ចេញ, ចាកចេញ | ៨. ដែរ | ១១. ណា៎ ដែរ |
| ៣. សុភី , កូន | ៦.ថ្ងៃ ,ព្រឹក | ៩. នេះ ហ្នឹង | |

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



លេខ ១១

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៨យ

លេខ ៥ង

# សិស្សអាចសរសេរពាក្យ ល្បះតាមរយៈលំហាត់សរសេរតាមអាន

**បំណិនសំណេរពាក់ព័ន្ធ : សរសេរតាមអាន**

សូមមើល មេរៀនទី៣២- ៤០ (ទំព័រទី៣២- ៥៧)

**ខ្លឹមសារ**

- សរសេរតាមអានចម្លងអំពីពាក្យក្នុងសៀវភៅភាសាខ្មែរអាន-សរសេរថ្នាក់ទី២៖

**មេរៀនទី៣២** : ព្រលឹម សាលារៀន បរវេសនកាល អញ្ជើញ គ្រែ ប្រញាប់ ស្លៀកពាក់ ម្ដាយ សំពះ ឪពុក ។

**មេរៀនទី៣៣** : បណ្ណាល័យ ក្រុម ម្លប់ សិស្ស សិស្ស ស្នូរ គ្រែះ អង្គុយ សិស្សានុសិស្ស ។

**មេរៀនទី៣៤** : ព្រលឹម កាយា អាហារ ស្អាត ហ៊ាន ឬក ពីរ រវល់ ស្រស់ស្រូប អៀនប្រៀន ។

**មេរៀនទី៣៦** : គិត ស៊ី ក្រោយ ក្រសារ ងងឹត ទ្រនំ ឆ្អែត ព្រលប់ បន្តិច ស្រេកឃ្លាន ។

**មេរៀនទី៣៧** : ការងារ ខ្ជាប់ខ្ជួន មាតាបិតា លទ្ធផល ព្យាយាម ការខិតខំរៀនសូត្រនឹងធ្វើឱ្យសិស្សមានអនាគតភ្លឺស្វាង។

**មេរៀនទី៣៩** : ដើរ យូរ បង្រៀន បង្អង់ មិត្ត ល្បែងកម្សាន្តធ្វើឱ្យអារម្មណ៍យើងបានធូរ ។

**មេរៀនទី៤០** : ធ្វេសប្រហែស ឆ្វេងស្ដាំ គ្រូបង្រៀន សៀវភៅពុម្ព ខ្ញុំកំពុងរកសៀវភៅពុម្ពភាសាខ្មែរ ។ ខ្ញុំភ្លេចដាក់វាចូលក្នុងកាតាប ។

## សកម្មភាពគំរូ

☑ សិស្សសរសេរពាក្យដែលគ្រូហៅនៅលើក្ដារឆ្នួន តាមខ្លឹមសារកំណត់ខាងលើ ។

☑ សិស្សចម្លងពាក្យលើក្ដារខៀនតាមខ្លឹមសារដែលគ្រូបានកំណត់ខាងលើដាក់ក្នុងសៀវភៅសរសេររៀងៗខ្លួន ។

☑ សិស្សជ្រើសរើសពាក្យទៅបំពេញល្បះដូចមានក្នុងលំហាត់ទំព័រទី ៣៤,ទី៣៧ និងទី ៤០ ។

បន្តទៅទំព័របន្ទាប់

**លេខ ៤ង**

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សក្នុងក្រុម**ក**ដែលមានគ្នា៤នាក់ និងក្រុម**ខ**ដែលមានគ្នា៤នាក់សរសេរពាក្យចំនួន៥ពាក្យក្នុងមួយក្រុមៗតាមការជ្រើសរើសរបស់ក្រុមនីមួយៗរួចដូរគ្នាពិនិត្យ និងកែលម្អគ្នាទៅវិញទៅមក ។ ឯគ្រូជាអ្នកណែនាំនិងសម្របសម្រួលសិស្សតាមក្រុម ។

☑ សិស្សសរសេរ ពាក្យ ឬឈ្មោះតាមការអានរបស់គ្រូដាក់ក្នុងសៀវភៅសរសេររបស់សិស្សរៀងៗខ្លួនបានត្រឹមត្រូវ ។

ឧទាហរណ៍ : ចូរសរសេរតាមអានចម្លងពាក្យនិងឈ្មោះខាងក្រោម (មេរៀនទី៣៧)។ ការងារ ខ្ជាប់ខ្ជួន មាតាបិតា លទ្ធផល ព្យាយាម ការខិតខំរៀនសូត្រនឹងធ្វើឱ្យសិស្សមានអនាគតភ្លឺស្វាង ។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ:**



លេខ ១០



លេខ ១១



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៤ង

## មេរៀន ៤៤

# សិស្សអាចតែងល្បះតាមរូបភាព ឬខ្លឹមសារដែលគ្រូបានកំណត់

### បំណិនសំណេរពាក់ព័ន្ធ : ការតែងល្បះ

សូមមើល មេរៀនទី៣២- ៤០ (ទំព័រទី៣២-

### ខ្លឹមសារ

- ពាក្យ និងល្បះស្តីពីរូបភាពក្នុងសៀវភៅភាសាខ្មែរអាន-សរសេរថ្នាក់ទី២ មេរៀនទី៣២-៤០: ទំព័រទី៣២,៣៧,៤០,៤៤និង៤៧ ។

### សកម្មភាពគំរូ

☑ សង្កេតមើលបណ្តុំរូបភាពដែលគ្រូបិទនៅលើក្តារខៀន រួចរកគំនិតបន្ទាប់បន្សំទាក់ទងគំនិតរបស់ ប្រធានបទរូបភាព តាមរយៈការបំផុសសំណួរក្នុងផែនទីគំនិតរបស់គ្រូជាគំរូ ។ ឧទាហរណ៍រូបភាពក្នុងសៀវភៅសិស្សទំព័រ៣៧៖

ពេលចេញលេង

នៅទីធ្លាសាលាមានសិស្សច្រើន

សាលារៀនមានដើមឈើច្រើន



អាកាសធាតុល្អ

សិស្សសប្បាយរីករាយ

សាលារៀនស្អាត

សិស្សជាច្រើនកំពុងលេង

☑ សិស្សជ្រើសពាក្យទាក់ទងមនុស្ស វត្ថុ សត្វ និងទីកន្លែងសរសេរបំពេញក្នុងល្បះតាមរូបភាពនីមួយៗបានត្រឹមត្រូវ ។

ឧទាហរណ៍ : ចូរមើលរូបរួចបំពេញល្បះខាងក្រោមដើម្បីពណ៌នាអំពីមនុស្ស វត្ថុ សត្វ និងទីកន្លែងក្នុងល្បះនីមួយៗឱ្យបានត្រឹមត្រូវ ។





១. តុនេះធ្វើអំពី......។

២. នៅលើតុមាន.....។

៣. អ្នកគ្រូឈ្មោះ......។

៤. ខ្ញុំស្រឡាញ់........ណាស់ ។

៥. សាលារៀនខ្ញុំឈ្មោះ..........។

៦. សាលារៀននេះ ........ហើយស្អាត ។

បន្តទៅទំព័របន្ទាប់

លេខ
៤ច

**បន្ត...**

## សកម្មភាពគំរូ

☑ សិស្សបំពេញល្បះតាមរូបភាពនីមួយៗក្នុងលំហាត់បានត្រឹមត្រូវ ។
ឧទាហរណ៍ : ចូរមើលរូបរួចបំពេញល្បះឱ្យបានត្រឹមត្រូវនិងសមស្របតាមរូបនីមួយៗ ។



១. នេះជាថ្ងៃ................។ សាលារៀនមាន............. ។
២. ខ្ញុំបាន........និង ......ជាមួយមិត្តភក្តិខ្ញុំ ។

☑ សិស្សតែងល្បះងាយៗតាមរូបភាពដែលគ្រូផ្តល់ឱ្យទៅតាមគំនិតផ្ទាល់ខ្លួនម្នាក់ៗបានត្រឹមត្រូវ ។



១..............................................
..................................................
.............................................។



២..............................................
..................................................
.............................................។

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៤ច

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ

*គ្រូអាចច្នៃប្រឌិតរូបភាពខ្សែ*

## លេខ ៤៨

# សិស្សអាចសរសេរតួអក្សរផ្ចង់ និងពាក្យបានស្អាតល្អ

**បំណិនសំណេរពាក់ព័ន្ធ : សរសេរអក្សរផ្ចង់**

សូមមើល មេរៀនទី៣២- ៤០ (ទំព័រទី៣២ - ៥៧) →

### សកម្មភាពគំរូ

☑ សិស្សសរសេរអក្សរផ្ចង់អំពីពាក្យ "សាលា"បានស្អាតល្អតាមទម្រង់អក្សរជ្រៀង តាមការណែនាំគំរូអំពីរបៀបគូស សរសេរ លើក្ដារខៀន ក្ដារឆ្នួន និងក្នុងសៀវភៅសរសេររៀងខ្លួនបានត្រឹមត្រូវ។
ឧទាហរណ៍ :




☑ សិស្សសរសេរអក្សរផ្ចង់អំពីពាក្យណាមួយ ដែលគេស្រឡាញ់ហើយរើសចេញពីបញ្ជីពាក្យត្រូវនឹងទម្រង់ និងទំហំតាមការកំណត់របស់គ្រូ។
ឧទាហរណ៍ : កាតាប លេង បាល់ សាលា អំពៅ សិស្ស អនាគត គ្រួសារ មាតាបិតា គុណ...។

☑ សិស្សចម្លងអក្សរផ្ចង់អំពីពាក្យណាមួយដែលគេពេញចិត្ត ហើយសរសេរពាក្យដដែលនោះឱ្យបានច្រើនដង (៣ដង) និងច្រើនបន្ទាត់ (៣ បន្ទាត់) ។
ឧទាហរណ៍ :




### ខ្លឹមសារ

អក្សរផ្ចង់អំពីពាក្យ "*សាលា* **ខិតខំ និងពេល**" ក្នុងសៀវភៅភាសាខ្មែរអាន-សរសេរថ្នាក់ទី២ ។



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូម

ហ្វឹកហាត់ផ្ទាល់ក្នុងថ្នាក់

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**

↓

*គ្រូអាចរកសម្ភារៈផ្សេងៗដូចជា៖ ក្ដារឆ្នួនមានក្រឡា ផ្ទាំងក្រដាសក្រឡាអ៊ីត...។*




**ដំណាក់កាលទី ៤ ត្រូវបានបញ្ចប់ហើយ!**

សូមធ្វើតេស្តសិស្សដោយប្រើ

តេស្តដំណាក់កាលទី ៤ និងតេស្តផ្ទាល់មាត់ប្រចាំឆមាសទី ១

នៃឧបសម្ព័ន្ធ ៣ នៅក្នុងសៀវភៅនេះ

ទំព័រទី ១៦៤ និងទី១៧០

# ដំណាក់កាលទី ៥ : មេរៀនទី ៤១-៥២(៥)

**( ទំព័រទី ៥៨ ដល់ ៩៤ )**

**អំណាន និងសំណេរ** : អត្ថបទ កំណាព្យ និងចម្រៀងអំពី

*១. មេរៀនទី៤១ : ម្ដាយឪពុកខ្ញុំ (កំណាព្យ)*
*២. មេរៀនទី៤២ : ពេលភ្ញៀវមកលេងផ្ទះ*
*៣. មេរៀនទី៤៤ : រឿងឪពុក និងកូនដឹកលាទៅលក់*
*៤. មេរៀនទី៤៥ : មិត្តល្អរបស់កូនឆ្មាប្ញូ*
*៥. មេរៀនទី៤៦ : ការរៀនអក្សរផ្ទង់*
*៦. មេរៀនទី ៤៩ : រឿងកូនទន្សាយ និងកូនឆ្មា*
*៧. មេរៀនទី ៥០ : គ្រូសាររីករាយ (ចម្រៀង)*

*(សប្ដាហ៍ទី៣ ខែ មករា ដល់ សប្ដាហ៍ទី៤ ខែ កុម្ភៈ)*

*( ៦៤ម៉ោង ៤,៩២ សប្ដាហ៍)*

***កំណត់សម្គាល់ :*** *(៥)ចំពោះមេរៀនទី៤៣ ទី៤៧ សមត្ថភាពនិយាយដែលមេរៀននីមួយៗមានចំនួន៦ម៉ោងសិក្សា និងមេរៀនទី៤៨ សមត្ថភាពស្ដាប់មានចំនួន៦ម៉ោងសិក្សា ។ មេរៀនទាំងនេះមិនទាក់ទងស្ដង់ដាអំណានទេគ្រូត្រូវបង្រៀនធម្មតា ។*

# លេខ ៥ក សិស្សអាចអានពាក្យក្នុងមេរៀនដោយផ្សំ និងប្រកប

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់តួអក្សរនិងសូរ**

សូមមើល មេរៀនទី ៤១-៥២ (ទំព័រទី ៥៨ -៩៨)

## ខ្លឹមសារ

- សូមស្រង់ពាក្យក្នុងមេរៀនទី ៤១-៥២ ដូចខាងក្រោម៖

**មេរៀនទី៤១ :** គោរព ចម្អិន សព្វ កិច្ចការ គេហដ្ឋាន

**មេរៀនទី៤២ :** ជម្រាប

**មេរៀនទី៤៤ :** ទម្ងន់ ទម្លាក់ សង្កត់

**មេរៀនទី៤៥ :** ទន្សាយ

**មេរៀនទី៤៦ :** បង្ហាញ

**មេរៀនទី៤៩ :** ប្រាកដ សប្បាយ

**មេរៀនទី៥០ :** សាមគ្គី ទូន្មាន

**មេរៀនទី៥១ :** ឧស្សាហ៍ ប្រសាសន៍

**មេរៀនទី៥២ :** គុម្ពោត ភ័យ សុខសាន្ត

## សកម្មភាពគំរូ

☑ សិស្សអានពាក្យដោយការញែកព្យាង្គរបស់ពាក្យនីមួយៗ ហើយថាតាមបន្តគ្នាម្តងម្នាក់ ឬថាតាមជាក្រុមតូចៗរហូតដល់ចប់ពាក្យនីមួយៗតាមការពន្យល់របស់គ្រូនៅលើក្តារខៀន ។

ឧទាហរណ៍ : គ្រូសរសេរពាក្យ គេហដ្ឋាន នៅលើក្តារខៀនរួចនាំសិស្សអាន :

-គ្រូថា គេ (គេ)

-សិស្សទី១ថា ហ (ហាក់)

-សិស្សទី២ថា ដ្ឋាន (ថាន)

☑ សិស្សអានពាក្យដោយការញែកព្យាង្គរបស់ពាក្យតាមការហៅរបស់គ្រូនៅលើក្តារខៀនរួចអានព្យាង្គទី១ក្នុងពាក្យនោះ ។ បន្ទាប់មកសិស្សម្នាក់ទៀតនៅខាងស្តាំដៃគេអានព្យាង្គមួយទៀតបន្តធ្វើបែបនេះរហូតដល់ចប់ពាក្យនីមួយៗ ។

ឧទាហរណ៍ :

-សិស្សទី១អានថា គេ (គេ)

-សិស្សខាងស្តាំដៃទី១ថា ហ (ហាក់)

-សិស្សបន្ទាប់ពីស្តាំដៃទី១ថា ដ្ឋាន (ថាន)

បន្តទៅទំព័របន្ទាប់

**លេខ ៥ក**

## បន្ត...

### សកម្មភាពគំរូ

☑ គ្រូនាំសិស្សលេងល្បែងទះដៃដើម្បីកំណត់ចំនួនព្យាង្គរបស់ពាក្យក្នុងការអាន ពាក្យ២ព្យាង្គ ៣ព្យាង្គឬច្រើនព្យាង្គដោយឱ្យសិស្សជ្រើសរើសពាក្យធ្លាប់រៀន ឬ ចេះចាំដោយខ្លួនឯង ។

ឧទាហរណ៍ : គ្រូទះដៃតាមចំនួនព្យាង្គរបស់ពាក្យ២ឬ៣ដងសិស្ស ត្រូវថាពាក្យ នោះដោយប្រកបឱ្យបាន២ព្យាង្គ៣ព្យាង្គ ។

-ទះដៃពីរដង : ចម្អិន គោរព សង្កត់ សប្បាយ ប្រាកដ គុម្ពោត ...(ពាក្យ២ព្យាង្គ)

-ទះដៃបីដង : គេហដ្ឋាន អក្សរផ្ចង់ សាមគ្គី ប្រជាប្រិយ ជំបូន្មាន...(ពាក្យបីព្យាង្គ)

-ទះដៃបួនដង : ញញឹមញញែម សង្កត់សង្កិន លន្លង់លន្លោច ជីដូនជីតា...(ពាក្យបួនព្យាង្គ)

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



លេខ ១០



លេខ ១១



លេខ ១៤

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៥ក

លេខ ៥ខ

# សិស្សអាចពន្យល់ពាក្យពិបាក ពាក្យន័យដូច និងពាក្យផ្ទុយ

**បំណិនអំណានពាក់ព័ន្ធ : ការចេះវាក្យសព្ទ**

សូមមើល មេរៀនទី៥១- ៥២ (ទំព័រទី ៥៨ -៩៥)

## ខ្លឹមសារ

- សូមមើលនិងស្រង់ ពន្យល់ពាក្យ ពាក្យផ្ទុយ ពាក្យន័យដូចក្នុងមេរៀនទី ៥១-៥២ ៖

**ពន្យល់ពាក្យ**

បន្ទុក កិច្ចការ សព្វ ភ្ញៀវ អញ្ជើញ គួរសម ស្មុះស្មា ស្វែង ទ្រាំ ដឹក ស្អែក ផ្ចិតផ្ចង់ ក្បួនខ្នាត បង្ហាញ ប្រាកដ សប្បាយ សាមគ្គី ទូន្មាន រាយមាយ ឧស្សាហ៍ ប្រសាសន៍ គ្រោះថ្នាក់ សុខសាន្ត

**ពាក្យន័យដូច**

**ប្រាណ** ខ្លួន កាយ ព្រះកាយ **ដៃ** ហត្ថា ព្រះហស្ត **បុរស** ប្រុស **មិត្ត** សម្លាញ់ ពួកម៉ាក ក្លើ **និទាន** និយាយ រៀបរាប់ **សិក្សា** រៀនសូត្រ រៀន **ប្រសាសន៍** សម្ដី និយាយ សង្ឃដីកា **សាហាវ** កាច ឃោរឃៅ

**ពាក្យផ្ទុយ**

នឿយ ≠ស្រណុក, ញញឹម ≠ក្រៀមក្រំ សរសើរ ≠បង្អាប់, ចាស់ ≠ ក្មេង បាត់ ≠ ឃើញ គង់, ដំបូង ≠ចុងក្រោយ ផ្ចិតផ្ចង់ ≠ ខ្ជីខ្ជា, សប្បាយ ≠ ទុក្ខ ទំនេរ ≠ រវល់, ឧស្សាហ៍ ≠ ខ្ជិល ខ្លាច ≠ ហ៊ាន

## សកម្មភាពគំរូ

☑ សិស្សគូសរង្វង់ជុំវិញពាក្យន័យដូច និងពាក្យផ្ទុយតាមតារាងពាក្យដែលគ្រូកំណត់ ។ ឧទាហរណ៍ : តារាងពាក្យ

| គូសរង្វង់ពាក្យន័យដូច | គូសរង្វង់ពាក្យន័យដូច | គូសរង្វង់ពាក្យផ្ទុយ |
|---|---|---|
| **សិក្សា** | រវល់ | គ្រោះថ្នាក់ |
| ទូន្មាន | **និទាន** | កាច |
| សុខសាន្ត | ប្រាកដ | **កើតទុក្ខ** |
| ឧស្សាហ៍ | **និយាយ** | ខ្លាច |
| **រៀន** | សាមគ្គី | **សប្បាយ** |

បន្តទៅទំព័របន្ទាប់

លេខ ៥២

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សផ្គូផ្គងពាក្យពិបាកទៅនឹងន័យរបស់វាបានត្រឹមត្រូវតាមការកំណត់របស់គ្រូ ។
ឧទាហរណ៍ : តារាងផ្គូផ្គងពាក្យពិបាកទៅនឹងន័យ

| ពាក្យពិបាក | និយមន័យ |
|---|---|
| | ការរាប់អានគ្នា ។ |
| សាមគ្គី | សេចក្ដីព្រមព្រៀង ដំណើរស្រុះគ្នា ។ |
| | ការរស់នៅជាមួយគ្នា ។ |
| | ការខិតខំសាមគ្គី ។ |
| ឧស្សាហ៍ | ការខិតខំរៀបចំ ។ |
| | ការខំប្រឹងប្រែង មិនខ្ជិល ។ |
| | ប្រៀនប្រដៅ អប់រំណែនាំ ។ |
| ទូន្មាន | ការណែនាំ ។ |
| | ការគ្រប់គ្រង ។ |

☑ សិស្សជ្រើសរើសពាក្យដែលមានន័យដូចគ្នានឹងពាក្យក្នុងល្បះឬអត្ថបទមកបំពេញបានត្រឹមត្រូវ ។
ឧទាហរណ៍ : ថ្ងៃមួយ(១)មានភ្ញៀវមកលេងផ្ទះ(២)ម៉ានី ។ ក្រោយពី(៣)រាក់ទាក់(៤)ជាមួយភ្ញៀវរួចម្ដាយម៉ានីហៅ(៥) : "អឺកូន(៦)! លោកពូ(៧)ឯងអញ្ជើញមកលេង" ។
-ម៉ានី គេហដ្ឋាន ស្រែកហៅ រួសរាយ ឪពុកមា ថ្ងៃនេះ បន្ទាប់មក មា ច្រៀង
(១)........ថ្ងៃនេះ (២)......គេហដ្ឋាន (៣)......បន្ទាប់ពី (៤).....រួសរាយ
(៥)........ស្រែកហៅ (៦).....ម៉ានី (៧)........មា ឪពុកមា

បន្តទៅទំព័របន្ទាប់ →

លេខ ៥២

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សផ្គុំព្យញ្ជនៈ ស្រៈ និងព្យាង្គក្នុងតារាងដោយគូសវង់ជុំវិញ បានជាពាក្យដែលមានន័យដូច បានត្រឹមត្រូវ ។

ឧទាហរណ៍ :

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៃ | ដ | ញ | ញឹ | ម | ម | ស | ត |
| ហ | ត្ថ | ា | ា | ខំ | មា | ិ | ា |
| ក | ា | យ | ស | ប្រឹ | ញឹ | ក្ស | ត្ត |
| ច | ា | ប្រា | ណ | ង | ក | ា | ក្ល |
| ព្យ | េ | សី | ច | ធ | រៀ | ប | ា |
| ក | ា | ន | យ | កូ | ន | រ | ហ |
| អ | ដូ | យា | េ | ក្លី | សូ | វ | ា |
| ជី | ត | ា | ម | បុ | ត្រ | ល់ | ន |

**ចម្លើយ :** ញញឹម-សើច , ខំប្រឹង-ព្យាយាម, កាយ- ប្រាណ, ដៃ-ហត្ថា, រៀនសូត្រ-សិក្សា, មិត្ត- ក្លើ , កូន - បុត្រ, មមាញឹក- រវល់, ហ៊ាន- ក្លាហាន, ជីតា- តា, ជីដូន-យាយ...

បន្តទៅទំព័របន្ទាប់

លេខ ៥ខ

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សផ្គុំព្យញ្ជនៈ ស្រៈ និងព្យាង្គក្នុងតារាងដោយគូសបន្ទាត់ត្រង់បានជាពាក្យផ្ទុយបានត្រឹមត្រូវ ។

ឧទាហរណ៍ :

| | | | | | |
|---|---|---|---|---|---|
| ដំ | អ | ធ | យ | បុ | ណ្យ |
| បា | ប | ក្រោ | គ | ស | ត |
| ត់ | ង | ◌ូ | ង់ | ងឹ | ល់ |
| ចុ | ក | ទ | ង | វ | ហ៊ា |
| ទំ | េ◌ | ន | រ | អ | ◌ា |
| ភ្ល | ◌ឺ | ខ្ល | ◌ា | ច | ន |

**ចម្លើយ :**

ដំបូង ≠ ចុងក្រោយ, បាត់ ≠ គង់, បាប ≠ បុណ្យ, ទំនេរ ≠ រវល់, ខ្លាច ≠ ហ៊ាន,
ភ្លឺ ≠ ងងឹត

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



លេខ ១៦



លេខ ១៣



លេខ ១៥

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៥ខ

លេខ ៥គ

# សិស្សអាចអានពាក្យក្នុងមេរៀនដោយមិនបាច់ផ្ទុំនិងប្រកប

## បំណិនអំណានពាក់ព័ន្ធ : ការចេះអានស្ទាត់

សូមមើល មេរៀនទី៤១ - ៥២ (ទំព័រទី ៥៨ -៩៤)

### ខ្លឹមសារ

- សូមស្រង់ពាក្យក្នុងមេរៀនទី៤១-៤៦ដូចខាងក្រោម ៖

**មេរៀនទី៤១ :** គោរព គ្រួសារ ចម្អិន អាហារ សព្វ កិច្ចការ គេហដ្ឋាន បន្ទុក សុខសាន្ត ចម្ការ ចិញ្ចឹម

**មេរៀនទី៤២ :** ភ្ញៀវ អញ្ជើញ ស្ទុះស្ទា ជម្រាបសួរ ត្រេកអរ, មុនពេលត្រឡប់ទៅវិញពូរបស់ម៉ានីសរសើរម៉ានីថាជាក្មេងល្អចេះគួរសម ។

**មេរៀនទី៤៤ :** ឪពុក បុរស បន្តិច ជិះ បែរ ស្វែង ស្ពាន ទម្លាក់ ទម្ងន់ ទ្រាំ រមៀល ។

**មេរៀនទី៤៥ :** កន្លែង សរសេរ ខ្មៅដៃ សួរ ដំណើរ, បូបូញញឹមហើយនិយាយ " អរគុណតូនី! មិត្តមានចិត្តល្អណាស់!"

**មេរៀនទី៤៦ :** អក្សរផ្ចង់ ផ្ចិតផ្ចង់ គូស បន្ទាត់ ក្បូនខ្នាត បង្ហាញ គំរូ សប្បាយ ស្អាត

**មេរៀនទី៤៩ :** អាទិត្យ មិត្ត ដើរ គួរ បន្តិច កំពុង ប្រញាប់ ដំណើរ ប្រាកដ

**មេរៀទី៥១ :** ជីរ ផល ស្លឹកគ្រៃ ប្រយោជន៍ ចម្ការ ទំនេរ ឪឡឹក ឧស្សាហ៍ ប្រសាសន៍

**មេរៀនទី៥២ :** បណ្តើរ ឃ្លាត សាហាវ ភ័យ ឆ្លេឆ្លា ត្រដាង ផ្ទះ គុម្ពោត សុខសាន្ត



បន្តទៅទំព័របន្ទាប់

## លេខ ៥គ

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សអានពាក្យដោយមិនបាច់ផ្សំនិងប្រកបបានយ៉ាងលឿនតាមការកំណត់របស់គ្រូ ឬតាមបញ្ជីពាក្យក្នុងលំហាត់ ។

*ឧទាហរណ៍ :គោរព ចម្អិន សព្វ កិច្ចការ គេហដ្ឋាន សុខសាន្ត ចម្ការ ចិញ្ចឹម អាទិត្យ មិត្ត ដើរ គួរ បន្តិច កំពុង ប្រញាប់ ដំណើរ ប្រាកដ ...។*

☑ សិស្សមើលបញ្ជីពាក្យដែលគ្រូសរសេរនៅលើក្តារខៀន។ បន្ទាប់មកគ្រូឱ្យសិស្ស២នាក់អានប្រណាំងគ្នាតាមបញ្ជីពាក្យនោះឱ្យបានលឿនបំផុតដោយមិនបាច់ផ្សំនិងប្រកបតាមដែលអាចធ្វើទៅបាន ។ សិស្សណាអានបានត្រឹមត្រូវហើយចប់មុនគេ សិស្សនោះជាអ្នកឈ្នះ ។

*ឧទាហរណ៍ : គោរព ចម្អិន សព្វ កិច្ចការ គេហដ្ឋាន សុខសាន្ត ចម្ការ ចិញ្ចឹម អាទិត្យ មិត្ត ដើរ គួរ បន្តិច កំពុង ប្រញាប់ ដំណើរ ប្រាកដ ...។*

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



លេខ ១០



លេខ ១១



លេខ ១៤



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៥គ

លេខ ៥យ

# សិស្សអាចបកស្រាយន័យរបស់ល្បះ វគ្គនៃចម្រៀង និងអត្ថបទ

ឧទាហរណ៍ :ឆ្លើយសំណួរកំណត់អំពីមនុស្ស សត្វ វត្ថុ....
ការបំពេញល្បះ វគ្គនៃចម្រៀង និងលំហាត់ក្លូស្ស " cloze"

**បំណិនអំណានពាក់ព័ន្ធ : ការចេះវាក្យសព្ទ**

**: ការអានដើម្បីយល់ន័យ**

សូមមើល មេរៀនទី៤១ -៥២(ទំព័រទី ៥៨ -៩៨ )

## ខ្លឹមសារ

♦ សូមដកស្រង់ល្បះ វគ្គ អត្ថបទ ក្នុងមេរៀនទី៤១-៥២ ៖
"ម្ដាយឪពុកខ្ញុំ ពេលភ្ញៀវមកលេងផ្ទះ រឿងឪពុក និងកូនដឹកលាទៅលក់ មិត្តល្អរបស់កូនឆ្មាបូបូ ការរៀនអក្សរផ្ចង់ រឿងកូនទន្សាយនិងកូនឆ្មា គ្រួសាររីករាយ ចម្ការរបស់ជីតាខ្ញុំ និងមេមាន់និងកូនមាន់ "

## សកម្មភាពគំរូ

☑ សិស្សឆ្លើយនឹងសំណួរក្នុងមេរៀនសៀវភៅសិស្សបានត្រឹមត្រូវ ។

**មេរៀនទី៤១ :**

១. តើអ្នកណាដេរប៉ះ បោកគក់ និងចម្អិនអាហារ?
២. តើអ្នកណាអ្នកធ្វើស្រែចម្ការ និងរកប្រាក់កាស?
៣. តើប្អូនគោរពឪពុកម្ដាយប្អូនឬទេ?

**មេរៀនទី៤២ :**

១. តើអ្នកណាមកលេងផ្ទះម៉ានី?
២. តើម៉ានីធ្វើដូចម្ដេចខ្លះ ពេលជួបលោកពូដំបូង?
៣. តើម៉ានីធ្វើដូចម្ដេចខ្លះពេលភ្ញៀវកំពុងនិយាយ?
៤. តើអ្នកត្រូវធ្វើដូចម្ដេចពេលមានភ្ញៀវមកលេងផ្ទះ?

**មេរៀនទី៤៤ :**

១. តើឪពុកនិងកូនដឹកលាទៅណា?
២. តើឪពុកនិងកូនធ្វើដូចម្ដេច ពេលឮអ្នកស្រុកនិយាយ?
៣. តើឪពុកនិងកូនធ្វើដូចម្ដេច ពេលឮតាចាស់និយាយ?
៤. ហេតុអ្វីបានជាឪពុកនិងកូននាំគ្នាសែងលា?

បន្តទៅទំព័របន្ទាប់

លេខ ៥យ

បន្ត...

## សកម្មភាពគំរូ

**មេរៀនទី៤៥ :**

១. ហេតុអ្វីបានជាប្អូយំ?

២. តើនរណាជាអ្នកឱ្យខ្មៅដៃទៅប្អូ?តើគេសន្យាឱ្យអ្វីទៀត?

៣. តើប្អូនិយាយដូចម្តេចនៅពេលទទួលបានខ្មៅដៃ ?

៤. តើពាក្យ " របស់ខ្ញុំ" ប្រើចំពោះនរណា?

**មេរៀនទី៤៦ :**

១. តើពេលរៀនអក្សរផ្ចង់ ដំបូងអ្នកគ្រូបានប្រាប់ពីអ្វីខ្លះ?

២. បន្ទាប់ពីអ្នកគ្រូណែនាំរួចហើយតើយើងត្រូវធ្វើដូចម្តេចខ្លះ?

៣. ពេលកែលម្អសំណេរយើងហើយតើអ្នកគ្រូធ្វើដូចម្តេចទៀត?

៤. ហេតុអ្វីបានប្អូនចូលចិត្តរៀនសរសេរអក្សរផ្ចង់?

**មេរៀនទី៤៩ :**

១. នៅថ្ងៃអាទិត្យតើតូនីទៅលេងផ្ទះនរណា?

២. តើប្អូកំពុងធ្វើអ្វី?

៣. តើម្តាយរបស់ប្អូកំពុងធ្វើអ្វី?

៤. តើតូនីនិយាយដូចម្តេចជាមួយប្អូ?

**មេរៀនទី៥០ :**

១. តើនរណាខ្លះជាអ្នកចិញ្ចឹមគ្រួសារ?

២. តើនរណាជាអ្នកនិទានរឿង?

៣. តើយាយប្រដៅចៅឱ្យធ្វើអ្វី?

**មេរៀនទី៥១ :**

១. តើចម្ការជីតារបស់គេស្ថិតនៅឯណា?

២. តើចម្ការនេះមានដំណាំអ្វីខ្លះ ?

៣. តើពេលទំនេរគេជួយធ្វើអ្វីខ្លះ?

៤. តើជីដូនរបស់គេសរសើរគេដូចម្តេច ?

បន្តទៅទំព័របន្ទាប់

លេខ ៥យ

**បន្ត...**

## សកម្មភាពគំរូ

**មេរៀនទី៥២ :**

១. តើមេមាន់បណ្ដើរកូនរកចំណីនៅឯណា?

២. តើមេមាន់ប្រដៅកូនដូចម្ដេច?

៣. នៅពេលស្ដាប់តាមដំបូន្មានរបស់មេ តើកូនមាន់រស់នៅដូចម្ដេច?

☑ សិស្សឆ្លើយនឹងសំណួរបន្ថែមរបស់គ្រូទាក់ទងចំណងជើងអត្ថបទ ។

ឧទាហរណ៍ : ចូរដាក់ចំណងជើងអត្ថបទខាងលើថ្មីមួយទៀតក្នុងមេរៀនទី ៤១,៤២,៤៤, ៤៥,៤៦, ៤៩ ,៥០, ៥១ និង៥២ ។

ចូរប្អូនរកឬប៉ាន់ស្មានចំណងជើងអត្ថបទថ្មីមួយទៀតឱ្យអត្ថបទខាងលើតាមគំនិតផ្ទាល់ខ្លួន ។

**ចម្លើយ :**

**មេរៀនទី៤១ :** ម្ដាយឪពុកខ្ញុំ → ពុកម៉ែខ្ញុំ ឬ...

**មេរៀនទី៤២ :** ពេលភ្ញៀវមកលេងផ្ទះ → ភ្ញៀវមកផ្ទះ ឬ...

**មេរៀនទី៤៤ :** រឿងឪពុកនិងកូនដឹកលាទៅលក់ → ឪពុក-កូននិងសត្វលា ឬ...

**មេរៀនទី៤៥ :** មិត្តល្អរបស់កូនឆ្មាបូបូ → មិត្តល្អរបស់បូបូ ឬ.....

**មេរៀនទី៤៦ :** ការរៀនអក្សរផ្ចង់ → យើងរៀនអក្សរផ្ចង់ ឬ......

**មេរៀនទី៤៩ :** រឿងកូនទន្សាយនិងកូនឆ្មា → រឿង តូនីនិងបូបូ ឬ...

**មេរៀនទី៥០ :** គ្រួសាររីករាយ → គ្រួសារល្អ ឬ...

**មេរៀនទី៥១ :** ចម្ការរបស់ជីតាខ្ញុំ → ចម្ការតាខ្ញុំ ឬ...

**មេរៀនទី៥២ :** មេមាន់និងកូន → ដំបូន្មានមេមាន់ ឬ...

☑ សិស្សប្រាប់ពាក្យចួនក្នុងអត្ថបទមេសូត្របានត្រឹមត្រូវតាមការណែនាំរបស់គ្រូនៅលើក្ដារខៀនដោយគូសរង្វង់ជុំវិញពាក្យចួននោះ ។ បន្ទាប់មកសិស្សអនុវត្ត ។

ឧទាហរណ៍ :

ខ្ញុំគោរព**ម៉ែ** ធ្វើការគ្មាន**ល្ហែ** ថែទាំ**គ្រួសារ**

ដេរប៉ះបោកគក់ ចម្អិន**អាហារ** មើលសព្វ**កិច្ចការ**

ក្នុងគេហដ្ឋាន ។

បន្តទៅទំព័របន្ទាប់ →

លេខ ៥យ

**មន្ត...**

## សកម្មភាពគំរូ

**ចម្លើយ :**

វគ្គ១ -ពាក្យម៉ែ ចូននឹងពាក្យ ល្វែ
-ពាក្យគ្រួសារ ចូននឹងពាក្យអាហារ ចូននឹងពាក្យកិច្ចការ ។
វគ្គ២ -ពាក្យពុក ចូននឹងពាក្យបន្ទុក
-ពាក្យសាន្ត ចូននឹងពាក្យប្រាណ ចូននឹងពាក្យបាន ។

☑ សិស្សជ្រើសរើសពាក្យក្នុងប្រអប់ដើម្បីបំពេញល្បះបានត្រឹមត្រូវ មេរៀនទី៥១-៥២ ៖

| ភ័យ | សុខសាន្ត | ចំណី | ដើរ |
|---|---|---|---|

១. មេបណ្តើរកូនរក....................នៅក្រោយភូមិ ។
២. ពេលកូនទៅឆ្ងាយពីខ្លួនមេមាន់......................រត់ឆ្លេឆ្លា ។
៣. កូនមាន់មិន.................................រកចំណីឆ្ងាយពីមេវាទេ ។
៤. កូនមាន់រស់នៅប្រកបដោយភាព................ព្រោះវាស្តាប់ដំបូន្មានរបស់ម្តាយ ។

☑ សិស្សបកស្រាយន័យរបស់ពាក្យពិបាកដោយប្រើបរិបទជាទីសេចក្តីជុំវិញពាក្យពិបាកនោះ។

ឧទាហរណ៍ : គាត់ដាំដំណាំ<u>**ហូបផ្លែ**</u>និងបន្លែគ្រប់មុខដូចជា **ឪឡឹក ត្រសក់ ល្ពៅ**...។

សិស្សពន្យល់ថា "**ហូបផ្លែ** " ជាពាក្យប្រើជាមួយ "**ដំណាំ**" ហើយដំណាំនេះមានដូចជាផ្លែ ឪឡឹក ត្រសក់ ល្ពៅ...ដែលគេបានដាំ ។

ដូច្នេះ "**ហូបផ្លែ**" មានន័យថាជាផ្លែរបស់ដំណាំ ឪឡឹក ត្រសក់ ល្ពៅ...ដែលគេបានដាំ ។

បន្តទៅទំព័របន្ទាប់

លេខ ៥យ

## បន្ត...

☑ សិស្សបំពេញលំហាត់ក្លូស្ស ដោយប្រើបរិបទជាទីសេចក្ដីក្នុងអត្ថបទតាមមេរៀនកំណត់ ។

ឧទាហរណ៍ មានមេមាន់មួយបណ្ដើរកូន ......(១) ចំណីនៅក្រោយផ្ទះ ។ .....(២) មកដល់គម្ពោតព្រៃមួយ ......(៣) មាន់បានឃ្លាតឆ្ងាយ ......(៤) មេវា ។ ពេលនោះមេមាន់..........(៥) ណាស់ព្រោះខ្លាចកូនមាន់ .............(៦) ។

ចម្លើយ: ១. រក  ២. ពេល  ៣. កូន  ៤. ពី  ៥. ភ័យ  ៦. គ្រោះថ្នាក់

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



លេខ ១០



លេខ ១១



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៥យ

លេខ ៥ង

# សិស្សអាចសរសេរពាក្យតាមរយៈលំហាត់សរសេរតាមអាន

## បំណិនសំណេរពាក់ព័ន្ធ : សរសេរតាមអាន

សូមមើល មេរៀនទី៤១ - ៥២ (ទំព័រទី ៥៨ -៩៤)

### ខ្លឹមសារ

- សរសេរតាមអានចម្លងអំពីពាក្យ ៖

**មេរៀនទី៤១ :** អាហារ សុខសាន្ត កិច្ចការ គេហដ្ឋាន ចម្ការ យើងត្រូវគោរពឪពុកម្តាយព្រោះគាត់ជាអ្នកមានគុណ ។

**មេរៀនទី៤២ :** ភ្លៀរ អញ្ជើញ ស្ពុះស្ពាជម្រាបសួរ ត្រេកអរ មុនពេលត្រឡប់ទៅវិញពូរបស់ម៉ានីសរសើរម៉ានីថាជាក្មេងល្អចេះគួរសម ។

**មេរៀនទី៤៤ :** បុរស ស្មែង ជិះ ទម្ងន់ ទម្លាក់ កាលយូរលង់ណាស់មកហើយមានបុរសម្នាក់និងកូនដឹកលាទៅលក់ឯផ្សារ ។

**មេរៀនទី៤៥ :** កន្លែង សរសេរ ខ្មៅដៃ សួរ ដំណើរ បូបូញញឹមហើយនិយាយ: "អរគុណតូនី! មិត្តមានចិត្តល្អណាស់!"។

**មេរៀនទី៤៦ :** ស្មើ បន្ទាត់ កិច្ចការ បង្ហាញ សប្បាយ ពេលរៀនសរសេរអក្សរយើងខំប្រឹងផ្ចិតផ្ចង់សរសេរឱ្យបានត្រឹមត្រូវ ។

**មេរៀនទី៤៩ :** អាទិត្យ ទន្សាយ មិត្ត សប្បាយ ជីតា ប្រាកដ បន្តិច គាត់ប្រាកដជាមានការអ្វីហើយ! អ៊ីចឹងយើងប្រញាប់ទៅជួយគាត់!

**មេរៀនទី៥០ :** ឱស្វាយចន្ទី កូនចៅ សាមគ្គី ជួបជុំរីករាយ ពុកម៉ែតាយាយ លោកមិនវាយមាយ ចិញ្ចឹមមើលថៃ ។

**មេរៀនទី៥១ :** ចម្ការ ផ្ទះ ទំនេរ ឪឡឹក ប្រសាសន៍ ខ្ញុំពេញចិត្តនឹងចម្ការជីតាខ្ញុំណាស់ព្រោះវាផ្តល់ប្រយោជន៍ដល់គ្រួសារខ្ញុំ ។

**មេរៀនទី៥២ : មេមាន់**

ពេលកូនមាន់មកជុំគ្នា មេមាន់បានត្រដាងស្លាបគ្របកូនទាំងអស់ ។ មេមាន់បាននិយាយប្រដៅកូនកុំឱ្យរកចំណីឆ្ងាយពីខ្លួនខ្លាចជួបនឹងសត្វសាហាវ ។ តាំងពីពេលនោះមកកូនមិនដែលដើររកចំណីឆ្ងាយពីមេរបស់វាឡើយ ។ ដោយសារការស្តាប់តាមដំបូន្មានរបស់មេ កូនមាន់ទាំងអស់រស់នៅជាមួយមេវាប្រកបដោយភាពសុខសាន្ត ។

បន្តទៅទំព័របន្ទាប់

លេខ ៥ង

បន្ត...

## សកម្មភាពគំរូ

- សិស្សសរសេរពាក្យដែលគ្រូហៅនៅលើក្តារឆ្នួន តាមខ្លឹមសារកំណត់ខាងលើ ។
- សិស្សចម្លងពាក្យពីលើក្តារខៀនដាក់ក្នុងសៀវភៅសរសេររៀងៗខ្លួន តាមដែលគ្រូហៅឡើងវិញ ។
- សិស្សក្នុងក្រុម(**ក**)ដែលមានគ្នា៤នាក់ និងក្រុម(**ខ**)ដែលមានគ្នា៤នាក់សរសេរពាក្យចំនួន៥ពាក្យក្នុងមួយក្រុមៗតាមការជ្រើសរើសរបស់ក្រុមនីមួយៗ រួចដូរគ្នាពិនិត្យ និងកែលម្អគ្នាទៅវិញទៅមក ។ ឯគ្រូជាអ្នកណែនាំនិងសម្របសម្រួលសិស្សតាមក្រុម ។
- សិស្សសរសេរពាក្យ ល្បះតាមការអានរបស់គ្រូដាក់ក្នុងសៀវភៅសរសេររបស់សិស្សរៀងៗខ្លួនបានត្រឹមត្រូវ ។

ឧទាហរណ៍ :ចូរសរសេរតាមអានចម្លងពាក្យនិងល្បះខាងក្រោម(មេរៀនទី៤១) ៖

អាហារ កិច្ចការ គេហដ្ឋាន សុខសាន្ត ចម្ការ យើងត្រូវគោរពឪពុកម្ដាយព្រោះគាត់ជាអ្នកមានគុណ ។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



លេខ ១០



លេខ ១១



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៥ង

លេខ ៥៩

# សិស្សអាចសរសេរឬបំពេញល្បះអំពីរូបឬខ្លឹមសារផ្សេងៗ

**បំណិនសំណេរពាក់ព័ន្ធ : ការតែងល្បះ**

សូមមើល មេរៀនទី៥១ -៥២ (ទំព័រទី ៥៨ -៩៥)

## ខ្លឹមសារ

- ល្បះនិងរូបភាពក្នុងសៀវភៅភាសាខ្មែរអាន-សរសេរថ្នាក់ទី២មេរៀនទី៥១-៥២ (ទំព័រទី៦០, ៦៣,៧៣,៨៩,៩០ និង៩៣)

## សកម្មភាពគំរូ

☑ សិស្សបំពេញល្បះក្នុងលំហាត់បានត្រឹមត្រូវ ។ (ទំព័រ ៦៣)

ឧទាហរណ៍ :

១. សិស្សល្អត្រូវចេះ.....................ចាស់ទុំ ។

២. មុនពេលចេញទៅសាលារៀនកូនត្រូវ........................ឪពុកម្ដាយ ។

៣. ពេលទទួលអំណោយរួចកុំភ្លេចនិយាយថា...............................!

☑ សិស្សសរសេររៀបរាប់ពីមនុស្សក្នុងគ្រួសាររបស់ប្អូនឱ្យបានត្រឹមត្រូវ ។ (ទំព័រ ៦០)

ឧទាហរណ៍ : ចូរសរសេររៀបរាប់ពីមនុស្សក្នុងគ្រួសាររបស់ប្អូនឱ្យបានត្រឹមត្រូវ ។

មនុស្សក្នុងគ្រួសាររបស់ខ្ញុំមាន.......នាក់ គឺឪពុក............................។

☑ សិស្សតែងល្បះតាមរូបភាពនីមួយៗក្នុងលំហាត់បានត្រឹមត្រូវ ។ (ទំព័រ ៧៣)

ឧទាហរណ៍ : ចូរតែងល្បះតាមន័យរបស់រូបភាពខាងក្រោមឱ្យបានសមស្រប ។








.......................................... .......................................... ..........................................

.......................................... .......................................... ..........................................

បន្តទៅទំព័របន្ទាប់

លេខ ៥៤

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សបំពេញពាក្យចួនក្នុងអត្ថបទចម្រៀងបានត្រឹមត្រូវ (ទំព័រទី៨៦) ។

ឧទាហរណ៍ : ចូរជ្រើសរើសពាក្យចួនក្នុងប្រអប់ទៅបំពេញបទចម្រៀងខាងក្រោម ។

| យាយ | សាលា | ម៉ែ | គ្នា | ប្រៀន |
|---|---|---|---|---|

| | | |
|---|---|---|
| ឱស្វាយចន្ទី | កូនចៅសាមគ្គី | ជួបជុំរីករាយ |
| ពុកម៉ែតា... | លោកមិនរាយមាយ | ចិញ្ចឹមមើលថៃ។ (ពីរដង) |
| ពុកម៉ែធ្វើការ | កូនទៅ......... | សិក្សាពូកែ |
| មកផ្ទះជួយថៃ | មិនឱ្យពុក... | ពិបាកទូន្មាន ។ (ពីរដង) |
| ទំនេរការងារ | ព្រលប់ជុំ..... | ស្តាប់តានិទាន |
| យាយប្រដៅ... | ចៅៗខំរៀន | គ្រូសាររីករាយ ។ (ពីរដង) |

☑ សិស្សមើលរូបភាពនិងអានល្បះខាងក្រោមរូបភាពរួចតម្រូវខ្លឹមសារនៃល្បះនោះឱ្យត្រូវនឹងរូបភាព ។

ឧទាហរណ៍ : តើខ្លឹមសារនិងរូបភាពណាត្រូវគ្នា? (ទំព័រទី៨៣)







តូនីនិងបូបូកំពុងអានសៀវភៅ។ តូនីនិងបូបូច្រៀងលេង។ ពួកគេលេងលោតអន្ទាក់។

***ចម្លើយ :*** ខ្លឹមសារ និងរូបភាពទី១ ។

បន្តទៅទំព័របន្ទាប់

លេខ ៥៥

**បន្ត...**

## សកម្មភាពគំរូ

☑ សិស្សបំពេញល្បះតាមរូបភាពបានត្រឹមត្រូវ ។

ឧទាហរណ៍ : ចូរបំពេញល្បះតាមរូបភាពខាងក្រោមឱ្យបានត្រឹមត្រូវ (ទំព័រទី៩០)



ឪពុកខ្ញុំកំពុង......។ ម្ដាយខ្ញុំជា.........។ បងស្រីជា........។

☑ សិស្សអានល្បះនិងមើលរូបភាពរួចតម្រូវល្បះជាមួយរូបភាពនោះដោយចុះលេខល្បះនៅក្នុងប្រអប់រូបបានត្រឹមត្រូវ(ទំព័រទី៨៨-៨៩) ។

ឧទាហរណ៍ : ចូរតម្រូវល្បះជាមួយរូបភាពខាងក្រោមដោយចុះលេខល្បះនៅក្នុងប្រអប់រូបឱ្យបានត្រឹមត្រូវ ។

១. បងស្រីខ្ញុំជាគ្រូពេទ្យ ។
២. ម្ដាយខ្ញុំជាគ្រូបង្រៀន ។
៣. ជីតាខ្ញុំតែងនិទានរឿងឱ្យខ្ញុំស្ដាប់ ។
៤.សែយ៉ាធ្វើលំហាត់នៅផ្ទះ ។
៥.ជីដូនយោលអង្រឹងចៅ ។
៦.ម៉ុកបោសសំរាម ។



**<u>ចម្លើយ :</u>**

រូបភាពទី១ ត្រូវនឹងល្បះទី៦
រូបភាពទី២ ត្រូវនឹងល្បះទី៤
រូបភាពទី៣ ត្រូវនឹងល្បះទី៣
រូបភាពទី៤ ត្រូវនឹងល្បះទី២
រូបភាពទី៥ ត្រូវនឹងល្បះទី១
រូបភាពទី៦ ត្រូវនឹងល្បះទី៥

បន្តទៅទំព័របន្ទាប់

លេខ ៥ច

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សមើលរូបភាព រួចតែងល្បះ អំពីរូបភាពនោះបានត្រឹមត្រូវ(ទំព័រទី៩០) ។

ឧទាហរណ៍ : ចូរមើលរូបភាពខាងក្រោម រួចតែងល្បះ អំពីរូបភាពនោះបានសមស្រប ។


................................។


................................។


................................។


................................។


................................។


................................។

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ


លេខ ១០


លេខ ១១

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៥ច

លេខ ៥៨

# សិស្សអាចសរសេរតួអក្សរផ្ចង់ និងពាក្យបានស្អាតល្អ

**បំណិនសំណេរពាក់ព័ន្ធ : សរសេរអក្សរផ្ចង់**

សូមមើល មេរៀនទី៤១ - ៥២ (ទំព័រទី ៥៨ -៩៤) →

## សកម្មភាពគំរូ

☑ សិស្សសរសេរអក្សរផ្ចង់អំពីពាក្យ "អាហារ" បានស្អាតល្អតាមទម្រង់អក្សរជ្រៀងនិងតាមការណែនាំគំរូអំពីរបៀបគូសសរសេរលើក្តារខៀន ក្តារឆ្នួននិងក្នុងសៀវភៅសរសេររៀងៗខ្លួនបានត្រឹមត្រូវ ។

ឧទាហរណ៍ :




☑ សិស្សសរសេរអក្សរផ្ចង់អំពីពាក្យណាមួយដែលគេស្រឡាញ់ហើយរើសចេញពីបញ្ជីពាក្យត្រូវនឹងទម្រង់និងទំហំតាមការកំណត់របស់គ្រូ ។

ឧទាហរណ៍ : គោរព អរគុណ សំពះ ញញឹម នរណា រាយមាយ ដំណាំ ឆ្លេឆ្លា ...។

☑ សិស្សចម្លងអក្សរផ្ចង់អំពីពាក្យណាមួយដែលគេពេញចិត្តហើយសរសេរពាក្យដដែលនោះឱ្យបានច្រើនដង (៣ដង) និងច្រើនបន្ទាត់ (៣បន្ទាត់) ។

ឧទាហរណ៍ :




## ខ្លឹមសារ

- អក្សរផ្ចង់អំពីពាក្យ ៖ "អាហារ សរសេរ និង មេមាន់"



## ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូម

ហ្វឹកហាត់ផ្ទាល់ក្នុងថ្នាក់

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**

↓

*គ្រូអាចរកសម្ភារៈផ្សេងៗដូចជា ៖ ក្តារឆ្នួនមានក្រឡា ផ្ទាំងក្រដាសក្រឡាអ៊ុត...។*




**ដំណាក់កាលទី ៥ ត្រូវបានបញ្ចប់ហើយ!**

សូមធ្វើតេស្តសិស្សដោយប្រើ

តេស្តដំណាក់ទី ៥

នៃឧបសម្ព័ន្ធ ៣ នៅក្នុងសៀវភៅនេះ

ទំព័រទី ១៧៣

# ដំណាក់កាលទី ៦ : មេរៀនទី ៥៤-៦២(៦)

( ទំព័រ ៩៨ ដល់ ១២៤ )

-**អំណាន និងសំណេរ** : អត្ថបទ កំណាព្យ និងចម្រៀងអំពី

*១. មេរៀនទី៥៤ : អាត្នោតគោខ្ញុំ*

*២. មេរៀនទី៥៦ : ទេសភាពវាលស្រែនៅរដូវវស្សា*

*៣. មេរៀនទី៥៧ : អ្នកលក់មួកនិងសត្វស្វា*

*៤. មេរៀនទី៥៨ : ការងារពុកម៉ែខ្ញុំ (ចម្រៀង)*

*៥. មេរៀនទី៥៩ : មុខរបរអ្នកភូមិខ្ញុំ*

*៦. មេរៀនទី៦០ : ដើមត្នោត*

*៧. មេសូត្រមេរៀនទី៦១ : កិច្ចការនៅសាលារៀន*

*៨. មេរៀនទី៦២ : រាជធានីភ្នំពេញ*

*សប្ដាហ៍ទី១ ខែ មិនា ដល់សប្ដាហ៍ទី៤ ខែ មេសា*

*( ៦៤ ម៉ោង / ៤,៩២សប្ដាហ៍)*

*<u>កំណត់សម្គាល់ :</u> (៦) ចំពោះមេរៀនទី៥៥សមត្ថភាពនិយាយមានចំនួន៤ម៉ោងសិក្សា ។ មេរៀននេះមិនទាក់ទងស្តង់ដាអំណានទេគ្រូត្រូវបង្រៀនធម្មតា។*

លេខ ៦ក

# សិស្សអាចអានពាក្យក្នុងមេរៀនដោយផ្សំនិងប្រកប

ឧទាហរណ៍ : គុម្ព អានថា  គំ

. ប្រយោជន៍  អានថា  ប្រ-យ៉ោច

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់តួអក្សរនិងសូរ**

សូមមើល មេរៀនទី ៥៤-៦២ (ទំព័រទី ៩៨-១២៤)

## ខ្លឹមសារ

- សូមស្រង់ពាក្យក្នុងមេរៀនទី៥៤-៦២ ដូចខាងក្រោម ៖

**មេរៀនទី៥៤ :** ប្រយោជន៍ អាចម៍

**មេរៀនទី៥៦ :** ញ័រញ្ជួយ ប្រជាប្រិយ គុម្ព លន្លង់លន្លោច  ទេសភាព

**មេរៀនទី៥៧ :** សម្រាន្ត

**មេរៀនទី៥៨ :** ទ្រព្យ  ត្បួញត្បែរ

**មេរៀនទី៥៩ :** តម្បាញ ជីវភាព ថ្ពរ

**មេរៀនទី ៦០ :** សម្បូរ  មាតុភូមិ ព្វជ៍  វត្ថុ  សម្បត្តិ

**មេរៀនទី៦១ :** សព្វ

**មេរៀនទី៦២ :** ចរាចរណ៍   ឯករាជ្យ  បរមរាជវាំង  សារមន្ទីរ

## សកម្មភាពគំរូ

☑ សិស្សអានពាក្យដោយការញែកព្យាង្គរបស់ពាក្យនីមួយៗហើយថាតាមបន្តគ្នាម្តងម្នាក់ឬថាតាមជាក្រុមតូចៗរហូតដល់ចប់ពាក្យនីមួយៗតាមការពន្យល់របស់គ្រូនៅលើក្តារខៀន ។

ឧទាហរណ៍ : គ្រូសរសេរពាក្យ **លន្លង់លន្លោច** នៅលើក្តារខៀនរួចនាំសិស្សអាន

| | |
|---|---|
| -គ្រូថា | **លន់** |
| -សិស្សទី១ថា | **លង់** |
| -សិស្សទី២ថា | **លន់** |
| -សិស្សទី៣ថា | **លោច** |

បន្តទៅទំព័របន្ទាប់

លេខ ៦ក

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សអានពាក្យដោយការញែកព្យាង្គរបស់ពាក្យតាមការហៅរបស់គ្រូនៅលើក្តារខៀនរួចអានព្យាង្គទី១ក្នុងពាក្យនោះ ។ បន្ទាប់មកសិស្សម្នាក់ទៀតនៅខាងស្តាំដៃគេអានព្យាង្គមួយទៀតបន្តធ្វើបែបនេះរហូតដល់ចប់ពាក្យនីមួយៗ ។

ឧទាហរណ៍ :

- -សិស្សទី១អានថា **លន់**
- -សិស្សខាងស្តាំដៃទី១អានថា **លង់**
- -សិស្សបន្ទាប់ពីស្តាំដៃទី១អានថា **លន់**
- -សិស្សបន្ទាប់ពីស្តាំដៃទី១ទៀតថា **លោច**

☑ គ្រូនាំសិស្សលេងល្បែងទះដៃដើម្បីកំណត់ចំនួនព្យាង្គរបស់ពាក្យក្នុងការអានពាក្យ ២ព្យាង្គ៣ព្យាង្គឬច្រើនព្យាង្គដោយឱ្យសិស្សជ្រើសរើសពាក្យធ្លាប់រៀនឬចេះចាំដោយខ្លួនឯង ។

ឧទាហរណ៍ : គ្រូទះដៃតាមចំនួនព្យាង្គរបស់ពាក្យ២ឬ៣ដងសិស្សត្រូវថាពាក្យនោះដោយប្រកបឱ្យបានពីរព្យាង្គបីព្យាង្គ

- -ទះដៃពីរដង : ប្រយោជន៍ ត្អូញត្អែរ តម្បាញ សម្បូរ ឰដ៏ ...(ពាក្យពីរព្យាង្គ។
- -ទះដៃបីដង : ទេសភាព មាតុភូមិ ចរាចរណ៍ ឯករាជ្យ...(ពាក្យបីព្យាង្គ) ។
- -ទះដៃបួនដង : លន្លង់លន្លោច បរមរាជវាំង សារមន្ទីរ ...(ពាក្យបួនព្យាង្គ) ។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



លេខ ១០

| | | | | | |
|---|---|---|---|---|---|
| ដំ | អ | ធ | យ | បុ | ណ្យ |
| បា | ប | ក្រោ | គ | ស | ត |
| ត់ | ង | ្វ | ង់ | ងឹ | ល់ |
| ចុ | ក | ទ | ង | រ | ហ៊ា |
| ទំ | េ | ន | រ | អ | ៣ |
| ភ្ល | ី | ខ្ល | ៣ | ច | ន |

លេខ ១៤



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៦ក

លេខ ៦ខ

# សិស្សអាចពន្យល់ពាក្យពិបាក ពាក្យន័យដូច និងពាក្យផ្ទុយ

**បំណិនអំណានពាក់ព័ន្ធ : ការចេះវាក្យសព្ទ**

សូមមើល មេរៀនទី ៥៤-៦២ (ទំព័រទី ៩៨-១២៤)

## ខ្លឹមសារ

- សូមមើលនិងស្រង់ ពន្យល់ពាក្យ ពាក្យផ្ទុយ ពាក្យន័យដូចក្នុងមេរៀនទី៥៤-៦២

**ពន្យល់ពាក្យ**

មេរៀនទី៥៤ : សម្បុរ ប្រយោជន៍
មេរៀនទី៥៦ : ប្រជាប្រិយ ទេសភាព លន្លង់លន្លោច
មេរៀនទី៥៧ : សំទុះ ចេចចាច
មេរៀនទី៥៨ : ទ្រព្យ ត្អូញត្អែរ
មេរៀនទី៥៩ : ត្បាញ ថ្នូរ ការស្វែត្រ
មេរៀនទី៦០ : មាតុភូមិ ព្វដំ សំណុំ វត្ថុ
មេរៀនទី៦១ : កិច្ចការ សោភា ខ្ជីខ្ជា
មេរៀនទី៦២ : ចិញ្ចាច ចរាចរណ៍ ឯករាជ្យ សារមន្ទីរ

**ពាក្យន័យដូច**

មេរៀនទី៥៤ : ឧស្សាហ៍ ព្យាយាម ខិតខំ
មេរៀនទី៥៦ : ទឹក គង្គា វារី
មេរៀនទី៥៧ : សម្រាន្ត ដេក គេង សិង និទ្រា ផ្ទុំ
មេរៀនទី៥៨ : កូន បុត្រ
មេរៀនទី៥៩ : មុខរបរ អាជីព
មេរៀនទី៦០ : សម្បត្តិ ទ្រព្យ ធនធាន
មេរៀនទី៦១ : ផ្កា បុប្ផា បុស្បា
មេរៀនទី៦២ : រាត្រី យប់

**ពាក្យផ្ទុយ**

មេរៀនទី៥៤ : ស្រួច ≠ ទាល
ខ្ពស់ ≠ ទាប
មាំ ≠ ទន់ជ្រាយ
មេរៀនទី៥៦ : យឺត ≠ លឿន
ឱន ≠ ងើប
មេរៀនទី៥៧ : ត្រជាក់ ≠ ក្តៅ
មេរៀនទី៥៨ : ក្រៅ ≠ ក្នុង
មេរៀនទី៥៩ : ក្មេង ≠ ចាស់
ធំ ≠ តូច
មេរៀនទី៦០ : មូល ≠ ជ្រុង
សម្បូរ ≠ ខ្សត់ខ្សោយ
មេរៀនទី៦១ : ខ្ជីខ្ជា ≠ ហ្មត់ចត់
មេរៀនទី៦២ : ភ្លឺចិញ្ចាច ≠ ងងឹតសូន្យ

បន្តទៅទំព័របន្ទាប់

លេខ ៦ខ

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សគូសរង់ជុំវិញពាក្យន័យដូច និងពាក្យផ្ទុយតាមតារាងពាក្យដែលគ្រូកំណត់ ។

ឧទាហរណ៍ : តារាងពាក្យ

| គូសរង់ពាក្យន័យដូច | គូសរង់ពាក្យន័យដូច | គូសរង់ពាក្យផ្ទុយ |
|---|---|---|
| **សម្រាន្ត** | ខិតខំ | ក្រមា |
| ព្យាយាម | **ទឹក** | សត្វ |
| សម្បុរ | ស្រែ | **លឿន** |
| អូស | **គង្គា** | រទេះ |
| **គេង** | លឿន | **យឺត** |

☑ សិស្សផ្គូផ្គងពាក្យពិបាកទៅនឹងន័យរបស់វាបានត្រឹមត្រូវតាមការកំណត់របស់គ្រូ ។

ឧទាហរណ៍ : តារាងផ្គូផ្គងពាក្យពិបាកទៅនឹងនិយមន័យ

| ពាក្យពិបាក | និយមន័យ |
|---|---|
| មាតុភាព → | ទីកន្លែងធ្វើការ ។ |
| | ទីកន្លែងកំណើត ។ |
| | ទីកន្លែងលំហែកាយ ។ |
| ការស្ទូត្រ | មូរខ្សែរគោ ។ |
| | មូរខ្សែពួរ ។ |
| | មូរសរសៃសូត្រ ។ |
| សារមន្ទីរ | ទីកន្លែងទុកវត្ថុបុរាណ ។ |
| | ទីកន្លែងទុកសម្លៀកបំពាក់សម័យ ។ |
| | ទីកន្លែងទុកសម្ភារនានា ។ |

បន្តទៅទំព័របន្ទាប់

លេខ ៦ខ

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សជ្រើសរើសពាក្យក្នុងប្រអប់ខាងក្រោមដែលមានន័យដូចគ្នានឹងពាក្យក្នុងល្បះ ឬអត្ថបទមកបំពេញបានត្រឹមត្រូវ ។

ឧទាហរណ៍ : _ថ្ងៃមួយ_ មានជាងដេរម្ជុលម្នាក់បានយកម្ជុលទៅលក់_តាម_ភូមិ ។ វេលាថ្ងៃត្រង់គាត់ឈប់សម្រាកនៅក្រោមដើមឈើមួយដែលមានម្លប់ត្រជាក់ ។ គាត់ក៏_សម្រាន្ត_លក់ទៅ ។ មួយ_សំទុះ_ក្រោយមកមានសំឡេង ចេចចាចៗធ្វើឱ្យគាត់ភ្ញាក់ ។

| | | | | | |
|---|---|---|---|---|---|
| ស្ងួរស័ព្ទ | ពេលមួយ | សម្រាក | ក្នុង | ស្រួបក់ | បោច |

**ចម្លើយ :**

(១)...ពេលមួយ, គ្រាមួយ (២)...ក្នុង (៣)...សម្រាក ,គេង ,ដេក (៤)...ស្រួបក់ (៥)...ស្ងួរ. ស្ងួរស័ព្ទ (៦)...និយាយ

☑ សិស្សផ្គុំព្យញ្ជនៈ ស្រៈ និងព្យាង្គក្នុងតារាងដោយគូសរង្វង់ជុំវិញបានជាពាក្យដែលមានន័យដូចបានត្រឹមត្រូវ ។

ឧទាហរណ៍ :

| | | | | | | | |
|---|---|---|---|---|---|---|---|
| ល | ក | ូ | ន | គ | ម | េ | ធ |
| អ | ា | ច | ម៍ | ង | ្គ | គ | ន |
| ទឹ | ក | ម | ហ | ្គ | ា | ង | ធា |
| ប | ុ | ត្រ | ក | ា | យ | ប់ | ន |
| ុ | េ | ទ | ្ក | ្រ | ទ | ព | ប |
| ប្ផា | ដ | ផ | ខ | ញ | ជី | ន | ត្រី |
| វ | ក | ច | ី | អា | វ | ា | ស |
| ម | ុ | ខ | រ | ប | រ | ែ | ម៉ |

**ចម្លើយ :** លាមក- អាចម៍ , ទឹក - គង្គា, កូន- បុត្រ , បុប្ផា-ផ្កា , អាជីព-មុខរបរ

ទ្រព្យ- ធនធាន , ម៉ែ-ម្ដាយ , ដេក- គេង, យប់ - រាត្រី

បន្តទៅទំព័របន្ទាប់ →

## លេខ ៦ខ

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សផ្គុំព្យញ្ជនៈ ស្រៈ និងព្យាង្គក្នុងតារាងដោយគូសរង់ជុំវិញជាពាក្យផ្ទុយបានត្រឹមត្រូវ ។

ឧទាហរណ៍ :

| | | | | | |
|---|---|---|---|---|---|
| ◌េ | យ | ◌ឺ | ត | ងើ | ប |
| ខ្ព | ល | ក់ | ◌េ | ក្ម | ង |
| ស់ | ជា | ◌ឿ | ក្តា | ◌ឹ | ស |
| ត្រ | ទា | ប | ន | ច | ម្ប |
| ខ | ◌្ស | ត់ | ◌ូ | ◌ា | ◌ូ |
| ឱ | ន | ត | ធំ | ស់ | រ |

**<u>ចម្លើយ</u>** : ត្រជាក់ ≠ ក្តៅ, លឿន ≠ យឺត , ខ្ពស់ ≠ ទាប, ក្មេង ≠ ចាស់, ធំ ≠ តូច សម្បូរ ≠ ខ្សត់ , ឱន ≠ ងើប

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



លេខ ១៦



លេខ ១៣



លេខ ១៤



លេខ ១៥

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តជំណាក់កាលទី ៦ខ

លេខ
៦គ

# សិស្សអាចអានពាក្យក្នុងមេរៀនដោយមិនបាច់ផ្ញុំនិងប្រកប

**បំណិនអំណានពាក់ព័ន្ធ : ការចេះអានស្ទាត់**

សូមមើល មេរៀនទី ៥៤-៦២ (ទំព័រទី ៩៨-១២៤)

## ខ្លឹមសារ

- សូមស្រង់ពាក្យក្នុងមេរៀនទី៥៤-៦២ដូចខាងក្រោម ៖

**មេរៀនទី៥៤ :** អាគ្នោត សម្បុរ មាឌ កន្ទុយ កម្លាំង ភ្នូររាស់ ឧស្សាហ៍ ប្រយោជន៍ អាចម៍ គ្រួសារ ។

**មេរៀទី៥៦ :** រដូវវស្សា សន្ទូង លន្លង់លន្លោច ទេសភាព គុម្ព កន្ទុយ ញ័ររញ្ជួយ ក្រមា ទោរទន់ ចម្រុះ ប្រជាប្រិយ ។

**មេរៀនទី៥៧ :** សម្រាក សម្រាន្ត ហ្វូង ម្លប់ ចេចចាច សត្វ ដំណើរ សំទុះ ភ្ញាក់ ។

**មេរៀនទី៥៨ :** ទំនេរ ត្បាញត្បែរ ចម្ការ ដំណាំ ឧស្សាហ៍ ហូរហៀ ទ្រព្យ ។

**មេរៀនទី៥៩ :** ក្រមា សូត្រ តម្បាញ ជ្រលក់ គុណភាព ការសូត្រ ផ្ទុរ សារុងសូត្រ ផាមួង ។

**មេរៀទី៦០ :** ដើមត្នោត សំណុំ ពាសពេញ ស្មើរ មាតុភូមិ ត្រដែត ឈ្មុយឆ្ងាញ់ ឰដ៏អាកាស ។

**មេរៀនទី៦១ :** កិច្ចការ របាំ សួនច្បារ ខ្ចីខ្ចា ការងារ សួនច្បារសាលាមានជីវ ម្ទេស ផ្កាល្អស្រស់សោភា ។

បន្តទៅទំព័របន្ទាប់

## លេខ ៦គ

## បន្ត...

### សកម្មភាពគំរូ

- ☑ សិស្សអានពាក្យដោយមិនបាច់ផ្សំនិងប្រកបបានយ៉ាងលឿនតាមការកំណត់របស់គ្រូ ឬតាមបញ្ជីពាក្យក្នុងលំហាត់ ។
  *ឧទាហរណ៍ : អាត្មោត សម្បុរ មាឌ កន្ទុយ កម្លាំង ភ្លូរាស់ ឧស្សាហ៍ អាចម៍ ប្រយោជន៍ គ្រួសារ ក្រមាសូត្រ តម្បាញ ជ្រលក់ គុណភាព ការសូត្រ ផ្កូរ សារុង សូត្រ ផាមួង ...។*
- ☑ សិស្សមើលបញ្ជីពាក្យដែលគ្រូសរសេរនៅលើក្តារខៀន ។ បន្ទាប់មកគ្រូឱ្យសិស្សពីរនាក់អានប្រណាំងគ្នាតាមបញ្ជីពាក្យនោះឱ្យបានលឿនបំផុតដោយមិនបាច់ផ្សំនិងប្រកបតាមដែលអាចធ្វើទៅបាន ។ សិស្សណាអានបានគ្រប់ពាក្យបានត្រឹមត្រូវហើយចប់មុនគេសិស្សនោះជាអ្នកឈ្នះ ។
  *ឧទាហរណ៍ : អាត្មោត សម្បុរ មាឌ កន្ទុយ កម្លាំង ភ្លូរាស់ ឧស្សាហ៍ អាចម៍*

### ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



លេខ ១០

| | | | | | |
|---|---|---|---|---|---|
| ដំ | អ | ធ | យ | បុ | ណ្យ |
| បា | ប | ក្រោ | គ | ស | ត |
| ត់ | ង | ូ | ង់ | ងឹ | ល់ |
| ចុ | ក | ទ | ង | រ | ហ៊ា |
| ទំ | េ | ន | រ | អ | ា |
| ភ្ល | ី | ខ្ល | ា | ច | ន |

លេខ ១៤



### ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៦គ

លេខ ៦៧

# សិស្សអាចបកស្រាយន័យរបស់វគ្គនៃចម្រៀង និងអត្ថបទ

ឧទាហរណ៍ : ជ្រើសរើសពាក្យចូនដើម្បីបំពេញវគ្គនៃចម្រៀង និងលំហាត់ក្លូស្ស "cloze"

**បំណិនអំណានពាក់ព័ន្ធ : ការចេះវាក្យសព្ទ**

**: ការអានដើម្បីយល់ន័យ**

សូមមើល មេរៀនទី ៥៤-៦២ (ទំព័រទី៩៨-១២៨)

## ខ្លឹមសារ

- សូមដកស្រង់ ល្បះ វគ្គ អត្ថបទក្នុង មេរៀនទី៥៤-៦២ ៖ "អាត្មោតគោខ្ញុំ ទេសភាពវាលស្រែនៅរដូវវស្សា អ្នកលក់មួកនិងសត្វស្វា ការងារពុកម៉ែខ្ញុំ មុខរបរអ្នកភូមិខ្ញុំ ដើមត្នោត កិច្ចការនៅសាលារៀន (មេសូត្រ) និងរាជធានីភ្នំពេញ"

## សកម្មភាពគំរូ

☑ សិស្សអាចឆ្លើយនឹងសំណួរក្នុងមេរៀនសៀវភៅសិស្សបានត្រឹមត្រូវ ។

**មេរៀនទី៥៤ :**

១. តើគោនោះឈ្មោះអ្វី? ញីឬឈ្មោល?
២. តើគោនោះមានរូបរាងដូចម្ដេច?
៣. តើគោនោះជាសត្វដូចម្ដេច?
៤. តើអ្នកចូលចិត្តចិញ្ចឹមគោដែរឬទេ? ហេតុអ្វី?

**មេរៀនទី៥៦ :**

១. តើវាលស្រែនៅរដូវវស្សាមានពណ៌ដូចម្ដេច?
២. តើគេប្រៀបធៀបវាលស្រែទៅនឹងអ្វី?
៣. នៅលើផ្ទៃមេឃមានសត្វអ្វីខ្លះ?
៤. តើប្អូនពេញចិត្តទេសភាពវាលស្រែនៅរដូវវស្សាដែរឬទេ?

បន្តទៅទំព័របន្ទាប់

លេខ
៦យ

**បន្ត......**

## សកម្មភាពគំរូ

**មេរៀនទី៥៧ :**

១. តើអ្នកលក់មួកសម្រាកនៅឯណា?

២. តើសត្វអ្វីយកមួកគាត់ទៅពាក់?

៣. តើគាត់ធ្វើដូចម្ដេចទើបយកមួកទាំងអស់បានមកវិញ?

**មេរៀនទី៥៨ :**

១. តើពេលទំនេរម្ដាយធ្វើអ្វីខ្លះ?

២. តើឪពុកធ្វើការងារអ្វី?

៣. តើឪពុកម្ដាយមានទឹកចិត្តដូចម្ដេចចំពោះកូន?

៤. តើអ្នកគួរធ្វើដូចម្ដេចដើម្បីឱ្យពុកម៉ែរបស់អ្នកសប្បាយចិត្ត?

**មេរៀនទី៥៩ :**

១. តើប្រជាជននៅភូមិនោះ គេច្រើនប្រកបមុខរបរអ្វី?

២. តើគេត្បាញអ្វីខ្លះនៅទីនោះ?

៣. តើគេយករបស់ទាំងនោះទៅនៅទីណា?

៤. តើប្រជាជននៅភូមិនោះ មានទឹកចិត្តដូចម្ដេចចំពោះមុខរបរពួកគេ?

**មេរៀនទី៦០ :**

១. តើប្រទេសកម្ពុជាយើងសម្បូរអ្វី?

២. តើដើមត្នោតមានដុះនៅកន្លែងណាខ្លះ?

៣. ដើមត្នោតផ្ដល់ផលប្រយោជន៍អ្វីខ្លះ?

៤. តើខ្មែរយើងមានទឹកចិត្តដូចម្ដេចចំពោះដើមត្នោត? ព្រោះអ្វី?

បន្តទៅទំព័របន្ទាប់ →

លេខ ៦យ

បន្ត...

## សកម្មភាពគំរូ

☑ សិស្សឆ្លើយសំណួរបន្ថែមរបស់គ្រូទាក់ទងចំណងជើងអត្ថបទ ។

ឧទាហរណ៍ : ចូរដាក់ចំណងជើងអត្ថបទខាងលើថ្មីមួយទៀត ។

ចូរប្អូនរកឬប៉ាន់ស្មានចំណងជើងអត្ថបទថ្មីមួយទៀតឱ្យអត្ថបទខាងលើតាមគំនិតផ្ទាល់ខ្លួន ។

<u>ចម្លើយ:</u>

**មេរៀនទី៥៤ :** អាគ្មោតគោខ្ញុំ ⟶ អាគ្មោត ឬ...

**មេរៀនទី៥៦ :** ទេសភាពវាលស្រែនៅរដូវវស្សា ⟶ វាលស្រែរដូវវស្សា ឬ...

**មេរៀនទី៥៧ :** អ្នកលក់មួកនិងសត្វស្វា ⟶ អ្នកលក់មួក ឬ...

**មេរៀនទី៥៨ :** ការងារពុកម៉ែខ្ញុំ ⟶ ពុកម៉ែខ្ញុំ ឬ...

**មេរៀនទី៥៩ :** មុខរបរអ្នកភូមិខ្ញុំ ⟶ តម្បាញជនបទ ឬ...

**មេរៀនទី៦០ :** ដើមត្នោត ⟶ ផលប្រយោជន៍ដើមត្នោត ឬ...

**មេរៀនទី៦១ :** កិច្ចការនៅសាលារៀន ⟶ ការងារសិស្សនៅសាលារៀន ឬ...

**មេរៀនទី៦២ :** រាជធានីភ្នំពេញ ⟶ ទិដ្ឋភាពរាជធានី ឬ...

☑ សិស្សអានវគ្គនៃចម្រៀងតាមការណែនាំរបស់គ្រូទៅតាមលំនាំបទ "ខ្ញុំមានមាត់សម្រាប់និយាយ" បានត្រឹមត្រូវ ។

☑ សិស្សអានវគ្គនៃកំណាព្យតាមការណែនាំរបស់គ្រូទៅតាមលំនាំបទ "បទកាកគតិ" បានត្រឹមត្រូវ ។

☑ សិស្សជ្រើសរើសពាក្យក្នុងប្រអប់ដើម្បីបំពេញល្បះបានត្រឹមត្រូវមេរៀនទី៥៤-៦២ ។

ឧទាហរណ៍ : ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញល្បះខាងក្រោម ។

| | | | | | | |
|---|---|---|---|---|---|---|
| ឈ្មោះ | សម្បុរ | គោ | មាឌ | បួន | មាំ | កោង |

ខ្ញុំមាន...............ឈ្មោលមួយក្បាល...........អាគ្មោត ។ គោខ្ញុំមាន...............ត្នោត ។ វាមាន..............ធំខ្ពស់ ស្វែងស្រួច..........ឧបចូលគ្នា ។ ជើងទាំង...............របស់អាគ្មោត...............ៗ ។

<u>**ចម្លើយ :**</u> ១.គោ ២.ឈ្មោល ៣.សម្បុរ ៤.មាឌ ៥.កោង ៦.បួន ៧.មាំ

បន្តទៅទំព័របន្ទាប់ ⟶

លេខ
៦ឃ

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សប្រាប់ពាក្យចូនក្នុងអត្ថបទកំណាព្យបានត្រឹមត្រូវតាមរយៈឧទាហរណ៍របស់គ្រូនៅលើក្តារខៀនដោយគូសរង្វង់ជុំវិញពាក្យចូននោះ ។ បន្ទាប់មកសិស្សអនុវត្ត ។ ឧទាហរណ៍ :

| | | |
|---|---|---|
| យើងទៅ**<u>សាលា</u>** | រៀនសព្វ**<u>កិច្ចការ</u>** | រៀនកត់**<u>ចំណាំ</u>** |
| រៀនអានរៀនលេខ | គំនូរ**<u>របាំ</u>** ដំណាំនានា ។ | កីឡានិង**<u>ដាំ</u>** |
| ........................... | ......................... | ........................ |

**<u>ចម្លើយ:</u>** វគ្គទី១ -ពាក្យ សាលា ចូននឹងពាក្យ កិច្ចការ
-ពាក្យ ចំណាំ ចូននឹងពាក្យ របាំ ចូននឹងពាក្យ ដាំ

☑ សិស្សបំពេញលំហាត់ក្លូស្ស (Cloze) ដោយប្រើបរិបទជាទីសេចក្តីក្នុងអត្ថបទតាមមេរៀនកំណត់ ។

ឧទាហរណ៍ : ប្រទេសកម្ពុជាយើង សម្បូរដើមត្នោត(១)ណាស់ ។

ដើមត្នោតដុះខ្ពស់.....(២)ហើយរាយស្ទើរពាសពេញទឹកដី......(៣)មាតុភូមិយើង ។ ដើមត្នោតមាន .......(៤)មូល ទ្រសំណុំស្លឹកពណ៌.......(៥)ហាក់ដូចជាឆត្របើក..........(៦) កណ្តាលព្វធ៍អាកាស ។ ដើមត្នោត ........(៧)ប្រយោជន៍ច្រើនណាស់ ។ ផ្កា.....(៨)គេគាបត្រងយកទឹក......(៩)រំងាស់បានជាស្ករ មានរស........(១០) ផ្អែមឈ្ងុយឆ្ងាញ់ ។ ដើមអាចយក........(១១)ធ្វើផ្ទះធ្វើទូក និង........(១២)យកមកធ្វើជាវត្ថុ.........(១៣)ទៀត ។

**<u>ចម្លើយ :</u>** ១.ត្នោត ២.ត្រដែត (ស្រឡះ) ៣.នៃ (របស់) ៤.រាង(លក្ខណៈ) ៥.បៃតង ៦.ចោល (ត្រដាង) ៧.មាន (ផ្តល់ឱ្យ) ៨.វា(ត្នោត) ៩.មក (ទៅ) ១០.រសជាតិ(ឱជារស រស) ១១.មក (ទៅ) ១២.អាច ១៣.ផ្សេងៗ(ដទៃ នានា)

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



<u>លេខ ១០</u>



<u>លេខ ១១</u>

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

<u>តេស្តដំណាក់កាលទី ៦ឃ</u>

លេខ ៦៦

# សិស្សអាចសរសេរពាក្យ ល្បះតាមរយៈលំហាត់សរសេរតាមអាន

## បំណិនសំណេរពាក់ព័ន្ធ : សរសេរតាមអាន

សូមមើល មេរៀនទី ៥៤-៦២ (ទំព័រទី ៩៨-១២៤)

### ខ្លឹមសារ

- សរសេរតាមអានចម្លងអំពីពាក្យ ៖

**មេរៀនទី៥៤** : មាឌ សម្បុរ ឧស្សាហ៍ ប្រយោជន៍ ស្រឡាញ់ រាល់ព្រឹកខ្ញុំតែងតែបោសសម្រាមហើយយកទៅដាក់ក្នុងរណ្ដៅ

សម្រាប់ធ្វើជី ។

**មេរៀនទី៥៦** : កម្រាល ខ្យល់បក់ក្រៀល ទោរទន់ រលក គ្មានអ្វីគួរឱ្យចង់គយគន់ជាងទេសភាពល្អស្រស់នារដូវវស្សានេះឡើយ ។

**មេរៀនទី៥៧** : ដេរ សម្រាន្ត សម្រាក ម្លប់ សំទុះ គាត់ងើយមើលទៅលើដើមឈើឃើញស្វាមួយហ្វូងកំពុងពាក់ម្ចក។

**មេរៀនទី៥៨** : ទំនេរ ទ្រព្យ ត្បាញត្បែរ ចម្ការ ឧស្សាហ៍ ហូរហែ ខ្ញុំមានពុកម៉ែពូកែកាត់ដេរ ពេលទំនេរថៃកូនប្រុសស្រី ទ្រព្យក្នុងផ្ទះទាំងចាស់ទាំងថ្មី ទោះហាត់នឿយក្ដីម៉ែមិនត្អូញត្អែរ ។

**មេរៀនទី៥៩** : **មុខរបរអ្នកភូមិខ្ញុំ**

នៅភូមិខ្ញុំ ប្រជាជនភាគច្រើនប្រកបមុខរបរតម្បាញ។ ពួកគេត្បាញហូលផាមួង សារុងសូត្រ និងក្រមាសូត្រ ។ ហូល ផាមួងនៅទីនោះមានគុណភាពល្អហើយលក់ដាច់ណាស់ ។ អ្នកភូមិខ្ញុំពេញចិត្តនឹងរបរនេះណាស់ ព្រោះធ្វើឱ្យជីវភាពពួកគេធូរធារ ។

**ចូរពន្យល់ពាក្យ** "គុណភាព"

**សំណួរ**

១. តើប្រជាជនភាគច្រើនប្រកបរបរអ្វី?

២. តើពួកគេត្បាញអ្វីខ្លះ?

៣. តើអ្នកភូមិមានទឹកចិត្តដូចម្ដេចចំពោះមុខរបរនេះ? ព្រោះអ្វី?

**លំហាត់**

១. ចូររកពាក្យន័យដូចនឹងពាក្យ "ប្រជាជន"

២. ចូររកពាក្យផ្ទុយនឹងពាក្យ "ធូរធារ"

**មេរៀនទី៦០** : សម្បុរ មាតុភូមិ ឆត្រពួដំអាកាស ប្រយោជន៍ ខ្មែរយើងពេញចិត្តនឹងដើមត្នោតណាស់ព្រោះវាជាសម្បត្តិធម្មជាតិតាំងពីដូនតាមក ។

**មេរៀនទី៦១** : កិច្ចការ របាំ សួនច្បារ ខ្ចីខ្ចា ការងារ សួនច្បារសាលា មានជីរ ម្ទេស ផ្កា ល្អស្រស់សោភា

**មេរៀនទី៦២** : វិថី អគារ រាត្រី ចិញ្ចាចចរាចរណ៍ ភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

បន្តទៅទំព័របន្ទាប់

លេខ ៦ង

## បន្ត...

### សកម្មភាពគំរូ

- ☑ សិស្សសរសេរពាក្យដែលគ្រូហៅនៅលើក្ដារឆ្នួនតាមខ្លឹមសារកំណត់ខាងលើ ។
- ☑ សិស្សចម្លងពាក្យលើក្ដារខៀនដាក់ក្នុងសៀវភៅសរសេររៀងខ្លួនតាមដែលគ្រូហៅឡើងវិញ ។
- ☑ សិស្សក្នុងក្រុម**ក**ដែលមានគ្នា៥នាក់និងក្រុម**ខ**ដែលមានគ្នា៥នាក់សរសេរពាក្យចំនួន៥ពាក្យក្នុងមួយក្រុមៗតាមការជ្រើសរើសរបស់ក្រុមនីមួយៗរួចដូរគ្នាពិនិត្យនិងកែលម្អគ្នាទៅវិញទៅមក ។ ឯគ្រូជាអ្នកណែនាំនិងសម្របសម្រួលសិស្សតាមក្រុម។
- ☑ សិស្សសរសេរល្បះឬអត្ថបទតាមការអានរបស់គ្រូដាក់ក្នុងសៀវភៅសរសេររបស់សិស្សរៀងៗខ្លួនបានត្រឹមត្រូវ ។

ឧទាហរណ៍ : ចូរសរសេរតាមអានចម្លងពាក្យនិងល្បះខាងក្រោម (មេរៀនទី៥៨) :

មាឌ សម្បុរ ប្រយោជន៍ ឧស្សាហ៍ ស្រឡាញ់

ខ្ញុំតែងកើបអាចម៍វាយកទៅដាក់ក្នុងរណ្ដៅសម្រាប់ធ្វើជី ។

ឧទាហរណ៍ :ចូរសរសេរតាមអានរៀបចំអត្ថបទខាងក្រោម (មេរៀនទី៥៩) ។

**មុខរបរអ្នកភូមិខ្ញុំ**

នៅភូមិខ្ញុំ ប្រជាជនភាគច្រើនប្រកបមុខរបរតម្បាញ ។ ពួកគេត្បាញហូលផាមួង សារុងសូត្រ និងក្រមាសូត្រ ។ ហូល ផាមួងនៅទីនោះមានគុណភាពល្អ ហើយលក់ដាច់ណាស់ ។ អ្នកភូមិខ្ញុំពេញចិត្តនឹងរបរនេះណាស់ព្រោះធ្វើឱ្យជីវភាពពួកគេធូរធារ ។

បន្តទៅទំព័របន្ទាប់

## លេខ ៦ង

**បន្ត...**

### សកម្មភាពគំរូ

**ចូរពន្យល់ពាក្យ** "គុណភាព"

**សំណួរ**

១. តើប្រជាជនភាគច្រើនប្រកបរបរអ្វី?

២. តើពួកគេត្បាញអ្វីខ្លះ?

៣. តើអ្នកភូមិមានទឹកចិត្តដូចម្ដេចចំពោះមុខរបរនេះ? ព្រោះអ្វី?

**លំហាត់**

១. ចូររកពាក្យន័យដូចនឹងពាក្យ " ប្រជាជន "

២. ចូររកពាក្យផ្ទុយនឹងពាក្យ " ធូរធារ " ។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



លេខ ១០



លេខ ១១



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៦ង

## លេខ ៦ច

# សិស្សអាចសរសេរឬបំពេញល្បះ អំពីរូប ឬខ្លឹមសារផ្សេងៗ

### បំណិនសំណេរពាក់ព័ន្ធ : ការតែងល្បះ

សូមមើល មេរៀនទី ៥៤-៦២ (ទំព័រទី ៩៨-១២៤)

### ខ្លឹមសារ

- ល្បះនិងរូបភាពក្នុងសៀវភៅ ភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី២មេរៀនទី៥៤-៦២ (ទំព័រទី១០០,១២១ និង១២៤)

### សកម្មភាពគំរូ

☑ សិស្សបំពេញល្បះតាមរូបភាពក្នុងលំហាត់បានត្រឹមត្រូវ (ទំព័រទី១០០ចំណុចគ)។

ឧទាហរណ៍ :



ខ្ញុំមាន...............។



ខ្ញុំស្រឡាញ់.........។



គោ..........ចំពោះគ្រួសារខ្ញុំ។

☑ សិស្សជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញល្បះបានត្រឹមត្រូវ (ទំព័រទី១០០, ១០៤,១០៧)

ឧទាហរណ៍ : ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញល្បះឱ្យបានត្រឹមត្រូវ ។

| ប្រយោជន៍ | រទេះ | ស្រឡាញ់ | ធំ | ភ្លូរ | ស្រែ | មួយ |
|---|---|---|---|---|---|---|

១. ខ្ញុំមានគោឈ្មោល.......................ក្បាលឈ្មោះអាត្នោត ។
២. វាមានមាឌ.............................ខ្ពស់ ស្វែងស្រួចកោងឧបចូលគ្នា ។
៣. គ្រួសារខ្ញុំទឹមវាដើម្បី................និងអូស...........។
៤. ខ្ញុំ.............អាត្នោតណាស់ព្រោះវាមាន....................ចំពោះគ្រួសារខ្ញុំ ។

បន្តទៅទំព័របន្ទាប់

លេខ ៦ច

**បន្ត...**

## សកម្មភាពគំរូ

☑ សិស្សជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញល្បះតាមរូបភាពបានត្រឹមត្រូវ ។

ឧទាហរណ៍ : ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។ (ទំព័រទី១១១)

| | | | | |
|---|---|---|---|---|
| លក់ដូរ | រាំ | រថាំ | គ្រូបង្រៀន | ជួសជុល |



ឪពុកខ្ញុំកំពុង.........ទូរទស្សន៍។



ម្តាយជាអ្នក.........................។



ឪពុកខ្ញុំជា............................។



ពួកគេកំពុង.....................។

☑ សិស្សរកពាក្យទៅបំពេញល្បះបានត្រឹមត្រូវ ។

ឧទាហរណ៍ : ចូររកពាក្យទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ (ទំព័រទី១០៧ )

១.ខ្ញុំជា............។ ២.ឪពុកខ្ញុំជា...........។ ៣.ម្តាយរបស់ខ្ញុំជា..........។

☑ សិស្សមើលរូបភាពរួចតែងល្បះនៅខាងក្រោមរូបភាពបានត្រឹមត្រូវ ។ (រូបភាពទំព័រទី១២១ ,១២៤)

ឧទាហរណ៍ : ចូរតែងល្បះតាមរូបភាពខាងក្រោមឱ្យបានត្រឹមត្រូវ ។







.................................។ .................................។ .................................។

បន្តទៅទំព័របន្ទាប់

លេខ ៦ច

# បន្ត...

## សកម្មភាពគំរូ

☑ ដំបូងគ្រូឱ្យសិស្សសង្កេតរូបក្នុងសៀវភៅទំព័រទី១២៤ រួចសួរសំណួរបំផុសអំពីរូបភាពនោះដើម្បីជួយសិស្សបង្កើតចម្លើយជា "**ផែនទីគំនិត**" ទាក់ទងនិងរូបភាព កំណត់គំនិតដែលអាចជា "**ប្រធានបទ**" **(រាជធានីភ្នំពេញ)** និងគំនិតបន្ទាប់បន្សំ(មនុស្សកំពុងអង្គុយលេង អគារខ្ពស់ៗ មានក្មេងៗច្រើន ក្មេងលេងក្នុងសួន កន្លែងអនុស្សាវរីយ៍ធំៗ ក្មេងកំពុងលេង) គាំទ្រឱ្យប្រធានបទនោះ ។




## ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



លេខ ១០



លេខ ១១

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៦ច

លេខ
៦៨

# សិស្សអាចសរសេរតួអក្សរផ្ចង់អំពីពាក្យបានស្អាតល្អ

**បំណិនសំណេរពាក់ព័ន្ធ : សរសេរអក្សរផ្ចង់**

សូមមើល មេរៀនទី ៥៤-៦២ (ទំព័រទី ៩៨-១២៤) ⟶

## សកម្មភាពគំរូ

☑ សិស្សសរសេរអក្សរផ្ចង់អំពីពាក្យ "នោល" បានស្អាតល្អតាមទម្រង់អក្សរជ្រៀងនិងតាមការណែនាំគំរូអំពីរបៀបគូសសរសេរលើក្ដារខៀនក្ដារឆ្នួននិងក្នុងសៀវភៅសរសេររៀងៗខ្លួនបានត្រឹមត្រូវ ។

ឧទាហរណ៍ :




☑ សិស្សសរសេរអក្សរផ្ចង់អំពីពាក្យណាមួយដែលគេស្រឡាញ់ហើយរើសចេញពីបញ្ជីពាក្យត្រូវនឹងទម្រង់និងទំហំតាមការកំណត់របស់គ្រូ។

ឧទាហរណ៍ : *វេលក ចេចចាច ដំណាំ ហូរហែ មុខរបរ ធនធាន ចំណាំ ចរាចរណ៍ ...។*

☑ សិស្សចម្លងអក្សរផ្ចង់អំពីពាក្យណាមួយដែលគេពេញចិត្តហើយសរសេរពាក្យដដែលនោះឱ្យបានច្រើនដង(៣ដង)និងច្រើនបន្ទាត់(៣បន្ទាត់) ។

ឧទាហរណ៍ :




## ខ្លឹមសារ

- អក្សរផ្ចង់អំពីពាក្យ ៖
  " នោល ការងារ រំងាស់ អាកាស "



## ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូម

ហ្វឹកហាត់ផ្ទាល់ក្នុងថ្នាក់

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**

↓

*គ្រូអាចរកសម្ភារៈផ្សេងៗដូចជា : ក្ដារឆ្នួនមានក្រឡា ផ្ទាំងក្រដាសក្រឡាអ៊ីត...។*




**ដំណាក់កាលទី ៦ ត្រូវបានបញ្ចប់ហើយ!**

សូមធ្វើតេស្តសិស្សដោយប្រើ

តេស្តដំណាក់កាលទី ៦

នៃឧបសម្ព័ន្ធ ៣ នៅក្នុងសៀវភៅនេះ

ទំព័រទី ១៧៩

# ដំណាក់កាលទី ៧ : មេរៀនទី ៦៣-៧១ (៧)

(ទំព័រទី១២៥ ដល់ ១៥១)

**-អំណាន និងសំណេរ** : អត្ថបទអំពី

*១. មេរៀនទី៦៣ : ភូមិរុងរឿង*

*២. មេរៀនទី៦៤ : ជីកទឹកកខ្វក់នាំឱ្យកើតជំងឺ*

*៣. មេរៀនទី៦៥ : សត្វលលកនិងស្រមោចខ្មៅ*

*៤. មេរៀនទី៦៦ : រឿងចាបនិងដំរី*

*៥. មេរៀនទី៦៧ : វត្ថុប្រើប្រាស់នៅក្នុងផ្ទះ*

*៦. មេរៀនទី៦៩ : បឹងទន្លេសាប*

*៧. មេរៀនទី៧០ : រឿងសង្គ្រាមរវាងគីង្គក់ និងតាព្រហ្ម*

*៨. មេរៀនទី៧១ : រឿងដង្កូវ និងក្អែក*

*(សប្តាហ៍ទី ១ ខែ ឧសភា ដល់ សប្តាហ៍ ទី៤ ខែ មិថុនា)*

*( ៦៤ ម៉ោង/ ៤,៩២សប្តាហ៍ )*

*<u>កំណត់សម្គាល់ :</u> (៧)ចំពោះមេរៀនទី៦៨សមត្ថភាពស្តាប់មានចំនួន៣ម៉ោងសិក្សា។ មេរៀននេះមិនទាក់ទងស្តង់ដាអំណានទេគ្រូត្រូវបង្រៀនធម្មតា។*

លេខ ៧ក

# សិស្សអាចអានពាក្យក្នុងមេរៀនដោយផ្សំនិងប្រកប

ឧទាហរណ៍ :សមរម្យ អានថា សំ-រំ

.មន្ទីរពេទ្យ អានថា មន់-ទី-ពែត

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់តួអក្សរនិងសូរ**

សូមមើល មេរៀនទី ៦៣-៧១ (ទំព័រទី ១២៥-១៥១)

## ខ្លឹមសារ

♦ សូមស្រង់ពាក្យក្នុងមេរៀនទី៦៣-៧១ ដូចខាងក្រោម ៖

**មេរៀនទី៦៣ :** ហេតុ សមរម្យ វត្ត មន្ទីរពេទ្យ

**មេរៀនទី៦៤ :** ធម្មតា អនាម័យ

**មេរៀនទី៦៥ :** តម្រង់ ទន្រ្តំ ដូច្នេះ សេចក្តី

**មេរៀនទី៦៦ :** ដណ្តើម

**មេរៀនទី៦៧ :** ទូរទស្សន៍ សម័យ

**មេរៀនទី៦៨ :** វស្សា ធម្មជាតិ កសិកម្ម

**មេរៀនទី៧០ :** រុក្ខជាតិ បង្អួរ មន្រ្តី តាព្រហ្ម សេនា

**មេរៀនទី៧១ :** ប្រាជ្ញា លាមក អាចម៍ កេរ្តិ៍

## សកម្មភាពគំរូ

☑ សិស្សមើលបញ្ជីពាក្យដែលព្យាង្គមួយចំនួនរបស់ពាក្យនីមួយៗត្រូវបានលុបចេញ សិស្សត្រូវអានពាក្យដែលមិនពេញលេញនោះ រួចហើយសរសេរបំពេញព្យាង្គដែលបាត់ ។ អត្ថន័យនៃពាក្យត្រូវបានផ្តល់ជូនដើម្បីជួយសិស្សឱ្យដឹងអំពីអ្វីដែលត្រូវបំពេញ បានជាពាក្យត្រឹមត្រូវមួយ ។

ឧទាហរណ៍ :

_____ + រម្យ : ដែលត្រូវបែប ត្រូវយ៉ាង ដែលមិនទាស់ភ្នែក ។

_____ + នា + ម័យ: មិនមានរោគ មិនមានជំងឺ ។

ម + ន្ទីរ + _____ : កន្លែងព្យាបាលជំងឺ ។

ពល+ _____ + នា: ពួកទាហាន ពួកពល កងទ័ព។

បន្តទៅទំព័របន្ទាប់

លេខ ៧ក

## បន្ត...

### សកម្មភាពគំរូ

☑ គ្រូសរសេរឈ្មោះរបស់ពាក្យនៅលើក្ដារខៀនដែលព្យាង្គនីមួយៗត្រូវបានសរសេរទៅតាមសូរពេញលេញ (អំណានពាក្យ) ប៉ុន្តែមិនមែនសរសេរទៅតាមពាក្យត្រឹមត្រូវពិតប្រាកដនោះទេ ។ គ្រូឱ្យសិស្សសរសេរពាក្យត្រឹមត្រូវពិតប្រាកដ ដោយមុនដំបូងសិស្សត្រូវអានព្យាង្គនីមួយៗសិន ។

ឧទាហរណ៍ :

មន់ - ទី - ពែត ត្រូវសរសេរដូចតទៅ: ____*មន្ទីរពេទ្យ*______________

សំ- រំ ត្រូវសរសេរដូចតទៅ: ________________________________

ផ័ម - មៈ - ជាត ត្រូវសរសេរដូចតទៅ: __________________________

បង់ - អោ ត្រូវសរសេរដូចតទៅ: ______________________________

☑ សិស្សអានពាក្យដោយការញែកព្យាង្គរបស់ពាក្យនីមួយៗហើយថាតាមបន្តគ្នាម្ដងម្នាក់ឬថាតាមជាក្រុមតូចៗរហូតដល់ចប់ពាក្យនីមួយៗតាមការពន្យល់របស់គ្រូនៅលើក្ដារខៀន ។

ឧទាហរណ៍ : គ្រូសរសេរពាក្យ **សមរម្យ** នៅលើក្ដារខៀន រួចនាំសិស្សអាន

-គ្រូថា **សម (សំ)**

-សិស្សថា **រម្យ (រំ)**

☑ សិស្សអានពាក្យដោយការញែកព្យាង្គរបស់ពាក្យតាមការហៅរបស់គ្រូនៅលើក្ដារខៀន រួចអានព្យាង្គទី១ក្នុងពាក្យនោះ។ បន្ទាប់មកសិស្សម្នាក់ទៀតនៅខាងស្ដាំដៃគេអានព្យាង្គមួយទៀតបន្តធ្វើបែបនេះរហូតដល់ចប់ពាក្យនីមួយៗ ។

ឧទាហរណ៍ :

-សិស្សទី១អានថា **អ (អៈ)**

-សិស្សខាងស្ដាំដៃទី១អានថា **នា (ណា ឬ ន៉ា)**

-សិស្សបន្ទាប់ពីស្ដាំដៃទី១អានថា **ម័យ (ម៉ៃ)**

បន្តទៅទំព័របន្ទាប់

លេខ ៧ក

## បន្ត...

### សកម្មភាពគំរូ

☑ គ្រូនាំសិស្សលេងល្បែងទះដៃដើម្បីកំណត់ចំនួនព្យាង្គរបស់ពាក្យក្នុងការអានពាក្យ ២ព្យាង្គ ៣ព្យាង្គ ឬច្រើនព្យាង្គដោយឱ្យសិស្សជ្រើសរើសពាក្យធ្លាប់រៀនឬចេះចាំដោយខ្លួនឯង ។

ឧទាហរណ៍ : គ្រូទះដៃតាមចំនួនព្យាង្គរបស់ពាក្យ២ឬ៣ដង សិស្សត្រូវថាពាក្យនោះដោយប្រកបឱ្យបានពីរព្យាង្គ បីព្យាង្គ ។

-ទះដៃពីរដង : ល្ងីងល្ងើយ សុខសាន្ត តម្រង់ សម័យ ធនធាន មន្ត្រី...(ពាក្យពីរព្យាង្គ)

-ទះដៃបីដង : មន្ទីរពេទ្យ អនាម័យ សាលារៀន ទូរទស្សន៍ កសិកម្ម បដិសេធ...(ពាក្យបីព្យាង្គ)

-ទះដៃបួនដង : ប្រដាប់ប្រដា រង្គោះរង្គើ អំពិលអំពែក បឹងទន្លេសាប សម្លៀកបំពាក់ ប្រជាពលរដ្ឋ...(ពាក្យបួនព្យាង្គ) ។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



លេខ ១០



លេខ ១១



លេខ ១៤



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៧ក

មេរៀន ៧ខ

# សិស្សអាចពន្យល់ពាក្យពិបាក ពាក្យន័យដូច និងពាក្យផ្ទុយ

**បំណិនអំណានពាក់ព័ន្ធ : ការចេះវាក្យសព្ទ**

សូមមើល មេរៀនទី ៦៣-៧១ (ទំព័រទី ១២៥-១៥១)

## ខ្លឹមសារ

- សូមមើលនិងស្រង់ពន្យល់ពាក្យ ពាក្យផ្ទុយ ពាក្យន័យដូចក្នុងមេរៀនទី៦៣-៧១ ៖

**ពន្យល់ពាក្យ**

**មេរៀនទី៦៣ :** សាមគ្គី សមរម្យ

**មេរៀនទី៦៤ :** ឃ្វាល អនាម័យ

**មេរៀនទី៦៥ :** ស្នា ព្រាន ទន្ត្រំ វារ

**មេរៀទី៦៦ :** ជោរ នាច

**មេរៀនទី៦៧ :** ទូរទស្សន៍ សម័យ

**មេរៀនទី៦៩ :** កសិកម្ម ធម្មជាតិ ធនធាន

**មេរៀនទី៧០ :** រុក្ខជាតិ បង្អុរ មន្ត្រី តាព្រហ្ម ពលសេនា

**មេរៀនទី៧១ :** ប្រស្នា បដិសេធ កេរ្តិ៍

**ពាក្យន័យដូច**

**មេរៀនទី៦៣ : ផ្លូវ** ថ្នល់ វិថី មាគ៌ា

**មេរៀនទី៦៤ : ឃ្វាល** ចាំ មើល រក្សា

**មេរៀនទី៦៥ : ស្លាប់** ងាប់ អស់ជីវិត ក្ស័យ មរណៈ អនិច្ចធម្ម អនិច្ចកម្ម សុគត

**មេរៀនទី៦៧ :** ឈាម លោហិត

**មេរៀនទី៦៩ :** ប្រជាជន ប្រជារាស្ត្រ ប្រជាពលរដ្ឋ

**មេរៀនទី៧១ :** ទ្រគោះ បោះបោក គំពោះគំរើយ

**ពាក្យផ្ទុយ**

**មេរៀនទី៦៣ :** រុងរឿង ≠ អាប់ឱន

**មេរៀនទី៦៤ :** កខ្វក់ ≠ ស្អាត; ឆ្អិន ≠ ឆៅ

**មេរៀនទី៦៥ :** គោក ≠ ទឹក; ស្លាប់ ≠ រស់; ចេញ ≠ ចូល

**មេរៀនទី៦៧ :** ទំនើប ≠ បុរាណ

**មេរៀនទី៧០ :** ក្ដៅ ≠ ត្រជាក់; ចាញ់ ≠ ឈ្នះ

**មេរៀនទី៧១ :** ស្អុយ ≠ ក្រអូប; ខុស ≠ ត្រូវ

បន្តទៅទំព័របន្ទាប់

លេខ ៧៦

## បន្ត...

### សកម្មភាពគំរូ

☑ គ្រូបង្ហាញរូបភាព និងផ្តល់បញ្ជីពាក្យដល់សិស្ស ។ ពាក្យមួយចំនួនមាននៅក្នុងរូបភាព និងមួយចំនួនទៀតមិនមានក្នុងរូបភាពនោះទេ ។ គ្រូឱ្យសិស្សគូសរង្វង់ជុំវិញពាក្យនីមួយៗដែលពួក គេអាចមើលឃើញក្នុងរូបភាព ។



បញ្ជីពាក្យ

***សេចក្តីណែនាំ :*** សូមគូសរង្វង់ជុំវិញពាក្យដែលអ្នកអាចមើលឃើញក្នុងរូបភាព ។

១. សេះ ២. គោ ៣. វត្ត ៤. សាលារៀន ៥. ឡាន ៦. គេហដ្ឋាន

៦. ដើមឈើ ៧. សាលាឃុំ ៨. ជ្រូក ៩. ទូក ១០. ដំរី ១១. ពាងទឹក

☑ គ្រូរៀបចំលំហាត់មួយដែលសិស្សអាចបង្កើតឃ្លាខ្លីៗដើម្បីបំពេញន័យរបស់ពាក្យកាន់តែច្បាស់ឡើង ។ ប៉ុន្តែលំហាត់នេះត្រូវមានលក្ខណៈពិសេស ដែលសិស្សអាចលេងជាមួយសូរដើមនៃពាក្យដែលបានផ្តល់ឱ្យ ។ ពោលគឺឃ្លានីមួយៗអាចមានពាក្យដែលចាប់ផ្តើមដោយសូរដូចគ្នា ។ ប៉ុន្តែឃ្លាដែលបង្កើតដោយសិស្សត្រូវមានន័យសមស្រប ។ សូមមើលបញ្ជីពាក្យខាងក្រោម :

ឧទាហរណ៍ :

អនាម័យ ស្អាត ប្រឹងប្រែង អាក្រក់ សេនា សមរម្យ ធនធាន ប្រមាញ់ សាមគ្គី ស្រឡាញ់ ប្រាជ្ញា កខ្វក់ អាចម៍ ស្អុយ ធម្មជាតិ ស្មោះស្ម័គ្រ កេរ្តិ៍ ស្និទ្ធស្នាល អនុវត្ត សុខភាព ប្រជាជន ស្លន់ស្លោ សម័យ សុខសាន្ត ។

**ឃ្លាដែលអាចបង្កើតបានមាន :** អនាម័យ អាក្រក់ ប្រជាជន ប្រឹងប្រែង សេនា ស្លន់ស្លោ សាមគ្គី ស្មោះស្ម័គ្រ ។ល។

បន្តទៅទំព័របន្ទាប់

លេខ ៧ខ

## បន្ត...

### សកម្មភាពគំរូ

☑ គ្រូឱ្យសិស្សប្រៀបធៀបដើម្បីបញ្ជាក់អត្ថន័យនៃពាក្យ ។

**ឧទាហរណ៍ :**

ស ដូច ......*សំឡី*......

កខ្វក់ ដូច .............

ច្រើន ដូច .............

ស្អាត ដូច ...........

ក្ដៅ ដូច ............

ត្រជាក់ ដូច ...........

ស្អុយ ដូច ............

ក្រអូប ដូច ...........

ប្រាជ្ញា ដូច .............

☑ គ្រូនាំសិស្សធ្វើលំហាត់មួយ ដោយឱ្យសិស្សគិតអំពីន័យផ្ទុយ ដោយផ្អែកទៅលើអត្ថន័យនៃល្បះ ។ ខាងក្រោមគឺជាឧទាហរណ៍ល្បះមួយចំនួនដែលគ្រូអាចធ្វើជាមួយសិស្ស ។

**ឧទាហរណ៍ :**

១. មន្ទីរពេទ្យនេះមិនស្អាតទេ ។ វាគឺ ___________។

២. នៅពេលជួបគ្រោះរាំងស្ងួត ភូមិរបស់យើងគឺជួបភាពក្រីក្រ ។ នៅពេលភ្លៀងបានធ្លាក់មក បច្ចុប្បន្ននេះ ភូមិរបស់យើងគឺ _____________។

៣. នៅរដូវវស្សាអាកាសធាតុ ត្រជាក់ ។ នៅរដូវប្រាំង អាកាសធាតុ ________។

៤. ក្មេងកើតជំងឺរាកនៅពេលផឹកទឹកឆៅ ។ ដើម្បីការពារជំងឺនេះក្មេងត្រូវផឹកទឹក _________។

បន្តទៅទំព័របន្ទាប់ →

លេខ ៧ខ

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សគូសរង្វង់ជុំវិញពាក្យន័យដូចនិងពាក្យផ្ទុយតាមតារាងពាក្យដែលគ្រូកំណត់

ឧទាហរណ៍ : តារាងពាក្យ

| គូសរង្វង់ពាក្យន័យដូច | គូសរង្វង់ពាក្យន័យដូច | គូសរង្វង់ពាក្យផ្ទុយ |
|---|---|---|
| ប្រទេស | លោហិត | ទំនើប |
| ប្រពៃណី | ឈ្មុះ | ខុស |
| ប្រជារាស្ត្រ | ក្រអូប | ប្រស្នា |
| ប្រភព | ជោគជ័យ | បុរាណ |
| ប្រជាពលរដ្ឋ | ស្អុយ | ត្រជាក់ |

☑ សិស្សផ្គូផ្គងពាក្យពិបាកទៅនឹងន័យរបស់វាបានត្រឹមត្រូវតាមការកំណត់របស់គ្រូ

ឧទាហរណ៍ : តារាងផ្គូផ្គងពាក្យពិបាកទៅនឹងនិយមន័យ

| **ពាក្យពិបាក** | **និយមន័យ** |
|---|---|
| **កេរ្តិ៍** → | សេចក្ដីសរសើរ ការល្បី ។ |
| | ទ្រព្យសម្បត្តិម៉ែឪចែកឱ្យ ។ |
| | របស់របរពីដូនតា ។ |
| | អ្នកនៅតាមស្រែចម្ការ ។ |
| **កសិកម្ម** → | ការធ្វើស្រែ ចម្ការ ចិញ្ចឹមសត្វ ។ |
| | អ្នកនៅតាមដងទន្លេមេគង្គ ។ |
| | ការយល់ត្រូវ លែងយកជាការ ។ |
| | ការយល់ព្រមលែងយកជាការ ។ |
| **បដិសេធ** → | ការមិនយល់ព្រមលែងយកជាការ ។ |

បន្តទៅទំព័របន្ទាប់ →

លេខ ៧ខ

**បន្ត...**

## សកម្មភាពគំរូ

☑ សិស្សជ្រើសរើសពាក្យក្នុងប្រអប់ខាងក្រោមដែលមានន័យដូចគ្នានឹងពាក្យក្នុងល្បះឬអត្ថបទមកបំពេញបានត្រឹមត្រូវ ។

ឧទាហរណ៍ : មានសត្វដង្កូវមួយកំពុង*ស៊ី*(១)ស្លឹកឈើ ។ ពេលនោះមានសត្វ*ក្អែក*(២) មួយហើរបម្រុងនឹង*ស៊ី*(៣)*ដង្កូវ*(៤)នោះ ។ ដង្កូវមានប្រាជ្ញាក៏ដាក់ប្រស្នាឱ្យក្អែក*ដោះស្រាយ*(៥)។ បើក្អែកដោះប្រស្នាមិន*រួច*(៦)មិនអាចស៊ី*វា*(៧) បានទេ ។

| ចឹក ឆី សើច បាន ហើរ ចាប កណ្ដូប ផឹក ស្រែក |
|---|

**ចម្លើយ :**

(១).......ឆី (២) .....ចាប (៣) ....ឆី, (៤) .....កណ្ដូប (៥).....ឆ្លើយ

(៦).....បាន (៧) ......កណ្ដូប ។

☑ សិស្សផ្គុំព្យញ្ជនៈ ស្រៈ និងព្យាង្គក្នុងតារាងដោយគូសវង់ជុំវិញបានជាពាក្យដែលមានន័យដូចបានត្រឹមត្រូវ ។

ឧទាហរណ៍ :

| | | | | | | | |
|---|---|---|---|---|---|---|---|
| េ | មី | ល | ិ | លា | ស | ម | ស្ត |
| អ | ផ្ល | ូ | វ | ម | ្ល | ្រ | ល |
| ឈ | ា | ម | ី | ក | ា | ប | អ |
| ឃ្វ | ា | ល | ថ | រ | ប់ | ជ | ា |
| សុ | ូ | ្រ | ា | ញ | ត | ា | ច |
| គ | ថ | ជ | ទ | ហិ | ី | ជ | ម៍ |
| ត | ប | ៃ | លោ | គោះ | ធ | ន | ឡ |
| ្រ | គ | ំ | ពោះ | គ | ំ | រើ | យ |

**ចម្លើយ :** ន័យដូចនឹងពាក្យ

មើល- ឃ្វាល ,វិថី- ផ្លូវ, ឈាម- លោហិត, ប្រជាជន- ប្រជារាស្ត្រ,

អាចម៍- លាមក, ស្លាប់- សុគត, ទ្រគោះ- គំរោះគំរើយ

បន្តទៅទំព័របន្ទាប់ →

លេខ ៧ខ

**បន្ត...**

## សកម្មភាពគំរូ

☑ សិស្សផ្គុំព្យញ្ជនៈ ស្រៈ និងព្យាង្គក្នុងតារាងដោយគូសរង់ជុំវិញជាពាក្យផ្ទុយបានត្រឹមត្រូវ ។

ឧទាហរណ៍ :

| | | | | | | |
|---|---|---|---|---|---|---|
| រ | ស់ | ស | ច | ◌ា | ញ់ | ប |
| ចេ | ◌ុ | ឆ្អ | ◌ិ | ន | ត្រ | ◌ុ |
| ខ | ញ | ង | ឱ | ង | ជ | វ |
| ស្ល | ◌ា | ប់ | រឿ | វ | ◌ា | ◌ា |
| ណ | ◌ា | ។ | ◌ូ | ង | ក់ | ណ |
| អ | ក្ដ | ត្រ | ឈ្ន | ◌ះ | ឆៅ | ឈ |
| េ◌ | ចូ | ល | ទ | ◌ំ | នើ | ប |

**ចម្លើយ :** ពាក្យផ្ទុយ

អាប់ឱន ≠ រុងរឿង, ស្លាប់ ≠ រស់, ឆ្អិន ≠ ឆៅ, ឈ្នះ ≠ ចាញ់, ត្រជាក់ ≠ ក្ដៅ, ខុស ≠ ត្រូវ, កខ្វក់ ≠ ស្អាត, ចេញ ≠ ចូល, ទំនើប ≠ បុរាណ

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**


លេខ ១៦


លេខ ១៣


លេខ ១៤


លេខ ១៥



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៧ខ

**លេខ ៧គ**

# សិស្សអាចអានពាក្យក្នុងមេរៀនដោយមិនបាច់ផ្ទំ និងប្រកប

**បំណិនអំណានពាក់ព័ន្ធ : ការចេះអានស្ទាត់**

សូមមើល មេរៀនទី ៦៣-៧១ (ទំព័រទី ១២៥-១៥១)

## ខ្លឹមសារ

- សូមស្រង់ពាក្យក្នុងមេរៀនទី៦៣-៧១ដូចខាងក្រោម ៖

**មេរៀនទី៦៣** : ប្រជាជន វត្ត ល្បីងល្បើយ ផល សាមគ្គី សុខសាន្ត រុងរឿង មន្ទីរពេទ្យ

**មេរៀនទី៦៤** : ឃ្វាល ទម្លាប់ ស្រែក ត្រពាំង ធម្មតា កខ្វក់ អនាម័យ សុខភាព

**មេរៀនទី៦៥** : វារ ព្រាន អាណិត សេចក្ដី ស្រមោច ប្រមាញ់ តម្រង់ ទន្ត្រំ បម្រុង

**មេរៀនទី៦៦** : ព្រៃ សត្វ ភ្ទាល់ ដណ្ដើម ភ្នំ សមុទ្រ ដោរ នាច ប្រាជ្ញា ឈ្លាសវៃ

**មេរៀនទី៦៧** : ទូរទស្សន៍ ស្រឡាញ់ សម័យ ក្បឿង វត្ថុ គ្រៃ សម្លៀកបំពាក់ បន្ទប់

**មេរៀនទី៦៩** : ប្រទេសកម្ពុជា លាតសន្ធឹង ព្រៃនាម ជម្រក ពិភពលោក ផ្ទៃដី ប្រភព ធនធាន ធម្មជាតិ

**មេរៀនទី៧០** : កង្កែប គីង្គក់ តាព្រហ្ម មន្ត្រី ទ័ព សេនា ស្លន់ស្លោ កម្លាំង ឯកភាព ជោគជ័យ

**មេរៀនទី៧១** : ប្រស្នា លាមក បដិសេធ ប្រាជ្ញា សត្វ កេរ្ដិ៍ឈ្មោះ ដង្កូវ ជូរចត់

បន្តទៅទំព័របន្ទាប់

**លេខ ៧គ** **បន្ត...**

## សកម្មភាពគំរូ

☑ សិស្សអានពាក្យដោយមិនបាច់ផ្សំនិងប្រកបបានយ៉ាងលឿនតាមការកំណត់របស់គ្រូ ឬតាមបញ្ជីពាក្យក្នុងលំហាត់ ។

*ឧទាហរណ៍ : ប្រជាជន ភូមិ ល្ងឹងល្ងើយ ផល សាមគ្គី សុខសាន្ត រុងរឿង វត្ត មន្ទីរពេទ្យ ទូរទស្សន៍ ស្រឡាញ់ សម័យ ក្បឿង វត្ថុ គ្រែ សម្លៀកបំពាក់ បន្ទប់... ។*

☑ សិស្សមើលបញ្ជីពាក្យដែលគ្រូសរសេរនៅលើក្ដារខៀន ។ បន្ទាប់មកគ្រូឱ្យសិស្សពីរនាក់អានប្រណាំងគ្នាតាមបញ្ជីពាក្យនោះឱ្យបានលឿនបំផុតដោយមិនបាច់ផ្សំនិងប្រកបតាមដែលអាចធ្វើទៅបាន ។ សិស្សណាអានបានគ្រប់ពាក្យបានត្រឹមត្រូវហើយចប់មុនគេសិស្សនោះជាអ្នកឈ្នះ ។

*ឧទាហរណ៍ : ប្រជាជន ភូមិ ល្ងឹងល្ងើយ ផល សាមគ្គី សុខសាន្ត រុងរឿង វត្ត មន្ទីរពេទ្យ*

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



លេខ ១០



លេខ ១១



លេខ ១៤

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៧គ

លេខ ៧យ

# សិស្សអាចបកស្រាយន័យរបស់ល្បះនិងអត្ថបទក្នុងមេរៀន

**បំណិនអំណានពាក់ព័ន្ធ : ការចេះវាក្យសព្ទ**
**: ការអានដើម្បីយល់ន័យ**

សូមមើល មេរៀនទី ៦៣-៧១ (ទំព័រទី ១២៥-១៥១)

## ខ្លឹមសារ

- សូមដកស្រង់ ល្បះ និងអត្ថបទក្នុងមេរៀនទី៦៣-៧១ ៖
  " ភូមិរុងរឿង ផឹកទឹកកខ្វក់នាំឱ្យកើតជំងឺ សត្វលលកនិងស្រមោចខ្មៅ រឿងចាបនិងដំរី វត្ថុប្រើប្រាស់នៅក្នុងផ្ទះ បឹងទន្លេសាប រឿងសង្គ្រាមរវាងគីង្គក់និងតាព្រហ្ម រឿងដង្កូវនិងក្អែក "

## សកម្មភាពគំរូ

☑ សិស្សឆ្លើយនឹងសំណួរក្នុងមេរៀនសៀវភៅសិស្សបានត្រឹមត្រូវ។

**មេរៀនទី៦៣ :**

១. តើភូមិរុងរឿងមានអ្វីខ្លះ?
២. តើប្រជាជននៅភូមិរុងរឿង ប្រកបមុខរបរអ្វី?
៣. តើប្រជាជនទាំងនោះមានជីវភាពដូចម្ដេចដែរ?
៤. ហេតុអ្វីបានជាគេហៅថា ភូមិរុងរឿង?

**មេរៀនទី៦៤ :**

១. តើស្នានិងស្ងាយទៅឃ្វាលគោនៅឯណា?
២. តើស្នាមានទម្លាប់ដូចម្ដេច?
៣. ហេតុអ្វីបានជាស្នាកើតជំងឺរាក?
៤. ហេតុអ្វីបានជាយើងផឹកទឹកស្អាត?

**មេរៀនទី៦៥ :**

១. តើលលកឃើញស្រមោចកំពុងធ្វើអ្វី? នៅកន្លែងណា?
២. តើសត្វស្រមោចបានរួចជីវិតដោយសារនរណា?
៣. ហេតុអ្វីបានជាស្រមោចវារឡើងខាំជើងព្រានប្រមាញ់?
៤. ចំពោះប្អូនវិញតើប្អូនធ្វើដូចស្រមោចដែរឬទេ? ព្រោះអ្វី?

បន្តទៅទំព័របន្ទាប់

លេខ ៧យ

## បន្ត...

### សកម្មភាពគំរូ

**មេរៀនទី៦៦ :**

១. តើចាបនិងដំរីដណ្ដើមគ្នាធ្វើអ្វី?

២. តើចាបហើរនាំដំរីទៅណា?

៣. តើចាបនិងដំរីភ្នាល់គ្នាធ្វើអ្វី?

៤. តើចាបធ្វើដូចម្ដេចទើបឈ្នះដំរី?

**មេរៀនទី៦៧ :**

១. តើផ្ទះនេះមានប៉ុន្មានបន្ទប់?

២. តើវត្ថុប្រើប្រាស់ក្នុងផ្ទះមានអ្វីខ្លះ?

៣. ហេតុអ្វីបានជាយើងត្រូវថែទាំសម្អាតវត្ថុប្រើប្រាស់ក្នុងផ្ទះ?

៤. តើប្អូនមានទឹកចិត្តដូចម្ដេចចំពោះផ្ទះរបស់ប្អូន?

**មេរៀនទី៦៩ :**

១. តើបឹងទន្លេសាបមានលក្ខណៈដូចម្ដេច?

២. តើនៅជុំវិញបឹងទន្លេសាបមានអ្វីដុះ?

៣. តើគេយកត្រីមកធ្វើអ្វីខ្លះ?

៤. ហេតុអ្វីបានជាដំណាំនៅជុំវិញបឹងទន្លេសាបផ្ដល់ផលបានច្រើន?

**មេរៀនទី៧០ :**

១. តើពួកសត្វណាខ្លះដែលឡើងទៅច្បាំងនឹងតាព្រហ្ម? ហេតុអ្វី?

២. តើអ្នកណាជាអ្នកបញ្ជាកងទ័ព?

៣. តើចម្បាំងនេះខាងណាជាអ្នកឈ្នះ? ហេតុអ្វី?

៤. តើតាព្រហ្មសន្យាដូចម្ដេច?

**មេរៀនទី៧១ :**

១. ហេតុអ្វីបានជាដង្កូវចោទប្រស្នាដល់ក្អែក?

២. តើដង្កូវបានដាក់ប្រស្នាអ្វីខ្លះដល់ក្អែក?

៣. តើក្អែកឆ្លើយដោះប្រស្នារបស់ដង្កូវយ៉ាងដូចម្ដេច?

៤. តើក្អែកបានស៊ីដង្កូវឬទេ? ព្រោះអ្វី?

បន្តទៅទំព័របន្ទាប់

លេខ ៧យ

**បន្ត...**

## សកម្មភាពគំរូ

☑ សិស្សឆ្លើយសំណួរបន្ថែមរបស់គ្រូទាក់ទងចំណងជើងអត្ថបទ ។

ឧទាហរណ៍ : ចូរប្អូនរកឬប៉ាន់ស្មានចំណងជើងអត្ថបទថ្មីមួយទៀតឱ្យអត្ថបទខាងលើតាមគំនិតផ្ទាល់ខ្លួន ។

**ចម្លើយ** :

**មេរៀនទី៦៣** : ភូមិរុងរឿង ⟶ ភូមិសម្បូរ ឬ...

**មេរៀនទី៦៤** : ផឹកទឹកកខ្វក់នាំឱ្យកើតជំងឺ ⟶ ផឹកកខ្វក់មានជំងឺ ឬ...

**មេរៀនទី៦៥** : សត្វលលកនិងស្រមោចខ្មៅ⟶ជួយគ្នាគ្រាមានអាសន្ន ឬ...

**មេរៀនទី៦៦** : រឿងចាបនិងដំរី ⟶ ប្រាជ្ញាចាប ឬ...

**មេរៀនទី៦៧** : វត្ថុប្រើប្រាស់នៅក្នុងផ្ទះ ⟶ សម្ភារៈប្រើប្រាស់ក្នុងផ្ទះ ឬ..

**មេរៀនទី៦៨** : បឹងទន្លេសាប ⟶ មោទនភាពបឹងទន្លេសាប ឬ...

**មេរៀនទី៦៩** : រឿងសង្គ្រាមរវាងគីង្គក់និងតាព្រហ្ម⟶ជម្លោះសុំទឹកភ្លៀង ឬ..

**មេរៀនទី៦៦** : រឿងដង្កូវនិងក្អែក ⟶ ក្អែកចង់ស៊ីដង្កូវ ឬ...

☑ សិស្សជ្រើសរើសសំណួរដែលត្រូវនឹងខ្លឹមសារចម្លើយដែលគ្រូកំណត់ដោយគូសរង្វង់ជុំវិញលេខសំណួរដែលត្រឹមត្រូវ(៨)

ឧទាហរណ៍ : ដង្កូវចូលចិត្តស៊ីស្លឹកឈើ ។ តើសំណួរណាដែលត្រូវនឹងចម្លើយខាងលើ?

១. តើដង្កូវចូលចិត្តរស់នៅទីណា?

២. តើដង្កូវចូលចិត្តស៊ីអ្វី? (ចម្លើយ: ⓶តើដង្កូវចូលចិត្តស៊ីអ្វី? )

៣. តើដង្កូវខ្លាចសត្វអ្វីខ្លះ?

☑ សិស្សជ្រើសរើសពាក្យក្នុងប្រអប់ដើម្បីបំពេញល្បះបានត្រឹមត្រូវ ។ មេរៀនទី៦៣-៦៦ ទំព័រទី១២៧ និង១៣៦,មេរៀនទី ៦៧-៦៩ និង៧០ទំព័រទី១៤០,១៤៤និង១៤៧ ។

ឧទាហរណ៍ : ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញល្បះខាងក្រោម ។ (ទំព័រ១៤០ ចំណុចគ)

| |
|---|
| ទទួលទាន ឈើ ភ្ញៀវ សម្អាត សម័យ |

១. ផ្ទះរបស់ខ្ញុំសង់អំពី...............ប្រក់ក្បឿង ។

២. នៅក្នុងផ្ទះនេះមានបន្ទប់ទទួល...........បន្ទប់ដេក បន្ទប់..........អាហារ ។

*__កំណត់សម្គាល់ :__ (៨)ជាធម្មតាគ្រូតែងតែឱ្យសិស្សរកចម្លើយទៅតាមសំណួរ ប៉ុន្តែក្នុងករណីនេះ ទាមទារឱ្យសិស្សរកសំណួរឱ្យត្រូវនឹងចម្លើយរបស់គ្រូវិញ ។*

**លេខ ៧ឃ**

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សរកពាក្យ (១ពាក្យ ២ពាក្យ ៣ពាក្យ) មកបំពេញក្នុងល្បះបានត្រឹមត្រូវតាមរូបភាព ។

ឧទាហរណ៍ ៖ ចូរបំពេញល្បះតាមរូបភាពខាងក្រោមឱ្យបានត្រឹមត្រូវ។(ទំព័រទី១៥១)







១. ដង្កូវកំពុង..........។ ២. ក្អែកទំលើ..........។ ៣. ឃ្មុំកំពុង..........។

☑ សិស្សឆ្លើយសំណួរអំពីអត្ថបទដោយបំពេញអក្សរក្នុងតារាងបានត្រឹមត្រូវតាមការណែនាំរបស់គ្រូ ។

ឧទាហរណ៍ ៖

១. តើដង្កូវសន្ទនាជាមួយសត្វអ្វី ? (ក្អែក)
២. តើក្អែកត្រូវដោះស្រាយអ្វី? (ប្រស្នា)
៣. តើក្អែកចង់ស៊ីអ្វី? (ដង្កូវ)
៤. តើពាក្យណាផ្ទុយនឹង"ស្អុយ"? (ក្រអូប)

| | | | |
|---|---|---|---|
| ១→ ើ | ___ | ___ | ២↓ េ |
| ៣↓ ដ | ៤→ ក្រ | ___ | ប |
| ___ | | | ___ |
| វ | | | ា |

☑ សិស្សគូសភ្ជាប់ឃ្លាបានជាល្បះត្រឹមត្រូវ ។

ឧទាហរណ៍ ៖ ចូរគូសភ្ជាប់ល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។ (ទំព័រទី១៤៤ចំណុចគ)

១. បឹងទន្លេសាបជាជម្រកត្រី — ក. ជាងគេលើពិភពលោក ។
២. បឹងទន្លេសាបជាប្រភពធនធាន → ខ. នៃប្រទេសកម្ពុជា ។
៣. បឹងនេះមានព្រៃនាមដុះជុំវិញ — គ. ធម្មជាតិមួយយ៉ាងសំខាន់នៃប្រទេសកម្ពុជា ។
៤. បឹងទន្លេសាបសម្បូរត្រីទឹកសាប — ឃ. ដែលជាជម្រកសម្រាប់ត្រីពង ។

បន្តទៅទំព័របន្ទាប់

លេខ ៧យ

បន្ត...

## សកម្មភាពគំរូ

☑ សិស្សបំពេញលំហាត់ក្លូស្ស (Cloze) ដោយប្រើបរិបទជាទីសេចក្ដីក្នុងអត្ថបទតាមមេរៀនកំណត់ ។

ឧទាហរណ៍ : បឹងទន្លេសាបជាជង្រុក.......(១)នៃប្រទេសកម្ពុជា ។ នៅរដូវ.......(២) បឹងទន្លេសាបលាតសន្ធឹង.......(៣)។ បឹងនេះមានព្រៃរនាម........(៤)ជុំវិញ ដែលជាជម្រកសម្រាប់.......(៥)ពង។ បឹងនេះសម្បូរ......(៦)ទឹកសាបជាងគេលើ .......(៧) ។ រៀងរាល់ឆ្នាំប្រជាជនយើង..........(៨)ត្រីបានច្រើនក្រៃលែង ។

**ចម្លើយ :**

(១) ត្រី (មច្ឆា) (៤) ដុះ(នៅ) (៦) ត្រី (មច្ឆា)

(២) វស្សា(ភ្លៀង) (៥) ត្រី(មច្ឆា) (៧) ពិភពលោក (លោក សកលលោក)

(៣) ល្វឹងល្វើយ(ធំធេងដាច់កន្ទុយភ្នែក) (៨) នេសាទ(រកត្រី)

☑ សិស្សបង់លេខសម្គាល់លំដាប់លំដោយសាច់រឿង ដែលពួកគេបានអានទៅតាមការយល់ដឹងរបស់គេ ។ ពួកគេត្រូវដាក់លេខ “១” នៅខាងមុខល្បះដែលចាប់ផ្ដើមមុនគេ និងដាក់លេខ “២” នៅខាងមុខល្បះដែលកើតឡើងបន្ទាប់ ។ល។

ឧទាហរណ៍ទី១ : អត្ថបទអំណាន មេរៀនទី៦៥ ទំព័រ ១៣១

### សត្វលលកនិងស្រមោចខ្មៅ

មានសត្វលលកមួយហើរទៅឃើញពួកស្រមោចខ្មៅ កំពុងលង់ទឹកហែលតោងគ្នា ។ លលកមានចិត្តអាណិត ក៏ពាំមែកឈើងាប់មួយមកដាក់ធ្វើជាស្ពានឱ្យស្រមោចទាំងនោះតោងវារឡើងមកលើគោក បានរួចផុតពីក្ដីស្លាប់ ។

ថ្ងៃមួយ មានព្រានប្រមាញ់ម្នាក់ ឃើញលលកទំលើមែកជ្រៃ ក៏លើកស្នាតម្រង់បម្រុងនឹងបាញ់លលកនោះ ។ ស្រមោចឃើញដូច្នេះ ក៏នាំគ្នាវារឡើងទៅខាំជើងព្រាន ។ នាយព្រានភ្ញាក់ ក៏ទន្រ្ទាំជើងឮសូរដល់លលក ។ លលកដឹងខ្លួនក៏ហើរចេញទៅរួចផុតពីសេចក្ដីស្លាប់ ។

បន្តទៅទំព័របន្ទាប់

លេខ ៧ឃ

បន្ត...

## សកម្មភាពគំរូ

________ ស្រមោចខ្មៅ វារឡើងទៅខាំជើងព្រាន ។

________ ស្រមោចខ្មៅ កំពុងលង់ទឹកហៃលតោងគ្នា ។

________ លលកដឹងខ្លួន ក៏ហើរចេញទៅ រួចផុតពីសេចក្ដីស្លាប់ ។

________ លលកបានជួយស្រមោចខ្មៅ ។

________ ព្រានប្រមាញ់ម្នាក់ លើកស្នាតម្រង់បម្រុងនឹងបាញ់លលក ។

ឧទាហរណ៍ទី២ : អត្ថបទអំណាន មេរៀនទី៦៦ទំព័រ ១៣៤

**សត្វលលកនិងស្រមោចខ្មៅ**

នៅព្រៃធំមួយ មានសត្វចាបនិងដំរីដណ្ដើមគ្នាធ្វើជាមេ ។

ថ្ងៃមួយ ដំរីបបួលចាបផឹកទឹកភ្នាល់គ្នា ។ បើអ្នកណាផឹកបានច្រើនជាងអ្នកនោះជាអ្នកឈ្នះ។ ចាបក៏យល់ព្រមហើយហើរនាំផ្លូវដំរីកាត់ព្រៃភ្នំទៅកាន់សមុទ្រ ។

ពេលនោះ ទឹកសមុទ្រកំពុងជោរ ចាបក៏ឱ្យដំរីផឹកទឹកមុន ។ ទឹកសមុទ្រប្រៃពិបាកលេបណាស់ តែដោយចង់ឈ្នះ ដំរីខំផឹកឥតឈប់ ។ ទឹកសមុទ្រនៅតែជោរឡើងដល់ពោះវា ទើបដំរីឈប់ផឹក ។ លុះទឹកនាច ចាបក៏ហើរទៅមាត់ទឹកឱនក្បាលជ្រលក់ចំពុះក្នុងទឹកធ្វើជាផឹក ។ ទឹកស្រកចុះចាបក៏លោតតាមទឹកនាចធ្វើជាផឹករហូតដល់ជើងដំរី ។ ចាបផឹកទឹករហូត ទាល់តែដំរីឃាត់ ។

________ ចាបហើរនាំផ្លូវដំរីកាត់ព្រៃភ្នំទៅកាន់សមុទ្រ ។

________ ចាបក៏បានធ្វើជាមេ ដោយសារប្រាជ្ញាឈ្លាសវៃរបស់ខ្លួន ។

________ ទឹកសមុទ្រកំពុងជោរ ចាបក៏ឱ្យដំរីផឹកទឹកមុន ។

________ ចាបផឹកទឹករហូត ទាល់តែដំរីឃាត់ ។

________ លុះទឹកនាច ចាបបានហើរទៅមាត់ទឹកឱនក្បាលជ្រលក់ចំពុះក្នុងទឹកធ្វើជាផឹក ។

☑ សិស្សវិភាគចំណុចសំខាន់នៅក្នុងសាច់រឿងដោយយោងទៅលើ **គំនិតសំខាន់ គំនិតលម្អិត** និង**សេចក្ដីសន្និដ្ឋាន** ។

បន្តទៅទំព័របន្ទាប់

លេខ ៧ឃ

**បន្ត...**

## សកម្មភាពគំរូ

អត្ថបទអំណាន : មេរៀនទី៦៥ ទំព័រ១៣១

### សត្វលលកនិងស្រមោចខ្មៅ

មានសត្វលលកមួយហើរទៅឃើញពួកស្រមោចខ្មៅ កំពុងលង់ទឹកហែលតោងគ្នា ។

លលកមានចិត្តអាណិត ក៏ពាំមែកឈើងាប់មួយមកដាក់ធ្វើជាស្ពានឱ្យស្រមោចទាំងនោះតោងវារឡើងមកលើគោក បានរួចផុតពីក្ដីស្លាប់ ។

ថ្ងៃមួយ មានព្រានប្រមាញ់ម្នាក់ ឃើញលលកទំលើមែកជ្រៃ ក៏លើកស្នាតម្រង់បម្រុងនឹងបាញ់លលកនោះ ។ ស្រមោចឃើញដូច្នេះ ក៏នាំគ្នាវារឡើងទៅខាំជើងព្រាន ។ នាយព្រានភ្ញាក់ ក៏ទន្ត្រំជើងឮសូរដល់លលក ។ លលកដឹងខ្លួនក៏ហើរចេញទៅ រួចផុតពីសេចក្ដីស្លាប់ ។

ចូរអានរឿងខាងលើបន្ទាប់មកសរសេរគំនិតសំខាន់គំនិតលម្អិត និងសេចក្ដីសន្និដ្ឋានក្នុងប្រអប់ខាងក្រោម :



**គំនិតសំខាន់**

________________

**គំនិតលម្អិត**

________________



**គំនិតលម្អិត**

________________

**សេចក្ដីសន្និដ្ឋាន**

________________________

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



លេខ ១៦



លេខ ១៣



លេខ ១៤



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៧ឃ

លេខ ៧ង

# សិស្សអាចសរសេរពាក្យល្បះអត្ថបទតាមរយៈលំហាត់សរសេរតាមអាន

## បំណិនសំណេរពាក់ព័ន្ធ : សរសេរតាមអាន

សូមមើល មេរៀនទី ៦៣-៧១ (ទំព័រទី ១២៥-១៥១)

## ខ្លឹមសារ

- សរសេរតាមអានអំពីពាក្យ កន្សោមពាក្យ ល្បះ និងអត្ថបទខ្លី ៖

**មេរៀនទី៦៣ :** សាមគ្គី រុងរឿង ជីវភាព សុខសាន្ត សមរម្យ ភូមិខ្ញុំមានវាលស្រែធំល្វឹងល្វើយផ្លូវថ្នល់ស្អាតមានសាលារៀន មន្ទីរពេទ្យនិងវត្តអារាម ។

**មេរៀនទី៦៤ :**

**ផឹកទឹកកខ្វក់នាំឱ្យកើតជំងឺ**

រាល់ថ្ងៃស្អានិងស្អាយតែងទៅឃ្វាលគោនៅវាលឆ្ងាយពីផ្ទះ ។ ជាទម្លាប់ស្អាតែងដាក់ទឹកឆ្អិនក្នុងដបយកទៅផឹក ។ ចំណែកឯស្អាយពេលស្រេកទឹកគេចុះទៅក្បង់ទឹកត្រពាំងផឹក ។ ពេលត្រឡប់មកផ្ទះវិញស្អាយក៏ចុកពោះរាកយ៉ាងខ្លាំង ។ ការផឹកកខ្វក់នាំឱ្យកើតជំងឺ ។ អនាម័យនាំឱ្យមានសុខភាពល្អ ។

**ចូរពន្យល់ពាក្យ** "អនាម័យ ឃ្វាល"

**សំណួរ**

១. តើពេលទៅឃ្វាលគោស្អាយកទឹកអ្វីទៅផឹក?

២. ហេតុអ្វីបានជាស្អាយកើតជំងឺ?

៣. តើប្អូនត្រូវធ្វើដូចម្ដេចដើម្បីឱ្យមានសុខភាពល្អ?

**លំហាត់**

១. ចូររកពាក្យន័យដូចនឹងពាក្យ "ផឹក"។

២. ចូររកពាក្យផ្ទុយនឹងពាក្យ "កខ្វក់" ។

**មេរៀនទី៦៥ :** ភ្ញាក់ ព្រាន ប្រជាជន កសិករ ឧស្សាហ៍ លលកដឹងខ្លួនក៏ហើរចេញទៅរួចផុតពីសេចក្ដីស្លាប់។

**មេរៀនទី៦៦ :** ដណ្ដើម ភ្ញាល់ ភ្នំ សមុទ្រ ជោរ នាច ប្រាថ្នា ឈ្លាសវៃ នៅព្រៃធំមួយមានសត្វចាប និងដំរី ដណ្ដើមគ្នាធ្វើជាមេ ។

**មេរៀនទី៦៧ :**

**វត្ថុប្រើប្រាស់នៅក្នុងផ្ទះ**

ផ្ទះខ្ញុំសង់អំពីឈើប្រក់ក្បឿងមានពីរខ្នង និងវត្ថុប្រើប្រាស់ជាច្រើន ។ បន្ទប់ទទួលភ្ញៀវ មានក្ដារជៀធំមួយ មានតុមួយ កៅអីពីរ និង ទូរទស្សន៍មួយ ។ បន្ទប់ទទួលទានអាហារមានតុមូលធំមួយ និងកៅអីប្រាំ ។ វត្ថុប្រើប្រាស់នៅក្នុងផ្ទះខ្ញុំមិនទំនើបទាន់សម័យមែន ប៉ុន្តែខ្ញុំសម្អាតវាជាប្រចាំ ។

បន្តទៅទំព័របន្ទាប់

លេខ
៧ង

**បន្ត...**

## ខ្លឹមសារ

**មេរៀនទី៦៩ :** ល្ងីងល្ងើយ វស្សា កម្ពុជាធនធាន ធម្មជាតិ រដូវប្រាំងទឹករាក់ប្រជាជនយើងនេសាទត្រីបានច្រើនក្រៃលែង ។

**មេរៀនទី៧០ :** រុក្ខជាតិ ខឹងសម្បារ បង្អួរ ស្លន់ស្លោ តាព្រហ្ម,កាលពីព្រេងនាយពិភពលោកកើតភាពរាំងស្ងួតក្ដៅហួតហែងគ្មានទឹកភ្លៀងសោះ ។

**មេរៀនទី៧១ :**

ក.ចូរសរសេរតាមអានរៀបចំអត្ថបទខាងក្រោម។

**រឿងដង្កូវនិងក្អែក**

មានសត្វដង្កូវមួយកំពុងស៊ីស្លឹកឈើ ។ ពេលនោះ មានសត្វក្អែកមួយហើរមកបម្រុងនឹងស៊ីដង្កូវនោះ ។ ដង្កូវមានប្រាជ្ញាក៏ដាក់ប្រស្នាឱ្យក្អែកដោះស្រាយ ។ បើក្អែកដោះប្រស្នាមិនរួចមិនអាចស៊ីវាបានទេ ។ ដោយភាពងឹតល្ងង់ ក្អែកមិនអាចដោះប្រស្នារួចឡើយ ហើយក៏ខានបានស៊ីដង្កូវនោះទៅ ។

ខ. ចូរពន្យល់ពាក្យ "ប្រស្នា បម្រុង"

**សំណួរ**

១. តើក្អែកបម្រុងស៊ីសត្វអ្វី?

២. តើដង្កូវធ្វើដូចម្ដេច?

៣. តើក្អែកបានស៊ីដង្កូវដែរឬទេ? ព្រោះអ្វី?

បន្តទៅទំព័របន្ទាប់

លេខ ៧ង

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សសរសេរពាក្យ ដែលគ្រូហៅនៅលើក្ដារឆ្នួន តាមខ្លឹមសារកំណត់ខាងលើ។

☑ សិស្សសរសេរបញ្ចប់ពាក្យផ្សំលើក្ដារឆ្នួន បន្ទាប់ពីស្ដាប់ព្យាង្គដំបូងនៃពាក្យ ។

ឧទាហរណ៍ :

គ្រូថា រុង .... សិស្សសរសេរ រុងរឿង

គ្រូថា អៀន .... សិស្សសរសេរ អៀនខ្មាស

គ្រូថា ថៃ ..... សិស្សសរសេរ ថៃរក្សា

គ្រូថា លាត ..... សិស្សសរសេរ លាតសន្ធឹង

គ្រូថា ស្លន់..... សិស្សសរសេរ ស្លន់ស្លោ

☑ សិស្សចម្លងពាក្យពីលើក្ដារខៀនដាក់ក្នុងសៀវភៅសរសេររៀងខ្លួន តាមការហៅរបស់គ្រូ ។

☑ សិស្សក្នុងក្រុម**ក**ដែលមានគ្នា៥នាក់និងក្រុម**ខ**ដែលមានគ្នា៥នាក់សរសេរពាក្យចំនួន៥ពាក្យក្នុងមួយក្រុមៗតាមការជ្រើសរើសរបស់ក្រុមនីមួយៗ រួចដូរគ្នាពិនិត្យនិងកែលម្អគ្នាទៅវិញទៅមក ។ ឯគ្រូជាអ្នកណែនាំនិងសម្របសម្រួលសិស្សតាមក្រុម ។

☑ សិស្សសរសេរពាក្យល្បះឬអត្ថបទតាមការអានរបស់គ្រូដាក់ក្នុងសៀវភៅសរសេររបស់សិស្សរៀងៗខ្លួនបានត្រឹមត្រូវ ។

ឧទាហរណ៍ : ចូរសរសេរតាមអានត្រួតពិនិត្យពាក្យនិងល្បះខាងក្រោម (មេរៀនទី ៦៣) ។

សាមគ្គី រុងរឿង សុខសាន្ត ជីវភាព សមរម្យ ភូមិខ្ញុំមានវាលស្រែធំល្វឹងល្វើយ ផ្លូវថ្នល់ស្អាតមានសាលារៀន មន្ទីរពេទ្យ និងវត្តអារាម ។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



លេខ ១៦



លេខ ១៣



លេខ ១៤

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៧ង

លេខ ៧៥

# សិស្សអាចបង្កើតល្បះនិងតែងល្បះតាមគំនិតច្នៃប្រឌិតរៀងៗខ្លួន

## បំណិនសំណេរពាក់ព័ន្ធ : ការតែងល្បះ

សូមមើល មេរៀនទី ៦៣-៧១ (ទំព័រទី ១២៥-១៥១)

### ខ្លឹមសារ

- ពាក្យទាំងឡាយដែលមានក្នុងមេរៀនទី៦៣-៧១ ។
  លំហាត់តារាងផ្នែក**ក**និង**ខ**ក្នុងសៀវភៅភាសាខ្មែរអាន-សរសេរថ្នាក់ទី២មេរៀនទី៦៩ទំព័រទី១៣០ ។ លំហាត់សំណេរតែងល្បះ នឹងពាក្យទំព័រទី១៣៣ចំណុចខ ។

### សកម្មភាពគំរូ

☑ សិស្សគូសភ្ជាប់ឃ្លាក្នុងតារាង**ក**ទៅតារាង**ខ**ឱ្យបានត្រឹមត្រូវតាមការកំណត់របស់គ្រូ ។

ឧទាហរណ៍ : ចូរគូសភ្ជាប់តារាង"**ក**"និងតារាង"**ខ**"ខាងក្រោមឱ្យបានត្រឹមត្រូវ ។

| ផ្នែក "**ក**" | ផ្នែក "**ខ**" |
|---|---|
| ១. ជាទម្លាប់ ស្មាតែងដាក់ | ក. នាំឱ្យកើតជំងឺ ។ |
| ២. ការផឹកទឹកកខ្វក់ | ខ. ទឹកឆ្អិនក្នុងដបយកទៅផឹក ។ |

☑ សិស្សតែងល្បះដោយប្រើពាក្យមួយចំនួនរបស់គ្រូទៅតាមគំនិតរៀងៗខ្លួនបានត្រឹមត្រូវ ។

ឧទាហរណ៍ : ចូរតែងល្បះដោយប្រើពាក្យ

| **ភូមិ** | **ថៃរក្សា** | **ប្រជាជន** | **វារ** |
|---|---|---|---|

-ផ្ទះខ្ញុំសង់នៅកណ្ដាល***ភូមិ*** ។

-សុខា ***ថៃរក្សា*** សៀវភៅវា ។

-នៅភូមិរបស់ខ្ញុំមាន ***ប្រជាជន*** ច្រើន ។

-ស្រមោច***វារ***តាងឡើងមែកឈើ ។

បន្តទៅទំព័របន្ទាប់

លេខ ៧៥

**បន្ត...**

## សកម្មភាពគំរូ

☑ សិស្សលេងល្បែងសិក្សាបង្កើតល្បះដោយប្រើបណ្ណពាក្យដែលគ្រូផលិតយ៉ាង តិចពី៣-៥បណ្ណពាក្យដើម្បីបង្កើតល្បះពេញលេញ ។ ដូចនេះគ្រូគួរធ្វើឬផលិតបណ្ណពាក្យទាំងនេះយ៉ាងតិចពី៥ទៅ១២បណ្ណពាក្យសម្រាប់ឱ្យសិស្សធ្វើលំហាត់ ។ គ្រូអាចប្រើបណ្ណពាក្យឬសរសេរពាក្យទាំងនេះ នៅលើក្តារខៀន ។

ឧទាហរណ៍: ចូររៀបបណ្ណពាក្យខាងក្រោមដើម្បីបង្កើតល្បះពេញលេញត្រឹមត្រូវ។

| | | | | | |
|---|---|---|---|---|---|
| ប្រជាជន | ភូមិ | សុខ | ណាស់ | ខ្ញុំ | រុងរឿង |

| | | | | |
|---|---|---|---|---|
| មាន | ភូមិ | ខ្ញុំ | ជីវភាព | សមរម្យ |

**ចម្លើយរំពឹងទុក :**

១. ភូមិខ្ញុំសុខសាន្ត ។
២. ភូមិខ្ញុំជាភូមិរុងរឿង ។
៣. ភូមិខ្ញុំឈ្មោះភូមិរុងរឿង ។
៤. ខ្ញុំស្រឡាញ់ភូមិខ្ញុំណាស់ ។
៥. ប្រជាជនមានជីវភាពសមរម្យ ។

☑ សិស្សបំពេញសាច់រឿងដោយប្រើប្រាស់ពាក្យពីមេរៀនដែលបានរៀនរួចហើយ ។ សិស្សត្រូវអានផ្នែកផ្សេងៗនៃសាច់រឿងដែលមានស្រាប់បន្ទាប់មក សរសេរគំនិតផ្ទាល់ខ្លួនអំពីរបៀបដែលសាច់រឿងគួរចាប់ផ្តើមនិងបញ្ចប់។ លំហាត់នេះតម្រូវឱ្យសិស្សទស្សន៍ទាយហេតុការណ៍ និងសកម្មភាពបន្ទាប់មកបង្ហាញគំនិតទាំងនោះទៅក្នុងសំណេររបស់ខ្លួន ។

បន្តទៅទំព័របន្ទាប់

លេខ ៧ច

## បន្ត...

## សកម្មភាពគំរូ

### ការត្រៀមខ្លួនសម្រាប់រដូវភ្លៀង



រដូវប្រាំងទើបបញ្ចប់ដូច្នេះ ម្តាយរបស់សុខាបានប្រាប់នាងឱ្យត្រៀមខ្លួន ចំពោះភ្លៀងធ្លាក់មុនចេញទៅសាលារៀន ។

→

↓

សុខា ហៀបនឹងជឿតាមមិត្តរបស់នាង ដែលថានាងមិនចាំបាច់យកឆត្រទៅជាមួយទេ ពីព្រោះរដូវភ្លៀងមិនទាន់មកដល់នៅឡើយ ប៉ុន្តែជាធម្មតា ម្តាយរបស់នាងគិតត្រូវ ។

←

↓

→

ខណៈដែលមិត្តរបស់នាងបានរត់សំដៅទៅផ្ទះពេលកំពុងភ្លៀង សុខាបានរីករាយក្នុងចិត្ត ព្រោះខ្លួនបាន ស្តាប់សម្តីម្តាយក្នុងការយកឆត្រមកជាមួយ។ នាងមិនទទឹកភ្លៀងឡើយ នៅពេលទទួរឆត្រ ។

### ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ

↓



លេខ ១០



លេខ ១១



### ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៧ច

លេខ ៧៨

# សិស្សអាចសរសេរតួអក្សរផ្ចង់អំពីពាក្យបានស្អាតល្អ

**បំណិនសំណេរពាក់ព័ន្ធ : សរសេរអក្សរផ្ចង់**

សូមមើល មេរៀនទី ៦៣-៧១ (ទំព័រទី ១២៥-១៥១) →

## ខ្លឹមសារ

- អក្សរផ្ចង់អំពីពាក្យ : "រុងរឿង អនាម័យ លលក ថៃទាំ សារភាព"

## សកម្មភាពគំរូ

☑ សិស្សសរសេរអក្សរផ្ចង់អំពីពាក្យ "លលក" បានស្អាតល្អតាមទម្រង់អក្សរជ្រៀងនិងតាមការណែនាំគំរូអំពីរបៀបគូសសរសេរលើក្តារខៀន ក្តារឆ្នួននិងក្នុងសៀវភៅសរសេររៀងៗខ្លួនបានត្រឹមត្រូវ ។

ឧទាហរណ៍ :




☑ សិស្សសរសេរអក្សរផ្ចង់អំពីពាក្យណាមួយដែលគេស្រឡាញ់ហើយរើសចេញពីបញ្ជីពាក្យត្រូវនឹងទម្រង់និងទំហំតាមការកំណត់របស់គ្រូ ។

ឧទាហរណ៍ : *សប្បាយ វាល ចុកពោះ ចាប បបួល*..។

☑ សិស្សចម្លងអក្សរផ្ចង់អំពីពាក្យណាមួយដែលគេពេញចិត្តហើយសរសេរពាក្យដដែលនោះឱ្យបានច្រើនដង (៣ដង) និងច្រើនបន្ទាត់ (៣បន្ទាត់) ។

ឧទាហរណ៍ :






**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូម

ហ្វឹកហាត់ផ្ទាល់ក្នុងថ្នាក់

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**

↓

*គ្រូអាចរកសម្ភារៈផ្សេងៗដូចជា : ក្តារឆ្នួនមានក្រឡា ផ្ទាំងក្រដាសក្រឡាអ៊ិត...។*




**ដំណាក់កាលទី ៧ ត្រូវបានបញ្ចប់ហើយ!**

សូមធ្វើតេស្តសិស្សដោយប្រើ

<u>តេស្តដំណាក់កាលទី ៧</u>

នៃឧបសម្ព័ន្ធ ៣ នៅក្នុងសៀវភៅនេះ

ទំព័រទី ១៨៥

# ដំណាក់កាលទី ៨ : មេរៀនទី ៧២-៨១ (៩)

**(ទំព័រ ១៥២ ដល់១៨០)**

-**អំណាន និងសំណេរ** : អត្ថបទ និងកំណាព្យអំពី

*១. មេរៀនទី ៧២ : ច្បារដំណាំ (កំណាព្យ)*

*២. មេរៀនទី ៧៣ : ផ្សារភូមិខ្ញុំ*

*៣. មេរៀនទី ៧៥ : រឿងមេក្រូច និងពស់*

*៤. មេរៀនទី ៧៦ : ក្មេងសុចរិត*

*៥. មេរៀនទី ៧៧ : ជីដូនជីតា*

*៦. មេរៀនទី ៧៨ : សេចក្តីជូនដំណឹង*

*៧. មេរៀនទី ៧៩ : រឿងសត្វត្មាត*

*៨. មេរៀនទី ៨០ : ថ្ងៃបុណ្យចូលឆ្នាំ*

*៩. មេរៀនទី ៨១ : បុណ្យភ្ជុំបិណ្ឌ*

*(សប្តាហ៍ទី ៣ ខែ មិថុនា ដល់ សប្តាហ៍ទី ៤ ខែ កក្កដា)*

*( ៧០ម៉ោង / ៥,៣៨ សប្តាហ៍)*

*__កំណត់សម្គាល់ :__ (៩) ចំពោះមេរៀនទី៧៤សមត្ថភាពនិយាយមានចំនួន៦ម៉ោងសិក្សា។ មេរៀននេះមិនទាក់ទងស្តង់ដាអំណានទេគ្រូត្រូវបង្រៀនធម្មតា ។*

លេខ ៨ក

# សិស្សអាចអានពាក្យក្នុងមេរៀនដោយផ្សំនិងប្រកប

ឧទាហរណ៍ :បន្លែ អានថា បន់- លែ

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់តួអក្សរនិងសូរ**

សូមមើល មេរៀនទី ៧២-៨១ (ទំព័រទី ១៥២-១៨០)

## ខ្លឹមសារ

- សូមស្រង់ពាក្យក្នុងមេរៀនទី៧២-៨១ ដូចខាងក្រោម ៖

**មេរៀនទី៧២** : ឥឡូវ

**មេរៀនទី៧៣** : បន្លែ តម្រូវ

**មេរៀនទី៧៥** : ព័ទ្ធ រន្ធ សម្លឹង

**មេរៀនទី៧៦** : សុចរិត អាទិត្យ

**មេរៀនទី៧៧** : ជរា វ៉ៃយ សូត្រ

**មេរៀនទី៧៨** : ប្រយ័ត្ន បក្សី សម្ភារៈ ចម្អិន

**មេរៀនទី៧៩** : ចិញ្ចឹម សម្លាប់

**មេរៀនទី៨០** : ចង្អាន់ អង្គញ់ ប្រជាប្រិយ ព្រ័ត្រ

**មេរៀនទី៨១** : ភ្នំបិណ្ឌ ភទ្របទ កុសល ព្រះសង្ឃ

## សកម្មភាពគំរូ

☑ សិស្សមើលបញ្ជីពាក្យដែលព្យាង្គមួយចំនួនរបស់ពាក្យនីមួយៗត្រូវបានលុបចេញ ។ សិស្សត្រូវអានពាក្យដែលមិនពេញលេញនោះ រួចហើយសរសេរបំពេញព្យាង្គដែលបាត់ ។ អត្ថន័យនៃពាក្យត្រូវបានផ្ដល់ជូនដើម្បីជួយសិស្សឱ្យដឹងអំពីអ្វីដែលត្រូវបំពេញបានជាពាក្យត្រឹមត្រូវមួយ ។

ឧទាហរណ៍ :

ឥ +_____ : វេលានេះ ។

_____ + ច + រិត: ការប្រព្រឹត្តល្អ ។

ជី +_____ + ជី + តា: យាយតា ។

ពិ+ ចា+ រ +____ : ការត្រិះរិះ រំពឹងគិត ការគិតហ្មត់ចត់ ។

ប្រ+ ជា+____ : ដែលជាទីស្រឡាញ់ពេញចិត្តរបស់ប្រជាជន ។

បន្តទៅទំព័របន្ទាប់

លេខ ៨ក

## បន្ត...

### សកម្មភាពគំរូ

☑ គ្រូសរសេរឈ្មោះរបស់ពាក្យនៅលើក្តារខៀនដែលព្យាង្គនីមួយៗត្រូវបានសរសេរទៅតាមសូរពេញលេញ (អំណានពាក្យ) ប៉ុន្តែមិនមែនសរសេរទៅតាមពាក្យត្រឹមត្រូវពិតប្រាកដនោះទេ ។ គ្រូឱ្យសិស្សសរសេរពាក្យត្រឹមត្រូវពិតប្រាកដដោយមុនដំបូងសិស្សត្រូវអានព្យាង្គនីមួយៗសិន ។

ឧទាហរណ៍ :

បន់ - លែ៉ ត្រូវសរសេរដូចតទៅ: ______*បន្លែ*______________

សំ- ឡឹង ត្រូវសរសេរដូចតទៅ: ______________________

សុ - ចៈ - រិត ត្រូវសរសេរដូចតទៅ: ______________________

សំ - ភា - រាក់ ត្រូវសរសេរដូចតទៅ: ______________________

ភ័ត - ទ្រៈ - បុត ត្រូវសរសេរដូចតទៅ: ______________________

បន្តទៅទំព័របន្ទាប់ →

លេខ ៨ក

**បន្ទ...**

## សកម្មភាពគំរូ

☑ គ្រូផ្តល់បញ្ជីពាក្យឱ្យសិស្ស ។ សិស្សត្រូវសរសេរចំនួនព្យាង្គដែលពួកគេបានឮក្នុងពាក្យនីមួយៗ ដាក់ក្នុងប្រអប់ទំនេរ ។

| ល្បែងរកចំនួនព្យាង្គ | | | | | | |
|---|---|---|---|---|---|---|
| ឈ្មោះសិស្ស : ________________ ថ្ងៃទី : ________________ | | | | | | |
| **ចូរហ្វឹកហាត់រកព្យាង្គក្នុងពាក្យខាងក្រោម ។** តើមានចំនួនព្យាង្គប៉ុន្មាននៅក្នុងពាក្យនីមួយៗ? អ្នកអាចរាប់ចំនួនព្យាង្គដោយសរសេរព្យាង្គនីមួយៗដែលអ្នកអានដាក់ក្នុងប្រអប់ទំនេរ។ ល្បែងនេះជួយយើងក្នុងការទះដៃនៅពេលអានព្យាង្គនីមួយៗ ។ | | | | | | |
| ពាក្យ | ព្យាង្គទី ១ | ព្យាង្គទី ២ | ព្យាង្គទី ៣ | ព្យាង្គទី ៤ | ព្យាង្គទី ៥ | តើមានចំនួនព្យាង្គប៉ុន្មាន? |
| ១.ជីដូនជីតា | ជី | ដូន | ជី | តា | | ៤ |
| ២.ឥឡូវ | | | | | | |
| ៣.ប្រជាប្រិយ | | | | | | |
| ៤.ប្រពៃណី | | | | | | |
| ៥.ពិចារណា | | | | | | |
| ៦.សម្ភារៈ | | | | | | |

☑ សិស្សអានពាក្យដោយការញែកព្យាង្គរបស់ពាក្យនីមួយៗហើយថាតាមបន្តគ្នាម្តងម្នាក់ឬថាតាមជាក្រុមតូចៗរហូតដល់ចប់ពាក្យនីមួយៗ តាមការពន្យល់របស់គ្រូនៅលើក្តារខៀន ។

ឧទាហរណ៍ : គ្រូសរសេរពាក្យ **សុចរិត** នៅលើក្តារខៀនរួចនាំសិស្សអាន ៖

-គ្រូថា **សុ (សុ)**
-សិស្សទី១ ថា **ច (ចះ)**
-សិស្សទី២ ថា **រិត (រ៉ិត)**

បន្តទៅទំព័របន្ទាប់

## លេខ ៨ក

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សអានពាក្យដោយការញែកព្យាង្គរបស់ពាក្យតាមការហៅរបស់គ្រូនៅលើក្ដារខៀនរួចអានព្យាង្គទី១ក្នុងពាក្យនោះ ។ បន្ទាប់មកសិស្សម្នាក់ទៀតនៅខាងស្ដាំដៃគេអានព្យាង្គមួយទៀតបន្តធ្វើបែបនេះរហូតដល់ចប់ពាក្យនីមួយៗ ។

ឧទាហរណ៍ :

-សិស្សទី១អានថា **សុ** (សុ)

-សិស្សខាងស្ដាំដៃទី១អានថា **ច** (ចៈ)

-សិស្សបន្ទាប់ពីស្ដាំដៃទី១អានថា **រិត** (រិុត)

☑ គ្រូនាំសិស្សលេងល្បែងទះដៃដើម្បីកំណត់ចំនួនព្យាង្គរបស់ពាក្យក្នុងការអានពាក្យ ២ព្យាង្គ ៣ព្យាង្គឬច្រើនព្យាង្គដោយឱ្យសិស្សជ្រើសរើសពាក្យធ្លាប់រៀន ឬចេះចាំដោយខ្លួនឯង ។

ឧទាហរណ៍ : គ្រូទះដៃតាមចំនួនព្យាង្គរបស់ពាក្យ ២ឬ៣ដងសិស្សត្រូវថាពាក្យនោះដោយប្រកបឱ្យបាន ពីរព្យាង្គ បីព្យាង្គ ។

-ទះដៃពីរដង : ចិញ្ចឹម សម្លាប់ ប្រយ័ត្ន...(ពាក្យពីរព្យាង្គ) ។

-ទះដៃបីដង : ភទ្របទ សម្ភារៈ មរណៈ ប្រជាប្រិយ...(ពាក្យបីព្យាង្គ) ។

-ទះដៃបួនដង : ជីដូនជីតា អនិច្ចកម្ម ពិចារណា ...(ពាក្យបួនព្យាង្គ) ។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



លេខ ១០



លេខ ១១



លេខ ១៤

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៨ក

# លេខ ៨ខ សិស្សអាចពន្យល់ពាក្យពិបាក ពាក្យន័យដូច និងពាក្យផ្ទុយ

**បំណិនអំណានពាក់ព័ន្ធ : ការចេះវាក្យសព្ទ**

សូមមើល មេរៀនទី ៧២-៨១ (ទំព័រទី ១៥២-១៨០)

## ខ្លឹមសារ

- សូមមើលនិងស្រង់ពន្យល់ពាក្យ ពាក្យផ្ទុយ ពាក្យន័យដូច ក្នុងមេរៀនទី ៧២-៨១ ៖

**ពន្យល់ពាក្យ**

**មេរៀនទី៧២ :** ច្បារ

**មេរៀនទី៧៣ :** ទំនិញ អ្នកភូមិ

**មេរៀនទី៧៥ :** ព័ទ្ធ វន្ទ

**មេរៀនទី៧៦ :** សុចរិត ស្និត

**មេរៀនទី៧៧ :** ជរា វ័យ

**មេរៀនទី៧៨ :** ប្រយ័ត្ន សម្ភារៈ បក្សី

**មេរៀនទី៧៩ :** សម្លាប់ ពិចារណា

**មេរៀនទី៨០ :** ចង្អាន់ ប្រជាប្រិយ

**មេរៀនទី៨១ :** បិណ្ឌ កុសល

**ពាក្យន័យដូច**

**មេរៀនទី៧២ : រួតរះ** ម៉ឺម្នា រវៀស ប្រញាប់ រួសរាន់

**មេរៀនទី៧៥ : ជូន** ឱ្យ ប្រគល់ ថ្វាយ ប្រគេន

**មេរៀនទី៧៦ : សុចរិត** ទៀងត្រង់ ស្មោះត្រង់

**មេរៀនទី៧២ : ជរា** ចាស់ ចំណាស់ ទ្រុឌទ្រោម

**មេរៀនទី៧៨ : ប្រកាស** ប្រាប់ ផ្សព្វផ្សាយ ជូនដំណឹង

**មេរៀនទី៧៩ : សម្លាប់** ពិឃាដ ធ្វើគុត ប្រល័យ ប្រហារ

**មេរៀនទី៨០ : ខ្មៀវខ្មារ** អ៊ូអរ អឹងកង កងរំពង

**មេរៀនទី៨១ : ចែកឋាន** ស្លាប់ ងាប់ មរណៈ អនិច្ចកម្ម

**ពាក្យផ្ទុយ**

**មេរៀនទី៧៣ :** ថោក ≠ ថ្លៃ
តូច ≠ ធំ

**មេរៀនទី៧៥ :** ខ្ទី ≠ សង
ស្រេកឃ្លាន ≠ ឆ្អែតឆ្អន់

**មេរៀនទី៧៧ :** មាំមួន ≠ ទន់ខ្សោយ

**មេរៀនទី៧៨ :** ឆ្អិន ≠ ឆៅ
ប្រយ័ត្ន ≠ ធ្វេសប្រហែស

**មេរៀនទី៧៩ :** អង្វរ ≠ សម្លុត
ជរា ≠ មាំមួន

**មេរៀនទី៨០ :** ខ្មៀវខ្មារ ≠ ស្ងាត់ជ្រងំ

បន្តទៅទំព័របន្ទាប់

លេខ ៨ខ

## បន្ត...

### សកម្មភាពគំរូ

☑ គ្រូបង្ហាញរូបភាពនិងផ្តល់បញ្ជីពាក្យដល់សិស្ស ។ ពាក្យមួយចំនួនមាននៅក្នុងរូបភាព និងមួយចំនួនទៀតមិនមានក្នុងរូបភាពនោះទេ ។ គ្រូឱ្យសិស្សគូសរង្វង់ជុំវិញពាក្យនីមួយៗដែលពួក គេអាចមើលឃើញក្នុងរូបភាព ។



<u>បញ្ជីពាក្យ</u>

***សេចក្តីណែនាំ :*** សូមគូសរង្វង់ជុំវិញពាក្យដែលអ្នកអាចមើលឃើញក្នុងរូបភាព។

១. តា ២. ភ្នំ ៣. ដើមឈើ ៤. សាលារៀន ៥. វត្ត ៦. ក្លោងទ្វារ ៧. របងវត្ត ៨. សត្វមាន់ ៩. ចេតីយ ១០. ឈើច្រត់ ១១. រថភ្លើង

☑ គ្រូរៀបចំលំហាត់មួយដែលសិស្សអាចបង្កើតឃ្លាខ្លីៗដើម្បីបំពេញន័យរបស់ពាក្យកាន់តែច្បាស់ឡើង ។ ប៉ុន្តែលំហាត់នេះត្រូវមានលក្ខណៈពិសេស ដែលសិស្សអាចលេងជាមួយសូរដើមនៃពាក្យដែលបានផ្តល់ឱ្យ ។ ពោលគឺឃ្លានីមួយៗអាចមានពាក្យដែលចាប់ផ្តើមដោយសូរដូចគ្នា ។ ប៉ុន្តែឃ្លាដែលបង្កើតដោយសិស្សត្រូវមានន័យសមស្រប។ សូមមើលបញ្ជីពាក្យខាងក្រោម :

ឧទាហរណ៍ : បាត្រ សម្លូត ទាញព្រ័ត្រ ប្រជាប្រិយ សម្លាប់ បន្លែ ទៀងត្រង់ ប្រពៃណី ជរា ប្រស្នា បិណ្ឌ ទេវតា ជីដូនជីតា បរិភោគ រូតរះ ប្រយ័ត្ន

**ឃ្លាដែលអាចបង្កើតបានមាន ៖** ប្រស្នាប្រជាប្រិយ ជីដូនជីតាជរា ។ល។

បន្តទៅទំព័របន្ទាប់

លេខ ៨ខ

## បន្ត...

### សកម្មភាពគំរូ

☑ គ្រូឱ្យសិស្សប្រៀបធៀបដើម្បីបញ្ជាក់អត្ថន័យនៃពាក្យ ។

ឧទាហរណ៍ :

ខ្លាំង ដូច ......*សេះ*......

ខ្សោយ ដូច .............

ចាស់ ដូច ...........

ល្អ ដូច ............

ថោក ដូច ...........

ស្ងាត់ ដូច ............

រហ័ស ដូច ...........

លឿន ដូច .............

☑ សិស្សគូសរង្វង់ជុំវិញ ពាក្យន័យដូច និងពាក្យផ្ទុយតាមតារាងពាក្យដែលគ្រូកំណត់

ឧទាហរណ៍ :

| គូសរង្វង់ពាក្យន័យដូច | គូសរង្វង់ពាក្យន័យដូច | គូសរង្វង់ពាក្យផ្ទុយ |
|---|---|---|
| វួតរះ | កំសាក | ថ្ងៃ |
| ឧស្សាហ៍ | សុចរិត | ថ្លៃ |
| ម្ទីម្នា | ស្រេចឃ្លាន | ស្ងួត |
| ចំណាយ | ទំនិញ | ថោក |
| សម្លឹង | ស្មោះត្រង់ | ខ្វី |

បន្តទៅទំព័របន្ទាប់

លេខ ៨២

**បន្ត...**

## សកម្មភាពគំរូ

☑ សិស្សផ្គូផ្គងពាក្យពិបាកទៅនឹងន័យរបស់វាបានត្រឹមត្រូវតាមការកំណត់របស់គ្រូ

ឧទាហរណ៍ : តារាងផ្គូផ្គងពាក្យពិបាកទៅនឹងនិយមន័យ :

| ពាក្យពិបាក | និយមន័យ |
|---|---|
| ប្រយ័ត្ន | |
| **ពិចារណា** → | ការត្រិះរិះ រំពឹងគិត ការគិតហ្មត់ចត់ ។ |
| កងរំពង | |
| កុសល | |
| ចិញ្ចឹម | ដែលជាទីស្រឡាញ់ពេញចិត្តរបស់ប្រជាជន ។ |
| **ប្រជាប្រិយ** → | |
| **ជរា** → | |
| វ័យ | ចំណាស់ សេចក្ដីគ្រាំគ្រា ទ្រុឌទ្រោម ។ |
| ស្ងាត់ជ្រងំ | |

☑ សិស្សជ្រើសរើសពាក្យក្នុងប្រអប់ខាងក្រោមដែលមានន័យដូចគ្នានឹងពាក្យក្នុងល្បះ ឬអត្ថបទមកបំពេញបានត្រឹមត្រូវ ។

ឧទាហរណ៍ : *ជីដូនជីតា*(១) ខ្ញុំមានវ័យចាស់ជរាទៅហើយ ។

ព្រឹកនេះ*ឪពុកម្ដាយ* (២) ខ្ញុំនិងខ្ញុំយក*នំចំណី* (៣) *ផ្លែឈើ* (៤) ទៅជូនគាត់ ។ យើងសប្បាយ*រីករាយ*(៥)ណាស់នៅពេលទៅដល់*ផ្ទះគាត់*(៦) ព្រោះបានជួប*លោកទាំងពីរ*(៧) ។ គាត់បាន*អង្អែល*(៨)និង*ឱប*(៩)ខ្ញុំ ។

| |
|---|
| ឪពុកម្ដាយ អ៊ំ ពូ មីង បងប្រុស ស្រី ចិត្ត សម្លៀកបំពាក់ ស្រុក ភូមិ ឪពុកម្ដាយ អ៊ំ ពូ មីង សរសើរ ស្រឡាញ់ ម្ហូបអាហារ គ្រឿងប្រើប្រាស់ |

**ចម្លើយ :** (១).ឪពុកម្ដាយ អ៊ំ ពូ មីង (២).បង ប្រុស ស្រី (៣).ម្ហូបអាហារ គ្រឿងប្រើប្រាស់ (៤).សម្លៀកបំពាក់ (៥).ចិត្ត (៦).ស្រុក ភូមិ (៧).ឪពុកម្ដាយ អ៊ំ ពូ មីង (៨).សរសើរ (៩).ស្រឡាញ់ ។

បន្តទៅទំព័របន្ទាប់

## លេខ ៨ខ

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សផ្គុំព្យញ្ជនៈនិងព្យាង្គក្នុងតារាងដោយគូសរង់ជុំវិញបានជាពាក្យដែលមានន័យដូចបានត្រឹមត្រូវ ។ ឧទាហរណ៍ :

| | | | | | | | |
|---|---|---|---|---|---|---|---|
| ផ | ជូ | ន | ខ្សៀ | វ | ខ្វ | ◌ា | រ |
| ម | ◌្យ | ជ | រា | ង់ | ចា | ស់ | ◌ូ |
| រ | ឈ | ព | ត | សុ | ច | រិ | ត |
| ណៈ | ក | ◌្រ | ◌ូ | បុ | ប្ផា | ប់ | រ |
| ក | ង | ប | ◌ឺ | ផ | ញា | ហ | ◌ះ |
| ទៀ | រំ | គ | ជ | ប | ◌្យ | ផ្ក | អ |
| ច | ព | ល់ | ◌្រ | ប | ក | ◌ា | ស |
| យ | ង | ែ◌ | ច | ក | ឋា | ន | យ |

**ចម្លើយ :**

រូតរះ- ប្រញាប់,
ផ្កា-បុប្ផា,
ប្រកាស-ផ្សព្វផ្សាយ,
ជរា-ចាស់,
ជូន-គល់,
សុចរិត- ទៀងត្រង់,
ខ្សៀវខ្វារ- កងរំពង,
ចៃកឋាន- មរណៈ

☑ សិស្សផ្គុំព្យញ្ជនៈ ស្រៈ និងព្យាង្គក្នុងតារាងដោយគូសរង់ជុំវិញជាពាក្យផ្ទុយបានត្រឹមត្រូវ ។ ឧទាហរណ៍ :

| | | | | | | |
|---|---|---|---|---|---|---|
| ៃ◌ | ឆ្អ | ត | ឆ្អ | ន់ | ច | ស |
| ទ | ន់ | ខ្សោ | យ | តូ | ហែ | ង |
| អ | ង្វ | រ | ◌្រ | ប | យ័ | ត្ន |
| ៃ◌ | ថ្ល | ◌ិ | ◌្រ | ក | អូ | ប |
| េ◌ | ◌្រ | ស | ក | ឃ្ល | ◌ា | ន |
| ធំ | ធ្វ | ម្ល | ថោ | ក | មួ | ភ |
| េ◌ | ខ្វី | ត | គ | មាំ | ស្អ | យ |

**ចម្លើយ :**

ក្រអូប ≠ ស្អុយ, តូច ≠ ធំ
ខ្វី ≠ សង, ថ្លៃ ≠ ថោក
អង្វរ ≠ សម្លុត
មាំមួន ≠ ទន់ខ្សោយ
ស្រេចឃ្លាន ≠ ឆ្អែតឆ្អន់
ប្រយ័ត្ន ≠ ធ្វេសប្រហែស

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



លេខ ១៦



លេខ ១៣



លេខ ១៤



លេខ ១៥



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៨ខ

លេខ ៨គ

# សិស្សអាចអានពាក្យក្នុងមេរៀនដោយមិនបាច់ផ្សំ និងប្រកប

**បំណិនអំណានពាក់ព័ន្ធ : ការចេះអានស្ទាត់**

សូមមើល មេរៀនទី ៧២-៨១ (ទំព័រទី ១៥២-១៨០)

## ខ្លឹមសារ

- សូមស្រង់ពាក្យក្នុងមេរៀនទី៧២-៨១ ដូចខាងក្រោម ៖

**មេរៀនទី៧២ :** ដង្កូវ ផ្លែផ្កា ចិញ្ចឹម ស្រោចទឹក ល្អី ច្បារ ដណ្ដើម ជ្រួយ

**មេរៀនទីទី៧៣ :** ទំនិញ តម្រូវការ ភាគច្រើន កន្លែង អ្នកភូមិ សម្រាប់ ផ្សារ

**មេរៀនទីទី៧៥ :** កន្លែង វន្ត ស្រេក ឃ្លាន សួស្ដី សម្បុក រុំព័ទ្ធ សម្លឹង

**មេរៀនទីទី៧៦ :** អាទិត្យ ម្ដាយ សុចរិត មៀន គីឡូក្រាម ក្រដាស ទៀងត្រង់

**មេរៀនទី៧៧ :** ជីដូនជីតា ជរា ម្ដាយ ឪពុក ឱប អង្អែល មាំមួន វ័យ ចំណាស់ ទូន្មាន ស្រឡាញ់

**មេរៀនទី៨១ :** ព្រះសង្ឃ ភ្នំបិណ្ឌ កុសល បាត្រ ប្រពៃណី ភទ្របទ ចង្ហាន់

## សកម្មភាពគំរូ

☑ សិស្សអានពាក្យដោយមិនបាច់ផ្សំនិងប្រកបបានយ៉ាងលឿនតាមការកំណត់របស់គ្រូ ឬតាមបញ្ជីពាក្យក្នុងលំហាត់ ។ ឧទាហរណ៍ : *ដង្កូវ ផ្លែផ្កា ចិញ្ចឹម ស្រោចទឹក ល្អី ច្បារ ដណ្ដើម ជ្រួយ ជីដូនជីតា ជរា ម្ដាយ អង្អែល មាំមួន វ័យ ទូន្មាន ស្រឡាញ់ ។ (ទំព័រ ១៥៣,១៦៧ )*

☑ សិស្សមើលបញ្ជីពាក្យដែលគ្រូសរសេរនៅលើក្ដារខៀន ។ បន្ទាប់មកគ្រូឱ្យសិស្សពីរនាក់អានប្រណាំងគ្នាតាមបញ្ជីពាក្យនោះឱ្យបានលឿនបំផុតដោយមិនបាច់ផ្សំនិងប្រកបតាមដែលអាចធ្វើទៅបាន។ សិស្សណាអានបានគ្រប់ពាក្យបានត្រឹមត្រូវហើយចប់មុនគេសិស្សនោះជាអ្នកឈ្នះ ។ ឧទាហរណ៍ : *ដង្កូវ ផ្លែផ្កា ចិញ្ចឹម ស្រោចទឹក ជីដូនជីតា ជរា ម្ដាយ អង្អែល មាំមួន វ័យ ទូន្មាន ស្រឡាញ់ ។ (ទំព័រ ១៥៣,១៦៧ )*

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



លេខ ១០



លេខ ១១



លេខ ១៤



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ តេស្តដំណាក់កាលទី ៨គ

លេខ ៨យ

# សិស្សអាចបកស្រាយន័យរបស់វគ្គនៃកំណាព្យ និងអត្ថបទមេរៀនតាមរយៈលំហាត់ផ្សេងៗ

## ឧទាហរណ៍ :ជ្រើសរើសពាក្យចូនដើម្បីបំពេញវគ្គនៃកំណាព្យ

**បំណិនអំណានពាក់ព័ន្ធ : ការចេះវាក្យសព្ទ**

**: ការអានដើម្បីយល់ន័យ**

សូមមើល មេរៀនទី ៧២-៨១ (ទំព័រទី ១៥២-១៨០)

## ខ្លឹមសារ

♦ សូមដកស្រង់ ល្បះ វគ្គ អត្ថបទ ក្នុងមេរៀនទី៧២-៨១ ៖

"ច្បារដំណាំ ផ្សារភូមិខ្ញុំ រឿងមេក្រួច និងពស់ ក្មេងសុចរិត ជីដូនជីតា សេចក្ដីជូនដំណឹង រឿងសត្វត្មាត ថ្ងៃបុណ្យចូលឆ្នាំ និងបុណ្យភ្ជុំបិណ្ឌ"

## សកម្មភាពគំរូ

☑ សិស្សឆ្លើយនឹងសំណួរក្នុងមេរៀនសៀវភៅសិស្សបានត្រឹមត្រូវ។

**មេរៀនទី៧២ :**

១. តើពល់ល្មាចប៉ាធ្វើអ្វីក្នុងច្បារ?

២. តើនៅក្នុងច្បារមានដំណាំអ្វីខ្លះ?

៣. តើគេប្រើជីអ្វីខ្លះសម្រាប់ដាក់ដំណាំ?

៤. តើគេជួយធ្វើការអ្វីខ្លះ ក្នុងច្បារ?

**មេរៀនទី៧៣ :**

១. តើផ្សារនៅភូមិរបស់អ្នកតូច ឬធំ?

២. តើផ្សារនៅភូមិរបស់អ្នកមានលក់អ្វីខ្លះ?

៣. ហេតុអ្វីបានជាទំនិញនៅផ្សារនេះមានតម្លៃថោក?

**មេរៀនទី៧៥ :**

១. តើមេក្រួចបានឃើញអ្វីនៅជិតសម្បុកវា?

២. តើមេក្រួចប្រើល្បិចដូចម្ដេច ដើម្បីរំដោះខ្លួនឯងនិងកូន?

៣. តើពស់បានស៊ីមេក្រួចនិងកូនក្រួចដែរឬទេ?

៤. តើអ្នកគួរយកតម្រាប់តាមមេក្រួចដែរឬទេ? ព្រោះអ្វី?

បន្តទៅទំព័របន្ទាប់

លេខ ៨យ

បន្ត...

## សកម្មភាពគំរូ

**មេរៀនទី៧៦ :**

១. តើសំណាងទៅផ្សារជាមួយអ្នកណា?

២. តើសំណាងបានសុំម្ដាយទិញអ្វីខ្លះ?

៣. តើសំណាងធ្វើដូចម្ដេច នៅពេលឃើញអ្នកលក់អាប់លុយលើស?

៤. តើអ្នកគិតថា សំណាងជាក្មេងដូចម្ដេច?

**មេរៀនទី៧៧ :**

១. តើជីដូនជីតាគេមានវ័យដូចម្ដេច?

២. តើម្ដាយឪពុកគេយកអ្វីទៅជូនជីដូនជីតា?

៣. តើជីដូនជីតាសាកសួរគេអំពីអ្វី?

៤. ហេតុអ្វីបានជាគេគោរពស្រឡាញ់ជីដូនជីតា?

**មេរៀនទី៧៨ :**

១. តើនរណាជាអ្នកប្រកាសដំណឹង?

២. តើគាត់ប្រកាសដំណឹងប្រាប់នរណាខ្លះ?

៣. តើគាត់ប្រកាសឱ្យប្រុងប្រយ័ត្នដូចម្ដេចខ្លះ?

៤. ហេតុអ្វីបានជាគាត់ប្រកាសដំណឹងនេះ?

**មេរៀនទី៧៩:**

១. តើត្មាតរស់នៅឯណា?

២. តើឪពុកត្មាតមានវ័យដូចម្ដេច?

៣. តើអ្នកណារកស៊ីចិញ្ចឹមត្មាតម្ដាយនិងឪពុក?

៤. តើព្រានពិចារណាដូចម្ដេចខ្លះ ក្រោយពីស្ដាប់សម្ដីត្មាត?

៥. តើប្អូនត្រូវធ្វើដូចម្ដេចចំពោះឪពុកម្ដាយប្អូន ពេលគាត់ចាស់ជរា?

**មេរៀនទី៨០ :**

១. តើបុណ្យចូលឆ្នាំខ្មែរចាប់ផ្ដើមពីថ្ងៃណា?ខែណា?

២. តើនៅតាមផ្ទះនីមួយៗ គេរៀបចំតុបតែងលម្អអ្វីខ្លះ?

៣. តើនៅតាមវត្តនិងផ្ទះ គេនាំគ្នាលេងល្បែងអ្វីខ្លះ?

៤. នៅពេលបុណ្យចូលឆ្នាំថ្មី តើអ្នកចូលចិត្តធ្វើអ្វី?

បន្តទៅទំព័របន្ទាប់

លេខ ៨យ

**បន្ត...**

## សកម្មភាពគំរូ

**មេរៀនទី៨១ :**

១. តើការដាក់បិណ្ឌចាប់ផ្ដើមពីថ្ងៃណាដល់ថ្ងៃណា? ខែណា?

២. តើថ្ងៃណាជាថ្ងៃភ្ជុំបិណ្ឌ?

៣. នៅថ្ងៃភ្ជុំបិណ្ឌ តើមនុស្សម្នាទាំងឡាយធ្វើអ្វីខ្លះ?

៤. តើអ្នកធ្វើអ្វីខ្លះ នៅថ្ងៃភ្ជុំបិណ្ឌ?

☑ សិស្សឆ្លើយសំណួរបន្ថែមរបស់គ្រូទាក់ទងចំណងជើងអត្ថបទ ។

ឧទាហរណ៍ : ចូរប្អូនរកឬប៉ាន់ស្មានចំណងជើងអត្ថបទថ្មីមួយទៀតឱ្យអត្ថបទខាងលើតាមគំនិតផ្ទាល់ខ្លួន ។

**ចម្លើយ :**

**មេរៀនទី៧២ :** ច្បារដំណាំ ⟶ សួនដំណាំ ឬ...

**មេរៀនទី៧៣ :** ផ្សារភូមិខ្ញុំ ⟶ ផ្សារក្នុងភូមិ ឬ...

**មេរៀនទី៧៥ :** រឿងមេក្រួចនិងពស់ ⟶ វិធីការពារខ្លួនពីសត្រូវ ឬ...

**មេរៀនទី៧៦ :** ក្មេងសុចរិត ⟶ ក្មេងស្មោះត្រង់ ឬ...

**មេរៀនទី៧៧ :** ជីដូនជីតា ⟶ យាយតា ដូនតា ឬ...

**មេរៀនទី៧៨ :** សេចក្ដីជូនដំណឹង ⟶ សេចក្ដីប្រកាស ឬ...

**មេរៀនទី៧៩ :** រឿងសត្វត្មាត ⟶ រឿងត្មាត ឬ...

**មេរៀនទី៨០ :** ថ្ងៃបុណ្យចូលឆ្នាំ ⟶ បុណ្យចូលឆ្នាំ ឬ...

**មេរៀនទី៨១ :** បុណ្យភ្ជុំបិណ្ឌ ⟶ ភ្ជុំបិណ្ឌ ឬ...

☑ សិស្សជ្រើសរើសសំណួរដែលត្រូវនឹងចម្លើយដែលគ្រូកំណត់ដោយគូសរង្វង់ជុំវិញលេខសំណួរបានត្រឹមត្រូវ ។

ឧទាហរណ៍ : មេក្រួចភ័យណាស់ព្រោះឃើញពស់សម្លឹងមើលខ្លួនដោយក្ដីស្រេកឃ្លាន ។

**សំណួរ**

១. តើមេក្រួចនៅឯណា?

២. តើមេក្រួចឃើញអ្វី?

៣. ហេតុអ្វីបានជា មេក្រួចខ្លាចពស់? ◯



បន្តទៅទំព័របន្ទាប់ ⟶

លេខ ៨យ

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សប្រាប់ពាក្យចួនក្នុងអត្ថបទកំណាព្យបានត្រឹមត្រូវតាមរយៈឧទាហរណ៍របស់គ្រូនៅលើក្តារខៀនដោយគូសរង់ជុំវិញពាក្យចួននោះ។បន្ទាប់មកសិស្សអនុវត្ត។

រាល់ល្ងាចម៉ោងប្រាំ តាមខ្ញុំចំណាំ ប៉ាចូលក្នុងច្បារ
ស្រោចទឹកបោចស្មៅ ដង្កូវនានា បេះចេញពីផ្កា
មិនឱ្យសល់មួយ ។

.......................... ........................ .......................

**<u>ចម្លើយ :</u>**

វគ្គទី១ -ពាក្យ ប្រាំ ចួននឹងពាក្យ ចំណាំ

-ពាក្យ ច្បារ ចួននឹងពាក្យ នានា ចួននឹងពាក្យ ផ្កា

☑ សិស្សជ្រើសរើសពាក្យក្នុងប្រអប់ដើម្បីបំពេញល្បះបានត្រឹមត្រូវ ។
(មេរៀនទី៧៧និង៨១ ទំព័រទី១៦៨និង១៧១ )

ឧទាហរណ៍ : ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោម ។
(ទំព័រទី១៦៨ ចំណុចខ)

| | | | | |
|---|---|---|---|---|
| ព្រោះ | វ័យ | គោរព | ព្រឹកនេះ | ជរា |

១. ជីដូនជីតាខ្ញុំមានវ័យចាស់...............ណាស់ទៅហើយ ។
២..........ម្តាយឪពុកខ្ញុំនិងខ្ញុំ យកនំចំណី ផ្លែឈើទៅជូនគាត់ ។
៣. ជីដូនជីតា.............ចំណាស់បន្តិចក្តីតែសុខភាពគាត់នៅមាំមួនល្អ ។
៤. ខ្ញុំ...........ស្រឡាញ់ជីដូនជីតាខ្ញុំណាស់.............គាត់តែងតែទូន្មានខ្ញុំឱ្យខិតខំរៀនសូត្រ ។

**ចម្លើយ :**

១. ជរា ២. ព្រឹកនេះ ៣. វ័យ ៤. គោរព ព្រោះ ។

បន្តទៅទំព័របន្ទាប់

លេខ ៨យ

## បន្ត...

### សកម្មភាពគំរូ

☑ សិស្សជ្រើសរើសពាក្យក្នុងប្រអប់ដើម្បីបំពេញក្នុងអត្ថបទបានត្រឹមត្រូវ ។ (មេរៀនទី៧៧ទំព័រ ១៦៨ និងមេរៀនទី៨១ទំព័រទី១៨០ ចំណុចខ)

ឧទាហរណ៍ : ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញក្នុងអត្ថបទខាងក្រោម ។ (ទំព័រទី១៨០ ចំណុចខ)

| | | | | | |
|---|---|---|---|---|---|
| ចង្ហាន់ | ភ្នំបិណ្ឌ | ប្រគេន | ភទ្របទ | កុះករ | កុសល |

ចាប់ពីថ្ងៃ១រោចដល់១៤រោចខែ........(១)គេនាំគ្នាដាក់បិណ្ឌឬកាន់បិណ្ឌ ។ ក្នុងការកាន់បិណ្ឌ អ្នកស្រុកចែកគ្នាដាក់វេនធ្វើ......(២)ទៅប្រគេនព្រះសង្ឃនៅឯវត្ត ។ នៅថ្ងៃទី១៥រោច គេធ្វើពិធីបុណ្យ..... (៣)នៅឯវត្ត ។ ពេលនោះ មានមនុស្សច្រើន...(៤)មកជួបជុំគ្នាច្រើនជាងថ្ងៃកាន់បិណ្ឌ ។ គេបានយកចង្ហាន់ នំចំណី ផ្លែឈើ តែ ស្ករ និងវត្ថុផ្សេងៗទៅ.........(៥)ព្រះសង្ឃ ។ អ្នកទាំងនោះនាំគ្នាប្រគេនចង្ហាន់ព្រះសង្ឃរាប់បាត្រដើម្បីបញ្ជូន........... (៦) ដល់ញាតិដែលបានចែកឋានទៅ ។

**ចម្លើយ** : ១.ភទ្របទ ២.ចង្ហាន់ ៣.ភ្នំបិណ្ឌ ៤.កុះករ ៥.ប្រគេន ៦.កុសល

☑ សិស្សបំពេញលំហាត់ក្លូស្ស (Cloze) ដោយប្រើបរិបទជាទីសេចក្តីក្នុងអត្ថបទតាមមេរៀនកំណត់ ។

ឧទាហរណ៍ : កាលពីព្រេងនាយមាន*ត្មាត*.....(១)មួយគ្រួសាររស់នៅលើ*ភ្នំ*......(២)។ ត្មាត ម្តាយនិងឪពុកចាស់*ជរា*.....(៣)ពុំអាចហើរបានឡើយ ។ *ត្មាត*........(៤) កូនតែងតែហើរទៅ*មក*.......(៥)រកចំណីមកចិញ្ចឹម ។ *ថ្ងៃមួយ*.....(៦)កូនត្មាតហើររកចំណី*ក៏*......(៧)បានជាប់អន្ទាក់ព្រាន ។ ព្រាន*បម្រុង*.....(៨)នឹងសម្លាប់តែកូនត្មាត*អង្វរ*......(៩): " ឱ! បងព្រានសូមបងព្រាន*កុំ*......(១០)សម្លាប់ ខ្ញុំអី! បើបង*សម្លាប់*.......(១១)ខ្ញុំ ដូចសម្លាប់ឪពុកម្តាយ*ខ្ញុំ*......(១២)ដែរព្រោះគាត់រស់នៅដោយសារ*ខ្ញុំ*........(១៣)ជាអ្នករកចិញ្ចឹម " ។

**ចម្លើយ :**

| | | | |
|---|---|---|---|
| ១. ចាប លលក ព្រាប | ៤. ចាប លលក ព្រាប | ៧. រួច | ១០. កុំ |
| ២. មែកឈើ ដើមឈើ | ៥. ចុះឡើង | ៨. ប្រុង រៀប | ១១. ប្រហារ |
| ៣. ទ្រុឌទ្រោម | ៦. ពេលមួយ | ៩. ត្អូញត្អែរ | ១២ និង១៣. យើងខ្ញុំ |

បន្តទៅទំព័របន្ទាប់ →

លេខ ៨យ

**បន្ត...**

## សកម្មភាពគំរូ

☑ សិស្សបង់លេខសម្គាល់លំដាប់លំដោយសាច់រឿងដែលពួកគេបានអានទៅតាមការយល់ដឹងរបស់គេ ។ ពួកគេត្រូវដាក់លេខ "១" នៅខាងមុខល្បះ ដែលចាប់ផ្ដើមមុនគេ និងដាក់លេខ "២" នៅខាងមុខល្បះដែលកើតឡើងបន្ទាប់ ។ល។ ឧទាហរណ៍ : អត្ថបទអំណាន មេរៀនទី៧៩ ទំព័រ ១៧២

### រឿងសត្វត្មាត

កាលពីព្រេងនាយ មានត្មាតមួយគ្រួសាររស់នៅលើភ្នំ ។

ត្មាតម្ដាយនិងឪពុកចាស់ជរា ពុំអាចហើរបានឡើយ ។ ត្មាតកូនតែងហើរទៅរកចំណីមកចិញ្ចឹម ។ ថ្ងៃមួយ កូនត្មាតហើររកចំណីក៏បានជាប់អន្ទាក់ព្រាន ។ ព្រានបម្រុងនឹងសម្លាប់តែកូនត្មាតអង្វរ : "ឱ ! បងព្រានសូមបងកុំសម្លាប់ខ្ញុំអី! បើបងសម្លាប់ខ្ញុំដូចសម្លាប់ម្ដាយឪពុកខ្ញុំដែរព្រោះគាត់រស់ដោយសារខ្ញុំជាអ្នករកចិញ្ចឹម" ។ សម្ដីនេះធ្វើឱ្យព្រានពិចារណា : "ឱ ! ខ្ញុំអើយ ខំរកស៊ីសព្វថ្ងៃពុំដែលបានជួយម្ដាយឪពុកជរារបស់ខ្ញុំសោះ" ។ ព្រានគិតហើយក៏លែងត្មាតទៅវិញ រួចតាំងចិត្តចិញ្ចឹមម្ដាយឪពុកដូចសត្វត្មាតដែរ ។

________ ត្មាតកូនតែងហើរទៅរកចំណីមកចិញ្ចឹមម្ដាយឪពុករបស់ខ្លួន ។

________ ព្រានតាំងចិត្តចិញ្ចឹមម្ដាយឪពុកដូចសត្វត្មាតដែរ ។

________ ព្រានគិតហើយក៏លែងត្មាតទៅវិញ ។

________ កូនត្មាតអង្វរព្រាន កុំឱ្យសម្លាប់ខ្លួនអី ព្រោះដូចសម្លាប់ម្ដាយឪពុករបស់ខ្លួនដែរ ។

________ កូនត្មាតជាប់អន្ទាក់ព្រាន ។

បន្តទៅទំព័របន្ទាប់ →

លេខ ៨យ

**បន្ត...**

## សកម្មភាពគំរូ

☑ សិស្សកំណត់បានអំពីល្បះណា ត្រូវ និងខុស បន្ទាប់ពីអានអត្ថបទអំណានទំព័រ ១៦៣ ។

***សេចក្ដីណែនាំ :*** ចូរអានល្បះខាងក្រោម ហើយសរសេរពាក្យ "ត្រូវ" ប្រសិនបើល្បះនោះត្រឹមត្រូវ និងពាក្យ "ខុស" ប្រសិនបើល្បះនោះមិនត្រឹមត្រូវ ។

| | |
|---|---|
| ១. សំណាងបានទៅសាលារៀនជាមួយម្ដាយ ។ | |
| ២. ម្ដាយសំណាងខឹងពីព្រោះគាត់ត្រូវចំណាយលុយបន្ថែមទៀតដល់អ្នកលក់។ | |
| ៣. អ្នកលក់អាប់លុយឱ្យម្ដាយសំណាងបានត្រឹមត្រូវ ។ | |
| ៤. ម្ដាយសំណាងបានទិញចេកអំបូងមួយស្និតពីផ្សារ ។ | |
| ៥. ម្ដាយសំណាងក្រីក្រ និងមិនបានទិញអ្វីទេពីផ្សារ ។ | |
| ៦. ម្ដាយសំណាងមានមោទនភាពចំពោះកូន បន្ទាប់ពីត្រឡប់មកពីផ្សារវិញ ។ | |
| ៧. អ្នកលក់និយាយថា សំណាងគឺជាក្មេងទៀងត្រង់ណាស់ ។ | |
| ៨. ចេកអំបូងថោកជាងផ្លែមៀន ។ | |

☑ សិស្សវិភាគចំណុចសំខាន់នៅក្នុងសាច់រឿង ដោយយោងទៅលើ **គំនិតសំខាន់ គំនិតលម្អិត** និង**សេចក្ដីសន្និដ្ឋាន**។

អត្ថបទអំណាន : មេរៀនទី៧៦ ទំព័រ១៦៣

### ក្មេងសុចរិត

ថ្ងៃអាទិត្យមុន សំណាងបានទៅផ្សារជាមួយម្ដាយ ។

សំណាងបានសុំម្ដាយទិញផ្លែមៀនកន្លះគីឡូក្រាមនិងចេកអំបូងមួយស្និត ។ អ្នកលក់ប្រាប់ថា មៀនមួយគីឡូក្រាមថ្លៃប្រាំពីរពាន់រៀល ឯចេកមួយស្និតថ្លៃពីរពាន់រៀល ។ ម្ដាយសំណាងហុចក្រដាសប្រាក់មួយម៉ឺនរៀលទៅអ្នកលក់ ។ គាត់ក៏អាប់លុយប្រាំពាន់ប្រាំរយរៀលមកវិញ ។ សំណាងប្រាប់អ្នកលក់ : "អ៊ំស្រីអាប់លុយលើសមួយពាន់រៀលហើយ" ។ អ្នកលក់សើចហើយនិយាយ : "អូ ! អ៊ំច្រឡំ អរគុណហើយក្មួយ ។ ក្មួយជាក្មេងទៀងត្រង់ណាស់ ។"

ម្ដាយសំណាងសប្បាយចិត្តណាស់ ដោយមានកូនឆ្លាត និងចេះធ្វើអំពើល្អយ៉ាងនេះ ។



បន្តទៅទំព័របន្ទាប់

លេខ ៨យ

## បន្ត...

### សកម្មភាពគំរូ

ចូរអានរឿងខាងលើ បន្ទាប់មកសរសេរ គំនិតសំខាន់ គំនិតលម្អិត និងសេចក្តីសន្និដ្ឋានក្នុងប្រអប់ខាងក្រោម :



**គំនិតសំខាន់**

____________________

____________________

**គំនិតលម្អិត**

____________________

____________________



**គំនិតលម្អិត**

____________________

____________________

**សេចក្តីសន្និដ្ឋាន**

____________________

____________________

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ:**



លេខ ១០



លេខ ១១

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៨យ

លេខ ៨ង

# សិស្សអាចសរសេរ ពាក្យ ល្បះ អត្ថបទតាមរយៈ លំហាត់សរសេរតាមអាន

**បំណិនសំណេរពាក់ព័ន្ធ : សរសេរតាមអាន**

សូមមើល មេរៀនទី ៧២-៨១ (ទំព័រទី ១៥២-១៨០)

## ខ្លឹមសារ

♦ សរសេរតាមអានអំពី ពាក្យ កន្សោមពាក្យ ល្បះ និង អត្ថបទខ្លី

**មេរៀនទី៧២ :**

ក. ចូរសរសេរតាមអាន រៀបចំអត្ថបទខាងក្រោម ។

**ការសម្អាតខ្លួនប្រាណ**

ការសម្អាតខ្លួនប្រាណនាំឱ្យមានសុខភាពល្អ ។ យើងត្រូវងូតទឹកដុសលាងខ្លួនប្រាណជាមួយសាប៊ូឱ្យបានស្អាតគ្រប់ពេលវេលា ។ មុនពេលបរិភោគអាហារ យើងត្រូវលាងដៃនឹងសាប៊ូជានិច្ច ។ ការយកដៃប្រឡាក់ទៅជូតភ្នែកនាំឱ្យឈឺភ្នែក ។ យើងត្រូវបោកគក់សម្លៀកបំពាក់ជាប្រចាំ ។

ខ.ចូរពន្យល់ពាក្យ"សុខភាព"

**សំណួរ**

១. តើយើងត្រូវសម្អាតខ្លួនប្រាណយ៉ាងដូចម្ដេច?

២. ហេតុអ្វីបានជាយើងត្រូវលាងដៃមុនពេលបរិភោគអាហារ?

៣. តើការសម្អាតខ្លួនប្រាណមានប្រយោជន៍អ្វី?

**មេរៀនទី៧៣ :**

ទំនិញ តម្រូវការ កន្លែង ភាគច្រើន អ្នកភូមិ

ផ្សារនៅភូមិខ្ញុំតូចល្មម ប៉ុន្តែមានលក់ទំនិញគ្រប់មុខស្របតាមតម្រូវការរបស់អ្នកភូមិ ។

**មេរៀនទី៧៥ :**

កន្លែង រន្ទ ស្រែកឃ្លាន សួស្ដី រុំព័ទ្ធ សម្លឹង

សួស្ដីបងពស់! ខ្ញុំរីករាយណាស់ដោយបានជួបបង ។

**មេរៀនទី៧៦ :**

ក. ចូរសរសេរតាមអាន រៀបចំអត្ថបទខាងក្រោម ។

**ក្មេងសុចរិត**

ថ្ងៃអាទិត្យមុនសំណាងបានទៅផ្សារជាមួយម្ដាយ ។ សំណាងបានសុំម្ដាយទិញផ្លែមៀនកន្លះគីឡូក្រាម និងចេកអំបូងមួយស្និត ។ ម្ដាយសំណាង ហុចក្រដាសប្រាក់មួយម៉ឺនរៀលទៅអ្នកលក់ ។ អ្នកលក់ ក៏អាប់លុយលើសមួយពាន់រៀល ។ ពេលនោះសំណាងក៏ប្រាប់អ្នកលក់ ។ អ្នកលក់សរសើរថាសំណាងជាក្មេងសុចរិតណាស់ ។

ខ. ចូរពន្យល់ពាក្យ «កន្លះ អាប់»

**សំណួរ**

១. តើសំណាងបានសុំម្ដាយទិញអ្វីខ្លះ?

២. តើសំណាងប្រាប់អ្នកលក់ដូចម្ដេច?

៣.តើអ្នកលក់សរសើរសំណាងដូចម្ដេច?

បន្តទៅទំព័របន្ទាប់

**លេខ ៨ង** **បន្ត...**

## ខ្លឹមសារ

**មេរៀនទី៧៧** : ជរា អង្កែល មាំមួន ឱប វ័យ ជីដូនជីតាខ្ញុំមានវ័យចំណាស់បន្តិចមែនតែសុខភាពគាត់នៅមាំមួនល្អ ។

**មេរៀនទី៧៨** : មាន់ទា ផ្កា សាយបក្សី ម្ហូបអាហារ សម្ភារៈ ពាក់ម៉ាស់ រដូវនេះមានបុណ្យទានច្រើនបងប្អូនតែងតែរៀបចំម្ហូបអាហារទៅវត្ត ។

**មេរៀនទី៧៩** :

ក.ចូរសរសេរតាមអានរៀបចំអត្ថបទខាងក្រោម ។

**រឿងសត្វត្មាត**

ឱ! បងព្រានសូមបងកុំសម្លាប់ខ្ញុំអី! បើបងសម្លាប់ខ្ញុំដូចសម្លាប់ម្ដាយឪពុកខ្ញុំដែរ ព្រោះគាត់រស់ដោយសារខ្ញុំជាអ្នករកចិញ្ចឹម ។ សម្ដីនេះធ្វើឱ្យព្រានពិចារណា :

«ឱ! ខ្ញុំអើយខំរកស៊ីសព្វថ្ងៃពុំដែលបានជួយម្ដាយ ឪពុកជរារបស់ខ្ញុំសោះ» ។ ព្រានគិតថាហើយក៏លែង ត្មាតទៅវិញរួចតាំងចិត្តចិញ្ចឹមម្ដាយឪពុកដូចសត្វ ត្មាតដែរ ។

ខ. ចូរពន្យល់ពាក្យ «ជរា ពិចារណា»

**សំណួរ**

១. ហេតុអ្វីបានជាសត្វត្មាតអង្វរព្រាន?

២. ពេលបានស្ដាប់សម្ដីត្មាតតើព្រានធ្វើដូចម្ដេច?

**មេរៀនទី៨០** : ទេវតា ឆ្នាំថ្មី ចង្ហាន់ ប្រជាប្រិយ បោះអង្គញ់ ល្បែង ចោលឈូងទាញព្រ័ត្រ លាក់កន្សែង ខ្សៀវខ្វារ តាមផ្ទះមានតុបតែងលម្អដោយផ្កាភ្លី គោមពណ៌ និងភ្លើងចម្រុះពណ៌យ៉ាងស្រស់ស្អាត ។

**មេរៀនទី៨១** : ចង្ហាន់ ព្រះសង្ឃ បាត្រ កុសល ញាតិ ចែកឋាន

ពិធីបុណ្យភ្ជុំបិណ្ឌជាប្រពៃណីរបស់ប្រជាជនខ្មែរដែលមានរយៈពេល១៥ថ្ងៃ ។ ចាប់ពីថ្ងៃ១រោចដល់១៥រោចខែភទ្របទគេនាំគ្នាកាន់បិណ្ឌ ។

បន្តទៅទំព័របន្ទាប់

លេខ ៨ង

# បន្ត...

## សកម្មភាពគំរូ

- ☑ សិស្សសរសេរពាក្យដែលគ្រូហៅនៅលើក្តារឆ្នួនតាមខ្លឹមសារកំណត់ខាងលើ ។
- ☑ សិស្សសរសេរ ពាក្យផ្សំ លើក្តារឆ្នួន បន្ទាប់ពីស្តាប់ព្យាង្គដំបូងនៃពាក្យ ។

ឧទាហរណ៍ :

គ្រូថា មាំ .... សិស្សសរសេរ មាំមួន

គ្រូថា ប្រជា .... សិស្សសរសេរ ប្រជាប្រិយ

គ្រូថា អា ..... សិស្សសរសេរ អាទិត្យ

គ្រូថា ស្មោះ ..... សិស្សសរសេរ ស្មោះត្រង់

គ្រូថា ផ្សព្វ..... សិស្សសរសេរ ផ្សព្វផ្សាយ

- ☑ សិស្សចម្លងពាក្យពីលើក្តារខៀនដាក់ក្នុងសៀវភៅសរសេររៀងខ្លួនតាមការហៅរបស់គ្រូ ។
- ☑ សិស្សក្នុងក្រុម(**ក**)ដែលមានគ្នា៥នាក់ និងក្រុម(**ខ**)ដែលមានគ្នា៥នាក់ សរសេរពាក្យចំនួន ៥ពាក្យក្នុងមួយក្រុមៗតាមការជ្រើសរើសរបស់ក្រុមនីមួយៗ រួចដូរគ្នាពិនិត្យ និងកែលម្អគ្នាទៅវិញទៅមក ។ ឯគ្រូជាអ្នកណែនាំ និងសម្របសម្រួលសិស្សតាមក្រុម ។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



លេខ ១០



លេខ ១១

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៨ង

លេខ ៨ច

# សិស្សអាចបង្កើតល្បះនិងអាចតែងល្បះ តាមគំនិតច្នៃប្រឌិតរៀងៗខ្លួនតាមរយៈលំហាត់

**បំណិនសំណេរពាក់ព័ន្ធ : ការតែងល្បះ**

សូមមើល មេរៀនទី ៧២-៨១ (ទំព័រទី ១៥២-១៨០)

## ខ្លឹមសារ

- ពាក្យទាំងឡាយដែលមានក្នុងមេរៀនទី៧២-៨១ ។

  មេរៀនទី៧២ (ទំព័រទី១៥៤)

  -លំហាត់សំណេរតែងល្បះ នឹង ពាក្យ ទំព័រទី១៥៤ ចំណុច គ ។

  -លំហាត់សំណេរតែងល្បះតាមរូបភាព និងពាក្យ

  -ពាក្យដែលសិស្សអាចប្រើបានដើម្បីសរសេរកថាខណ្ឌខ្លីស្តីពីរូបភាពកំណត់ដោយគ្រូ ។

## សកម្មភាពគំរូ

☑ សិស្សតែងល្បះដោយប្រើពាក្យមួយចំនួនក្នុងលំហាត់ ទៅតាមគំនិតរៀងៗខ្លួនបានត្រឹមត្រូវ ។

ឧទាហរណ៍ : ចូរតែងល្បះនឹងពាក្យខាងក្រោម:

១. សម្អាត: .............................................។

២. បរិភោគ:............................................។

**ចម្លើយ :**

- ខ្ញុំបោស ***សម្អាត*** បន្ទប់មុនពេលចូលគេង ។

-បូណា ***បរិភោគ*** អាហារមួយថ្ងៃបីដង ។

-សុខា ***សម្អាត*** ធ្មេញក្រោយពេល ***បរិភោគ*** បាយរួច ។

☑ សិស្សលេងល្បែងសិក្សាបង្កើតល្បះ ដោយប្រើបណ្ណពាក្យដែលគ្រូផលិតយ៉ាងតិចពី៣-៥បណ្ណពាក្យដើម្បីបង្កើតជាល្បះពេញលេញ ។ ដូចនេះគ្រូគួរធ្វើ ឬផលិតបណ្ណពាក្យទាំងនេះយ៉ាងតិចពី៩ទៅ១២បណ្ណពាក្យសម្រាប់ឱ្យសិស្សធ្វើលំហាត់ ។ គ្រូអាចប្រើបណ្ណពាក្យ ឬសរសេរពាក្យទាំងនេះនៅលើក្តារខៀន ។

បន្តទៅទំព័របន្ទាប់

លេខ ៨៤

**បន្ត...**

## សកម្មភាពគំរូ

ឧទាហរណ៍ ៖ ចូររៀបបណ្តាពាក្យខាងក្រោមដើម្បីបង្កើតជាល្បះពេញលេញបានត្រឹមត្រូវ ។

| | | | | | |
|---|---|---|---|---|---|
| មាន | ស្រោច | នៅក្នុង | ច្បារ | ខ្ញុំ | ស្រស់បំព្រង |
| ផ្ការីក | សួន | ។ | ដំណាំ | ទឹក | សាលារៀន |

**ចម្លើយរំពឹងទុក ៖**

១. ខ្ញុំស្រោចផ្កា ។
២. ខ្ញុំស្រោចដំណាំ ។
៣. ខ្ញុំមានសួនដំណាំ ។
៤. នៅក្នុងសួនច្បារមានផ្ការីកស្រស់បំព្រង ។
៥. សាលារៀនខ្ញុំមានសួនផ្ការីកស្រស់បំព្រង ។
.............................................................។

☑ សិស្សមើលរូបភាពរួចតែងល្បះនៅខាងក្រោមរូបភាពបានត្រឹមត្រូវ ។
(រូបភាពទំព័រទី១៦៨ ,១៧៧ និង១៨០ )

ឧទាហរណ៍ ៖ ចូរតែងល្បះតាមរូបភាពខាងក្រោមឱ្យបានត្រឹមត្រូវ ។ (ទំព័រទី១៦៨)



.................................។



....................................។

☑ សិស្សប្រើពាក្យមួយចំនួនដើម្បីសរសេរកថាខណ្ឌខ្លីទាក់ទងរូបភាពកំណត់ដោយគ្រូ។
ឧទាហរណ៍ ៖ គ្រូឱ្យសិស្សមើលរូបភាពក្នុងសៀវភៅសិស្សមេរៀនទី៨១ (ទំព័រទី១៧៨)

លេខ ៨៤ **បន្ត...**

## សកម្មភាពគំរូ

☑ សិស្សបំពេញសាច់រឿងដោយប្រើប្រាស់ពាក្យពីមេរៀនដែលបានរៀនរួចហើយ។ សិស្សត្រូវអានផ្នែកផ្សេងៗនៃសាច់រឿងដែលមានស្រាប់ បន្ទាប់មកសរសេរគំនិតផ្ទាល់ខ្លួនអំពីរបៀបដែលសាច់រឿងគួរចាប់ផ្ដើម និងបញ្ចប់ ។ លំហាត់នេះតម្រូវឱ្យសិស្សទស្សន៍ទាយ ហេតុការណ៍ និងសកម្មភាព បន្ទាប់មកបង្ហាញគំនិតទាំងនោះទៅក្នុងសំណេររបស់ខ្លួន ។ សាច់រឿងនេះក៏អាចជួយសិស្សឱ្យចេះប្រើប្រាស់ឈ្នាប់ដូចជា "ប៉ុន្តែ , ហេតុដូច្នេះ ..." នៅពេលសរសេរសាច់រឿង ។

### ព្រះអាទិត្យ និងពពកភ្នាល់គ្នា



កាលពីព្រេងនាយ ព្រះអាទិត្យ និងពពកបានភ្នាល់គ្នា ។ ព្រះអាទិត្យជឿជាក់ថាពន្លឺរបស់ខ្លួនអាចបញ្ចេញគ្រប់ពេល ។

→ ប៉ុន្តែ ...

↓ ព្រះអាទិត្យចាប់ផ្ដើមបញ្ចេញពន្លឺយ៉ាងខ្លាំង បន្ទាប់ពីភ្នាល់គ្នាថាពពកអាចបាំងព្រះអាទិត្យបាន។

← (ប្រអប់ទទេ)

↓ ហេតុដូច្នេះ ...

→ ជាចុងក្រោយ ព្រះអាទិត្យយល់ស្របជាមួយពពកថា ព្រះអាទិត្យអាចបញ្ចេញពន្លឺបាន លុះត្រាតែមិនមានពពក និងភ្លៀងបាំងពន្លឺរបស់ខ្លួន ។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



លេខ ១០



លេខ ១១

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូមប្រើ

តេស្តដំណាក់កាលទី ៨៤

លេខ
៨ឆ

# សិស្សអាចសរសេរតួអក្សរផ្ចង់អំពីពាក្យបានស្អាតល្អ

**បំណិនសំណេរពាក់ព័ន្ធ : សរសេរអក្សរផ្ចង់**

សូមមើល មេរៀនទី ៧២-៨១ (ទំព័រទី ១៥២-១៨០)

## សកម្មភាពគំរូ

☑ សិស្សសរសេរអក្សរផ្ចង់អំពីពាក្យ "សុខភាព" បានស្អាតល្អតាមទម្រង់អក្សរជ្រៀងនិងតាមការណែនាំគំរូអំពីរបៀបគូសសរសេរលើក្ដារខៀន ក្ដារឆ្នួននិងក្នុងសៀវភៅសរសេររៀងៗខ្លួនបានត្រឹមត្រូវ។ ឧទាហរណ៍:




☑ សិស្សសរសេរអក្សរផ្ចង់អំពីពាក្យណាមួយដែលគេស្រឡាញ់ហើយរើសចេញពីបញ្ជីពាក្យត្រូវនឹងទម្រង់និងទំហំតាមការកំណត់របស់គ្រូ។
ឧទាហរណ៍ : *ស្រោចទឹក អ្នកភូមិ សម្លឹង ទៀងត្រង់ ចំណាស់ មាំមួន ទេវតា ប្រជាប្រិយ ...*។

☑ សិស្សចម្លងអក្សរផ្ចង់អំពីពាក្យណាមួយដែលគេពេញចិត្តហើយសរសេរពាក្យដដែលនោះឱ្យបានច្រើនដង (៣ដង) និងច្រើនបន្ទាត់ (៣បន្ទាត់)។ ឧទាហរណ៍ :




## ខ្លឹមសារ

- អក្សរផ្ចង់អំពីពាក្យ:
"សុខភាព ចំណាយ
និយាយ សុចរិត
កាពារ ពិចារណា
មេសា ចំណី"

## ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះ សូម

ហ្វឹកហាត់ផ្ទាល់ក្នុងថ្នាក់

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**

គ្រូអាចរកសម្ភារៈផ្សេងៗដូចជា: ក្ដារឆ្នួនមានក្រឡាផ្ទាំងក្រដាសក្រឡាអ៊ិត...។




**ដំណាក់កាលទី៨ ត្រូវបានបញ្ចប់ហើយ!**

សូមធ្វើតេស្តសិស្សដោយប្រើ

តេស្តដំណាក់កាលទី ៨ និងតេស្តផ្ទាល់មាត់ប្រចាំឆមាសទី ២

នៃឧបសម្ព័ន្ធ ៣ នៅក្នុងសៀវភៅនេះ

ទំព័រទី ១៩១ និងទី ១៩៧

# ឧបសម្ព័ន្ធ ១

# បញ្ជីល្បែងសិក្សា

| លរ | ឈ្មោះល្បែងសិក្សា | បំណិនអំណានពាក់ព័ន្ធ | រូបភាព |
| --- | --- | --- | --- |
| ១ | បណ្ណស្រៈនិស្ស័យចល័ត | • ការស្គាល់តួអក្សរ និងសូរ<br>• ការចេះអានស្ទាត់ |  |
| ២ | ល្បែងសិក្សាឡូតូស្រៈ | • ការស្គាល់តួអក្សរ និងសូរ<br>• ការចេះអានស្ទាត់ |  |
| ៣ | បណ្ណព្យញ្ជនៈចល័ត | • ការស្គាល់តួអក្សរនិងសូរ<br>• ការចេះអានស្ទាត់ |   |
| ៤ | ល្បែងសិក្សាឡូតូព្យញ្ជនៈ | • ការស្គាល់តួអក្សរ និងសូរ<br>• ការចេះអានស្ទាត់ |   |
| ៥ | ល្បែងសិក្សាអានស្រៈ និងព្យញ្ជនៈចល័ត | • ការស្គាល់តួអក្សរនិងសូរ<br>• ការចេះវាក្យសព្ទ<br>• ការចេះអានស្ទាត់ |  |
| ៦ | ល្បែងសិក្សាអានស្រៈ និងព្យញ្ជនៈ | • ការស្គាល់តួអក្សរនិងសូរ<br>• ការចេះវាក្យសព្ទ<br>• ការចេះអានស្ទាត់ |  |

| លរ | ឈ្មោះល្បែងសិក្សា | បំណិនអំណានពាក់ព័ន្ធ | រូបភាព |
|---|---|---|---|
| ៧ | ការអានព្យញ្ជនៈប្រើមូសិកទន្ត និងត្រីសព្ទ | • ការស្គាល់តួអក្សរនិងស្វរ<br>• ការចេះវាក្យសព្ទ<br>• ការចេះអានស្ទាត់<br>• ការអានដើម្បីយល់ន័យ |  |
| ៨ | ល្បែងសិក្សាផ្គូផ្គងពាក្យនិងរូបភាព (១ព្យាង្គ, ២ព្យាង្គ, ៣ព្យាង្គ, ស្រៈពេញតួ, ចម្រុះព្យាង្គ, ផ្ញើជើង) | • ការស្គាល់តួអក្សរនិងស្វរ<br>• ការចេះវាក្យសព្ទ<br>• ការចេះអានស្ទាត់ |  |
| ៩ | បណ្ណស្រៈពេញតួចល័ត | • ការស្គាល់តួអក្សរនិងស្វរ<br>• ការចេះអានស្ទាត់ |  |
| ១០ | ល្បែងសិក្សាបង្កើតពាក្យ | • ការស្គាល់តួអក្សរនិងស្វរ<br>• ការចេះវាក្យសព្ទ<br>• ការចេះអានស្ទាត់<br>• ការអានដើម្បីយល់ន័យ |  |
| ១១ | ល្បែងសិក្សាបង្កើតល្បះ | • ការចេះវាក្យសព្ទ<br>• ការចេះអានស្ទាត់<br>• ការអានដើម្បីយល់ន័យ |  |

<table>
<tr><th>លរ</th><th>ឈ្មោះល្បែងសិក្សា</th><th>បំណិនអំណានពាក់ព័ន្ធ</th><th>រូបភាព</th></tr>
<tr><td>១២</td><td>សុសវែរល្បែងសិក្សាចល័ត</td><td>

- ការស្គាល់តួអក្សរ និងស្វរ
- ការចេះវាក្យសព្ទ
- ការចេះអានស្ទាត់
- ការអានដើម្បីយល់ន័យ

</td><td></td></tr>
<tr><td>១៣</td><td>បដិសព្ទ (ពាក្យផ្ទុយ)</td><td>

- ការស្គាល់តួអក្សរ និងស្វរ
- ការចេះវាក្យសព្ទ
- ការចេះអានស្ទាត់

</td><td>
</td></tr>
<tr><td>១៤</td><td>ល្បែងសិក្សារកពាក្យពិបាក ពាក្យន័យដូច និងពាក្យផ្ទុយ</td><td>

- ការស្គាល់តួអក្សរនិងស្វរ
- ការចេះវាក្យសព្ទ
- ការចេះអានស្ទាត់

</td><td>
<table>
<tr><td>ដំ</td><td>អ</td><td>ធ</td><td>យ</td><td>បុ</td><td>ណ្យ</td></tr>
<tr><td>បា</td><td>ប</td><td>ក្រោ</td><td>គ</td><td>ស</td><td>ត</td></tr>
<tr><td>ត់</td><td>ង</td><td>ួ</td><td>ង់</td><td>ងឹ</td><td>ល់</td></tr>
<tr><td>ចុ</td><td>ក</td><td>ទ</td><td>ង</td><td>រ</td><td>ហ៊ា</td></tr>
<tr><td>ទំ</td><td>ែ</td><td>ន</td><td>រ</td><td>អ</td><td>ា</td></tr>
<tr><td>ភ្លួ</td><td>ី</td><td>ខ្លួ</td><td>ា</td><td>ថ</td><td>ន</td></tr>
</table>
</td></tr>
<tr><td>១៥</td><td>ល្បែងសិក្សាពាក្យផ្ទុយ និងពន្យល់ពាក្យ</td><td>

- ការចេះវាក្យសព្ទ
- ការចេះអានស្ទាត់
- ការអានដើម្បីយល់ន័យ

</td><td>
</td></tr>
<tr><td>១៦</td><td>ពាក្យន័យដូច</td><td>

- ការស្គាល់តួអក្សរ និងស្វរ
- ការចេះវាក្យសព្ទ
- ការចេះអានស្ទាត់

</td><td></td></tr>
</table>

# ឧបសម្ព័ន្ធ

# កម្មវិធីសិក្សា *អានខ្មែរ* ក្នុងបច្ចេកវិទ្យាចល័ត

| លរ | មេរៀន | ការរៀនអំពីសូរ | ការហ្វឹកហាត់អានពាក្យតាមរយៈល្បែងសិក្សា | | | ការអានរឿងខ្លី |
|---|---|---|---|---|---|---|
| ១ | ស្រៈ<br>និស្ស័យ | ◌ា ◌ិ ◌ី ◌ឹ ◌ឺ ◌ុ<br>◌ូ ◌ួ ◌ើ ◌ឿ ◌ៀ<br>◌េ ◌ែ ◌ៃ ◌ោ ◌ៅ<br>◌ុំ ◌ំ ◌ាំ ◌ះ ◌ុះ<br>◌េះ ◌ោះ | រកតួអក្សរទៅ<br>តាមសំឡេង | ផ្គូផ្គងតួអក្សរ<br>ឬពាក្យដែល<br>ដូចគ្នា | រកតួអក្សរ<br>ឬពាក្យ |  |
| ២ | ព្យញ្ជនៈ | ក ខ គ ឃ ង ច ឆ<br>ជ ឈ ញ ដ ឋ ឌ ឍ<br>ណ ត ថ ទ ធ ន ប ផ<br>ព ភ ម យ រ ល វ ស<br>ហ ឡ អ | រកតួអក្សរទៅ<br>តាមសំឡេង | ផ្គូផ្គងតួអក្សរ<br>ឬពាក្យដែល<br>ដូចគ្នា | រកតួអក្សរ<br>ឬពាក្យ |  |
| ៣ | ព្យញ្ជនៈ<br>ពួក អ | ក ខ ច ឆ ដ ឋ ណ ត<br>ថ ប ផ ស ហ ឡ អ<br>ផ្សំជាមួយស្រៈនិស្ស័យ | រកពាក្យតាមសូរ | ផ្គូផ្គង<br>ពាក្យនឹង<br>រូបភាព | ផ្គូផ្គងតួអក្សរ<br>ឬពាក្យដែល<br>ដូចគ្នា |  |
| ៤ | ព្យញ្ជនៈ<br>ពួក អ៊ | គ ឃ ង ជ ឈ ញ ឌ<br>ឍ ទ ធ ន ព ភ ម យ រ<br>ល វ ផ្សំជាមួយស្រៈ<br>និស្ស័យ | រកពាក្យមាន<br>សូរខុសគេ | ផ្គូផ្គង<br>ពាក្យនឹង<br>រូបភាព | ផ្គូផ្គងតួអក្សរ<br>ឬពាក្យដែល<br>ដូចគ្នា |  |
| ៥ | សញ្ញា<br>ធ្មេញ<br>កណ្ដុរ | ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉<br>ផ្សំជាមួយស្រៈនិស្ស័យ | ជ្រើសរើសទៅ<br>តាមសូរ | រកពាក្យទៅ<br>តាមសំឡេង | ផ្គូផ្គងតួអក្សរ<br>ឬពាក្យដែល<br>ដូចគ្នា |  |
| ៦ | សញ្ញា<br>ត្រីសព្ទ | ប៊ ស៊ ហ៊ អ៊<br>ផ្សំជាមួយស្រៈនិស្ស័យ | ចំណាត់ថ្នាក់<br>ពាក្យតាមសូរ | រកពាក្យទៅ<br>តាមសំឡេង | ផ្គូផ្គងតួអក្សរ<br>ឬពាក្យដែល<br>ដូចគ្នា |  |
| ៧ | ព្យញ្ជនៈ<br>ប្រកបគ្មាន<br>បន្តក់និង<br>មានបន្តក់<br>(១) | ក ក់ ង ង់ ច ច់ ញ ញ់<br>ត ត់ ន ន់ ប ប់ ម យ<br>ល ល់ វ ស ស់ ផ្សំ<br>ជាមួយព្យញ្ជនៈប្រកប | ផ្គូផ្គង<br>ពាក្យនឹង<br>រូបភាព | ផ្គូផ្គង<br>ពាក្យនឹង<br>រូបភាព | រកតួអក្សរ<br>ឬពាក្យ |  |

| | | | | | | |
|---|---|---|---|---|---|---|
| ៨ | ព្យញ្ជនៈ ប្រកបគ្មានបន្តក់និងមានបន្តក់ (២) | ក ក់ ង ង់ ច ច់ ញ ញ់ ត ត់ ន ន់ ប ប់ ម យ ល ល់ វ ស ស់ ផ្សំជាមួយព្យញ្ជនៈប្រកប | ប្រកបពាក្យ | ផ្គូផ្គងពាក្យនឹងរូបភាព | រកតួអក្សរ ឬពាក្យ |  |
| ៩ | ស្រៈពេញតួ | អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ | ផ្គូផ្គងពាក្យនឹងរូបភាព | រកពាក្យទៅតាមសំឡេង | ផ្គូផ្គងតួអក្សរ ឬពាក្យដែលដូចគ្នា |  |
| ១០ | ជើងព្យញ្ជនៈ | ◌្ក ◌្ខ ◌្គ ◌្ឃ ◌្ង ◌្ច ◌្ឆ ◌្ជ ◌្ឈ ញ ◌្ញ ◌្ដ ◌្ឋ ◌្ឌ ◌្ឍ ◌្ណ ◌្ត ◌្ថ ◌្ទ ◌្ធ ◌្ន ◌្ប ◌្ផ ◌្ព ◌្ភ ◌្ម ◌្យ ◌្រ ◌្ល ◌្វ ◌្ស ◌្ហ ◌្អ | រកពាក្យទៅតាមសំឡេង | ផ្គូផ្គងតួអក្សរ ឬពាក្យដែលដូចគ្នា | រកតួអក្សរ ឬពាក្យ |  |
| ១១ | ព្យញ្ជនៈផ្ញើជើង (១) | ក្ដ ក្ង ក្ន ក្ប ក្ម ក្រ ក្ល ក្ស ក្អ ផ្សំជាមួយស្រៈនិស្ស័យ | ជ្រើសរើសទៅតាមសូរ | រកពាក្យទៅតាមសំឡេង | ផ្គូផ្គងតួអក្សរ ឬពាក្យដែលដូចគ្នា |  |
| ១២ | ព្យញ្ជនៈផ្ញើជើង (២) | ខ្ច ខ្ជ ខ្ទ ខ្ន ខ្ម ខ្ព ខ្ម ខ្យ ខ្ល ខ្វ ខ្ស ផ្សំជាមួយស្រៈនិស្ស័យ | រកពាក្យមានសូរខុសគេ | ជ្រើសរើសទៅតាមសូរ | ផ្គូផ្គងតួអក្សរ ឬពាក្យដែលដូចគ្នា |  |
| ១៣ | ព្យញ្ជនៈផ្ញើជើង (៣) | គ្ន គ្ម គ្រ ផ្សំជាមួយស្រៈនិស្ស័យ | រកពាក្យទៅតាមសំឡេង | ផ្គូផ្គងតួអក្សរ ឬពាក្យដែលដូចគ្នា | រកតួអក្សរ ឬពាក្យ |  |
| ១៤ | ព្យញ្ជនៈផ្ញើជើង (៤) | ឃ្ង ឃ្ន ឃ្ម ឃ្ល ឃ្វ ផ្សំជាមួយស្រៈនិស្ស័យ | រកពាក្យមានសូរខុសគេ | ផ្គូផ្គងតួអក្សរ ឬពាក្យដែលដូចគ្នា | រកតួអក្សរ ឬពាក្យ |  |
| ១៥ | ព្យញ្ជនៈផ្ញើជើង (៥) | ច្ន ច្ប ច្យ ច្រ ផ្សំជាមួយស្រៈនិស្ស័យ | រកពាក្យមានសូរខុសគេ | រកពាក្យទៅតាមសំឡេង | រកតួអក្សរ ឬពាក្យ |  |
| ១៦ | ព្យញ្ជនៈផ្ញើជើង (៦) | ឆ្ក ឆ្គ ឆ្ង ឆ្ដ ឆ្ន ឆ្ព ឆ្ម ឆ្ល ឆ្វ ឆ្អ ផ្សំជាមួយស្រៈនិស្ស័យ | ជ្រើសរើសទៅតាមសូរ | ផ្គូផ្គងពាក្យនឹងរូបភាព | ផ្គូផ្គងតួអក្សរ ឬពាក្យដែលដូចគ្នា |  |
| ១៧ | ព្យញ្ជនៈផ្ញើជើង (៧) | ជ្រ ជ្វ ផ្សំជាមួយស្រៈនិស្ស័យ | រកពាក្យទៅតាមសំឡេង | ផ្គូផ្គងតួអក្សរ ឬពាក្យដែលដូចគ្នា | រកតួអក្សរ ឬពាក្យ |  |

| | | | | | | |
|---|---|---|---|---|---|---|
| ១៨ | ព្យញ្ជនៈ ផ្ញើជើង (៨) | ឈ្ង ឈ្ន ឈ្ម ឈ្ល ឈ្វ ផ្សំជាមួយស្រៈនិស្ស័យ | រកពាក្យមានសូរព្យញ្ជនៈផ្ញើជើង ឬព្យាង្គតម្រួត | ចំណាត់ថ្នាក់ពាក្យតាមសូរ | រកតួអក្សរ ឬពាក្យ |  |
| ១៩ | ព្យញ្ជនៈ ផ្ញើជើង (៩) | ត្ន ត្យ ត្ម ត្រ ត្ល ត្អ ផ្សំជាមួយស្រៈនិស្ស័យ | បង្កើតពាក្យ | ផ្គូផ្គង ពាក្យនឹង រូបភាព | ផ្គូផ្គងតួអក្សរ ឬពាក្យដែល ដូចគ្នា |  |
| ២០ | ព្យញ្ជនៈ ផ្ញើជើង (១០) | ថ្ក ថ្គ ថ្ង ថ្ន ថ្ព ថ្ម ថ្ល ថ្វ ផ្សំជាមួយស្រៈនិស្ស័យ | រកពាក្យមានសូរ ខុសគេ | ផ្គូផ្គងពាក្យនឹង រូបភាព | រកតួអក្សរ ឬពាក្យ |  |
| ២១ | ព្យញ្ជនៈ ផ្ញើជើង (១១) | ទ្រ ទ្វ ផ្សំជាមួយស្រៈនិស្ស័យ | រកពាក្យមានសូរ ខុសគេ | ផ្គូផ្គងពាក្យនឹង រូបភាព | រកតួអក្សរ ឬពាក្យ |  |
| ២២ | ព្យញ្ជនៈ ផ្ញើជើង (១២) | ធ្ង ធ្ន ធ្ម ធ្យ ធ្ល ធ្វ ផ្សំជាមួយស្រៈនិស្ស័យ | រកពាក្យ តាមសូរ | រកពាក្យទៅ តាមសំឡេង | ផ្គូផ្គងតួអក្សរ ឬពាក្យដែល ដូចគ្នា |  |
| ២៣ | ព្យញ្ជនៈ ផ្ញើជើង (១៣) | ប្ត ប្រ ប្ល ប្អ ផ្សំជាមួយស្រៈនិស្ស័យ | ផ្គូផ្គង ពាក្យនឹង រូបភាព | រកពាក្យទៅ តាមសំឡេង | ផ្គូផ្គងតួអក្សរ ឬពាក្យដែល ដូចគ្នា |  |
| ២៤ | ព្យញ្ជនៈ ផ្ញើជើង (១៤) | ផ្ក ផ្ង ផ្ច ផ្ញ ផ្គ ផ្ត ផ្ទ ផ្ល ផ្យ ផ្អ ផ្សំជាមួយស្រៈនិស្ស័យ | រកពាក្យមានសូរព្យញ្ជនៈផ្ញើជើង ឬព្យាង្គតម្រួត | ផ្គូផ្គង ពាក្យនឹងរូប ភាព | រកតួអក្សរ ឬពាក្យ |  |
| ២៥ | ព្យញ្ជនៈ ផ្ញើជើង (១៥) | ព្ន ព្យ ព្រ ព្ល ផ្សំជាមួយស្រៈនិស្ស័យ | ផ្គូផ្គង ពាក្យនឹង រូបភាព | រកពាក្យទៅ តាមសំឡេង | ផ្គូផ្គងតួអក្សរ ឬពាក្យដែល ដូចគ្នា |  |
| ២៦ | ព្យញ្ជនៈ ផ្ញើជើង (១៦) | ភ្ង ភ្ជ ភ្ញ ភ្ន ភ្ល ផ្សំជាមួយស្រៈនិស្ស័យ | រកពាក្យមានសូរព្យញ្ជនៈផ្ញើជើង ឬព្យាង្គតម្រួត | ផ្គូផ្គង ពាក្យនឹង រូបភាព | ផ្គូផ្គងតួអក្សរ ឬពាក្យដែល ដូចគ្នា |  |
| ២៧ | ព្យញ្ជនៈ ផ្ញើជើង (១៧) | ម្ក ម្ខ ម្ង ម្ច ម្ជ ម្ញ ម្ត ម្ថ ម្ន ម្ភ ម្យ ម្រ ម្ល ម្យ ម្ហ ម្អ ផ្សំជាមួយស្រៈនិស្ស័យ | រកពាក្យមានសូរព្យញ្ជនៈផ្ញើជើង ឬព្យាង្គតម្រួត | ផ្គូផ្គង ពាក្យនឹងរូប ភាព | ផ្គូផ្គងតួអក្សរ ឬពាក្យដែល ដូចគ្នា |  |
| ២៨ | ព្យញ្ជនៈ ផ្ញើជើង (១៨) | ល្ខ ល្ង ល្ប ល្ព ល្ម ល្វ ល្ហ ល្អ ផ្សំជាមួយស្រៈនិស្ស័យ | ចំណាត់ថ្នាក់ពាក្យតាមសូរ | ផ្គូផ្គង ពាក្យនឹង រូបភាព | រកតួអក្សរ ឬពាក្យ |  |

| | | | | | | |
|---|---|---|---|---|---|---|
| ២៩ | ព្យញ្ជនៈ ផ្ញើជើង (១៩) | ស្ក ស្គ ស្ង ស្ច ស្ដ ស្ត ស្ថ ស្ទ ស្ន ស្ប ស្ព ស្ម ស្រ ស្ល ស្វ ស្អ ផ្សំជាមួយស្រៈនិស្ស័យ | រកពាក្យមានសូរ ព្យញ្ជនៈផ្ញើជើង ឬព្យាង្គតម្រួត | ចំណាត់ថ្នាក់ ពាក្យតាមសូរ | ផ្គូផ្គង ពាក្យនឹង រូបភាព |  |
| ៣០ | ព្យាង្គ តម្រួត (១) | ង្ក ង្ខ ង្គ ង្ឃ ង្រ ង្វ ង្ស ង្ហ ង្អ ញ្ច ញ្ឆ ញ្ជ ញ្ឈ ញ្ញ ណ្ដ ណ្ឋ ន្ត ន្ថ ន្ទ ន្យ ន្ស ម្ព ម្ភ ម្ម ម្រ ម្ល | បង្កើតពាក្យ | រកពាក្យទៅ តាមសំឡេង | រកតួអក្សរ ឬពាក្យ |  |
| ៣១ | ព្យាង្គ តម្រួត (២) | ង្ក្រ ង្គ្រ ញ្ច្រ ញ្ជ្រ ន្ត្រ ន្ទ្រ | រកពាក្យមានសូរ ព្យញ្ជនៈផ្ញើជើង ឬព្យាង្គតម្រួត | ចំណាត់ថ្នាក់ ពាក្យតាមសូរ | បង្កើតពាក្យ |  |

# ឧបសម្ព័ន្ធ៣

# តារាងសង្ខេបតេស្តដំណាក់កាល និង
# តេស្តផ្ទាល់មាត់ប្រចាំឆមាស

| តេស្តដំណាក់កាល | | តេស្តផ្ទាល់មាត់ | |
|---|---|---|---|
| លេខតេស្ត ដំណាក់កាល | កម្រិតស្តង់ដាដែលគ្របដណ្តប់ | លេខតេស្ត | កម្រិតស្តង់ដាដែលគ្របដណ្តប់ |
| តេស្តទី១ | ១ក, ១ខ, ១គ, ១ឃ, ១ង, ១ច,១ឆ | តេស្តឆមាសទី១ | ១ក,១ខ, ១គ,១ឃ ២គ ៣គ ៤គ |
| តេស្តទី២ | ២ក, ២ខ, ២គ, ២ឃ | | |
| តេស្តទី៣ | ៣ក, ៣ខ, ៣គ, ៣ឃ | | |
| តេស្តទី៤ | ៤ក, ៤ខ, ៤គ, ៤ឃ, ៤ង, ៤ច | | |
| តេស្តទី៥ | ៥ក, ៥ខ, ៥គ, ៥ឃ, ៥ង, ៥ច | តេស្តឆមាសទី២ | ៥គ ៦គ ៧គ ៨គ |
| តេស្តទី៦ | ៦ក, ៦ខ, ៦គ, ៦ឃ,៦ង,៦ច | | |
| តេស្តទី៧ | ៧ក,៧ខ,៧គ,៧ឃ,៧ង,៧ច | | |
| តេស្តទី៨ | ៨ក,៨ខ, ៨គ, ៨ឃ, ៨ង,៨ច | | |

# សេចក្តីណែនាំទូទៅសម្រាប់
# ការធ្វើតេស្តដំណាក់កាល និងតេស្តផ្ទាល់មាត់ប្រចាំឆមាស

## ១. ការធ្វើតេស្តដំណាក់កាល

### ការរៀបចំទូទៅ

- មុនពេលធ្វើតេស្តសំណេរក្នុងថ្នាក់រៀន គ្រូត្រូវប្រាប់សិស្សជាមុនថាត្រូវធ្វើនៅថ្ងៃណា ពេលព្រឹក ឬពេលល្ងាច ។
- គ្រូចែកសិស្ស២០ទៅ២៥នាក់ក្នុងពេលអនុវត្តតេស្តសំណេរ បើសិស្សមានចំនួនច្រើន ត្រូវធ្វើ២ដងក្នុងមួយថ្នាក់ ។
- គ្រូរៀបចំសិស្សអង្គុយជាជួរដោយឃ្លាតពីគ្នាឱ្យបានឆ្ងាយគ្នាតាមដែលអាចធ្វើបាន ។
- គ្រូផ្តល់សន្លឹកតេស្តអ៊ិតនិងប៊ិកហ្វឺតលុបជ្រះដល់សិស្សម្នាក់ៗ ។
- គ្រូឱ្យសិស្សធ្វើតេស្តទៅតាមពេលវេលាកំណត់នៅក្នុងសន្លឹកតេស្តអ៊ិតនីមួយៗ និង ណែនាំសិស្សធ្វើមួយសំណួរម្តងៗមុនបន្តទៅសំណួរបន្ទាប់ទៀតនៅផ្នែកនីមួយៗ ។ ផ្នែកនីមួយៗត្រូវចំណាយពេល៥នាទីសម្រាប់ការណែនាំរបស់គ្រូនិងការធ្វើសំណួរ របស់សិស្ស ។

ពន្យល់សិស្សថាសន្លឹកតេស្តអ៊ិតនេះ សិស្សម្នាក់ៗត្រូវធ្វើដោយខ្លួនឯង ។ បើសំណួរណាដែលពួកគេមិនចេះ មិនមែនជាបញ្ហានោះទេ ។ មិនមែនសិស្សគ្រប់រូបសុទ្ធតែចេះនោះទេ ប៉ុន្តែពួកគេនឹងអាចរៀនអ្វីមួយបន្ទាប់ពីការធ្វើតេស្តនេះ ។ លំហាត់នីមួយៗសិស្សមានពេលកំណត់ច្បាស់លាស់ ។ បន្ទាប់ពីធ្វើចប់ផ្នែកនីមួយៗ គ្រូប្រាប់ថាបន្តទៅមុខទៀត ។ សិស្សមិនគួរធ្វើកិច្ចការនៅក្នុងផ្នែកណាមួយមុនការណែនាំរបស់គ្រូឡើយ ។ សិស្សគ្រប់រូបគួរធ្វើតេស្តក្នុងពេលតែមួយ និងមានចំនួនម៉ោងសម្រាប់ធ្វើកិច្ចការដូចគ្នា ។

សួរសិស្សថាពួកគេបានត្រៀមខ្លួនរួចហើយឬនៅបើត្រៀមហើយចាប់ផ្តើមធ្វើលំហាត់។

## ២. ការធ្វើតេស្តផ្ទាល់មាត់ប្រចាំឆមាស

### ការរៀបចំទូទៅ

គ្រូបង្រៀន និងគ្រូបង្វឹកអំណានរៀបចំធ្វើតេស្តសិស្សម្នាក់និងគ្រូ ដើម្បីពិនិត្យតាមដានដោយផ្ទាល់ពីសមត្ថភាពសិស្សលើការអាន និងការបញ្ចេញសំឡេងអក្សរ និងពាក្យ ។ ផ្នែកនេះមានសារៈសំខាន់ណាស់ក្នុងការបណ្តុះបំណិនអានស្ទាត់ ។ ដើម្បីធ្វើការវាយតម្លៃបែបនេះបាន គ្រូត្រូវមានជំនួយ និងរៀបចំពេលវេលាឱ្យសិស្សធ្វើការសិក្សាដោយខ្លួនឯងខណៈដែលគ្រូកំពុងធ្វើតេស្តសិស្សផ្សេងទៀត ។

# តេស្តដំណាក់កាលទី ១ ( ៣៥នាទី )

<u>សេចក្តីណែនាំ</u>

**១ក. សិស្សអាចអានស្រៈនិស្ស័យទាំងអស់បានច្បាស់លាស់ ។ (ការស្គាល់តួអក្សរនិងសូរ និង ការចេះអានស្ទាត់)**

*សំណួរផ្ទៀងផ្ទាត់គឺតម្រូវឱ្យសិស្សសម្រេចចិត្តថា ចម្លើយនីមួយៗ ត្រូវ ឬខុស ។* គ្រូឱ្យសិស្សអានស្រៈនិស្ស័យក្នុងជួរមានប្រាំតួ ចំនួនពីរដង រួចឱ្យសិស្សគូសសញ្ញា √ បើជាស្រៈនិស្ស័យរៀបតាមលំដាប់លំដោយ បើស្រៈនិស្ស័យទាំងនោះមិនរៀបតាមលំដាប់លំដោយទេ ត្រូវគូសសញ្ញា × លើបន្ទាត់ខាងចុងសំណួរ ។

**១ខ. សិស្សអាចអានព្យញ្ជនៈ និងជើងព្យញ្ជនៈទាំងអស់បានច្បាស់លាស់ ។ (ការស្គាល់តួអក្សរនិងសូរ និង ការចេះអានស្ទាត់)**

*សំណួរផ្ទៀងផ្ទាត់គឺ តម្រូវឱ្យសិស្សសម្រេចចិត្តថា ចម្លើយនីមួយៗ ត្រូវ ឬ ខុស ។* គ្រូឱ្យសិស្សអានព្យញ្ជនៈឬជើងព្យញ្ជនៈក្នុងជួរមានប្រាំតួចំនួនពីរដង រួចឱ្យសិស្សគូសសញ្ញា √ បើជាព្យញ្ជនៈឬជើងព្យញ្ជនៈរៀបតាមលំដាប់លំដោយបើព្យញ្ជនៈឬជើងព្យញ្ជនៈទាំងនោះមិនរៀបតាមលំដាប់លំដោយទេត្រូវគូសសញ្ញា × លើបន្ទាត់ខាងចុងសំណួរ ។

**១គ. សិស្សអាចអានការផ្សំសូរព្យញ្ជនៈនិងស្រៈដើម្បីអានពាក្យនិងល្បះបានត្រឹមត្រូវ ។ (ការចេះវាក្យសព្ទ និង ការចេះអានស្ទាត់)**

*សំណួរផ្គូផ្គងគឺ តម្រូវឱ្យសិស្សមើលរូប រួចគូសព្រួញ ឬ វង់យកពាក្យមួយដែលត្រូវ នឹងរូបនោះ ។* គ្រូឱ្យសិស្សមើលរូបភាពនិងអានពាក្យចំនួនពីរដង រួចគូសវង់Oយកពាក្យណាមួយដែលត្រូវជាមួយនឹងរូបភាពនោះ ។

**១ឃ. សិស្សអាចអានការផ្សំសូរព្យញ្ជនៈនិងស្រៈដើម្បីអានពាក្យនិងល្បះបានត្រឹមត្រូវ ។ (ការចេះវាក្យសព្ទ និង ការចេះអានស្ទាត់)**

*សំណួរពហុជ្រើសរើសគឺ តម្រូវឱ្យសិស្ស គូសវង់យកចម្លើយតែមួយតាមគ្រូបានហៅ ។* គ្រូហៅពាក្យឬល្បះណាមួយក្នុងជួរនីមួយៗ ឱ្យសិស្សស្តាប់ចំនួនពីរដងរួចឱ្យសិស្សគូសវង់Oលើពាក្យឬល្បះដែលត្រឹមត្រូវតាមសមត្ថភាពខ្លួនឯង ។

**១ង. សិស្សចេះអានយល់ ពាក្យ ឃ្លា ល្បះខ្លី ដែលប្រើមូសិកទន្ត និងត្រីសព្ទ ។ (ការចេះវាក្យសព្ទ និង ការអានដើម្បីយល់ន័យ)**

*សំណួរផ្គូផ្គងគឺ តម្រូវឱ្យសិស្សមើលរូប រួចគូសព្រួញ ឬវង់យកពាក្យឬល្បះមួយដែលសរសេរត្រឹមត្រូវនឹងរូបនោះ ។* គ្រូឱ្យសិស្សមើលរូបភាព និងអានពាក្យចំនួនពីរដង រួចគូសវង់Oយកពាក្យ ឬឃ្លា ឬល្បះណាមួយដែលត្រូវជាមួយនឹងរូបភាពនោះ ។

**១ច. សិស្សអាចប្រកបព្យញ្ជនៈនិងព្យញ្ជនៈ ព្យញ្ជនៈស្រៈនិងព្យញ្ជនៈ ប្រកបខាងចុងមាន : ក ខ គ ឃ ច ជ ត ថ ទ ព ប ស និង ន ណ ង ញ ម យ ល វ ដែលប្រើវណ្ណយុត្ត (៉ ៊ ់) ។**
**(ការចេះវាក្យសព្ទ និង ការអានដើម្បីយល់ន័យ)**

*សំណួរពហុជ្រើសរើសគឺ គ្រូតម្រូវឱ្យសិស្សគូសរង្វង់យកចម្លើយតែមួយតាមគ្រូបានហៅ។* គ្រូហៅពាក្យឬល្បះណាមួយក្នុងជួរនីមួយៗ ឱ្យសិស្សស្ដាប់ចំនួនពីរដងរួចឱ្យសិស្សគូសរង្វង់Oលើពាក្យឬល្បះដែលត្រឹមត្រូវតាមសមត្ថភាពខ្លួនឯង ។

**១ឆ. សិស្សអាចអានស្រៈពេញតួ និងពាក្យទាំងអស់បានច្បាស់លាស់ ។**
**(ការចេះវាក្យសព្ទ និង ការអានដើម្បីយល់ន័យ)**

*សំណួរផ្គូផ្គងគឺ គ្រូតម្រូវឱ្យសិស្សមើលរូប រួចគូសព្រួញ ឬ រង្វង់យកពាក្យឬល្បះមួយដែលសរសេរត្រឹមត្រូវនឹងរូបនោះ ។* គ្រូឱ្យសិស្សមើលរូបភាព និងអានពាក្យចំនួនពីរដង រួចគូសរង្វង់Oយកពាក្យណាមួយដែលសរសេរបានត្រឹមត្រូវជាមួយនឹងរូបភាពនោះ ។

# តេស្តដំណាក់កាលទី ១ (៣៥នាទី)

## ឈ្មោះសិស្ស_______________

**១ក.** សិស្សអាចអានស្រៈនិស្ស័យទាំងអស់បានច្បាស់លាស់ ។
(ការស្គាល់តួអក្សរនិងសូរ និង ការចេះអានស្ទាត់)

**សំណួរផ្លាស់**

| | | | | | | |
|---|---|---|---|---|---|---|
| ១ | ◌ា | ◌ិ | ◌ី | ◌ឹ | ◌ឺ | ____ |
| ២ | ◌ុ | ◌ៅ | ◌ូ | ◌េះ | ◌ឿ | ____ |
| ៣ | ◌ៀ | ◌េ | ◌ែ | ◌ៃ | ◌ោ | ____ |
| ៤ | ◌ៅ | ◌ុំ | ◌ំ | ◌ាំ | ◌ះ | ____ |
| ៥ | ◌ុ | ◌េះ | ◌ោ | ◌ឺ | ◌ើ | ____ |
| ៦ | ◌ែ | ◌ូ | ◌ៅ | ◌ឹ | ◌ៀ | ____ |

ពិន្ទុ

| |
|---|
| |
| ៦ |

**១ខ.** សិស្សអាចអានព្យញ្ជនៈនិងជើងព្យញ្ជនៈទាំងអស់បានច្បាស់លាស់ ។
(ការស្គាល់តួអក្សរនិងសូរ និង ការចេះអានស្ទាត់)

**សំណួរផ្លាស់**

| | | | | | | |
|---|---|---|---|---|---|---|
| ១ | ទ្ធ | ខ្ទ | គ្គ | ឈ្ប | ង្វ | ____ |
| ២ | ច្វ | ឆ្ន | ជ្ជ | ឈ្ប | ញ្ញ | ____ |
| ៣ | ប្រ | ល្ល | រ្វ | ស្ស | ហ្វ | ____ |
| ៤ | ◌្ត | ◌្ក | ◌្ង | ◌្ន | ◌្ជ | ____ |
| ៥ | ◌្ឃ | ◌្យ | ◌្រ | ◌្ឈ | ◌្ញ | ____ |
| ៦ | ◌្ផ | ◌្ន | ◌្ទ | ◌្ហ | ◌្អ | ____ |

ពិន្ទុ

| |
|---|
| |
| ៦ |

**១គ.** សិស្សអាចអានការផ្សំសូរព្យញ្ជនៈនិងស្រៈដើម្បីអានពាក្យនិងល្បះ ។
(ការចេះវាក្យសព្ទ  និង ការចេះអានស្ទាត់)

## ផ្គូផ្គងរូបភាពទៅនឹងពាក្យ

ពិន្ទុ

| | | | | |
|---|---|---|---|---|
| ១ |  | ដំបៅ | ដាំ | កោះ |
| ២ |  | ដេរ | ហោះ | បបរ |
| ៣ |  | ចរចា | អាហារ | កាផា |
| ៤ |  | តាខេ | កកូរ | កីឡា |
| ៥ |  | ចំណី | ចំណាំ | ដំបៅ |
| ៦ |  | សរសេរ | កោះ | ហូរហែ |

| |
|---|
| |
| ៦ |

**១ឃ.** សិស្សអាចអានការផ្សំសូរព្យញ្ជនៈនិងស្រៈដើម្បីអានពាក្យនិងល្បះ ។
(ការចេះវាក្យសព្ទ  និង ការចេះអានស្ទាត់)

ពិន្ទុ

| | | | | | |
|---|---|---|---|---|---|
| ១ | គោះ | ឈឺ | ពោះ | យូរ | ជូរ |
| ២ | ឈើ | ញី | លី | លើ | ឃុំ |
| ៣ | ភរ | ភេ | ទា | ទំ | ធំ |
| ៤ | គគីរ | សាគរ | ឃោរឃៅ | គយៀរ | ជំងឺ |
| ៥ | ឈូឆរ | ញញូរ | ណោមរា | ទទា | ធានា |
| ៦ | ពូទីចុះពីលើនាវា។ | គោញីតាឈុំឈឺ ។ | | សេះថៅងឺជាសះដំបៅងា។ | |

| |
|---|
| |
| ៦ |

**១ង.** សិស្សអាចអានយល់ពាក្យ ឃ្លា ល្បះខ្លី ដែលប្រើមូសិកទន្ត និងត្រីសព្ទ ។ (ការចេះវាក្យសព្ទ  និង  ការអានដើម្បីយល់ន័យ)

### សំណួរផ្គូផ្គងរូបភាពទៅនឹងពាក្យនិងល្បះ

| | | | | |
|---|---|---|---|---|
| ១ |  | ហ៊ូតៅ | តៅហ៊ូ | ហ៊ៅតូ |
| ២ |  | ទ្រអ៊ូ | អ៊ូទ្រ | ទ្រូអ៊ិ |
| ៣ |  | តាវ៉ែន | វ៉ែតាន | វ៉ែនតា |
| ៤ |  | រ៉ណារ | រណារ៉ | រណារ៉រ |
| ៥ |  | វារចៅចេះវ៉ា។ | ចៅវ៉ាចេះវារ។ | ចេះវ៉ាចៅវារ។ |
| ៦ |  | ចៀរអ៊ំៗ ជ័រកៅស៊ូ មមាញឹក។ | ជ័រកៅស៊ូអ៊ំៗ មមាញឹកចៀរ។ | អ៊ំៗមមាញឹកចៀរ ជ័រកៅស៊ូ។ |

| ពិន្ទុ |
|---|
| |
| ៦ |

**១ច.** សិស្សអាចប្រកបព្យញ្ជនៈនិងព្យញ្ជនៈ ព្យញ្ជនៈស្រៈនិងព្យញ្ជនៈប្រកបខាងចុងដែល ប្រើវណ្ណយុត្ត ។ (ការចេះវាក្យសព្ទ និង ការអានដើម្បីយល់ន័យ)

### សំណួរពហុជ្រើសរើស

| | | | | | |
|---|---|---|---|---|---|
| ១ | កាច់ | មេឃ | ហ៊ាន | ប៉ើង | កែវ |
| ២ | អំណាច | ទឹកកក | នាគរាជ | រលួយ | អំបិល |
| ៣ | សារម៉ាវ | សុភាព | រសៀល | រុងរឿង | ចំណេញ |
| ៤ | តាភាពជូតប៉ី។ | ចៅជុំដឹកទឹកកក។ | | មីងពេញទិញនោង។ | |
| ៥ | បងអ៊ុតដុត ពោតហូប។ | សិស្សជិះទោងនៅ សាលារៀន។ | | មីងប៉ានយកទៀបធំៗ ទៅទុកហូប។ | |
| ៦ | ពូប៊ីថាទីនេះអ៊ូអរ។ | ពូពយទិញភួយមួយ។ | | ពេលទំនេរបងកែវទៅ រៀនហែលទឹក។ | |

| ពិន្ទុ |
|---|
| |
| ៦ |

**១៨.** សិស្សអាចអានស្រៈពេញតួ និងពាក្យទាំងអស់បានច្បាស់លាស់ ។
(ការចេះវាក្យសព្ទ និង ការអានដើម្បីយល់ន័យ)

**ពិន្ទុ**

| |
|---|
| |
| ៦ |

### សំណួរផ្គូផ្គងរូបភាពទៅនឹងពាក្យ និងឈ្មោះ

| | | | | |
|---|---|---|---|---|
| ១ |  | អរគា | គារអ | អគារ |
| ២ |  | សីឥ | ឥសី | ឥស |
| ៣ |  | ឫស | សឫ | ស្ងប |
| ៤ |  | ឱថស | ឱសថ | សឱថ |
| ៥ |  | ឪទឹន | ឪនឹទ | ឪទនឹ |
| ៦ |  | ពូឱមក្រឪឈូក នៅឯបឹងដក។ | នៅឯបឹងក្រឪ ឈូកដកពូឱម។ | ពូឱមដកក្រឪឈូក នៅឯបឹង ។ |

**ពិន្ទុសរុប**

| |
|---|
| |
| ៤២ |

# តេស្តដំណាក់កាលទី ២ (២០នាទី)

## <u>សេចក្ដីណែនាំ</u>

**២ក. សិស្សអាចប្រាប់សូររបស់ព្យញ្ជនៈផ្ញើជើង និងព្យញ្ជនៈផ្ញើជើងផ្សំនឹងស្រៈ ។ (ការស្គាល់តួអក្សរ និង សូរ)**

*សំណួរពហុជ្រើសរើសគឺ តម្រូវឱ្យសិស្ស គូសរង្វង់យកចម្លើយតែមួយតាមគ្រូបានហៅ* ។ គ្រូហៅព្យញ្ជនៈផ្ញើជើងឬព្យញ្ជនៈផ្ញើជើងផ្សំនឹងស្រៈណាមួយក្នុងចំណោមព្យញ្ជនៈផ្ញើជើងឬព្យញ្ជនៈផ្ញើជើងផ្សំនឹងស្រៈទាំងប្រាំឱ្យសិស្សស្ដាប់ពីរដង រួចគូសរង្វង់តាមសមត្ថភាពខ្លួនឯង ។

**២ខ. សិស្សអាចអានយល់ពាក្យដែលមានព្យញ្ជនៈផ្ញើជើងផ្សំនឹងស្រៈនិស្ស័យព្រមទាំងពាក្យដែលមានឬគ្មានព្យញ្ជនៈប្រកបខាងចុង ។ (ការស្គាល់តួអក្សរនិងសូរ និង ការចេះវាក្យសព្ទ)**

*សំណួរផ្គូផ្គងគឺតម្រូវឱ្យសិស្សមើលរូប រួចគូសព្រួញ ឬរង្វង់យកពាក្យមួយដែលត្រូវនឹងរូបនោះ ។* គ្រូឱ្យសិស្សមើលរូបភាពនិងអានពាក្យចំនួនពីរដង រួចគូសរង្វង់ Oយកពាក្យណាមួយដែលត្រូវជាមួយនឹងរូបភាពនោះ ។

**២គ. សិស្សអាចអានពាក្យ ឃ្លា ល្បះខ្លីដែលកើតចេញពីព្យញ្ជនៈផ្ញើជើង ផ្សំនឹងស្រៈ និងព្យញ្ជនៈប្រកបបានស្ទាត់ ។ (ការចេះអានស្ទាត់)**

*សំណួរពហុជ្រើសរើសគឺ តម្រូវឱ្យសិស្ស គូសរង្វង់យកចម្លើយតែមួយតាមគ្រូបានហៅ* ។ គ្រូហៅពាក្យ ឃ្លាឬល្បះណាមួយក្នុងចំណោមឃ្លាឬល្បះដែលកើតពីព្យញ្ជនៈផ្ញើជើងឬព្យញ្ជនៈផ្ញើជើងផ្សំនឹងស្រៈទាំងប្រាំឱ្យសិស្សស្ដាប់ពីរដងរួចគូសរង្វង់ O តាមសមត្ថភាពខ្លួនឯង ។

**២ឃ. សិស្សអាចអាន ឃ្លា ល្បះខ្លីៗដែលប្រើពាក្យកើតចេញពីព្យញ្ជនៈផ្ញើជើង ផ្សំនឹងស្រៈនិស្ស័យមាន ឬគ្មានព្យញ្ជនៈប្រកបខាងចុង ។ (ការអានដើម្បីយល់ន័យ)**

*សំណួរឆ្លាស់គឺតម្រូវឱ្យសិស្សសម្រេចចិត្តថាចម្លើយនីមួយៗត្រូវ ឬខុស ។* គ្រូឱ្យសិស្សអានល្បះមួយចំនួនពីរដង រួចឱ្យសិស្សគូសសញ្ញា ✓ បើល្បះនោះមានន័យគ្រប់គ្រាន់អាចស្ដាប់បានប៉ុន្តែបើល្បះនោះគ្មានន័យទេត្រូវគូសសញ្ញា X លើបន្ទាត់ខាងចុងឃ្លាឬល្បះនោះ ។

# តេស្តដំណាក់កាលទី ២ (២០នាទី)

## ឈ្មោះសិស្ស____________

**២ក.** សិស្សអាចប្រាប់សូរព្យញ្ជនៈផ្ញើជើង និងព្យញ្ជនៈផ្ញើជើងផ្សំនឹងស្រៈ ។ (ការស្គាល់តួអក្សរនិងសូរ)

ពិន្ទុ

| |
|---|
| |
| ៦ |

**សំណួរពហុជ្រើសរើស**

| | | | | | |
|---|---|---|---|---|---|
| ១ | ខ្ព | ឆ្គ | គ្អ | ធ្វ | ផ្វ |
| ២ | ព្យ | ភ្ន | ថ្គ | ម្ទ | ល្ប |
| ៣ | ស្ល | ម្យ | ល្វ | ធ្យ | ខ្ទ |
| ៤ | ខ្ទះ | ឆ្កោ | ថ្មី | ធ្លា | ផ្គុំ |
| ៥ | ផ្ញើ | ភ្នុំ | ស្មា | ព្រៃ | ញ្នៅ |
| ៦ | ម្ដុំ | ស្តាំ | ល្វា | ម្សៅ | ធ្លុះ |

**២ខ.** សិស្សអាចអានយល់ពាក្យដែលមានព្យញ្ជនៈផ្ញើជើងផ្សំនឹងស្រៈនិស្ស័យព្រមទាំងពាក្យដែលមានឬគ្មានព្យញ្ជនៈប្រកបខាងចុង ។ (ការស្គាល់តួអក្សរនិងសូរ និង ការចេះវាក្យសព្ទ)

**សំណួរផ្គូផ្គងរូបភាពទៅនឹងពាក្យ**

ពិន្ទុ

| |
|---|
| |
| ៦ |

| | | | | |
|---|---|---|---|---|
| ១ |  | ខ្ញីខ្ញា | ខ្ញី | ខ្ញាប់ខ្ញួន |
| ២ |  | ផ្គាក់ | ផ្កាយ | ផ្ញីថ្ម |
| ៣ |  | ភ្លើង | ភ្លេចភ្លាំង | ភ្នំភ្លើង |
| ៤ |  | សក់ម្នា | ម្នាស | ម្នាស់ |
| ៥ |  | ព្យៅ | ល្ពៅ | ស្ពៅ |
| ៦ |  | យស្វា | ស្វាយ | សាយ្វ |

**២គ.** សិស្សអានពាក្យ ឃ្លា ល្បះខ្លីដែលកើតចេញពីព្យញ្ជនៈផ្ញើជើង ផ្សំនឹងស្រៈ និងព្យញ្ជនៈប្រកបយ៉ាងស្ទាត់ ។ (ការចេះអានស្ទាត់)

**សំណួរពហុជ្រើសរើស**

**ពិន្ទុ**

| | | | | | |
|---|---|---|---|---|---|
| ១ | ខ្ទឹម | ថ្កាម | ផ្កាក់ | ភ្លើង | ម្តេច |
| ២ | ស្មៀម | ម្អម | ល្អិត | ស្បែ | ល្បែង |
| ៣ | ផ្ទិតផ្ទង់ | ស្គមស្គាំង | ល្អិតល្អន់ | ម្ហូបម្ហុប | ខ្ពង់ខ្ពស់ |
| ៤ | ភ្លេចភ្លាំង | ត្អូញត្អែរ | ធ្លុះធ្លាយ | ថ្លៃថ្លា | ផ្ទិតផ្ទង់ |
| ៥ | ស្ពានអាកាស | ត្បាល់កិនម្សៅ | ម្នាងសិលា | ម្ចាស់ផែនដី | ល្ខោនបាសាក់ |
| ៦ | រាជធានីភ្នំពេញមានស្ពានអាកាស ។ | | សុភីខំរៀនយ៉ាងខ្ជាប់ខ្ជួន ។ | | ក្មួយខ្ញុំកើតឆ្នាំម្សាញ់ ។ |

| |
|---|
| |
| ៦ |

**២ឃ.** សិស្សអាចអាន ឃ្លា ល្បះខ្លីៗដែលប្រើពាក្យកើតចេញពីព្យញ្ជនៈផ្ញើជើង ផ្សំនឹងស្រៈ និស្ស័យមានឬគ្មានព្យញ្ជនៈប្រកបខាងចុង ។ (ការអានដើម្បីយល់ន័យ)

**សំណួរឆ្លាស់**

**ពិន្ទុ**

| | | |
|---|---|---|
| ១ | ស្វាស៊ីផ្លែស្វាយទុំ ។ | ________ |
| ២ | ថ្ងៃនេះ មេឃក្តៅស្អុះស្អាប់ ។ | ________ |
| ៣ | ខ្ញុំម្សាញ់កើតឆ្នាំក្មួយ ។ | ________ |
| ៤ | ទឹកឡើងល្វល្វាចលិចដើមល្ហុង ។ | ________ |
| ៥ | សុភានិយាយមិនដែលឆ្គាំឆ្គង ។ | ________ |
| ៦ | ឪពុកគ្រួសារផ្គត់ផ្គង់ខំរកប្រាក់ខ្ញុំ ។ | ________ |

| |
|---|
| |
| ៦ |

**ពិន្ទុសរុប**

| |
|---|
| |
| ២៤ |

# តេស្តដំណាក់កាលទី ៣ (២០នាទី)

## សេចក្ដីណែនាំ

**៣ក. សិស្សអាចបំបែកពាក្យព្យាង្គតម្រួត ព្យញ្ជនៈព្យាង្គតម្រួត ។ (ការស្គាល់តួអក្សរនិងស្វរ)**

*សំណួរផ្គូផ្គងគឺតម្រូវឱ្យសិស្សមើលរូប រួចគូសព្រួញ ឬ វង់យកពាក្យឬល្បះមួយដែលសរសេរត្រឹមត្រូវ នឹងរូបនោះ ។* គ្រូឱ្យសិស្សមើលរូបភាពនិងអានពាក្យចំនួនពីរដង រួចគូសវង់Oយកពាក្យណាមួយដែលសរសេរបានត្រឹមត្រូវជាមួយនឹងរូបភាពនោះ ។

**៣ខ. សិស្សអាចអានពាក្យព្យាង្គតម្រួតព្រមទាំងស្រៈនិស្ស័យ និងព្យញ្ជនៈប្រកបខាងចុងបានត្រឹមត្រូវ ។ (ការស្គាល់តួអក្សរនិងស្វរ  និង ការចេះវាក្យសព្ទ)**

*សំណួរផ្គូផ្គងគឺតម្រូវឱ្យសិស្សមើលរូប រួចគូសព្រួញ ឬវង់យកពាក្យមួយដែលត្រូវនឹងរូបនោះ ។* គ្រូឱ្យសិស្សមើលរូបភាព និងអានពាក្យចំនួនពីរដងរួចគូសវង់Oយកពាក្យណាមួយដែលត្រូវជាមួយនឹងរូបភាពនោះ ។

**៣គ. សិស្សអាចអានស្ទាត់ពាក្យ ឃ្លា ល្បះខ្លីៗដែលជាពាក្យព្យាង្គតម្រួត។ (ការចេះអានស្ទាត់)**

*សំណួរពហុជ្រើសរើសគឺតម្រូវឱ្យសិស្សគូសវង់យកចម្លើយតែមួយតាមគ្រូបានហៅ ។* គ្រូហៅពាក្យឬល្បះណាមួយក្នុងជួរនីមួយៗឱ្យសិស្សស្តាប់ចំនួនពីរដងរួចឱ្យសិស្សគូសវង់ O លើពាក្យឬល្បះដែលត្រឹមត្រូវតាមសមត្ថភាពខ្លួនឯង ។

**៣ឃ. សិស្សអាចអានយល់ ឃ្លា ល្បះខ្លីៗ ដែលប្រើពាក្យព្យាង្គតម្រួតកើតឡើងពីព្យញ្ជនៈផ្ញើជើងមួយនជើងពីរ ។  (ការអានដើម្បីយល់ន័យ)**

*សំណួរឆ្លាស់គឺតម្រូវឱ្យសិស្សសម្រេចចិត្តថា ចម្លើយនីមួយៗ ត្រូវឬខុស ។* គ្រូឱ្យសិស្សអានល្បះមួយចំនួនពីរដងរួចឱ្យសិស្សគូសសញ្ញា ✓   បើល្បះនោះមានន័យគ្រប់គ្រាន់អាចស្ដាប់បានប៉ុន្តែបើល្បះនោះគ្មានន័យទេត្រូវគូសសញ្ញា X លើបន្ទាត់ខាងចុងឃ្លា ឬល្បះនោះ ។

# តេស្តដំណាក់កាលទី ៣ (២០ នាទី)

## ឈ្មោះសិស្ស____________

**៣ក.** សិស្សអាចបំបែកពាក្យព្យាង្គតម្រួត ព្យញ្ជនៈព្យាង្គតម្រួត។ (ការស្គាល់តួអក្សរនិងសូរ)

ពិន្ទុ

| |
|---|
| |
| ៦ |

**ផ្គូផ្គងរូបភាពទៅនឹងពាក្យ**

| | | | | |
|---|---|---|---|---|
| ១ |  | កងែប្ក | បង្កែក | កង្កែប |
| ២ |  | ចង្អេរ | ចរ្អេង | ចរង្អេ |
| ៣ |  | ទយ្សាន | ទន្សាយ | នទ្សាយ |
| ៤ |  | ជម្ពូ | ជ្ពមូ | ជូម្ព |
| ៥ |  | កញ្ច្រែង | ក្រែញ្ចង | កញ់ច្រែង |
| ៦ |  | កញ្ជ្រាេង | កង្ជ្រោញ | កញ្ជ្រោង |

**៣ខ.** សិស្សអាចអាន ពាក្យព្យាង្គតម្រួតព្រមទាំងស្រៈនិស្ស័យ និងព្យញ្ជនៈប្រកបខាងចុងបានត្រឹមត្រូវ ។ (ការស្គាល់តួអក្សរនិងសូរ និង ការចេះវាក្យសព្ទ)

ពិន្ទុ

| |
|---|
| |
| ៦ |

**ផ្គូផ្គងរូបភាពទៅនឹងពាក្យ**

| | | | | |
|---|---|---|---|---|
| ១ |  | កម្ពុជា | ចម្លាក់ | ចម្ការ |
| ២ |  | កន្លង់ | អន្ទង់ | អណ្តើក |
| ៣ |  | បណ្ណាល័យ | សណ្ឋាន | បញ្ឈប់ |
| ៤ |  | អង្គុយ | ចង្អេរ | កង្ហារ |
| ៥ |  | តន្ត្រីសម័យ | នំបញ្ចុក | ទន្ទ្រានខេត្ត |
| ៦ |  | ផន្ទ្រី | ត្រីកញ្ជ្រូក | ត្រីកន្ត្រប់ |

**៣គ.** សិស្សអាចអានស្ទាត់ ពាក្យ ឃ្លា ល្បះខ្លីៗដែលជាពាក្យព្យាង្គតម្រួត ។
(ការចេះអានស្ទាត់)

**សំណួរពហុជ្រើសរើស**

**ពិន្ទុ**

| | | | | | |
|---|---|---|---|---|---|
| ១ | អង្កុរ | សង្ឃឹម | បង្ខំ | សង្ខារ | បង្វែរ |
| ២ | កញ្ចែ | កញ្ញា | កណ្ដាល | កន្ទាយ | សម្បុរ |
| ៣ | កញ្ជ្រឹល | កញ្ជ្រោង | អង្រ្កង | អង្គ្រង | ចន្ទ្រា |
| ៤ | បន្ថែមបន្ថយ | សន្ទោសន្ទៅ | បន្ថែបង្ការ | សម្លក់សម្លឹង | ឯកសណ្ឋាន |
| ៥ | បន្តិចបន្តួច | កន្ទុំរុយ | ទន្រ្ទានខេត្ត | ត្រីកន្ទ្រប់ | ត្រីកញ្ជ្រូក |
| ៦ | សម្ពស្សទៅកម្សាន្តឯចម្ការ។ | បញ្ញាបេះកញ្ចែត ដាក់កញ្ជើ ។ | | ចន្ទ្រាកាប់ចិញ្ច្រាំដើមទន្រ្ទានខេត្ត ។ | |

| |
|---|
| |
| ៦ |

**៣ឃ.** សិស្សអាចអានយល់ ឃ្លា ឬ ល្បះខ្លីៗដែលប្រើពាក្យព្យាង្គតម្រួត ។
(ការអានដើម្បីយល់)

**ពិន្ទុ**

**សំណួរឆ្លាស់**

| | | |
|---|---|---|
| ១ | ទន្សាយផឹកទឹកសន្សើម ។ | _________ |
| ២ | កញ្ជ្រឹលជំងឺគេយកសិស្សថ្នាំបង្ការចាក់ទៅ ។ | _________ |
| ៣ | ពូឈុំយួរសម្ភារៈសម្លោងសម្លាយ ។ | _________ |
| ៤ | កញ្ជ្រោងសង្គ្រប់ទន្សាយនៅក្រោមដើមអង្ក្រង ។ | _________ |
| ៥ | បន្ទប់រៀនសម្អាតនារី ។ | _________ |
| ៦ | យើងគោរពភ្លើងសញ្ញាចរាចរណ៍ ។ | _________ |

| |
|---|
| |
| ៦ |

**ពិន្ទុសរុប**

| |
|---|
| |
| ២៤ |

# តេស្តដំណាក់កាលទី ៤ (៣០នាទី)

## <u>សេចក្តីណែនាំ</u>

**៤ក. សិស្សអាចអានពាក្យក្នុងមេរៀនដោយផ្សំនិងប្រកប ។ (ការស្គាល់តួអក្សរនិងសូរ)**

*សំណួរពហុជ្រើសរើសគឺតម្រូវឱ្យសិស្ស គូសរង្វង់០យកចម្លើយតែមួយតាមចំនួនព្យាង្គដែលគ្រូបានហៅ ។* គ្រូឱ្យសិស្សរកពាក្យដែលមានចំនួនព្យាង្គ ( មួយព្យាង្គ  ពីរព្យាង្គ បីព្យាង្គ បួនព្យាង្គ ប្រាំព្យាង្គ) ក្នុងជួរនីមួយៗដោយឱ្យសិស្សគូសរង្វង់០ចម្លើយត្រឹមត្រូវតាមសមត្ថភាពខ្លួនឯង ។

**៤ខ. សិស្សអាចអានពាក្យក្នុងមេរៀន ដោយមិនបាច់ផ្សំ និងប្រកប។ (ការចេះវាក្យសព្ទ)**

*សំណួរផ្គូផ្គងគឺតម្រូវឱ្យសិស្សមើលពាក្យពិបាក រួចគូសវង់យកឃ្លាជាបរិបទមួយ ត្រូវនឹងពាក្យពិបាកនោះ ។* គ្រូអានពាក្យពិបាកឱ្យសិស្សស្តាប់ចំនួនពីរដង រួចឱ្យសិស្សរកនិយមន័យពាក្យពិបាកនោះដោយគូសរង្វង់០យកចម្លើយមួយត្រឹមត្រូវ ។ ពន្យល់ពាក្យនៅក្នុងសំណួរទីមួយនិងទីពីរ ។

*សំណួរផ្គូផ្គងគឺតម្រូវឱ្យសិស្សមើលពាក្យន័យដូច រួចគូសវង់យកពាក្យមួយដែលមានន័យដូចនឹងពាក្យនោះ ។* គ្រូឱ្យសិស្សរកន័យដូចនៃពាក្យ ដោយគូសរង្វង់០យកពាក្យណាដែលមានន័យដូចគ្នាក្នុងសំណួរទីបីនិងទីបួន ។

*សំណួរផ្គូផ្គងគឺតម្រូវឱ្យសិស្សមើលពាក្យផ្ទុយ រួចគូសវង់យកពាក្យមួយដែលផ្ទុយនឹងពាក្យនោះ។* គ្រូឱ្យសិស្សរកពាក្យផ្ទុយ ដោយគូសរង្វង់០យកពាក្យណាដែលមានន័យផ្ទុយគ្នាក្នុងសំណួរទីប្រាំ។

*សំណួរបំពេញល្បះ គឺតម្រូវឱ្យសិស្ស គូសវង់យកពាក្យន័យដូចមួយមកបំពេញចម្លើយឱ្យល្បះនោះមានន័យគ្រប់គ្រាន់។* គ្រូឱ្យសិស្សអានល្បះ ឬកថាខណ្ឌមួយដើម្បីរកពាក្យន័យដូចទៅបំពេញចន្លោះនៅក្នុងល្បះលេខ១ លេខ២ លេខ៣ ឱ្យបានត្រឹមត្រូវដោយគូសរង្វង់០ពាក្យនោះទៅជំនួសក្នុងសំណួរទីប្រាំមួយត្រង់ចំនុច (១) (២) និង (៣) ។

**៤គ. សិស្សអាចពន្យល់ពាក្យពិបាក  ពាក្យន័យដូច និងពាក្យផ្ទុយ ។ (ការចេះអានស្ទាត់)**

*សំណួរពហុជ្រើសរើស គឺតម្រូវឱ្យសិស្ស គូសវង់យកចម្លើយតែមួយតាមគ្រូបានហៅ ។* គ្រូហៅពាក្យឬល្បះណាមួយក្នុងជួរនីមួយៗឱ្យសិស្សស្តាប់ចំនួនពីរដង រួចឱ្យសិស្សគូសរង្វង់០លើពាក្យឬល្បះដែលត្រឹមត្រូវតាមសមត្ថភាពខ្លួនឯង ។

**៤ឃ. សិស្សអាចបកស្រាយន័យល្បះ និងអត្ថបទដែលបានកំណត់ក្នុងមេរៀនតាមរយៈលំហាត់ផ្សេងៗ ។ (ការចេះវាក្យសព្ទ និង ការអានដើម្បីយល់ន័យ)**

*សំណួរបំពេញល្បះគឺតម្រូវឱ្យសិស្ស គូសរង្វង់យកពាក្យមួយ មកបំពេញចម្លើយឱ្យល្បះនោះមានន័យគ្រប់គ្រាន់ ។* គ្រូឱ្យសិស្សអានល្បះដើម្បីរកពាក្យទៅបំពេញន័យចន្លោះនៅក្នុងល្បះនីមួយៗដោយបំពេញលេខពាក្យនោះក្នុងល្បះនីមួយៗឱ្យមានន័យត្រឹមត្រូវ ។

**៤ង. សិស្សអាចសរសេរពាក្យ ល្បះ តាមរយៈលំហាត់សរសេរតាមអានក្នុងសៀវភៅឬតាមការកំណត់របស់គ្រូ ។ (សរសេរតាមអាន)**

*សរសេរតាមអានចម្លងគឺតម្រូវឱ្យសិស្សចម្លងតាមពាក្យឬល្បះដែលគ្រូកំណត់ ។* គ្រូឱ្យសិស្សអានពាក្យឬឃ្លាទាំងប្រាំមួយចំនួនពីរដង ហើយឱ្យសិស្សសរសេរតាមពាក្យខាងលើឱ្យបានត្រឹមត្រូវតាមសមត្ថភាពសរសេរផ្ទាល់ខ្លួនក្នុងពេលវេលាកំណត់មួយជាក់លាក់ លើសន្លឹកតេស្តអ៊ុត ។

**៤ច. សិស្សអាចតែងល្បះតាមរូបភាព ឬខ្លឹមសារដែលគ្រូបានកំណត់ ។ (ការតែងល្បះ)**

*សំណេរគឺកំណត់ឱ្យសិស្សសរសេរខ្លឹមសារជាល្បះឬកថាខណ្ឌតាមរូបភាពមួយផ្ទាំង ។* គ្រូឱ្យសិស្សមើលរូបភាព (មេរៀនទី៣៣ទំព័រ៣៧) ហើយពណ៌នាដោយមាត់ទទេសិន ទើបឱ្យសិស្សសរសេរសេចក្តីពណ៌នាក្នុងសន្លឹកអ៊ុតចំនួនបីល្បះដែលគ្រូកំណត់ ។

# តេស្តជំណាក់កាលទី ៤ (៣០នាទី)

## ឈ្មោះសិស្ស_______________

ពិន្ទុ

៦

**៤ក.** សិស្សអាចអានពាក្យក្នុងមេរៀនដោយផ្សំ និងប្រកប ។ (ការស្គាល់តួអក្សរ និងស្វរ)

**សំណួរជ្រើសរើស**

| | | | | | |
|---|---|---|---|---|---|
| ១ | ពាក្យ១ព្យាង្គ | វិស្សមកាល | រៀនសូត្រ | សិស្សានុសិស្ស | ម៉ែ |
| ២ | ពាក្យ២ព្យាង្គ | លោកគ្រូអ្នកគ្រូ | ព្យាយាម | ឫក | សណ្ដាប់ធ្នាប់ |
| ៣ | ពាក្យ២ព្យាង្គ | សិស្ស | សណ្ឋាគារ | ប្រយោជន៍ | ត្រីចង្វា |
| ៤ | ពាក្យ៣ព្យាង្គ | ឫកពា | បញ្ជិតបញ្ជៀង | អង្គុយ | អនាគត |
| ៥ | ពាក្យ៤ព្យាង្គ | កណ្ដៀតក្អម | បម្រុង | សន្ធោសន្ធៅ | បង្ការ |
| ៦ | ពាក្យ៥ព្យាង្គ | បវេសនកាល | កញ្ជ្រោង | ងងឹតងងុល | ស្លៀកពាក់ |

**៤ខ.** សិស្សអាចពន្យល់ពាក្យពិបាក ពាក្យន័យដូចនិងពាក្យផ្ទុយ ។ (ការចេះវាក្យសព្ទ)

**សំណួរផ្គូផ្គងពីពាក្យទៅនិយមន័យ**

ពិន្ទុ

៦

<table>
<tr><td>១</td><td>ពន្យល់ពាក្យ "បណ្ណាល័យ"</td><td>កន្លែងដាក់ សម្ភារៈ ។</td><td colspan="2">កន្លែងដាក់ សម្លៀកបំពាក់ ។</td><td colspan="2">កន្លែងសម្រាប់តម្កល់ទុកសៀវភៅ គម្ពីរក្បួនច្បាប់ ។</td></tr>
<tr><td>២</td><td>ពន្យល់ពាក្យ "ទ្រនំ"</td><td>ទីកន្លែងដែលសត្វស្លាបតែងហើរ ។</td><td colspan="2">ទីកន្លែងដែលសត្វស្លាបតែងទំ ។</td><td colspan="2">ទីកន្លែងដែលសត្វតែងរកស៊ី ។</td></tr>
<tr><td colspan="7">សំណួរបំពេញពាក្យន័យដូច និងពាក្យផ្ទុយ</td></tr>
<tr><td>៣</td><td>ពាក្យន័យដូច " ព្យាយាម "</td><td>សងគុណ</td><td>អនាគត</td><td>តបស្នង</td><td>ប្រឹងប្រែង</td><td>កម្សាន្ត</td></tr>
<tr><td>៤</td><td>ពាក្យន័យដូច " ហូប"</td><td>យើង</td><td>ខ្ញុំ</td><td>គាត់</td><td>វា</td><td>ញ៉ាំ</td></tr>
<tr><td>៥</td><td>ពាក្យផ្ទុយ "ទូលាយ"</td><td>កើតទុក្ខ</td><td>វែង</td><td>ខ្ពស់</td><td>ចង្អៀត</td><td>ធ្ងន់</td></tr>
<tr><td rowspan="3">៦</td><td colspan="2" rowspan="3">ការងារទីមួយរបស់សិស្សគឺ<u>ខិតខំ</u>(១) រៀនសូត្រ ។ សិស្សត្រូវឆ្លៀត<u>ពេល</u>(២) ខិតខំរៀនសូត្រឱ្យបានខ្ជាប់ខ្ជួន ។ ការរៀនសូត្រ<u>ល្អ</u>(៣) គឺដោយសារការព្យាយាម ។</td><td>(១)</td><td>ដំបូង</td><td>ជាប់ជានិច្ច</td><td>ប្រឹងប្រែង</td></tr>
<tr><td>(២)</td><td>មកពី</td><td>រកឱកាស</td><td>ហ៊ឹកហាត់</td></tr>
<tr><td>(៣)</td><td>ពូកែ</td><td>លទ្ធផល</td><td>ខ្សោយ</td></tr>
</table>

**៩គ.** សិស្សអាចអានពាក្យក្នុងមេរៀន ដោយមិនបាច់ផ្សំនិងប្រកប ។ (ការចេះអានស្ទាត់)

ពិន្ទុ

| |
|---|
| |
| ៦ |

## សំណួរជ្រើសរើស

| | | | | | |
|---|---|---|---|---|---|
| ១ | ព្រលឹម | សាលារៀន | បរវេសនកាល | អញ្ជើញ | អារម្មណ៍ |
| ២ | ឪពុក | ម្តាយ | កន្ទើយ | អាហារ | ស្រស់ស្រូប |
| ៣ | អៀនប្រៀន | សំណាក | រីករាយ | កើតទុក្ខ | មាតា |
| ៤ | ប្រញាប់ | សំពះ | អង្គុយ | ប្រទាន | ត្រឹមត្រូវ |
| ៥ | ចង្កឹះ | ឫកពា | បែបបទ | ញញឹម | ក្រសារ |
| ៦ | មេស្សូត្រ | ត្រីក្រាញ់ | អំណាន | មាត់បឹង | លំហាត់ |

**៩ឃ.** សិស្សអាចបកស្រាយន័យល្បះ និងអត្ថបទ ។ (ការចេះវាក្យសព្ទនិងការអានដើម្បីយល់ន័យ)

ពិន្ទុ

| |
|---|
| |
| ៦ |

## សំណួរបំពេញល្បះ

១.ទង់ជាតិ ២.ស្លូតបូត ៣.បក់រវិចៗ ៤. រៀន ៥.ញញឹម ៦.បណ្ណាល័យ

| | | |
|---|---|---|
| ១ | ថ្ងៃនេះជាថ្ងៃចូល............................................................ដំបូង ។ | ____ |
| ២ | នៅចំកណ្តាលទីធ្លាសាលារៀនមានដង.........................មួយខ្ពស់ ។ | ____ |
| ៣ | ទង់ជាតិ.......................................................នៅពេលត្រូវខ្យល់ ។ | ____ |
| ៤ | នៅក្នុង............................មានសិស្សជាច្រើនកំពុងអានសៀវភៅ ។ | ____ |
| ៥ | គ្រូជាមនុស្ស...........................................ហើយចិត្តល្អណាស់ ។ | ____ |
| ៦ | សិស្សទាំងឡាយចេញពីបន្ទប់រៀនប្រកបដោយទឹកមុខ.............. ។ | ____ |

**៤ង.** សិស្សអាចសរសេរពាក្យ ល្បះ តាមរយៈលំហាត់សរសេរតាមអាន ។
(សរសេរតាមអាន)

**ពិន្ទុ**

| |
|---|
| ៦ |

សាលារៀន ប្រញាប់ ហ៊ាន ខ្ជាប់ខ្ជួន ល្បែងកម្សាន្ត ខ្ញុំកំពុងរកសៀវភៅភាសាខ្មែរ ។

## សរសេរតាមអានចម្លង

....................................................................................................................

....................................................................................................................

....................................................................................................................

....................................................................................................................

....................................................................................................................

....................................................................................................................

....................................................................................................................

....................................................................................................................

....................................................................................................................

....................................................................................................................

....................................................................................................................

....................................................................................................................

....................................................................................................................

....................................................................................................................

....................................................................................................................

៤ច. សិស្សអាចតែងល្បះតាមរូបភាព ឬខ្លឹមសារដែលគ្រូបានកំណត់ ។ (ការតែងល្បះ)

ពិន្ទុ

| |
|---|
| |
| ៦ |

**ចូរតែងល្បះតាមរូបភាពខាងក្រោមឱ្យបានបីល្បះ ។**



## សេចក្តីពណ៌នា

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

ពិន្ទុសរុប

| |
|---|
| |
| ៣៦ |

# តេស្តផ្ទាល់មាត់ប្រចាំឆមាសទី ១

## សេចក្តីណែនាំ

### ១.១ ចំណេះដឹងពីអក្សរ (តេស្ត ៦០វិនាទី)

គ្រូបង្ហាញសិស្សបញ្ជីអក្សរ ប្រាប់ថាបញ្ជីនេះមានព្យញ្ជនៈ ស្រៈនិស្ស័យ ស្រៈពេញតួ ជើងព្យញ្ជនៈ និងសញ្ញាពិសេស (វណ្ណយុត្តិ) ។ សិស្សត្រូវអានអក្សរម្តងមួយៗឱ្យបានច្រើនតាមដែលអាចធ្វើបាន ។ គ្រូត្រូវឱ្យសិស្សសាកល្បងអានអក្សរណាមួយហើយនិយាយថាល្អណាស់បើសិស្សអានត្រូវ ។ ប្រសិនបើសិស្សអានខុសត្រូវកែតម្រូវ ។

នៅពេលសិស្សអាន គ្រូគប្បីយកចុងប៊ិកចង្អុលតាមតួអក្សរនីមួយៗនៅលើក្រដាសរបស់ខ្លួនម្តងមួយៗ ។ គ្រូត្រូវគូសសញ្ញា/នៅលើតួអក្សរណាដែលសិស្សអាន ខុស ប៉ុន្តែក្នុងរយៈពេល៣វិនាទីបើសិស្សអានអក្សរនោះត្រូវវិញ គ្រូគប្បីគូសរង់ជុំវិញសញ្ញា / នេះរួចឱ្យសិស្សអានបន្តទៀត ។ ប្រសិនក្នុងរយៈពេល៣វិនាទីសិស្សមិនអាចអានបាន គ្រូត្រូវប្រាប់អក្សរនោះដល់សិស្សហើយចង្អុលអក្សរបន្ទាប់ឱ្យសិស្សអានជាបន្តទៅមុខទៀត ។ គូសអក្សរដែលប្រាប់សិស្ស ថាជាអក្សរអានមិនបាន ។

ក្រោយពេល៦០វិនាទីកន្លងផុតប្រាប់សិស្សឱ្យឈប់ ហើយគូសរង់ក្រចកជុំវិញពាក្យចុងបំផុតដែលសិស្សអាន ។ ប្រសិនបើសិស្សមិនអាចអានបានបន្ទាត់ដំបូង ត្រូវថាអរគុណហើយបញ្ឈប់លំហាត់នេះដោយគូសសញ្ញានៅប្រអប់ខាងក្រោមហើយបន្តទៅលំហាត់មួយទៀត ។

